# របាយការណ៍ប្រចាំប្រទេសស្តីពីការអនុវត្តន៍សិទ្ធិមនុស្ស ~ ឆ្នាំ២០០៦

## ចេញផ្សាយដោយការិយាល័យលិទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង ការងារ

## ថ្ងៃទី ៦ ខែមីនា ឆ្នាំ២០០៧

## អារម្ភកថា

នៅលើពិភពលោកយើងនេះ ទាំងបុរសទាំងស្ត្រីកំពុងតែជំរុញចង់បានសិទ្ធិសេរីភាពផ្ទាល់ខ្លួន និង សេរីភាពផ្នែកនយោបាយកាន់តែធំធេងឡើង និង ចង់បានការបើកស្ថាប័នលិទ្ធិប្រជាធិបតេយ្យនានា។ ពួកគេកំពុងតែព្យាយាមទាមទារនូវអ្វីដែលលោកប្រធានាធិបតី ប៊ូស ហៅថា " **ការទាមទារសេចក្តីថ្លៃថ្នូរដោយមិនមានការចចារ** "។

ទោះបីជាមានការប្រឈមមុខទៅនឹងគ្រោះថ្នាក់ផ្ទាល់ខ្លួន និង ជាការប្រឆាំងទៅនឹងភាពចំឡែកដ៏ធំក៏ដោយ ជនក្លាហាននានា និង ក្រុមអង្គការមិនមែនរដ្ឋាភិបាលនៅតែខិតខំបង្ហាញឱ្យឃើញពីការរំលោភសិទ្ធិមនុស្ស។ ពួកគេខិតខំធ្វើការការពារសិទ្ធិរបស់ក្រុមជនជាតិភាគតិច និង ក្រុមសាសនា កម្មករ និង ស្ត្រី និង ព្យាយាមធ្វើការបញ្ឈប់ការជួញដូរមនុស្ស។ ពួកគេបំពេញការងារដើម្បីកសាងសង្គមដែលមានភាពសកម្ម ធានាឱ្យមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និង សាងសង់លិទ្ធិប្រជាធិបតេយ្យដែលយកច្បាប់ជាមូលដ្ឋាន និង មានការទទួលខុសត្រូវខ្ពស់។

អ្នកស្នេហាជាតិដែលមិនអាចនៅស្ងប់ស្ងៀមទាំងនេះ កំពុងតែធ្វើការជំរុញឱ្យមានការផ្លាស់ប្តូរនូវការកើតសេរីភាពដែលពីមុនមកគេគិតថាមិនអាចធ្វើទៅបាន។ តាមពិត អស់រយៈពេលជាច្រើនជំនាន់មកនេះ សិទ្ធិសេរីភាពបានរីកបាចសាចពាសពេញពិភពលោកដែលកំពុងតែរីកលូតលាស់ របបលិទ្ធិផ្តាច់ការបានដួលរលំរលាយ ហើយលិទ្ធិប្រជាធិបតេយ្យថ្មីៗមួយចំនួនតូចបានងើបផុសឡើង។ សិទ្ធិដែលត្រូវបានគេដាក់ឱ្យគោរពនៅក្នុងសេចក្តីប្រកាសជាសកលនៃសិទ្ធិមនុស្ស ត្រូវបានការពារកាន់តែខ្លាំងឡើងៗ និង ត្រូវបានគេគោរពនៅក្នុងប្រទេសកាន់តែច្រើនជាងពេលអតីតកាល។

ការងារដ៏ប្រសើរនេះបានបន្តដំណើរការ - ប៉ុន្តែវាមិនទាន់មានភាពពេញលេញ ហើយវាកំពុងតែប្រឈមមុខទៅនឹងកត្តារារាំងដ៏អាក្រក់បំផុត។ មិនមានអ្វីដែលត្រូវភ្ញាក់ផ្អើលនោះទេ ចំពោះជនទាំងឡាយណាដែលមានការភ័យខ្លាចការតវ៉ាចង់បានលិទ្ធិប្រជាធិបតេយ្យ តែងតែធ្វើការប្រឆាំងទៅនឹងជនដែលធ្វើការតស៊ូមតិ និងធ្វើសកម្មភាពដើម្បីទាមទារសិទ្ធិសេរីភាព។ កាលពីអតីតកាល យើងធ្លាប់បានឃើញមានការខិតខំប្រឹងប្រែងធ្វើការបំភិតបំភ័យ និង យាយីដល់អ្នកការពារសិទ្ធិមនុស្ស និង អង្គការសង្គមស៊ីវិល និង ដើម្បីកំណត់ ឬ បិទសកម្មភាពរបស់ជន/អង្គការទាំងនោះ។ ច្បាប់អយុត្តិធម៌ត្រូវបានគេប្រើប្រាស់ជាអាវុធនយោបាយប្រឆាំងនឹងជនទាំងឡាយណាដែល

មានគំនិតឯករាជ្យ ។ លើសពីនេះ ក៏នៅមានការខិតខំបំបាត់សំលេងដែលជំទាស់ប្រឆាំងតាមមធ្យោបាយក្រៅផ្លូវច្បាប់ផងដែរ ។

នៅពេលដែលអង្គការមិនមែនរដ្ឋាភិបាល និង អ្នកការពារសិទ្ធិមនុស្សផ្សេងៗស្ថិតនៅក្រោមការឡោមព័ទ្ធបិទជិត សេរីភាព និង លិទ្ធិប្រជាធិបតេយ្យកំពុងតែត្រូវបានគេធ្វើឱ្យចុះខ្សោយ ។ លិទ្ធិប្រជាធិបតេយ្យនៅលើពិភពលោកត្រូវតែការពារអ្នកការពារលិទ្ធិប្រជាធិបតេយ្យ ។ នេះគឺជាផ្នែកមួយដ៏សំខាន់នៃបេសកកម្មរបស់យើងនៅពេលបច្ចុប្បន្ននេះ ហើយយើងសង្ឃឹមថា របាយការណ៍ប្រចាំប្រទេសស្តីពី*ការអនុវត្តន៍សិទ្ធិមនុស្ស*របស់ក្រសួងការបរទេស (Department of State) សំរាប់ឆ្នាំ២០០៦ នឹងជួយជំរុញដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ ។ តាមមតិយោបល់នេះ ខ្ញុំសូមបញ្ជូនរបាយការណ៍នេះទៅកាន់អង្គរដ្ឋសភាសហរដ្ឋអាមេរិក (The United States Congress) ។

ខនដូលីសា រ៉ាយ
(Condoleezza Rice)
រដ្ឋមន្ត្រី

# សេចក្តីផ្តើម

របាយការណ៍នេះរៀបរាប់អំពីការអនុវត្តន៍របស់រដ្ឋាភិបាលនៅក្នុងការអនុវត្តន៍កិច្ចសន្យាអន្តរជាតិលើបញ្ហាសិទ្ធិមនុស្ស។ សិទ្ធិជាមូលដ្ឋាននេះ ដូចដែលបានបង្ហាញជូននៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ជួយចូលរួមបង្កើតបានជាអ្វីដែលលោកប្រធានាធិបតី ប៊ូស ហៅថា " ការទាមទារសេចក្តីថ្លៃថ្នូររបស់មនុស្សដោយមិនមានការចចារ" ។ ដូចដែលលោកស្រីរដ្ឋមន្ត្រី រ៉ាយ បានលើកឡើង ការសន្យាពេញលេញរបស់សេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិ មិនអាចធ្វើឱ្យមានការយល់ជ្រួតជ្រាបក្នុងរយៈពេលខ្លីបាននោះទេ ប៉ុន្តែវាគឺជាកិច្ចការបន្ទាន់ដែលមិនអាចអូសបន្លាយពេលបានឡើយ ។

សេចក្តីប្រកាសជាសកលបានអំពាវនាវឱ្យ"គ្រប់បុគ្គល និង ធាតុរបស់សង្គម... ធ្វើការជំរុញឱ្យមានការគោរពសិទ្ធិ និងសេរីភាពទាំងនេះ និង ធ្វើដោយវិធានការណ៏រីកចំរើនទៅមុខជាលក្ខណៈជាតិ និង អន្តរជាតិ ដើម្បីធានាដល់វិសាលភាព និង ប្រសិទ្ធិភាពនៃការទទួលស្គាល់ និង ការតាមដាន..." ។

សហរដ្ឋអាមេរិកអនុវត្តគោលការណ៍សិទ្ធិមនុស្សរបស់ខ្លួនយ៉ាងម៉ត់ចត់បំផុត ។ ពួកយើងបានដឹងថា ពួកយើងសរសេររបាយការណ៏នេះនៅក្នុងពេលពេលដែលការកត់ត្រារបស់ពួកយើង ហើយវិធានការណ៏ដែលពួកយើងបានចាត់ដើម្បីឆ្លើយតបទៅនឹងភាវរវករដែលកំពុងតែធ្វើការវាយប្រហារមកលើពួកយើង ត្រូវបានគេចោទសួរ ។ សហរដ្ឋអាមេរិកនឹងបន្តឆ្លើយតបដោយត្រង់ៗទៅនឹងការខ្វល់ខ្វាយពិតៗចំពោះអ្នកដទៃ ដោយអាចផ្តល់តាមមធ្យោបាយជារបាយការណ៏ដែលយើងបានបញ្ជូនជាដំណាក់កាលៗ ស្របជាមួយនឹងកាតព្វកិច្ចរបស់ពួកយើងដែលស្ថិតក្រោមសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សផ្សេងៗដែលពួកយើងគឺជាផ្នែកមួយនៅក្នុងនោះ ។ ពួកយើងក៏បានសន្យាធ្វើការបន្តឱ្យមានការរីកចំរើននានា ។ ច្បាប់សហរដ្ឋអាមេរិក គោលនយោបាយ និង ការកាត់ទោសជនជាប់សង្ស័យជាភាវរវករបានធ្វើឡើងអស់រយៈពេល៥ឆ្នាំកន្លងមកហើយ ។ ប្រព័ន្ធលិទ្ធិប្រជាធិបតេយ្យរបស់រដ្ឋាភិបាល មិនមានលក្ខណៈខ្វះចន្លោះនោះឡើយ ប៉ុន្តែវាមាន*គណនីយភាព...* ធ្វើឱ្យសង្គមស៊ីវិលមានការរីកចំរើន មានសេរីភាពសារព័ត៌មានពេញលេញ សាខារដ្ឋាភិបាលឯករាជ្យ ហើយនិងច្បាប់ដែលបានត្រូវបង្កើតឡើងយ៉ាងល្អបំផុត ដើរតួជាអ្នកកែតម្រូវរាល់កំហុសឆ្គងទាំងអស់ ។

របាយការណ៏ប្រចាំប្រទេសដែលមានការយល់ព្រមដោយសភាស្តីពីការអនុវត្តន៏សិទ្ធិមនុស្ស គឺជាធាតុដ៏សំខាន់របស់កិច្ចខិតខំប្រឹងប្រែងរបស់សហរដ្ឋអាមេរិក ក្នុងការជំរុញឱ្យមានការគោរពសិទ្ធិមនុស្សទូទាំងពិភពលោក ។ អស់រយៈពេលពាទសវត្សមកនេះ របាយការណ៏ប្រចាំឆ្នាំត្រូវបានគេប្រើប្រាស់ទូទៅនៅទីនេះ និង នៅក្នុងប្រទេសផ្សេងៗទៀត សំរាប់ធ្វើជាឯកសារយោងដើម្បីធ្វើការវាយតម្លៃពីការរីកចំរើន និង ឧបសគ្គរារាំងនៅសេសសល់ ។ របាយការណ៏ទាំងនេះ ក៏ត្រូវបានយកទៅប្រើប្រាស់ជាមូលដ្ឋានគ្រឹះសំរាប់ធ្វើកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល អង្គការនានា និង បុគ្គលទាំងឡាយណាដែលមានបំណងចង់បំបាត់ការរំលោភសិទ្ធិមនុស្ស និង ធ្វើការពង្រឹងសមត្ថភាពរបស់ប្រទេសដើម្បីការពារសិទ្ធិមូលដ្ឋានទាំងនេះ ។ របាយការណ៏នេះធ្វើការពិនិត្យឡើងវិញលើការអនុត្តន៏របស់

ប្រទេសនីមួយៗនៅក្នុងឆ្នាំ ២០០៦។ របាយការណ៍នីមួយៗរាយការណ៍ពីប្រទេសនោះតែមួយគត់។ ប៉ុន្តែ គំរូទូលំទូលាយមានលក្ខណៈត្រឹមត្រូវ នឹងត្រូវបានរៀបរាប់នៅខាងក្រោមនេះ ដោយមានការផ្តល់ជាឧទាហរណ៍ បញ្ជាក់តាមប្រទេសនីមួយៗថែមទៀត។ ឧទាហរណ៍ដែលយើងបានស្រង់ចេញមក គឺមានលក្ខណៈជាការបរិយាយ ពេញលេញ មិនមែនគ្រាន់តែជាពាក្យពីរបីម៉ាត់នោះឡើយ។

## និន្នាការក្តីសង្ឃឹម ប៉ុន្តែមានហេតុការណ៍អាក្រក់

ដូចដែលរបាយការណ៍ពិនិត្យឡើងវិញបានបង្ហាញនៅលើសកលលោកក្នុងឆ្នាំ ២០០៦ នេះ បុរស និង ស្ត្រី កំពុងបន្តធ្វើការទាមទារឱ្យមានការគោរពសិទ្ធិរបស់ពួកគេ ហើយរដ្ឋាភិបាលរបស់ពួកគេត្រូវតែបំពេញកិច្ចការឱ្យ ឆ្លើយតបទៅនឹងអ្វីដែលពួកគេកំពុងចង់បាន និង សំលេងរបស់ពួកគេត្រូវបានគេស្តាប់ និង សន្លឹកឆ្នោតរបស់ពួកគេ ត្រូវបានរាប់ដោយយុត្តិធម៌ ដើម្បីឱ្យមានច្បាប់យុត្តិធម៌ និង យុត្តិធម៌សំរាប់ជនទូទៅទាំងអស់។ នៅមានការរីកលូត លាស់លើការទទួលស្គាល់ថា លិទ្ធិប្រជាធិបតេយ្យគឺជាទំរង់រដ្ឋាភិបាលដែលត្រូវបំពេញទៅតាមតំរូវការរបស់ប្រជា ពលរដ្ឋចំពោះសេចក្តីថ្លៃថ្នូរ សេរីភាព និង សមភាព។ ទាំងនេះគឺជានិន្នាការក្តីសង្ឃឹមពិតៗ ប៉ុន្តែរបាយការណ៍នេះ ក៏បានឆ្លុះបញ្ចាំងឱ្យឃើញពីអ្វីដែលផ្ទុយទៅនឹងការគិតមួយចំនួនផងដែរ :

**ទី១ ការរីកចំរើនលើផ្នែកសិទ្ធិមនុស្ស និង លិទ្ធិប្រជាធិបតេយ្យគឺមានការលំបាកក្នុងការធ្វើឱ្យបានជ័យជំនះ និង មានការលំបាកនៅក្នុងការរក្សានិរន្តភាព។ ចំណែកនៅក្នុងប្រទេសមួយចំនួនបានទទួលការរីកចំរើនគួរឱ្យកត់ សំគាល់ ប្រទេសខ្លះមានការដើរយឺតជាងគេ និង ប្រទេសមួយចំនួនទៀតមានការថយក្រោយទៅវិញ។**

ដូចដែលឧទាហរណ៍មួយចំនួនខាងក្រោមនេះបានបង្ហាញជូន ការអនុវត្តន៍នៅក្នុងប្រទេសជាច្រើនមានការ ខុសគ្នាយ៉ាងខ្លាំង អាស្រ័យលើកត្តាផ្សេងៗ ដូចជា ក៏រិតការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល សមត្ថភាពរបស់ស្ថាប័ន ទំហំ នៃអំពើពុករលួយ និង ភាពរឹងមាំរបស់សង្គមស៊ីវិល។

នៅក្នុងខែមករា ឆ្នាំ២០០៦ **ប្រទេសលីបេរីយ៉ា** បានធ្វើការជ្រើសរើសរដ្ឋាភិបាលរបស់គណបក្សសាមគ្គី ភាព ដែលដឹកនាំដោយលោកស្រី Ellen Johnson-Sirleaf ដែលជាអ្នកដឹកនាំរដ្ឋជាស្ត្រីទីមួយនៅក្នុងប្រទេស អាហ្វ្រិក ដែលកាន់តំណែងជំនួសរដ្ឋាភិបាលជាតិបណ្តោះអាសន្នរបស់ប្រទេសលីបេរីយ៉ា ដែលបានដើរតួជារដ្ឋាភិ បាលបណ្តោះអាសន្នចាប់តាំងពីបញ្ចប់សង្គ្រាមស៊ីវិលបំផ្លិចបំផ្លាញរយៈពេល ១៤ ឆ្នាំ នៅឆ្នាំ ២០០៣ មក។ រដ្ឋា ភិបាលនេះ បានចាត់វិធានការណ៍សំខាន់ៗដើម្បីកែលំអភាពចុះអន់ខ្សោយផ្នែកសិទ្ធិមនុស្សពីអតីតកាល ថែមទាំង បានធ្វើការជាមួយដៃគូរអន្តរជាតិនានា ដើម្បីស្តារឡើងវិញនូវស្ថានភាពយុត្តិធម៌របស់ប្រទេស និង បង្កើតការិយា ល័យការពារក្តីសាធារណៈនៅក្នុងទីក្រុងផងដែរ។ ប្រធានាធិបតីបានបណ្តេញចេញ ឬ ផ្អាកការងាររបស់បុគ្គលិក រដ្ឋាភិបាលដែលប្រព្រឹត្តអំពើពុករលួយជាច្រើននាក់។ គណៈកម្មការសន្តិភាព និង ផ្សះផ្សារ ដែលត្រូវបានគេបង្កើត ឡើងនៅក្នុងឆ្នាំ២០០៥ ដើម្បីស៊ើបអង្កេតអំពីការរំលោភសិទ្ធិមនុស្ស និង បទឧក្រិដ្ឋសង្គ្រាមដែលត្រូវបានធ្វើឡើង នៅក្នុងសង្គ្រាមស៊ីវិល បានចាប់ផ្តើមប្រមូលរបាយការណ៍ពីសាក្សី។ ទោះជាមានការរីកចំរើនបែបនេះក៏ដោយ ប្រ

ទេសលីបេរីយ៉ានៅបន្តប្រឈមមុខនឹងឧបសគ្គផ្នែកសិទ្ធិមនុស្សធ្ងន់ធ្ងរជាច្រើនទៀត ដែលរួមមានប្រព័ន្ធតុលាការអន់ខ្សោយ អំពើពុករលួយ និង និទណ្ឌភាព អំពើហឹង្សាផ្នែកយេនឌ័រ និង ភាពក្រីក្រដែលធ្វើឱ្យមានពលកម្មកុមារ។

មានការកាត់បន្ថយការសំលាប់រង្គាលនៅក្នុងតំបន់ដែលងាយរងគ្រោះនៅក្នុងប្រទេស**ឥណ្ឌូណេស៊ី** ដែលធ្វើឡើងដោយយោធា និង ប៉ូលីស ក្នុងលក្ខណៈជានយោបាយ។ មានការបោះឆ្នោតដោយសេរី និង យុត្តិធមិចំនួនហាសិបបួន ត្រូវបានគេរៀបចំឡើងនៅថ្នាក់ខេត្ត ថ្នាក់តំបន់ជានុសិទ្ធិ ថ្នាក់ស្រុក និង ថ្នាក់ក្រុង ដែលមានការបោះឆ្នោតដ៏គួរឱ្យចាប់អារម្មណ៍បំផុតនោះ គឺនៅខែធ្នូ ក្នុងខេត្តអាសេ(Aceh) ដែលជាកន្លែងដែលមេបញ្ជាការពួកឧទាមបានឈ្នះធ្វើជាអ្នកដឹកនាំរដ្ឋ។ ទោះបីជាអំពើហិង្សាផ្នែកសាសនាអន្តរតំបន់បានចុះថយក៏ដោយ វានៅមានបន្តនៅក្នុងតំបន់មួយចំនួនទៀតនៅឡើយ។ រដ្ឋាភិបាល និង តុលាការ មិនអាចប្រឈមមុខទៅនឹងការរំលោភសិទ្ធិមនុស្ស និង ការសម្លាប់រង្គាលនៅក្នុងប្រទេសឥណ្ឌូណេស៊ី និង ទីម័រខាងកើតបានឡើយ។

របាយការសិទ្ធិមនុស្សនៅក្នុង**ប្រទេសម៉ារ៉ុក**បានបង្ហាញពីការរីកចំរើនគួរឱ្យកត់សំគាល់ ទោះជាវានៅមានបញ្ហាខ្លះៗក៏ដោយ។ រដ្ឋាភិបាលបានចាប់ផ្តើមដោះស្រាយបញ្ហាការរំលោភសិទ្ធិមនុស្សពីអតីតកាល ដោយធ្វើការផ្តល់សំណងជម្ងឺចិត្តតាមរយៈក្រុមប្រឹក្សាពិគ្រោះយោបល់ស្តីពីសិទ្ធិមនុស្ស ចំពោះករណីឃាត់ខ្លួនពិសេសៗ ការបាត់ខ្លួន និង ការរំលោភសិទ្ធិ នៅក្នុងចន្លោះពេលឆ្នាំ១៩៥៦ និង ឆ្នាំ១៩៩៩។ នៅក្នុងខែកុម្ភៈ រដ្ឋាភិបាលបានអនុម័តច្បាប់ប្រឆាំងការធ្វើទារុណកម្ម ទោះបីជារបាយការណ៍ស្តីពីការធ្វើទារុណកម្មដោយសាខាផ្សេងៗរបស់កំលាំងសន្តិសុខនានានៅបន្តកើតមានក៏ដោយ។ មានការពិភាក្សាគ្នាយ៉ាងស៊ីជំរៅ និង ដោយចំហរជាសាធារណៈ និង ជាមួយសារព័ត៌មាន ទោះជានៅមានការបន្តកំណត់ហាមឃាត់ចំពោះសេរីភាពសារព័ត៌មាន និង ការបញ្ចេញមតិក៏ដោយ។ នៅក្នុងអំឡុងឆ្នាំនោះ រដ្ឋាភិបាលបានដាក់ទោសអ្នកសារព័ត៌មានមួយចំនួនដែលរំលោភលើការកំរិតបទបញ្ញត្តិសេរីភាពការបញ្ចេញមតិ និង មានអ្នកសារព័ត៌មានជាច្រើនបានអនុវត្តការងារដោយមិនហ៊ានបង្ហាញអត្តសញ្ញាណខ្លួនឯង។ ការរត់ពន្ធមនុស្សជាពិសេសសំរាប់ជួញដូរផ្លូវភេទ និង ពលកម្មកុមារ នៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភណ៍នៅឡើយ តែទោះជាយ៉ាងណាក៏ដោយ នៅមានទាំងរដ្ឋាភិបាល និង សង្គមស៊ីវិល កំពុងតែមានភាពកាន់តែសកម្មនៅក្នុងការដោះស្រាយបញ្ហាទាំងនេះ។

នៅក្នុង**ប្រទេសសាធារណៈរដ្ឋប្រជាមានិតកុងហ្គោ** បានរៀបចំឱ្យមានការបោះឆ្នោតជាលក្ខណៈប្រជាធិបតេយ្យ ដើម្បីជ្រើសរើសប្រធានាធិបតី និង អង្គនីតបញ្ញត្តិលើកទី១របស់ខ្លួនសំរាប់រយៈពេលជាង ៤០ឆ្នាំមកនេះ ដោយបានបញ្ចប់របបគ្រប់គ្រងបណ្តោះអាសន្នបន្ទាប់ពីសង្គ្រាមស៊ីវិលរយៈពេល៣ឆ្នាំ។ រដ្ឋធម្មនុញ្ញថ្មី ត្រូវបានប្រកាសឱ្យប្រើប្រាស់។ ប៉ុន្តែរបាយការណ៍សិទ្ធិមនុស្សរបស់ប្រទេសនេះនៅមានភាពអន់ខ្សោយនៅឡើយ។ បន្ថែមលើជំលោះរ៉ាំរ៉ៃនៅក្នុងភាគខាងកើតរបស់ប្រទេស ដែលជាតំបន់មានការគ្រប់គ្រងទន់ខ្សោយរបស់រដ្ឋាភិបាល ហើយក្រុមយោធានៅបន្តប្រព្រឹត្តការរំលោភបំពានធ្ងន់ធ្ងរ កំលាំងសន្តិសុខរបស់រដ្ឋាភិបាលនៅទូទាំងប្រទេសក៏មានការប្រព្រឹត្តិបទល្មើសរំលោភសិទ្ធិមនុស្សដោយមិនមានការដាក់ទោសឡើយ។

នៅក្នុង**ប្រទេសហៃទី (Haiti)** ប្រជាពលរដ្ឋបង្ហាញឆន្ទៈរបស់ពួកគេចំពោះលិទ្ធិប្រជាធិបតេយ្យ ដោយធ្វើមានការបោះឆ្នោតចំនួន ៣ ដងនៅក្នុងឆ្នាំ ២០០៦។ មានប្រជាពលរដ្ឋចំនួនច្រើនជាង ៣,៥ លាននាក់បានចុះឈ្មោះបោះឆ្នោត និង អត្រាអ្នកមកបោះឆ្នោតត្រូវបានគេសង្ឃឹមថា មានចំនួនលើសពី ៧០%របស់អ្នកចុះឈ្មោះសំរាប់ជុំទី១នៃការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និង ការបោះឆ្នោតជ្រើសរើសសភានៅក្នុងខែកុម្ភៈ។ បន្ទាប់ពីមានស្ថេរភាព និង ការបោះឆ្នោតប្រកបដោយមិនមានអំពើហិង្សា អ្នកបោះឆ្នោតបានជ្រើសរើសលោកប្រធានាធិបតី រ៉េនី ប្រេវ៉ាល់ (Rene Preval) និង បានបំពេញកៅអីរដ្ឋសភាចំនួន ១២៩ កៅអី។ នៅក្នុងខែធ្នូ ប្រទេសហៃទីបានរៀបចំការបោះឆ្នោតជ្រើសរើសចៅហ្វាយក្រុងលើកទី១ នៅបន្ទាប់ពីរយៈពេលជាង១ទសវត្សកន្លងមកនេះ។ ប៉ុន្តែនៅមានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញ ដើម្បីស្តារឡើងវិញនូវប្រព័ន្ធច្បាប់ ដោយគិតរួមទាំងការសំរួលដល់ភាពអដំណើរការរបស់ប្រព័ន្ធតុលាការ និង បន្តបណ្តុះបណ្តាលពីជំនាញថ្មីៗ និង ពិនិត្យមើលសមត្ថភាពកងប៉ូលីសជាតិហៃទីផងដែរ។

នៅក្នុងប្រទេស**អ៊ុយក្រែន (Ukraine)** មានបដិវត្តន៍ពណ៌ទឹកក្រូចមួយលើការអនុវត្តន៍សិទ្ធិមនុស្សកំពុងបន្តដំណើរការ។ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រខែធ្នូ ឆ្នាំ២០០៦ គឺជាការបោះឆ្នោតដែលមានភាពសេរីបំផុតក្នុងរយៈពេលទទួលឯករាជ្យចំនួន១៥ឆ្នាំមកនេះ។ ប្រទេសនេះកំពុងបន្តដំណើរការរីកចំរើនលើសេរីភាពការបញ្ចេញមតិ សេរីភាពក្នុងការបង្កើតសមាគមន៍ និង ការអភិវឌ្ឍន៍លើផ្នែកសង្គមស៊ីវិល។ ទោះបីជាមានភាពរីកចំរើនទាំងនេះក៏ដោយ នៅមានបញ្ហាធ្ងន់ធ្ងរមួយចំនួននៅបន្តកើតមាននៅឡើយ ដែលរួមមានអំពើពុករលួយនៅគ្រប់ផ្នែករបស់រដ្ឋាភិបាល។

ទោះបីជារបាយការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេស**គីជីស្ថាន** (Kyrgyzstan) មានភាពប្រសើរឡើងគួរឱ្យចាប់អារម្មណ៍ បន្ទាប់ពីមានការផ្លាស់ប្តូរទៅជាការគ្រប់គ្រងដោយការបោះឆ្នោតតាមលិទ្ធិប្រជាធិបតេយ្យក្នុងឆ្នាំ ២០០៥ ក៏ដោយ នៅក្នុងអំឡុងពេលឆ្នាំ ២០០៦ មានការប្រឆាំងតវ៉ាដោយសន្តិភាពរយៈពេល១សប្តាហ៍ដែលបានបញ្ចប់ដោយលទ្ធផលការទទួលយករដ្ឋធម្មនុញ្ញដែលគេធ្វើវិសោធនកម្មដែលផ្តល់ឱ្យមានការប្រើប្រាស់មូលទានបត្រ័ និង តារាងតុល្យការ។ ទោះជាយ៉ាងណា នៅចុងខែធ្នូ រដ្ឋសភាបានអនុម័តរដ្ឋធម្មនុញ្ញមួយទៀត ដោយបានលុបចោលនូវមូលទានបត្រ័ និង តារាងតុល្យការសំខាន់ៗមួយចំនួន។ រដ្ឋាភិបាលក៏បានយាយីដល់អង្គការមិនមែនរដ្ឋាភិបាលដែលទទួលមូនីធិពីបរទេសផងដែរ។

ទោះបីជាលោកប្រធានាធិបតី មូសារ៉ាហ្វ បានធ្វើការប្តេជ្ញាចិត្តថា នឹងជំរុញឱ្យមានអន្តរកាលលិទ្ធិប្រជាធិបតេយ្យ និង "ឱ្យឈានដល់ក៏រិតមធ្យម" របាយការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេសប៉ាគីស្ថាននៅមានភាពអន់ថយនៅឡើយ។ នៅមានការកំណត់សិទ្ធិសេរីភាពនៃការធ្វើសកម្មភាព ការបញ្ចេញមតិ សកម្មភាពសមាគមន៍ និង សាសនានៅឡើយ។ នៅមានការបាត់ខ្លួនសកម្មជន និង អ្នកប្រឆាំងនយោបាយនៅតាមខេត្តជាបន្តបន្ទាប់នៅឡើយ ជាពិសេសនៅក្នុងខេត្តដែលកំពុងជួបប្រទះជាមួយភាពចលាចលផ្ទៃក្នុង និង ការបះបោរប្រឆាំងតវ៉ា។ កំលាំងសន្តិសុខនៅបន្តប្រព្រឹត្តការសំលាប់ក្រៅច្បាប់។ មានការឃាត់ខ្លួនតាមតែអំណាច និង ការធ្វើទារុណកម្មនៅមានទំហំធំធេង

នៅឡើយ។ អំពើពុករលួយនៅរីករាលដាលពាសពេញរដ្ឋាភិបាល និង កងកំលាំងប៉ូលីស។ ជាចំណុចវិជ្ជមាន នៅក្នុងខែធ្នូ សភាជាតិបានបានអនុម័តច្បាប់ការពារស្ត្រី ហើយលោកប្រធានាធិបតីមូសារ៉ាហ្វបានចុះហត្ថលេខាលើច្បាប់នេះ - ដែលធ្វើឱ្យវាក្លាយជាលើកទី១នៅក្នុងរយៈពេល ៣ ទសវត្សដែលរដ្ឋាភិបាលប្រទេសប៉ាគីស្ថានបានធ្វើការបោះបង់ចោលច្បាប់ដែលផ្តល់ផលអាក្រក់ចំពោះសិទ្ធិស្ត្រី។ ច្បាប់នេះ បានធ្វើវិសោធនកម្មបទបញ្ញត្តិស្តីពីការរំលោភ និង សាហាយស្មន់ នៅក្នុងឆ្នាំ ១៩៧៩ ដែលចងក្រងឡើងដោយ Hudood Ordinance ដោយធ្វើការផ្ទេរបទល្មើស នៃការរំលោភសេពសន្ថវៈពីច្បាប់សាសនារបស់ប្រទេសប៉ាគីស្ថាន (Sharia law) ទៅជាច្បាប់ព្រហ្មទណ្ឌ (Penal Code) របស់ប្រទេសនេះ។ ច្បាប់នេះ ក៏បានលប់បំបាត់ចោលនូវរាល់តំរូវការចំពោះជនរងគ្រោះដោយការរំលោភសេពសន្ថវៈឱ្យបង្ហាញជូនសាក្សីជាបុរសចំនួន ៤ នាក់ទៅលើការកាត់ទោសដោយមានវត្តមានរបស់អ្នកសារព័តិមាន។

ទោះបីជានៅក្នុង**ប្រទេសអេហ្ស៊ីប**មានការរៀបចំឱ្យមានការបោះឆ្នោតលើកទី១ ក្នុងឆ្នាំ ២០០៥ ដើម្បីជ្រើសរើសប្រធានាធិបតីចូលរួមដោយពហុភាគីដែលមិនធ្លាប់មានសោះនោះក៏ដោយ នៅក្នុងឆ្នាំ ២០០៦ មានបាតុកម្មសាធារណៈមួយដែលទាមទារសុំឱ្យមានការធ្វើលិទ្ធិប្រជាធិបតេយ្យកម្ម និង ការទទួលខុសត្រូវរបស់រដ្ឋាភិបាលត្រូវបានទទួលរងប្រតិកម្មមិនសមស្របពីសំណាក់រដ្ឋាភិបាល។ ការបន្តដាក់ឃុំឃាំងអតីតបេក្ខភាពប្រធានាធិបតីលោក អាយម៉ាន់ នួរ (Ayman Nour) បានធ្វើឱ្យលេចឡើងនូវការព្រួយបារម្ភណ៍ពីមាគ៌ានៃការធ្វើកំណែទម្រង់ផ្នែកនយោបាយ និង លិទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសនេះ។ ទិន្នាការនេះ បន្តចាប់តាំងពីឆ្នាំ ២០០៥ នៅពេលដែលរដ្ឋាភិបាលបានឃាត់ខ្លួន និង ដាក់ឃុំឃាំងសកម្មជនរាប់រយនាក់ដែលមានទំនាក់ទំនងទៅនឹងក្រុមមូស្លីមភាតរភាព ដែលត្រូវហាមឃាត់ - ប៉ុន្តែ - មានភាពអត់ធ្មត់ (banned-but-tolerated Muslim Brotherhood) ជាពិសេសនៅក្នុងអន្តរកាលជាច្រើនសប្តាហ៍ចុងក្រោយ។ ចៅក្រមជាន់ខ្ពស់ ២ រូប ត្រូវបានកោះហៅមកដើម្បីធ្វើការសាកសួរនៅក្នុងខែកុម្ភៈ ចំពោះការទាមទារចង់បានឱ្យមានប្រព័ន្ធតុលាការឯករាជ្យ។ ប៉ូលីសអេហ្ស៊ីបបានធ្វើការឃាត់ខ្លួន និង ដាក់ឃុំឃាំងសកម្មជនជាង ៥០០ នាក់ដែលបានចូលរួមនៅក្នុងការធ្វើបាតុកម្មគាំទ្រឱ្យមានប្រព័ន្ធតុលាការឯករាជ្យ លើសពីនេះទៀត មានករណីធ្វើទារុណកម្មធ្ងន់ធ្ងរដែលធ្វើឡើងដោយអាជ្ញាធរ ត្រូវបានគេចុះក្នុងរបាយការណ៍។ រដ្ឋាភិបាលក៏បានឃាត់ខ្លួន ដាក់ឃុំឃាំង និង រំលោភបំពានទៅលើអ្នកបើកសេវាកម្មអ៊ីនធឺណែត (Internet bloggers) ជាច្រើននាក់ផងដែរ។

នៅក្នុង**ប្រទេសកាហ្សាស្តង់ (Kazakhstan)** រដ្ឋាភិបាលបានហាមឃាត់ដល់ការប្រឆាំងផ្នែកនយោបាយតាមរយៈការអនុវត្តនីប្រព័ន្ធចុះឈ្មោះស្មុគស្មាញបំផុត និង រារាំង ឬ បដិសេធនីដល់ការចុះឈ្មោះរបស់គណបក្សនយាបាយផងដែរ។ គណបក្សដែលមានការគាំទ្រដល់រដ្ឋាភិបាលជាច្រើនដែលលេចមុខឡើង បានចូលរួមជាមួយការដឹកនាំដ៏តឹងរឹងបំផុតរបស់លោកប្រធានាធិបតី ណាហ្សាបាយូ (Nazarbayev) របស់គណបក្សអូតង់ (Otan Party) និង បានបន្សល់ទុកនូវលំហនយោបាយតិចបំផុតចំពោះការបញ្ចេញទស្សនៈជ្រើសរើស និង ធ្វើការតស៊ូមតិសំរាប់ឱ្យមានការធ្វើកំណែទម្រង់។ រដ្ឋាភិបាលបានយាយីដល់ការប្រឆាំងផ្នែកនយោបាយតាមរយៈការចោទប្រកាន់

ផ្នែកតុលាការដែលបំរើឱ្យនយោបាយ និង ការហាមឃាត់ដល់សេរីភាពក្នុងការប្រជុំ ដោយអនុម័តច្បាប់ហាមឃាត់ដល់សេរីភាពការបញ្ចេញមតិ និង ការយាយីដល់អង្គការមិនមែនរដ្ឋាភិបាលនានា។

ប្រទេសរុស្ស៊ីបានឆ្លងកាត់ការធ្វើវិមជ្ឈការអំណាចនៅក្នុងសាខាប្រតិបត្តិ ដោយរួមមានការធ្វើវិសោធនកម្មដើម្បីជ្រើសរើសច្បាប់ និង ប្រព័ន្ធនីតិកម្មថ្មីសំរាប់គណបក្សនយោបាយទាំងឡាយ ដែលផ្តល់អំណាចយ៉ាងធំធេងដល់រដ្ឋាភិបាលដើម្បីធ្វើការកំណត់បទបញ្ជា ធ្វើការស៊ើបអង្កេត កំណត់ព្រំដែន និង អាចដល់ការបិទគណបក្សនោះថែមទៀត។ ដោយការអនុវត្តន៏តាម State Duma អំពើពុករលួយ និង ការជ្រើសរើសយកការអនុវត្តន៏ច្បាប់ សម្ពាធនយោបាយលើប្រព័ន្ធតុលាការ និង ការដាក់ក៏រិតកំណត់ចំពោះអង្គការមិនមែនរដ្ឋាភិបាល និង ប្រព័ន្ធផ្សព្វផ្សាយដែលនិន្នការទាំងនេះបានផ្តល់ផលឱ្យមានភាពកាន់តែចុះខ្សោយនៃការទទួលខុសត្រូវរបស់រដ្ឋាភិបាល។ នៅក្នុងរដ្ឋឆេចឆិនយ៉ា (Chechenya) និង តំបន់ផ្សេងៗទៀតនៃខសកាស៊ើសខាងជើង (North Caucasus) ការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនៅបន្តកើតមាននៅឡើយ ដោយគិតរួមទាំងការសំលាប់ក្រៅសំណាញ់ច្បាប់ និងការរំលោភលើសិទ្ធិរបស់ជនស៊ីវិលដោយកងកំលាំងសហព័ន្ធ និង កងកំលាំងសន្តិសុខរបស់រដ្ឋឆេចឆិន។ ក្រុមសកម្មប្រយុទ្ធឧទ្ទាម បានធ្វើការវាយប្រហាដោយគ្រាប់បែកភាវរកម្ម និង មានការបាត់ខ្លួនអ្នកជាប់ពាក់ព័ន្ធជាមួយនឹងសកម្មភាពនយោបាយនៅក្នុងតំបន់។ នៅក្នុងករណីដែលកំពុងកើនឡើងនេះ សាលាក្តីសហគមន៍អឺរ៉ុបលើបញ្ហាសិទ្ធិមនុស្សបានជំរុញឱ្យប្រទេសរុស្ស៊ីធ្វើការទទួលខុសត្រូវចំពោះបទល្មើសទាំងនេះ។

នៅក្នុងប្រទេស**វ៉េនីហ្ស៊ុអ៊ីឡា** (Venezuela) រដ្ឋាភិបាលរបស់លោកឆាវ៉េសបន្តបង្រួបបង្រួមអំណាចជាមួយនឹងសាខាប្រតិបត្តិនានា។ រដ្ឋាភិបាលបន្តធ្វើការយាយីដល់បក្សប្រឆាំង និង អង្គការមិនមែនរដ្ឋាភិបាលនានា និង កំពុងតែព្យាយាមធ្វើឱ្យភាពឯករាជ្យរបស់ប្រព័ន្ធតុលាការចុះខ្សោយ។ អ្នកសង្កេតការណ៍អន្តរជាតិបានចាត់ទុកថា ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីនៅក្នុងខែធ្នូ ជាការបោះឆ្នោតដោយសេរី និង យុត្តិធម៌ ដែលនៅក្នុងការបោះឆ្នោតនោះ លោកប្រធានាធិបតីឆាវ៉េបានត្រូវគេជ្រើសរើសម្តងទៀតជាប្រធានាធិបតីដោយមានសំលេងឆ្នោតគាំទ្រចំនួន ៦៣%។ នៅក្នុងការសំដែងមតិនៅក្នុងកម្មវិធីសម្ពោធរបស់គាត់ លោកប្រធានាធិបតីឆាវ៉េសបានស្នើឱ្យសភាជាតិ ដែលគណបក្សរបស់គាត់បានគ្រប់គ្រងកៅអីចំនួន ១០០% ឱ្យប្រគល់អំណាចដល់រូបគាត់ ដើម្បីធ្វើការគ្រប់គ្រងដោយក្រិត្យប្រតិបត្តិ។

នៅក្នុងប្រទេសហ្វីជី (Fiji) និង ប្រទេសថៃ (Thailand) ឧត្តមសេនីយ៍យោធាបានធ្វើការផ្តួលរំលំរដ្ឋាភិបាលដែលទទួលបានដោយការបោះឆ្នោតតាមលិទ្ធិប្រជាធិបតេយ្យ។

**ហេតុការណ៏អាក្រក់ទី២ គឺថា មានអសន្តិសុខកើតឡើងដោយសារទំនាស់ផ្ទៃក្នុង និង/ឬ ទំនាស់រវាងប្រទេស ដែលអាចគំរាមកំហែង ឬ រាំងរាំងដល់ការរីកចំរើនផ្នែកសិទ្ធិមនុស្ស និង រដ្ឋាភិបាលប្រជាធិបតេយ្យ។**

ទោះបីជារដ្ឋាភិបាលរបស់ប្រទេស អ៊ីរ៉ាក់ មានការបន្តការប្តេជ្ញាចិត្តជំរុញឱ្យមានការផ្សះផ្សាជាតិ និង ការសាងសង់ប្រទេសឡើងវិញតាមរយៈការបោះឆ្នោត និង បង្កើតច្បាប់ ដែលផ្នែកទាំង ២ នេះញ៉ាំងឱ្យមានអំពើហិង្សាផ្នែកសាសនា និង សកម្មភាពភាវរកម្ម ដែលធ្វើឱ្យមានការចុះអន់ថយដល់ការវិវត្តផ្នែកសិទ្ធិមនុស្ស និង លិទ្ធិប្រជា

ធិបតេយ្យនៅក្នុងអំឡុងឆ្នាំ ២០០៦។ ទោះបីជារដ្ឋធម្មនុញ្ញប្រទេសអ៊ីរ៉ាក់ និង ច្បាប់ផ្តល់ឱ្យមានក្របខណ្ឌការងារខ្លាំងក្លាសំរាប់ការការពារសិទ្ធិមនុស្សក៏ដោយ ក្រុមឃោធាបានធ្វើការវាយប្រហាលើសិទ្ធិមនុស្សតាមទិសដៅខុសគ្នាចំនួន ២ : ជនដែលគេអះអាងថាជាអ្នកបង្កអសន្តិសុខដល់រដ្ឋាភិបាល ជាក្រុមភាវរកម្មអាល់កៃដា ក្រុមដែលមិនអាចធ្វើការផ្សះផ្សាបាននៃរបប B'athist និង ក្រុមបះបោរដែលកំពុងតែបង្កសង្គ្រាមឧទ្ទាម និង សមាជិករបស់ក្រុមឃោធាស៊ីអា Shi'a និង កងកំលាំងឃោធាផ្សេងៗ - ដែលជាធម្មតាជាសម្ព័ន្ធមិត្តនឹងរដ្ឋាភិបាល - ដែលប្រព្រឹត្តអំពើទារុណកម្ម និង បទល្មើសផ្សេងៗទៀត។

ទោះបីជានៅក្នុងប្រទេសអាហ្គានីស្ថានបានទទួលការរីកចំរើនផ្នែកសិទ្ធិមនុស្សជាច្រើនក៏ដោយ ចាប់តាំងពីការដួលរលំរបបតាលីបង់នៅឆ្នាំ ២០០១ មក របាយការណ៍សិទ្ធិមនុស្សរបស់ប្រទេសនេះនៅមានភាពអន់ថយនៅឡើយ។ ទាំងនេះគឺដោយសារស្ថាប័នថ្នាក់កណ្តាលមានភាពទន់ខ្សោយ និង ការបះបោះធ្ងន់ធ្ងរ : ក្រុមអាល់កៃដា ក្រុមតាលីបង់ និង ក្រុមជ្រុលនិយមផ្សេងៗទៀតដែលបង្កើនការវាយប្រហារលើបុគ្គលិករដ្ឋាភិបាល កំលាំងសន្តិសុខ អង្គការមិនមែនរដ្ឋាភិបាល និង បុគ្គលិកជំនួយមនុស្សធម៌សង្គ្រោះបន្ទាន់ផ្សេងៗ និង ជនស៊ីវិលគ្មានប្រដាប់អាវុធ និង ការវាយប្រហារអត្តឃាតដោយគ្រាប់បែកដៃ មានការកើនឡើងខ្លាំងក្លាក្នុងឆ្នាំនីមួយៗ ក៏ដូចជាការវាយប្រហារមកលើសាលារៀន និង គ្រូបង្រៀន។ នៅមានសេចក្តីរាយការណ៍បន្តមកថា មានករណីឃាត់ខ្លួនដោយគ្មានមូលហេតុ និង ឃុំឃាំងមនុស្ស ការសំលាប់មនុស្សក្រៅប្រព័ន្ធតុលាការ ការធ្វើទារុណកម្ម និង ស្ថានភាពពន្ធធនាគារអន់។ នៅក្នុងខែធ្នូ លោកប្រធានាធិបតី កាហ្សៃ (Karzai) បានប្រកាសឱ្យប្រើប្រាស់ផែនការសកម្មភាពយុត្តិធម៌អន្តរកាល (Transitional Justice Action Plan) ដើម្បីដោះស្រាយករណីការរំលោភសិទ្ធិមនុស្សពីអតីតកាល និង ដើម្បីធ្វើឱ្យសមត្ថភាពស្ថាប័ននៃប្រព័ន្ធតុលាការមានភាពកាន់តែប្រសើរឡើង។

ជំហានសំខាន់ៗរបស់**ប្រទេសលីបង់** (Lebanon) ចំពោះការធ្វើកំណែទម្រង់នៅបន្ទាប់ពីការធ្វើឃាតអតីតនាយករដ្ឋមន្ត្រី រ៉ាហ្វិក ហារីរី (Hafiq Hariri) និង ការដកទ័ពភ្លាមៗរបស់ប្រទេសស៊ីរីនៅបន្ទាប់ពីការកាន់កាប់រយៈពេលជាង៣ទសវត្សមកនេះ ត្រូវបានអាក់ខានចាប់តាំងពីទំនាស់នៅក្នុងខែកក្កដា-សីហាឆ្នាំ២០០៦ រវាងក្រុមហ៊ិបាឡាស និង ប្រទេសអ៊ីស្រាអែល។ នៅមុនពេលទំនាស់បានកើតឡើង រដ្ឋាភិបាលលីបង់បានចាប់ផ្តើមដកចេញនូវឧបសគ្គនានាដែលហាមឃាត់ដល់ការបង្កើតសមាគន៏ និង គណបក្សនយោបាយ។ បន្ទាប់ពីក្រុមហ៊ិបាឡាសបានចូលទៅក្នុងទឹកដីអ៊ីស្រាអែលពីដែនដីលីបង់ និង បានចាប់ជំរិត និង សំលាប់ទាហានអ៊ីស្រាអែលជាច្រើននាក់ ទាហានរបស់អ៊ីស្រាអែលក៏បានតបតតាមរយៈការលុកលុយចូលទឹកដីលីបង់ទៅវិញដែរ។ ទំនាស់នេះត្រូវបានបញ្ចប់ដោយមានការបញ្ឈប់អំពើវាយប្រហារគ្នាដោយកងកំលាំងអង្គការសហប្រជាជាតិ។ ទោះបីជាមានការអន្តរាគមន៏បញ្ឈប់ការវាយប្រហារ និង ការដាក់ពង្រាយកងកំលាំងប្រដាប់អាវុធរបស់លីបង់ និង កងកំលាំងបណ្តោះអាសន្នរបស់កងរក្សាសន្តិសុខនៃអង្គការសហប្រជាជាតិនៅភាគខាងត្បូងប្រទេសក៏ដោយ ក្រុមឃោធាលីបង់ និង ក្រុមហ៊ិបាឡាស នៅតែមានសកម្មភាពនៅលើដែនដីភាគច្រើននៅក្នុងប្រទេសនេះ។

នៅក្នុង**ទីម័រខាងកើត** (East Timor) មានការប៉ះទង្គិចដ៏ឃោរឃៅបន្តបន្ទាប់គ្នាបានកើតឡើងរវាងកំលាំងការពារជាតិ និង ក្រុមឃោឃាបះបោរ ប៉ូលីស និង ជនស៊ីវិលដែលបណ្តាលឱ្យមានការវាយតប់គ្នា និង អំពើហិង្សាពាសពេញទីក្រុង។ តាមសំណូមពររបស់រដ្ឋាភិបាល កងកំលាំងមកពីប្រទេសអូស្ត្រាលី ញូវហ្សេឡង់ដ៏ ម៉ាឡេស៊ី និង ប៉ទុយហ្គាល ត្រូវបានគេផ្តល់សិទ្ធិឱ្យទទួលខុសត្រូវចំពោះសន្តិសុខនៅក្នុងទីក្រុងនេះ។ នៅថ្ងៃទី២៥ ខែសីហា កងកំលាំងបេសសកម្មរួមរបស់អង្គការសហប្រជាជាតិ បានទទួលខុសត្រូវលើកិច្ចការប៉ូលីស។ ទំនាស់ផ្ទៃក្នុងនេះបានធ្វើឱ្យប្រជាពលរដ្ឋប្រហែល ១៥០ ០០០ នាក់ផ្លាស់ប្តូរទីលំនៅដែលជាចំនួនលើសពី ១៥% នៃប្រជាពលរដ្ឋសរុប។

**ទី៣ ទោះបីជាមានការរីកចំរើនផ្នែកសិទ្ធិមនុស្ស និង គោលការណ៍សិទ្ធិប្រជាធិបតេយ្យនៅក្នុងគ្រប់តំបន់នៅលើពិភពលោកក៏ដោយ មនុស្សជាច្រើននៅមានការភ័យខ្លាច តែមានក្តីសុបិន្តចង់បានសេរីភាព។**

បណ្តាប្រទេសដែលអំណាចត្រូវបានប្រមូលផ្តុំក្នុងដៃរបស់អ្នកដឹកនាំដែលមិនមានការទទួលខុសត្រូវ-ទោះជាប្រើលិទ្ធិផ្តាច់ការ ឬ អំណាចអាជ្ញាធរក៏ដោយ ត្រូវបានគេគិតថា គឺជាអ្នករំលោភសិទ្ធិមនុស្សតាមប្រព័ន្ធ។

នៅក្នុងឆ្នាំ ២០០៦ ប្រទេសកូរ៉េខាងជើងនៅតែជាប្រទេសមួយក្នុងចំណោមប្រទេសដែលនៅដាច់តែឯងនៅលើពិភពលោក និង ជារបបដែលដើរថយក្រោយ។ របបនេះគ្រប់គ្រងរាល់ចំណុចទាំងអស់នៃជីវិតប្រជាពលរដ្ឋដោយធ្វើការបដិសេធន៍មិនឱ្យមានសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន ការប្រជុំ និង សមាគម និងធ្វើការកំណត់កំរិតព្រំដែនសេរីភាពការធ្វើសកម្មភាពនានា និង សិទ្ធិរបស់កម្មករ។ រដ្ឋធម្មនុញ្ញផ្តល់ឱ្យ "សិទ្ធិសេរីភាពខាងសាសនា" ប៉ុន្តែមិនមានសេរីភាពសាសនាពិតប្រាកដណាមួយនៅក្នុងប្រទេសនេះនោះទេ។ មានប្រជាពលរដ្ឋប្រហែល ១៥០ ០០០ ទៅ ២០០ ០០០ នាក់ ដោយគិតរួមទាំងអ្នកទោសនយោបាយ ត្រូវបានគេដាក់ឃុំឃាំង និង មានអ្នកទោសជាច្រើននាក់ស្លាប់ដោយសារការធ្វើទារុណកម្ម ការអត់អាហារ ជម្ងឺ និង ការដាក់ចោលដោយគ្មានការការពារគ្រោះថ្នាក់។

រដ្ឋាភិបាលយោធានៅក្នុងប្រទេសភូមាបានប្រើប្រាស់ការសំលាប់ ការរំលោភ ការធ្វើទារុណកម្ម ការឃុំខ្លួនតាមតែទំនើងចិត្ត នឹង បង្ខំឱ្យប្រជាពលរដ្ឋរុះរើលំនៅដ្ឋានចេញពីភូមិទាំងមូល ជាពិសេសចំពោះក្រុមជនជាតិភាគតិច ដើម្បីរក្សាការក្តោបក្តាប់អំណាចរបស់ខ្លួន។ អ្នកទោស និង ជនជាប់ឃុំឃាំង ងាយរងការធ្វើទារុណកម្ម និង ត្រូវបានដាក់ឃុំយ៉ាងវេទនាបំផុត ដែលជាការគំរាមកំហែងដល់អាយុជីវិតរបស់ពួកគេ។ ការតាមដាន ការយាយី និង ការដាក់ពន្ធធនាគារអ្នកទោសសកម្មជននយោបាយ នៅបន្តកើតមាននៅឡើយ លោកស្រីបណ្ឌិតទទួលរង្វាន់ណូបែល និង ជាអ្នកដឹកនាំបក្សប្រឆាំង គឺលោកស្រីអង់សានស៊ូជី ស្ថិតនៅក្នុងការតាមដាន និង ការឃុំខ្លួននៅក្នុងផ្ទះ និង មានអ្នកទោសនយោបាយច្រើនជាង ១ ១០០ នាក់ ត្រូវបានជាប់ឃុំនៅក្នុងពន្ធធនាគារ។ ការបង្ខំឱ្យមនុស្សធ្វើការ ការរត់ពន្ធមនុស្ស ការកេណ្ឌកុមារយកទៅធ្វើយោធា និង ការរើសអើងផ្នែកសាសនា នៅមានទំហំធំធេងនៅក្នុងប្រទេសនៅឡើយ។ រដ្ឋាភិបាលបានធ្វើការជួបប្រជុំនៅក្នុងសន្និបាតជាតិបំភាន់ភ្នែក ដោយធ្វើការជ្រើសរើសប្រតិភូសំរាប់បំរើផលប្រយោជន៍ឱ្យរដ្ឋាភិបាល និង ហាមឃាត់មិនឱ្យមានការពិភាក្សាដោយសេរីនោះទេ។ ដោយការចាត់ទុកថាជា "ផែនទីនាំផ្លូវទៅកាន់លិទ្ធិប្រជាធិបតេយ្យ" សន្និបាតនេះ ត្រូវបានគេបង្កើតឡើងដើម្បីទាត់ចោល

នូវលទ្ធផលការបោះឆ្នោតនៅក្នុងឆ្នាំ១៩៩០ ហើយជ្រើសរើសយករបបថ្មីដែលគេហៅថា រដ្ឋធម្មនុញ្ញរបបមេត្រីភាព។ របបឃោរឃៅ និង ការដឹកនាំដែលធ្វើឱ្យមានការខូចខាត បានធ្វើឱ្យមានចំនួនជនភៀសខ្លួនហូរចេញក្រៅប្រទេស ការរីករាលដាលជម្ងឺឆ្លង និង ការរត់ពន្ធគ្រឿងញៀន និង មនុស្សទៅកាន់ប្រទេសជិតខាង។

រដ្ឋាភិបាលប្រទេសអ៊ីរ៉ង់ បានរំលោភសេរីភាពការបញ្ចេញមតិ និង ការប្រជុំយ៉ាងខ្លាំងក្លា ដោយធ្វើការបន្ថែមសម្ពាធលើការបង្ក្រាបដល់ការបះបោរ អ្នកសារព័ត៌មាន និង អ្នកធ្វើការទាមទារឱ្យមានការផ្លាស់ប្តូររបបគ្រប់គ្រងនានា - គឺជាការគ្រប់គ្រងដែលគេហៅថា ការឃាត់ខ្លួន និង ការឃុំឃាំងតាមតែទំនើងចិត្ត ការធ្វើទារុណកម្ម ការបាត់ខ្លួនសកម្មជន ការប្រើកំលាំងហួសហេតុ និង ការបដិសេធចំពោះការកាត់ទោសដោយមានភាពយុត្តិធម៌នៅចំពោះមុខសាធារណៈ។ រដ្ឋាភិបាលបន្តឃុំខ្លួន និង ធ្វើបាបក្រុម បាហាអ៊ី (Baha'is) និង ជនជាតិភាគតិចកាន់សាសនាផ្សេងៗ និង រៀបចំសន្និសីទថ្កោលទោសដើម្បីបដិសេធចំពោះអត្ថិភាពនៃការសំលាប់បំផ្លិចបំផ្លាញនានា។ នៅក្នុងការប្រជុំដើម្បីជ្រើសរើសអ្នកជំនាញការនៅថ្ងៃទី១៥ ខែធ្នូ នៅក្នុងប្រទេសអ៊ីរ៉ង់ មានបេក្ខភាពចំនួនច្រើនជាង ២/៣ ដែលបានដាក់ពាក្យ-ដោយគិតរួមទាំងបេក្ខជនជាស្ត្រីផងនោះ-ត្រូវបានគេចាត់ទុកថា មិនមានលក្ខណៈគ្រប់គ្រាន់ ដោយទុកឱ្យមានកៅអីជាច្រើនមិនមានអ្នកចូលប្រគួតប្រជែង។ បេក្ខជនរាប់រយនាក់នៅក្នុងការបោះឆ្នោតជ្រើសរើសចៅហ្វាយក្រុង ក៏ត្រូវបានគេចាត់ទុកថា មិនមានលក្ខណៈគ្រប់គ្រាន់នោះដែរ។ រដ្ឋាភិបាលបន្តបំពានទៅនឹងការអំពាវនាវរបស់ជនក្នុងស្រុក និង បណ្តាប្រទេសអន្តរជាតិចំពោះការសុំឱ្យមានការទទួលខុសត្រូវរបស់ខ្លួននៅក្នុងឆ្នាំ២០០៦ ដោយធ្វើការគាំទ្រដល់ចលនាភារវកម្មនៅក្នុងប្រទេសស៊ីរី និង លីបង់ ក៏ដូចជាសុំឱ្យមានការបំផ្លាញចោលនូវរដ្ឋសមាជិករបស់អង្គការសហប្រជាជាតិ។

នៅក្នុងប្រទេសហ្ស៊ីមបាវ៉េ រដ្ឋាភិបាលលោក មូហ្គាប បន្តការរំលោភសិទ្ធិមនុស្សនៅទូទាំងប្រទេស។ អំពើពុករលួយតាមផ្លូវការ និង និទណ្ឌភាព កើតមាននៅពាសពេញប្រទេស។ ច្បាប់សំងាត់ផ្លូវការឆ្នាំ២០០២ និង ច្បាប់សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ នៅតែមានសុពលភាពដដែល ដែលច្បាប់នេះ បានដាក់កំរិតយ៉ាងធ្ងន់ធ្ងរដល់សេរីភាពរបស់បុគ្គល។ នៅក្នុងការបោះឆ្នោតវិសមញ្ញជ្រើសរើសសមាជិកសភាឆ្នាំ២០០៦ និង ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្នាក់ស្រុក ការបោកបញ្ឆោតរបស់រដ្ឋាភិបាលលើនីតិវិធីបោះឆ្នោត បានដកសិទ្ធិបោះឆ្នោតរបស់អ្នកបោះឆ្នោត និង ធ្វើការកែប្រែលទ្ធផលការបោះឆ្នោតទៅកាន់បេក្ខជនរបស់គណបក្សកាន់អំណាច។ ដោយមានការគ្រប់គ្រងដ៏លើសលុបរបស់គណបក្សកាន់អំណាច គេបានធ្វើការកែប្រែរដ្ឋធម្មនុញ្ញដោយមិនចាំបាច់មានការពិភាក្សាឱ្យបានល្អិតល្អន់នោះឡើយ។ កងកំលាំងសន្តិសុខធ្វើការយាយី វាយដំ និង ឃាត់ខ្លួនអ្នករិះគន់រដ្ឋាភិបាល និង អ្នកគាំទ្រគណបក្សប្រឆាំងតាមតែទំនើងចិត្ត។ មានការបង្កចលាចលដោយកងប្រដាប់អាវុធ និង ការរឹបអូសទ្រព្យសម្បត្តិជនស្លូតត្រង់នៅបន្តកើតមាន និង ជួនកាលមានប្រើអំពើហិង្សាថែមទៀតផង។ យុទ្ធនាការបង្ខំប្រជាពលរដ្ឋឱ្យរុះរើលំនៅដ្ឋានដែលធ្វើឱ្យប្រជាពលរដ្ឋប្រមាណ ៧០០ ០០០ នាក់ គ្មានទីជំរកនៅក្នុងពេលបំពេញប្រតិបត្តិការតាមបទបញ្ជានៅក្នុងឆ្នាំ ២០០៥ នៅបន្តកើតមាននៅក្នុងទ្រង់ទ្រាយកាន់តែតូចជាងមុន។ រដ្ឋាភិបាលបានជ្រៀតជ្រែកដល់ កិច្ចខិតខំប្រឹងប្រែងរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការព្យាយាមផ្តល់ជំនួយដល់ជនក្រី

ក្រ។ នៅក្នុងខែធ្នូ លោក មូហ្គាប និង ជនស្មោះត្រង់នឹងគាត់ បានធ្វើការពន្យារអាណត្តិរបស់គាត់រយៈពេល ២ ឆ្នាំ ថែមទៀតដោយ លើកការបោះឆ្នោតជ្រើសរើសប្រធានាធិបតីទៅឆ្នាំ ២០១០។

នៅក្នុងប្រទេសគុយបា រដ្ឋាភិបាលដែលដឹកនាំជាបណ្តោះអាសន្នដោយលោក រ៉ូល កាស្ត្រូ (Raul Castro) ដោយសារជម្ងឺ របស់លោក ហ្វីដែល កាស្ត្រូ (Fidel Castro) បន្តឱ្យមានអំពើហិង្សា និង ការរំលោភលើសិទ្ធិរបស់ប្រជាពលរដ្ឋទាំងអស់ ដោយគិតរួមទាំងសិទ្ធិមូលដ្ឋានក្នុងការផ្លាស់ប្តូររដ្ឋាភិបាលដោយអហិង្សា ឬ ការរិះគន់ដល់ការធ្វើបដិវត្តន៍ ឬ អ្នកដឹកនាំប្រទេសនេះ។ នៅក្នុងឆ្នាំ ២០០៦ រដ្ឋាភិបាលបានបង្កើនកំរិតការយាយីដល់ជនបះបោរ និង ប្រជាពលរដ្ឋផ្សេងទៀត ដែលពួកគេចាត់ទុកថា ជាការគំរាមកំហែងដល់រដ្ឋាភិបាល ជាញឹកញាប់តាមរយៈសកម្មភាពជាហ្វូងមនុស្សដែលគេហៅថា "សកម្មភាពបដិសេធ" ដោយមានទាំងការជេរប្រទេចដោយពាក្យសំដី និង ការធ្វើទុក្ខទោសផ្នែករាង្គកាយផងដែរ។ ការវាយដំ និង ការធ្វើបាបជនជាប់ឃុំឃាំង និង អ្នកទោស ក៏ត្រូវបានគេធ្វើឡើងដោយមិនមានការដាក់ទោសដល់អ្នកប្រព្រឹត្តនោះឡើយ។ ទោះជាមានការដោះលែងអ្នកទោសមួយចំនួនក្នុងឆ្នាំនេះក៏ដោយ យ៉ាងហោចណាស់មានអ្នកទោសនយោបាយចំនួន ២៨៣ នាក់ និង អ្នកជាប់ឃុំឃាំងមួយចំនួនទៀត ត្រូវបានដាក់ក្នុងពន្ធនាគាររហូតមកដល់ចុងឆ្នាំ ដែលក្នុងនោះមានអ្នកគាំទ្រនយោបាយចំនួន ៥៩ នាក់ ក្នុងចំណោមទាំង ៧៥ នាក់ និង សកម្មជនសិទ្ធិមនុស្សមួយចំនួនទៀតត្រូវបានគេដាក់ពន្ធនាគារនៅក្នុងខែមីនា ឆ្នាំ ២០០៣។

នៅក្នុងប្រទេសចិន របាយការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេសនេះមានការធ្លាក់ចុះនៅក្នុងតំបន់ខ្លះនៅក្នុងឆ្នាំ ២០០៦។ មានការកើនឡើងនូវចំនួនទិន្នន័យនៃបទល្មើសដែលទទួលការចាប់អារម្មណ៍ខ្លាំងពីសំណាក់សាធារណៈជន ពាក់ព័ន្ធទៅនឹងការតាមដាន ការយាយី ការឃុំខ្លួន និង ការដាក់ពន្ធនាគារសកម្មជននយោបាយ និង សកម្មជនសាសនា អ្នកសារព័ត៌មាន និង អ្នកនិពន្ធ ក៏ដូចជាមេធាវីការពារក្តីដែលព្យាយាមអនុវត្តសិទ្ធិរបស់ពួកគេតាមផ្លូវច្បាប់ផងដែរ។ មានសមាជិកគ្រួសាររបស់ពួកគេមួយចំនួនត្រូវទទួលការគំរាមកំហែង និង ឃុំខ្លួនផងដែរ។ ការធ្វើបាតុកម្មក្នុងចំនួនច្រើន និង ការតវ៉ានានាដែលសុំឱ្យមានការដោះស្រាយបញ្ហាទុក្ខព្រួយ នៅបន្តមាននៅឡើយ ហើយនៅពេលខ្លះត្រូវបានបង្ក្រាបដោយអំពើឃោរឃៅបំផុត។ ច្បាប់ការគ្រប់គ្រងរបស់រដ្ឋាភិបាលថ្មីៗ ត្រូវបានគេយកមកដាក់កំរិតលើ : អង្គការមិនមែនរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ ដោយគិតរួមទាំងប្រព័ន្ធអ៊ីនធឺណែតផងដែរ និង ដាក់គំនាបលើតុលាការ និង ចៅក្រមកាត់សេចក្តី។ មានការបង្ក្រាបជាច្រើនធ្វើឡើងចំពោះក្រុមសាសនាដែលមិនបានចុះបញ្ជី និង ក្រុមសាសនារបស់ក្រុមជនជាតិភាគតិច ជាពិសេសរបស់ក្រុម Uighurs និង ក្រុមទីបេ ដែលនៅតែជាបញ្ហាដែលត្រូវព្រួយបារម្ភណ៍នៅឡើយ។

នៅក្នុងប្រទេសបេឡារុស (Belarus) រដ្ឋាភិបាលរបស់លោកលូកាសិនកូ (Lukashenko Government) នៅបន្តប្រើប្រាស់ និងដាក់សម្ពាធកាន់តែធ្ងន់ធ្ងរចំពោះគោលនយោបាយបិទសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋដដែល។ ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីនៅខែមីនា ត្រូវបានក្លែងបន្លំយ៉ាងច្រើន។ មានប្រជាពលរដ្ឋរហូតដល់ ១០០០ នាក់ ត្រូវបានឃាត់ខ្លួននៅក្នុងការបន្តបង្ក្រាបដល់ការតវ៉ារបស់សាធារណៈជនប្រឆាំងនឹងលទ្ធផលនៃការ

បោះឆ្នោត និង មានមនុស្សជាច្រើននាក់ត្រូវបានកាត់ឱ្យជាប់ពន្ធនាគារក្នុងរយៈពេលខ្លី។ មានសកម្មជនកាន់តែច្រើន និង សមាជិកគណបក្សប្រឆាំងជាច្រើន ដោយគិតរួមទាំងលោក អាឡិចសាន់ឌឺ គូសូលីន (Aleksander Kozulin) ដែលបានប្រតិបត្តិការនយោបាយប្រឆាំងនឹងលោក លូកាសិនកូ នៅក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតីនេះ ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារដែលមានរយៈពេលពី ២ ទៅ ៥ឆ្នាំកន្លះ។

**រដ្ឋាភិបាលអេរីទ្រាន** បន្តធ្វើសកម្មភាពជារដ្ឋាភិបាលដែលប្រើកំលាំងបង្ក្រាបយ៉ាងខ្លាំងក្លាបំផុតនៅក្នុងអាហ្វ្រិកសាហារ៉ា ហើយរបាយការណ៍សិទ្ធិមនុស្សរបស់ប្រទេសនេះមានការធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងឆ្នាំ ២០០៦។ កងកំលាំងសន្តិសុខរបស់រដ្ឋាភិបាលបានប្រព្រឹត្តការសំលាប់ក្រៅសំណាញ់ច្បាប់ជាច្រើន មានប្រភពរបាយការណ៍ដែលអាចទុកចិត្តបានមួយបានរាយការណ៍ថា កំលាំងរក្សាសន្តិសុខរបស់រដ្ឋាភិបាលបានបាញ់ប្រជាពលរដ្ឋដែលព្យាយាមឆ្លងព្រំដែនទៅកាន់ប្រទេសអេត្យូពាដោយត្រង់ៗតែម្តង។ រដ្ឋាភិបាលពង្រីកយុទ្ធនាការធ្វើការឃាត់ខ្លួនអ្នកដែលរត់គេចខ្លួនចេញពីប្រទេស ក៏ដូចជាសាច់ញាតិរបស់ពួកគេ និង មានព័ត៌មានគួរឱ្យទុកចិត្តមួយទៀតបានឱ្យដឹងថា ជនមួយចំនួនដែលគេឃាត់ខ្លួនទទួលរងនូវការធ្វើទារុណកម្ម។ ដូចដែលរដ្ឋាភិបាលនេះបានប្រព្រឹត្តនៅក្នុងឆ្នាំ ២០០៥ រដ្ឋាភិបាលបានចេញបញ្ជាឱ្យអង្គការជំនួយមនុស្សធម៌ជាតិ និង អន្តរជាតិជាច្រើនចាកចេញពីប្រទេស ទោះជាមានគ្រោះរាំងស្ងួតធ្ងន់ធ្ងរនៅក្នុងតំបន់ស្នែងក្របី(Horn of Afric) នៅក្នុងអាហ្វ្រិកក៏ដោយ។ នៅមានការកំណត់កំរិតយ៉ាងធ្ងន់ធ្ងរចំពោះសេរីភាពខាងសាសនាផងដែរ។

**ហេតុការណ៍អាក្រក់ទី ៤ គឺថា នៅពេលដែលមានការជំរុញចង់បានឱ្យសេរីភាពផ្ទាល់ខ្លួន និងសេរីភាពខាងនយោបាយរីកដុះដាលកាន់តែខ្លាំង វាត្រូវប្រឈមមុខនៅនឹងការប្រឆាំងតបតពីសំណាក់អ្នកដែលមានអារម្មណ៍ភ័យខ្លាចមានការផ្លាស់ប្តូររបបនយោបាយ និង របបសង្គមកាន់តែខ្លាំងដែរ។**

អ្នកការពារសិទ្ធិមនុស្ស និង អង្គការមិនមែនរដ្ឋាភិបាល មានសារសំខាន់ណាស់ចំពោះជ័យជំនះរបស់ជាតិ។ នៅក្នុងពិភពលោកថ្ងៃនេះ បញ្ហាការប្រឈមមុខទៅនឹងវដ្តនានាកាន់តែមានភាពសាំញ៉ាំឡើង សូម្បីតែធ្វើការដោះស្រាយបញ្ហាជាមួយតែអ្នកដែលមានអំណាចបំផុតតែមួយរូបក៏ដោយ។ ការចូលរួមរបស់សង្គមស៊ីវិល និង ការផ្តល់គំនិតដោយសេរី និងព័ត៌មាន មានតួនាទីសំខាន់ណាស់នៅក្នុងការដោះស្រាយការលំបាកនៅក្នុងប្រទេស និងឧបសគ្គអន្តរជាតិនានា។ ការកំរិតកំណត់ទំហំផ្នែកនយោបាយដល់អង្គការមិនមែនរដ្ឋាភិបាល និងការពិភាក្សាជាសាធារណៈ គឺគ្រាន់តែជាការកំណត់កំរិតដល់ការរីកលូតលាស់របស់សង្គមខ្លួនឯងតែប៉ុណ្ណោះ។

នៅគ្រប់ទីកន្លែងនៅលើសកលលោកក្នុងឆ្នាំ ២០០៦ តែងតែមានរដ្ឋាភិបាលដែលឆ្លើយតបទៅនឹងការកើនឡើងនៃតំរូវការសេរីភាពក្នុងការធ្វើនយោបាយ និង សេរីភាពផ្ទាល់ខ្លួន ដោយមិនបានទទួលយកកាតព្វកិច្ចរបស់ខ្លួនទៅបំពេញដើម្បីបំរើប្រជាពលរដ្ឋនោះទេ ប៉ុន្តែបែរជាបង្ក្រាបជនទាំងឡាយណាដែលមានបំណងចង់ធ្វើការតវ៉ារកសិទ្ធិមនុស្ស និង ចំពោះជនទាំងឡាយណាដែលបង្ហាញពីការរំលោភទាំងនេះ ដូចជា អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដោយគិតរួមទាំងអ៊ីនធឺណែតផងដែរ។ មានប្រទេសដែលស្ថិតនៅក្នុងភាពរំជើបរំជួលមួយចំនួនបានអនុម័តច្បាប់ ឬ អនុវត្តច្បាប់ និងបទបញ្ញត្តិ ដែលមានការជ្រើសរើសសំរាប់ប្រឆាំងនឹងអង្គការរដ្ឋា

ភិបាល និងអ្នកសារព័ត៌មាន។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និង អ្នកសារព័ត៌មាន ក៏ងាយរងគ្រោះដោយសារវិធានការណ៍ក្រៅផ្លូវច្បាប់ ដែលជាញឹកញាប់ គឺដោយសារការធ្វើឃាតដោយឃាតករមិនដឹងមុខ។ ឧទាហរណ៍ :

នៅក្នុងប្រទេសរូស្ស៊ីក្នុងឆ្នាំ ២០០៦ ច្បាប់ថ្មីសំរាប់អង្គការ ត្រូវបានប្រកាសសុពលភាពនៅក្នុងខែមេសា ដែលបានដាក់បទបញ្ជាកាន់តែតឹងរឹងចំពោះអង្គការមិនមែនរដ្ឋាភិបាល ការតាមដានម៉ត់ចត់ចំពោះសកម្មភាពរបស់អង្គការ តំរូវការឱ្យមានការផ្តល់របាយការណ៍ម៉ត់ចត់ និង ល្អិតល្អន់ពីសកម្មភាពរបស់ខ្លួន និង ផ្តល់អំណាចដល់ផ្នែកសេវាកម្មចុះឈ្មោះរបស់សហព័ន្ធដើម្បីបដិសេធដល់ការចុះឈ្មោះរបស់អង្គការ ឬ ការបិទអង្គការនោះ បើមានការផ្តល់ព័ត៌មានក្លែងក្លាយ និង លក្ខណៈវិនិច្ឆ័យដែលពឹងផ្អែកលើគំនិត។ សេរីភាពក្នុងការបញ្ចេញមតិ និង ភាពឯករាជ្យរបស់ប្រព័ន្ធផ្សព្វផ្សាយមានការថយចុះដោយសារសម្ពាធរបស់រដ្ឋាភិបាល និង ការកំណត់កំរិតនានា។ នៅក្នុងខែតុលា មានបុគ្គលមិនស្គាល់មុខបានធ្វើឃាតអ្នកការពារសិទ្ធិមនុស្ស អាណាប៉ូលីកូកាយ៉ា(Anna Politkovskaya) ដែលជាអ្នកសារព័ត៌មានដែលលេចធ្លោបំផុត ចំពោះការសរសេររិះគន់ពីការរំលោភសិទ្ធិមនុស្សនៅក្នុងរដ្ឋឆេចឆិន។ រដ្ឋាភិបាលប្រើប្រាស់ការគ្រប់គ្រងបណ្តាញទូរទស្សន៍ និង វិទ្យុទាំងអស់ ក៏ដូចជាបណ្តាញសារព័ត៌មានដែលមានឥទ្ធិពលបំផុតនៅក្នុងតំបន់ ដោយធ្វើការកំណត់កំរិតការទទួលព័ត៌មានដែលមានផលប៉ះពាល់ដល់រដ្ឋាភិបាល។

នៅក្នុងប្រទេស**បេឡារុស** ការពិនិត្យលើពន្ធដារយ៉ាងល្អិតល្អន់ និង តំរូវការចុះឈ្មោះដល់អង្គការ បានធ្វើឱ្យមានការលំបាកដល់សង្គមស៊ីវិលធ្វើប្រតិបត្តិការ និង មានការធ្វើការវាយប្រហារដល់សមាជិកសារព័ត៌មានឯករាជ្យនានានៅបន្តកើតមានឡើងនៅឡើយ។ នៅក្នុងខែវិច្ឆិកា សកម្មជនគាំទ្រលិទ្ធិប្រជាធិបតេយ្យម្នាក់ឈ្មោះ ឌ្មីទ្រីដា ស្កេវិច (Dmitriy Dashkevich) ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ១៨ ខែ ចំពោះការបើកប្រតិបត្តិការអង្គការដែលមិនមានការចុះបញ្ជីត្រឹមត្រូវ។

នៅក្នុងប្រទេស**ហ្កាស្សាស្តង់** រដ្ឋាភិបាលប្រទេសនេះបានទទួលចុះឈ្មោះគណបក្សប្រឆាំង True Ak Zhol នៅបន្ទាប់ពីសហការីដឹកនាំ១រូបត្រូវបានគេសំលាប់ និង បានបកស្រាយច្បាប់មាត្រាទី ៥ នៃរដ្ឋធម្មនុញ្ញយ៉ាងតឹងរឹងបំផុត ដើម្បីផ្អាកសកម្មភាពអង្គការមិនមែននយោបាយដែលទទួលមូលនិធិបរទេសចំពោះសកម្មភាពបណ្តុះបណ្តាល ដោយបានបញ្ជាក់ថា ការផ្តល់ព័ត៌មាន គឺមានតំលៃស្មើនឹងការផ្តល់មូលនិធិដល់គណបក្សនយោបាយ។ នៅក្នុងខែកក្កដា លោកប្រធានាធិបតី Nazarbayev បានចុះហត្ថលេខាលើច្បាប់មួយដែលកំណត់កំរិតដល់ប្រព័ន្ធផ្សព្វផ្សាយដែលគេចាត់ទុកថាជាការដើរថយក្រោយពីសំណាក់អង្គការសំរាប់សន្តិសុខ និង កិច្ចសហប្រតិបត្តិការនៅក្នុងសេរីភាពសារព័ត៌មាននៅក្នុងអឺរ៉ុប។ រដ្ឋាភិបាលបន្តប្រើប្រាស់ច្បាប់ដាក់កំរិត ដើម្បីធ្វើការផាកពិន័យ កាត់ទោស និង ផ្អាកសកម្មភាពរបស់ប្រព័ន្ធផ្សព្វផ្សាយ អ្នកកាសែត និង អ្នករិះគន់រដ្ឋាភិបាល។ នៅក្នុងខែមេសា សមាជិករបស់សារព័ត៌មានដែលគេផ្អាកសកម្មភាពមួយរូបត្រូវបានគេវាយដំយ៉ាងព្រៃផ្សៃបំផុត។

នៅក្នុងប្រទេស**តួកម៉េនីស្តង់** (Turkmensistan) សេរីភាពការបញ្ចេញមតិ ការបង្កើតសមាគមន៍ និង ការប្រជុំ ត្រូវបានកំណត់យ៉ាងតឹងរឹងបំផុត ហើយរដ្ឋាភិបាលព្យាយាមធ្វើការត្រួតត្រានូវរាល់សកម្មភាពរបស់អង្គការទាំងអស់។ បណ្តាញទូរទស្សន៍ខ្សែកាបដែលមានទីតាំងនៅបរទេសទាំងអស់ អាចប្រើប្រាស់នៅទូទាំងប្រទេស ប៉ុន្តែ

ត្រួតត្រាទូវរាល់បណ្តាញផ្សព្វផ្សាយក្នុងស្រុកទាំងអស់ ហើយអ្នកសារព័ត៌មានក្នុងស្រុកត្រូវបានហាមឃាត់ពីការធ្វើទំនាក់ទំនងជាមួយអ្នកសារព័ត៌មានបរទេស លើកលែងតែមានការអនុញ្ញាតជាពិសេសណាមួយ។ មានសេវាប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែតតិចតួចបំផុតដែលបានដាក់ឱ្យប្រើប្រាស់តាមរយៈទូរគមនាគមន៍របស់រដ្ឋ មិនមានបណ្តាញថ្មីណាមួយត្រូវបានអនុញ្ញាតឱ្យបើកនៅក្នុងទីក្រុងនោះទេ ចាប់តាំងពីខែកញ្ញា ឆ្នាំ២០០២ មក។ នៅក្នុងខែសីហា រដ្ឋាភិបាលបានឃាត់ខ្លួនអ្នកសារព័ត៌មានឈ្មោះ អូហ្គុលស្ប៉ាប៉ា មីរ៉ាដូវ៉ា (Ogulspapar Myradova), អាណាគូបាន អាម៉ាន់ឃ្លិកឆូ (Annakurban Amanklichev) និង សាប៉ាដឺឌី ហាជីយូ (Sapardurdy Hajiyev) និង បានកាត់ទោសពួកគេឱ្យជាប់ពន្ធនាគារពី ៦ ទៅ ៧ ឆ្នាំ ចំពោះការកាន់កាប់អាវុធ នៅក្នុងការកាត់ទោសក្នុងបន្ទប់សំងាត់មួយ។ នៅក្នុងខែកញ្ញា លោក Myradova អ្នកឆ្លើយឆ្លងសារព័ត៌មានរបស់សារព័ត៌មានវិទ្យុអឺរ៉ុបសេរី/វិទ្យុសេរីភាពត្រូវស្លាប់នៅក្នុងពន្ធនាគារនៅក្រោមការសង្ស័យ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍មកថា រូបរាង និង សហការី ត្រូវទទួលរងការធ្វើទារុណកម្មនៅក្នុងពេលជាប់ឃុំឃាំងនៅក្នុងរដូវក្តៅ ដើម្បីធ្វើឱ្យពួកគេផ្តល់ចំលើយសារភាពពីទោសកំហុសថា បានកាន់កាប់អាវុធខុសច្បាប់។ នៅថ្ងៃទី២១ ខែធ្នូ លោកប្រធានាធិបតី សាប៉ាមូរ៉ាត បានស្លាប់។

រដ្ឋាភិបាល**យូប៊ែហ្គីស្តង់** បានព្យាយាមធ្វើការត្រួតត្រានូវរាល់សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលស្ទើរតែទាំងអស់ និង បានបិទអង្គការសង្គមស៊ីវិលចំនួនច្រើនជាង ២០០ អង្គការ ដោយគិតរួមទាំងអង្គការអន្តរជាតិដែលមានប្រតិបត្តិការនៅក្នុងប្រទេសនេះផងដែរ ដោយត្រូវបានគេដកស្រង់មកបញ្ជាក់ថា មានការរំលោភលើបទបញ្ជានៃច្បាប់។ អ្នកសារព័ត៌មានឯករាជ្យ និង សកម្មជនសិទ្ធិមនុស្ស កំពុងប្រឈមមុខនឹងការធ្វើទុក្ខទោសនានា។

រដ្ឋាភិបាលប្រទេស**ស៊ីរី** ធ្វើការត្រួតត្រាដល់ការផ្សព្វផ្សាយព័ត៌មានយ៉ាងតឹងរឹងបំផុត និង ធ្វើការហាមឃាត់នូវរាល់កម្មភាពរិះគន់ដល់រដ្ឋាភិបាល និង ការធ្វើការពិភាក្សាពីបញ្ហាសាសនា ដោយគិតរួមទាំងសិទ្ធិខាងសាសនា និង សិទ្ធិរបស់ក្រុមជនជាតិភាគតិចផងដែរ។ មានការឃុំខ្លួន និង ការវាយដំដល់បុគ្គលណាដែលហ៊ានបញ្ចេញមតិដែលលើសពីការកំរិតរបស់រដ្ឋ ឧទាហរណ៍ជាក់ស្តែង នៅក្នុងខែកុម្ភៈ មានការឃាត់ខ្លួនអ្នកសារព័ត៌មាន១រូបឈ្មោះ អាដែលម៉ាហ្វូស (Adel Mahfouz) នៅបន្ទាប់ពីគាត់អំពាវនាវសុំឱ្យមានការបកស្រាយពីសកម្មភាពសាសនា បន្ទាប់ពីពេលមានរូបចំអករបស់លោកព្រះរាជគ្រូមហាម៉ាត់នៅក្នុងរូបតុក្កតា។ រដ្ឋាភិបាលពឹងផ្អែកលើសារព័ត៌មាន និងការបោះពុម្ពផ្សាយច្បាប់ផ្ទាល់ខ្លួន ច្បាប់ព្រហ្មទណ្ឌ និង ច្បាប់ភាពអាសន្នដើម្បីត្រួតពិនិត្យការប្រើប្រាស់អ៊ីនធឺណែត ហើយរដ្ឋាភិបាលនេះបានដាក់កំរិតដល់ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិច។ ការយាយីដល់សកម្មជនសិទ្ធិមនុស្សក្នុងស្រុក តែងកើតមានជាញឹកញាប់ ដោយគិតរួមទាំងមានការតាមដានយ៉ាងជិតដិត និង ការដាក់ការហាមប្រាមដល់ការធ្វើដំណើរ នៅពេលដែលពួកគេព្យាយាមចូលរួមនៅក្នុងអង្គសិក្ខាសាលានានា និង សន្និសីទនៅក្រៅប្រទេស។

នៅក្នុងប្រទេសអៀរ៉ង់ សេរីភាពក្នុងការបញ្ចេញមតិតែងតែមានកំរិតទាបជានិច្ចនៅគ្រប់ពេលទាំងអស់ ព្រោះរដ្ឋាភិបាលបានបិទសារព័ត៌មានឯករាជ្យមួយឈ្មោះថា *Shargh and Iran* និង បិទសិទ្ធិដល់ការប្រើប្រាស់

គេហទំព័រព័ត៌មានតាមអ៊ីនធឺណែត ដោយគិតរួមទាំងការសែតញូវយ៉កថែម និង ប៊ីប៊ីស៊ី និង មានការដាក់ព័ន្ធធនាគារអ្នកសារព័ត៌មាន និង អ្នកផ្សព្វផ្សាយដំណឹងនានាផងដែរ។ អាជ្ញាធរបានដាក់បំរាមមិនឱ្យចាកចេញពីប្រទេស ដើម្បីធ្វើជាអាវុធប្រឆាំងនឹងអ្នកសារព័ត៌មាន។

នៅក្នុង**ប៊ូរុនឌី** (Burundi) មានការកើនឡើងលើការឃាត់ខ្លួន ការដាក់ឃុំឃាំង និង ការគំរាមកំហែងដល់អ្នកសារព័ត៌មាន ព្រមទាំងសកម្មជនសិទ្ធិមនុស្សពីសំណាក់រដ្ឋាភិបាល។ ប៉ូលីសបានឃាត់ខ្លួនបុគ្គលផ្សេងៗ និង បានដាក់ឃុំអស់រយៈពេលជាច្រើនខែចំពោះប្រធានអង្គការប្រឆាំងអំពើពុករលួយមួយដែលឈានមុខគេនៅក្នុងប្រទេស។ អភិបាលខេត្តរបស់ខេត្តមួយបានហៅអង្គការសិទ្ធិមនុស្សដែលឈានមុខគេមួយ គឺ សម្ព័ន្ធអីតិកា (Iteka league) ថា ជាសត្រូវនៃសន្តិភាព ហើយនៅក្នុងខែវិច្ឆិកា បុគ្គលិករបស់រដ្ឋាភិបាលបានប្រកាសថា មានអង្គការអន្តរជាតិចំនួន ៣២ អង្គការ អាចប្រឈមមុខទៅនឹងការបណ្តេញចេញពីប្រទេស ចំពោះការខកខានមិនបានបញ្ជូនរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនតាមកាលកំណត់ទៅកាន់រដ្ឋាភិបាល។

នៅក្នុងប្រទេស**រវ៉ាន់ដា** (Rwanda) មានការកំរិតព្រំដែនចំពោះមុខងាររបស់សង្គមស៊ីវិល។ អង្គការសិទ្ធិប្រជាធិបតេយ្យ និង អង្គការអន្តរជាតិ ត្រូវបានតំរូវដោយច្បាប់ឱ្យធ្វើការចុះបញ្ជីរៀងរាល់ឆ្នាំ និង ផ្តល់ព័ត៌មានពីសកម្មភាពរបស់ខ្លួនទៅកាន់រដ្ឋាភិបាល។ តាមរបាយការណ៍ អាជ្ញាធរបានតំរូវឱ្យអង្គការមួយចំនួនទទួលយកការបញ្ជាពីរដ្ឋាភិបាលចំពោះគំរោងមួយចំនួន មុនពេលអនុញ្ញាតឱ្យទទួលជំនួយពីម្ចាស់ជំនួយអន្តរជាតិ។ លើសពីនេះ អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ត្រូវបានគេសង្ឃឹមទុកថា ត្រូវចូលរួមគ្នាក្នុងការចាត់ចែងសកម្មភាពរបស់ខ្លួន។

នៅក្នុងប្រទេស**វេនីហ្ស៊ូអេឡា** រដ្ឋាភិបាលបន្តធ្វើការយាយី និង ធ្វើការបំភិតបំភ័យដល់ក្រុមសង្គមស៊ីវិល ជាពិសេសចំពោះប្រធានអង្គការឃ្លាំមើលការបោះឆ្នោតមួយ ហៅថា ស៊ូម៉េត (Sumate) ដែលទទួលការកាត់ទោសចំពោះ បទចោទប្រកាន់ពីអំពើចារកម្ម និង ក្បត់ជាតិ ចំពោះការទទួលជំនួយបរទេស ត្រូវបានផ្អាកជាបណ្តោះអាសន្ន ប៉ុន្តែវានៅបន្តធ្វើឱ្យពួកគេមានការភិតភ័យជានិច្ច។ នៅចុងឆ្នាំ ពង្រាងច្បាប់មួយស្ថិតនៅក្នុងការពិចារណារបស់សភាជាតិ ដែលប្រសិនបើត្រូវបានដាក់ប្រើប្រាស់ច្បាប់នេះ នឹងបង្កើនការគ្រប់គ្រងរបស់រដ្ឋាភិបាលចំពោះសកម្មភាពរបស់អង្គការគ្រប់គ្រងការផ្តល់ហិរញ្ញប្រទាន និង ដាក់កំរិតដល់អង្គការនានាមិនឱ្យធ្វើសកម្មភាពពាក់ព័ន្ធទៅនឹងការផ្សព្វផ្សាយពីសិទ្ធិមនុស្ស ឬលិទ្ធិប្រជាធិបតេយ្យនោះឡើយ។ ការធ្វើវិសោធនកម្មច្បាប់ព្រហ្មទណ្ឌដែលដាក់អោយមានទោសជាប់ពន្ធនាគារពីបទការប្រមាថមន្ត្រីសាធារណៈ និង ការវាយប្រហាដោយអំពើហិង្សាចំពោះអ្នកសារព័ត៌មាន បានជះឥទ្ធិពលបង្កឱ្យមានបរិយាកាសធ្វើការត្រួតពិនិត្យដល់សកម្មភាពផ្សព្វផ្សាយព័ត៌មាន។ រដ្ឋាភិបាលបានបង្កើនកំរិតការយាយីចំពោះសារព័ត៌មានឯករាជ្យ និង សារព័ត៌មានដែលប្រឆាំងនឹងរដ្ឋាភិបាល។ នៅក្នុងខែធ្នូ លោកប្រធានាធិបតីឆាវេបានប្រកាសថា រដ្ឋាភិបាលនឹងមិនផ្តល់អាជ្ញាប័ណ្ណជាថ្មីម្តងទៀតចំពោះការផ្សព្វផ្សាយរបស់ទូរទស្សន៍/វិទ្យុខារាខាស ដែលជាបណ្តាញទូរទស្សន៍ផ្សព្វផ្សាយពាណិជ្ជកម្មមួយដែលមានអាយុកាលច្រើនជាងគេបំផុតនៅក្នុងប្រទេសនេះ។ រដ្ឋាភិបាលបានចោទប្រកាន់ម្ចាស់បណ្តាញនេះថាជា "អ្នកជំនួញធ្វើរដ្ឋប្រហា" និង ពីបទរំលោភលើសេចក្តីទុកចិត្តរបស់សាធារណៈ។

នៅក្នុង**ប្រទេសចិន** ទាំងអង្គការក្នុងស្រុក និង អង្គការអន្តរជាតិនៅបន្តប្រឈមមុខទៅនឹងការតាមដានយ៉ាងមត់ចត់ និង ការដាក់កំរិតកំណត់ចំពោះសកម្មភាពរបស់ខ្លួននៅឡើយ។ រហូតដល់ចុងឆ្នាំ២០០៦ សារព័ត៌មានដោយគ្មានព្រំដែនបានផ្តល់សេចក្តីរាយការណ៍ថា មានអ្នកសារព័ត៌មានចំនួន ៣១ នាក់ និង អ្នកសរសេរអត្ថបទដាក់តាមអ៊ីនធឺណែតចំនួន ៥២ នាក់ផ្សេងទៀតត្រូវបានរដ្ឋាភិបាលដាក់ពន្ធនាគារ។ នៅពេលដែលរដ្ឋាភិបាលជំរុញឱ្យមានការប្រើប្រាស់អ៊ីនធឺណែត រដ្ឋាភិបាលក៏បានចាត់វិធានការណ៍ដើម្បីធ្វើការគ្រប់គ្រងការប្រើប្រាស់ផងដែរ ដោយធ្វើការត្រួតពិនិត្យខ្លឹមសារ កំរិតព័ត៌មាន និងដាក់ទោសចំពោះជនទាំងឡាយណាដែលរំលោភបទបញ្ជា។ រដ្ឋាភិបាលបានដាក់ការកំណត់តំរូវការតឹងរឹងបំផុតចំពោះការចុះបញ្ជីសេវាកម្មអ៊ីនធឺណែត ដោយដាក់ប្រព័ន្ធត្រួតពិនិត្យផ្ទាល់លើខ្លឹមសារ និង ពង្រីកនិយមន័យខ្លឹមសារអត្ថបទដែលផ្សើរតាមប្រព័ន្ធផ្ទាល់ឱ្យកាន់តែខុសច្បាប់។ រដ្ឋាភិបាលតែងតែបិទមិនអាចឱ្យប្រើប្រាស់បានចំពោះគេហទំព័រដែលរដ្ឋាភិបាលគិតថាមានភាពចំរូងចំរាស់ ហើយតាមសេចក្តីរាយការណ៍ អាជ្ញាធរបានចាប់ផ្តើមដាក់ប្រព័ន្ធបច្ចេកវិទ្យាកាន់តែមានភាពសាំញ៉ាំ ដែលជំរុញឱ្យមានការបិទផ្លូវទំនាក់ទំនងដល់ខ្លឹមសារពិសេសៗជាជាងគេហទំព័រទាំងមូលតែម្តង។

**ប្រទេសវៀតណាម** បន្តធ្វើការត្រួតពិនិត្យ និង ដាក់កំរិតដល់ប្រព័ន្ធអ៊ីនធឺណែត ដោយបានបិទច្រកអត្ថបទស្តីពីសិទ្ធិមនុស្សអន្តរជាតិ និង គេហទំព័រដំណឹងផ្សេងៗ។ ច្បាប់ប្រទេសនេះ អាចអនុញ្ញាតឱ្យប្រជាពលរដ្ឋធ្វើការប្តឹងដោយចំហរអំពីភាពខ្វះខាតរបស់រដ្ឋាភិបាល និង អំពើពុករលួយ ប៉ុន្តែរដ្ឋាភិបាលនៅបន្តហាមឃាត់សារព័ត៌មានពីការសរសេរអត្ថបទដែលចោទសួរដល់តួនាទីគណបក្សកុំម្មុយនីស ជំរុញឱ្យមានពហុបក្ស ឬ គណបក្សពហុលិទ្ធិប្រជាធិបតេយ្យ ឬ សួរពីបញ្ហាគោលនយោបាយសិទ្ធិមនុស្ស។ រដ្ឋាភិបាលហាមឃាត់មិនឱ្យប្រើប្រាស់សេវាកម្មអ៊ីនធឺណែតតាមរយៈអ្នកផ្តល់សេវាកម្មឯករាជ្យ និង តំរូវឱ្យម្ចាស់អ៊ីនធឺណែត Cybercafe ធ្វើការចុះឈ្មោះពីព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជនរបស់ខ្លួន និង គេហទំព័រដែលពួកគេប្រើប្រាស់។ រដ្ឋាភិបាលបានចេញផ្សាយព័ត៌មានពីជនបះបោរផ្នែកនយោបាយ និង សាសនាជាច្រើន ដោយគិតរួមទាំង លោកបណ្ឌិត ផាមហុងសាន់ (Pham Hong Son) ផងដែរ ដែលត្រូវបានគេដាក់ពន្ធនាគារចំពោះការបកប្រែអត្ថបទនៅតាមអ៊ីនធឺណែត លើបញ្ហាលិទ្ធិប្រជាពិបតេយ្យ និង ការផ្សព្វផ្សាយព័ត៌មានទាំងនេះតាមអ៊ីនធឺណែត។

### ការប្រល័យពូជសាសន៍ គឺជាហេតុការណ៍អាក្រក់ជាងគេបំផុត

**វា**ស្ទើរតែរយៈពេល ៦០ ឆ្នាំទៅហើយ បន្ទាប់ពីការទទួលយកសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស-- ដែលជាចំណាប់អារម្មណ៍មួយលើការជាស់សតិសម្បញ្ញៈរបស់មនុស្សជាតិឱ្យចងកំហឹងទៅនឹងការបំផ្លិចបំផ្លាញដ៏ធំធេង (Holocaust) និង ការបំផ្លិចបំផ្លាញដ៏មហិមារបស់សង្គ្រាមលោកលើកទី ២ --ការសំលាប់រង្គាលនៅបន្តកើតមាននៅក្នុងតំបន់ដាហ្វឺរបស់ប្រទេសស៊ូដង់។

ទោះបីជាមានកិច្ចព្រមព្រៀងសន្តិភាពច្បាស់លាស់នៅក្នុងខែមករា ឆ្នាំ២០០៥ ដែលបានបញ្ចប់សង្គ្រាមស៊ីវិលរយៈពេល២២ឆ្នាំរវាងភាគខាងជើង និង ភាគខាងត្បូង និង ការបង្កើតឱ្យមានរដ្ឋាភិបាលរួបរួមមួយនៅក្នុងឆ្នាំនោះក៏ដោយ ជំលោះផ្នែកជាតិសាសន៍នៅបន្តកើតមាននៅក្នុងប្រទេសស៊ូដង់ ដែលអ្វីជាហេតុការអាក្រក់បំផុតនោះ

គឺនៅក្នុងតំបន់ដាហ្វួ។ រដ្ឋាភិបាលរបស់ប្រទេសស៊ូដង់ និង ក្រុមយោធាដែលមានរដ្ឋាភិបាលជាបង្អែក ត្រូវធ្វើការទទួលខុសត្រូវលើអំពើប្រល័យពូជសាសន៍នៅក្នុងដំបន់ដាហ្វួ ហើយភាគីទាំងអស់របស់ក្រុមបំផ្លិចបំផ្លាញនេះបានប្រព្រឹត្តបទល្មើសយ៉ាងធ្ងន់ធ្ងរ ដោយរួមមានទាំងការសំលាប់រង្គាលជនស៊ីវិលពាសពេញប្រទេស ការរំលោភសេពសន្ថវៈធ្វើជាឧបករណ៍សង្គ្រាម ការធ្វើទារុណកម្មតាមប្រព័ន្ធ អំពើចោរកម្ម និង ការចាប់ជំរិតកុមារយកទៅធ្វើយោធា។ រហូតដល់ចុងឆ្នាំ ២០០៦ យ៉ាងហោចណាស់ ជំលោះនៅក្នុងតំបន់ដាហ្វួបានធ្វើឱ្យជនស៊ីវិល ២០០ ០០០ នាក់ស្លាប់បាត់បង់ជីវិត និង ចំនួន ២ លាននាក់ធ្វើការផ្លាស់ទីជំរកដោយសារការវាយប្រហារបង្ហូរឈាម។ មានជនភៀសខ្លួនច្រើនជាង ២៣៤ ០០០ នាក់បានភៀសខ្លួនទៅកាន់តំបន់ជិតខាងឈ្មោះ Chad ហើយ ទាំងនៅក្នុង Chad ទាំងសាធារណៈរដ្ឋអាហ្វ្រិកកណ្តាល ធ្លាប់ទទួលរងជំលោះជាតិសាសន៍ដូចគ្នានៅតាមព្រំដែនជាមួយស៊ូដង់ដែរ។

ទោះបីជាវាមានការបង្ហាញពីការផ្តល់ការគាំទ្រចំពោះក្របខណ្ឌការងារ Addis Ababa របស់ខ្លួនក៏ដោយ រដ្ឋាភិបាលស៊ូដង់បានបដិសេធន៍ចោលជាសាធារណៈចំពោះកងកំលាំងអន្តរជាតិនៅក្នុងដំបន់ដាហ្វួ និង បន្តប្រតិបត្តិការយោធាយ៉ាងព្រៃផ្សៃនៅក្នុងរយៈពេលកន្លះឆ្នាំ ២០០៦ ក្រោយមក។ ស្ថានភាពតោកយ៉ាកផ្នែកសន្តិសុខបានបង្ខំឱ្យអង្គការអន្តរជាតិមួយចំនួន និង អង្គការមនុស្សធម៌នានា ត្រូវកាត់បន្ថយទំហំការងារ ឬ ផ្អាកប្រតិបត្តិការរបស់ខ្លួន។

### ការពារអ្នកការពារសិទ្ធិ និងលិទ្ធិប្រជាធិបតេយ្យ

ប្រសិនបើការសន្យាដ៏ធំធេងរបស់សេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស ត្រូវធ្វើការបំពេញ សហគមន៍អន្តរជាតិ -- និង ជាពិសេសប្រទេសលិទ្ធិប្រជាធិបតេយ្យនៃពិភពលោក មិនអាចទទួលយកបានទេថា ហេតុការណ៍អាក្រក់នៅថ្ងៃនេះងាយធ្វើការផ្លាស់ប្តូរនោះ។ តាមពិត ពួកគេកំពុងតែជំរុញយើងទាំងអស់គ្នាឱ្យចូលរួមជាមួយជនទាំងអស់នោះដែលកំពុងធ្វើការដើម្បីសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និង ការធ្វើកំណែទម្រង់ផ្នែកនយោបាយ។

ក្នុងឆ្នាំ២០០៦ អ្នកការពារសិទ្ធិមនុស្សដែលមានភាពក្លាហាន ត្រូវបានទទួលការចាប់អារម្មណ៍ពីរដ្ឋាភិបាលប្រជាធិបតេយ្យៈ

ការប្តេជ្ញាចិត្តរបស់ប្រទេសដែលអនុម័តដោយសន្និបាតទូទៅរបស់អង្គការសហប្រជាជាតិនៅក្នុងឆ្នាំ២០០៦ ផ្តោតការសង្កត់ធ្ងន់ចំពោះតំរូវការដើម្បីធ្វើការការពារអ្នកការពារសិទ្ធិមនុស្សនៅក្នុងប្រទេសអ៊ីរ៉ង់ បេឡារុស កូរ៉េខាងជើង និង ភូមា។

មូលនិធិលិទ្ធិប្រជាធិបតេយ្យរបស់អង្គការសហប្រជាជាតិ ដែលផុសចេញគំនិតមួយតាមការផ្តល់ជូនទៅសន្និបាតទូទៅដោយលោកប្រធានាធិបតី ប៊ូស ក្នុងឆ្នាំ ២០០៤ ហើយត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៥ បានបញ្ចប់ឆ្នាំទីមួយរបស់ខ្លួនដោយជោគជ័យ។ គណៈកម្មការដឹកនាំរបស់មូលនិធិនេះ បានយល់ព្រមផ្តល់មូលនិធិដល់គំរោងចំនួន ១២៥ គំរោង ក្នុងចំណោមគំរោងស្នើរសុំចំនួន ១ ៣០០ ដែលត្រូវបានផ្ញើរមកពីប្រទេសចំនួនជាង ១០០

ប្រទេស ដោយមានការបញ្ចេញសាច់ប្រាក់ចំនួនច្រើនជាង ៣៥ លានដុល្លារសហរដ្ឋសំរាប់ផ្តល់ជូន ដែលភាគច្រើនផ្តល់ដល់អង្គការសង្គមស៊ីវិលដែលមានការគាំទ្រលិទ្ធិប្រជាធិបតេយ្យ ។

នៅថ្នាក់តំបន់ នៅក្នុងខែមិថុនា ឆ្នាំ២០០៦ សន្និបាតទូទៅនៃអង្គការរបស់រដ្ឋអាមេរិក (General Assembly of the organization of American States) បានអនុម័តសេចក្តីប្រកាសសានតូដូមីងហ្គូ (Santo Domingo) ដែលជាការប្តេជ្ញាចិត្តជាពហុភាគីដ៏ធំថ្មីមួយ ធ្វើឡើងដោយប្រទេសនៅក្នុងដំបន់ ដើម្បី "ធានាដល់សិទ្ធិសេរីភាពដល់គ្រប់បុគ្គលទាំងអស់ឱ្យបានទទួលភាពរីករាយជាមួយនឹងសេរីភាពក្នុងការបញ្ចេញមតិ ដោយគិតរួមទាំងការពិភាក្សាបញ្ហានយោបាយដោយមិនមានការហាមឃាត់ និង ធ្វើការដោះដូរគំនិតដោយសេរីតាមរយៈមធ្យោបាយគ្រប់ប្រភេទ ដោយគិតរួមទាំងអ៊ីនធឺណែតផងដែរ" ។ រដ្ឋមន្ត្រីក្រសួងការបរទេសក៏បានចេញសេចក្តីប្រកាសពីការប្តេជ្ញាចិត្តដើម្បីធ្វើការរៀបចំ និង ជំរុញឱ្យមានយុទ្ធសាស្ត្រ និង គោលការណ៍អនុវត្តការងារល្អប្រសើរចំពោះបញ្ហាទាំងនេះផងដែរ ។

គណៈកម្មការអន្តររដ្ឋអាមេរិករបស់សន្និបាតទូទៅនៃអង្គការរបស់រដ្ឋប្រទេសអាមេរិកស្តីពីសិទ្ធិមនុស្ស អង្គភាពសំរាប់អ្នកការពារសិទ្ធិមនុស្ស បានចេញរបាយការណ៍បង្ហាញឱ្យឃើញពីបញ្ហាធ្ងន់ធ្ងរជាច្រើនដែលក្រុមអ្នកការពារទាំងនេះបានប្រឈមមុខនៅក្នុងប្រទេសមួយចំនួន ដោយបានសង្កត់ធ្ងន់ទៅលើតំរូវការឱ្យរដ្ឋាភិបាលធ្វើការគាំទ្រដល់ការងាររបស់ពួកគេ ។

នៅមុនខែកក្កដា **សន្និបាតរបស់អ្នកដឹកនាំរដ្ឋរបស់សហភាពអាហ្វ្រិក** មានអង្គការសង្គមស៊ីវិលមកពីប្រទេសអាហ្វ្រិកចំនួន ១៩ប្រទេស បានជួបប្រជុំនៅក្នុងក្រុងបានជុល (Banjul) ប្រទេសហ្គាមប្បៀ (Gambia) ដើម្បីរៀបចំអនុសាសន៍ដាក់ជូនមេដឹកនាំ ទាក់ទងទៅនឹងតួនាទីរបស់សង្គមស៊ីវិលនៅក្នុងយន្តការតាមដានរដ្ឋជាមិត្តរបស់អាហ្វ្រិកចំពោះការបំពេញភារកិច្ចរបស់ខ្លួនតាមកាតព្វកិច្ចនៅក្នុងសន្ធិសញ្ញា មធ្យោបាយផ្សេងៗ ដើម្បីធ្វើឱ្យសង្គមស៊ីវិលអាចទទួលព័ត៌មានបានប្រសើរជាងមុន និង ច្បាប់សញ្ជាតិដើម្បីលុបបំបាត់ការរើសអើង ។ អនុសាសន៍ទាំងនេះ ត្រូវបានអនុម័តយល់ព្រមនៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំកំពូល ។

នៅក្នុងតំបន់ដ៏ធំធេងរបស់មជ្ឈឹមបូពា និង អាហ្វ្រិកខាងជើង វេទិការសំរាប់អនាគតបាននាំបុគ្គលិករដ្ឋាភិបាលទាំងអស់ និង អ្នកតំណាងសង្គមស៊ីវិលនៅក្នុងតំបន់ រួមជាមួយដៃគូរបស់ប្រទេសធំៗទាំង ៨ (G-8) ឱ្យមកជួបជុំគ្នានៅក្នុងសមុទ្រមរណៈ (Dead Sea) នៅក្នុងប្រទេសហ្សកដង់ (Jordan) ។ មានអ្នកដឹកនាំអង្គការសង្គមស៊ីវិលចំនួនប្រហែល ៥០នាក់ ដែលតំណាងឱ្យអង្គការរាប់រយអង្គការមកពីប្រទេសចំនួន ១៦ នៅក្នុងតំបន់បានចូលរួមក្នុងកិច្ចពិភាក្សាស្តីពីច្បាប់ តម្លាភាព ការផ្តល់អំណាចដល់ស្ត្រី និង យុវជន និង បរិស្ថានច្បាប់សំរាប់សង្គមស៊ីវិល ។ ពួកគេក៏បានធ្វើការពិភាក្សារកវិធីដើម្បីពង្រឹងកំណែទម្រង់ ដោយធ្វើការបង្កើតយន្តការតាមដានលើការអនុវត្តន៍អនុសាសន៍ទាំងនោះ ។ ទោះជាមានការលំបាកនៅចំពោះមុខក៏ដោយ ការទទួលយក និង ការអនុវត្តន៍អនុសាសន៍ដែលដាក់ជូនដោយសង្គមស៊ីវិល -- វេទិការនេះបានជួយបើកលំហនយោបាយដែលមិនធ្លាប់មានពីពេលមុនមក សំរាប់អង្គការសង្គមស៊ីវិលដើម្បីបង្កើត និង ធ្វើទំនាក់ទំនងជាមួយរដ្ឋាភិបាលនៅក្នុងតំបន់ ។

តាមការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិនៅក្នុងខែធ្នូ ឆ្នាំ២០០៦ លោកស្រីរដ្ឋមន្ត្រី រ៉ាយ បានបើកឱ្យប្រើប្រាស់នូវគំនិតផ្តួចផ្តើមសំខាន់ៗរបស់សហរដ្ឋអាមេរិកចំនួន២ ដើម្បីជួយគាំទ្រដល់អ្នកការពារលិទ្ធិប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស ។

លោកស្រីបានប្រកាសពីការបង្កើតមូលនិធិអ្នកការពារសិទ្ធិមនុស្ស ដែលត្រូវគ្រប់គ្រងដោយក្រសួងការពារជាតិ ដែលនឹងត្រូវបញ្ចេញសាច់ប្រាក់មួយចំនួនតូចដើម្បីជួយអ្នកការពារសិទ្ធិមនុស្សដែលកំពុងប្រឈមមុខទៅនឹងតំរូវការវិសាមញ្ញដោយសារការគៀបសង្កត់ពីរដ្ឋាភិបាល ។ ការផ្តល់មូលនិធិនេះ អាចចំណាយសំរាប់ការការពារតាមផ្លូវច្បាប់ ថ្លៃព្យាបាល ឬ តំរូវការចាំបាច់របស់សមាជិកគ្រួសារសកម្មជន ។

លោកស្រី រ៉ាយ ក៏បានប្រកាសផ្សាយផងដែរពី<u>គោលការណ៍ណែនាំចំនួន ១០</u> សំរាប់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធទៅនឹងការគាំទ្ររបស់រដ្ឋាភិបាលចំពោះអង្គការមិនមែនរដ្ឋាភិបាល ។ គោលការណ៍សំខាន់ៗទាំងនេះនឹងផ្តល់ការនែនាំចំពោះប្រព្រឹត្តិកម្មរបស់សហរដ្ឋអាមេរិកចំពោះអង្គការមិនមែនរដ្ឋាភិបាល ហើយនឹងប្រើគោលការណ៍ទាំងនេះដើម្បីធ្វើការវាយតម្លៃសកម្មភាពរបស់រដ្ឋាភិបាលផ្សេងៗ ។ គោលការណ៍នោះមានន័យថា ត្រូវបំពេញឯកសាររបស់អង្គការសហប្រជាជាតិឱ្យបានល្អិតល្អន់ និងវែង និង ឯកសារអន្តរជាតិពាក់ព័ន្ធទៅនឹងអ្នកការពារសិទ្ធិមនុស្ស និង អាចជួយប្រមូលការគាំទ្រទូទាំងសកលលោកសំរាប់អង្គការដែលកំពុងប្រយុទ្ធប្រឆាំងទៅនឹងការលំបាកទាំងនេះ ដោយបំរើមុខងារជាធនធានជំនួយសំរាប់រដ្ឋាភិបាល អង្គការអន្តរជាតិ ក្រុមសង្គមស៊ីវិល និង អ្នកសារព័ត៌មាននានា ។

នៅពេលលិទ្ធិប្រជាធិបតេយ្យធ្វើការគាំទ្រដល់អ្នកគាំទ្រលិទ្ធិប្រជាធិបតេយ្យ និង សង្គមស៊ីវិល ពួកយើងកំពុងតែជួយបុរស និង នារីទាំងឡាយនៅក្នុងប្រទេសទូទាំងសកលលោកធ្វើការតំរង់ទិសដៅព្រេងវាសនារបស់ខ្លួនទៅរកសិទ្ធិសេរីភាព ។ ហើយតាមរយៈការធ្វើបែបនោះ ពួកយើងកំពុងតែជួយសាងសង់ពិភពលោកមួយដែលមានសុវត្ថិភាព និង ភាពរីកចំរើនកាន់តែខ្លាំងឡើង ។

ពួកយើងទាំងអស់គ្នាត្រូវតែការពារអ្នកការពារសិទ្ធិទាំងនោះ ព្រោះពួកគេជាភ្នាក់ងារសំរាប់ធ្វើឱ្យមានការផ្លាស់ប្តូរដោយសន្តិភាព និង តាមលិទ្ធិប្រជាធិបតេយ្យ ។

# របាយការណ៍ប្រចាំប្រទេសកម្ពុជា

ប្រទេសកម្ពុជាជាប្រទេសរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានរដ្ឋាភិបាលកើតឡើងដោយការបោះឆ្នោត និង មានប្រជាពលរដ្ឋប្រហែលជា ១៣.៨ លាននាក់។ បន្ទាប់ពីការបោះឆ្នោតជាតិនៅឆ្នាំ ២០០៣ នៅក្នុងឆ្នាំ ២០០៤ គណបក្សប្រជាជនកម្ពុជាដែលដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និង រណសិរ្សរួបរួមជាតិសំរាប់អព្យាក្រិត្យ សន្តិភាព កិច្ចសហប្រតិបត្តិការ និង ឯករាជ្យ ដែលហៅកាត់ថា ហ៊ុនស៊ិនប៉ិច ដឹកនាំដោយសម្តេចក្រុមព្រះ នរោត្តម នរណ្ដឫទ្ធិ បានបង្កើតជារដ្ឋាភិបាលចំរុះ (Coalition Government)។ តែទោះជាយ៉ាងណាក៏ដោយ គណបក្សប្រជាជនកម្ពុជាបានក្តោបក្តាប់ភាគច្រើនចំពោះផ្នែកទាំង ៣របស់រដ្ឋាភិបាល និង ស្ថាប័នជាតិផ្សេងៗទៀត ដែលអំណាចភាគច្រើនប្រមូលផ្តុំនៅលើដៃរបស់នាយករដ្ឋមន្ត្រី។ ទោះជាអាជ្ញាធរស៊ីវិលដែលជាធម្មតាតែងតែគ្រប់គ្រងកងកំលាំងសន្តិសុខក៏ដោយ ជាការអនុវត្តន៏ជាក់ស្តែង កងកំលាំងសន្តិសុខទាំងនោះគឺឆ្លើយតបទៅនឹងការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា។

របាយការណ៍សិទ្ធិមនុស្សនៅមានភាពអន់ថយនៅឡើយ។ ភ្នាក់ងាររបស់រដ្ឋាភិបាល បានសំលាប់មនុស្សនៅក្រៅសំណាញ់ច្បាប់ និង កងកំលាំងសន្តិសុខធ្វើសកម្មភាពបទល្មើសដោយមិនមានការដាក់ទោសទណ្ឌ។ នៅមានឆន្ទៈផ្នែកនយោបាយតិចតួចក្នុងការដោះស្រាយបញ្ហាដែលរដ្ឋាភិបាលមិនបានបំពេញ និង បញ្ហាដែលអាជ្ញាធរមិនអនុវត្តច្បាប់។ អ្នកជាប់ឃុំឃាំងត្រូវបានគេធ្វើទុក្ខទោស ជាញឹកញាប់គឺដើម្បីបង្ខំឱ្យពួកគេសារភាពទោសកំហុស ហើយស្ថានភាពពន្ធនាគារមានភាពលំបាកខ្លាំង។ អ្នកធ្វើការត្រួតពិនិត្យលើបញ្ហាសិទ្ធិមនុស្សបានរាយការណ៍ថា មានការចាប់ខ្លួនតាមតែទំនើងចិត្ត និង ការឃុំខ្លួនមុនការកាត់ទោសរយៈពេលវែង ប្រព័ន្ធតុលាការមានភាពអន់ខ្សោយ និង មានការបដិសេធមិនឱ្យមានការកាត់សេចក្តីដោយយុត្តិធម៌។ ទំនាស់ដីធ្លី និង ការបង្ខំប្រជាពលរដ្ឋឱ្យរុះរើលំនៅដ្ឋាន ជាញឹកញាប់គឺមានការប្រើអំពើហិង្សា ដែលទាំងនេះគឺជាបញ្ហាដែលកំពុងរីកដុះដាលឡើង។ រដ្ឋាភិបាលដាក់កំរិតលើសេរីភាពក្នុងការបញ្ចេញមតិ និង សារព័ត៌មាន តាមរយៈការប្រើប្រាស់បណ្តឹងបរិហារកេរ្តិ៍ និង ការផ្តល់ព័ត៌មានមិនពិត ប្រើការគ្រប់គ្រង ឬ ឥទ្ធិពលលើខ្លឹមសាររបស់ទូរទស្សន៍ និង វិទ្យុ និង ជួនកាលមានការជ្រៀតជ្រែកលើសេរីភាពខាងការប្រជុំផងដែរ។ អំពើពុករលួយកើតមានពាសពេញប្រទេស និង បន្តរហូតដល់គ្រប់ច្រកល្ហកនៃសង្គម ដោយគិតរួមទាំងផ្នែកប្រតិបត្តិ នីតិបញ្ញត្តិ និង សាខាតុលាការរបស់រដ្ឋាភិបាល។ អំពើហិង្សានៅក្នុងគ្រួសារ និង ការរំលោភសិទ្ធិកុមារនៅកើតមាន។ ការអប់រំកុមារមិនមានលក្ខណៈគ្រប់គ្រាន់ ហើយការរត់ពន្ធស្ត្រីភេទ និង កុមារនៅតែបន្តកើតមាន។ រដ្ឋាភិបាលផ្តល់ជំនួយតិចតួចចំពោះជនពិការ។ សកម្មភាពប្រឆាំងទៅនឹងសហជីពដោយនយោជក និង មានភាពទន់ខ្សោយនៅក្នុងការអនុវត្តន៏ច្បាប់ការងារ នៅបន្តកើតមាន និង ពលកម្មកុមារ នៅជាបញ្ហានៅឡើយ។

នៅផ្នែកវិជ្ជមាន ក្នុងខែមករា រដ្ឋាភិបាលបានដោះលែងសកម្មជនសិទ្ធិមនុស្សចំនួន ៥ នាក់ដែលបានជាប់ទោសនៅក្នុងឆ្នាំ ២០០៥ ពីបទចោទប្រកាន់ថា បរិហាកេរ្តិ៍ និង ញុះញង់បង្កចលាចល។ អភ័យឯកសិទ្ធិរបស់សមា

ជិកសភាត្រូវបានប្រគល់ឱ្យវិញដល់មេដឹកនាំគណបក្សប្រឆាំង គឺ លោក សម រង្ស៊ី ដែលបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញដោយមិនមានហេតុការណ៍អាក្រក់អ្វីកើតមានឡើងនៅក្នុងខែកុម្ភៈ ក៏ដូចជាសមាជិកគណបក្សប្រឆាំងពីររូបទៀត។ សមាជិកសភាតំណាងរាស្ត្រលោក ជាម ចន្ទី ត្រូវបានដោះលែងពីពន្ធនាគារ បន្ទាប់ពីមានការលើកលែងទោសពីព្រះមហាក្សត្រ។ រដ្ឋាភិបាលក៏បានកែលំអច្បាប់បរិហាកេរ្តិ៍មួយក៏រិតផងដែរ។

# ការគោរពសិទ្ធិមនុស្ស

## ផ្នែកទី ១ : ការគោរពចំពោះសេចក្តីសុច្ចរិតរបស់បុគ្គល ដោយគិតរួមទាំងសេរីភាពពី :

### ក- ការរួចផុតពីការធ្វើទុក្ខទោសតាមតែទំនើងចិត្ត និង ដោយខុសច្បាប់

មិនមានរបាយការណ៍ដែលផ្តល់ដំណឹងថា រដ្ឋាភិបាល ឬ ភ្នាក់ងាររបស់រដ្ឋាភិបាលប្រព្រឹត្តការកាប់សំលាប់ដែលជំរុញដោយផ្លូវនយោបាយនោះឡើយ។ តែទោះជាយ៉ាងណា អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សបានរាយការណ៍មកថា មានការសំលាប់នៅក្រៅប្រព័ន្ធច្បាប់នៅបន្តកើតមានឡើង។

នៅក្នុងអំឡុងឆ្នាំដែល អង្គការបានកត់ត្រាទុកយ៉ាងហោចណាស់មានករណីការសំលាប់ក្រៅសំណាញ់ច្បាប់ចំនួន ៤៤ករណីបានកើតឡើង។ អង្គការនានាបានកត់សំគាល់ឃើញថា នៅក្នុង ២៦ករណី អ្នកប្រព្រឹត្តបានគេចផុតពីប្រព័ន្ធយុត្តិធមិបន្ទាប់ពីការប្រព្រឹត្តិបទល្មើស។ នៅក្នុងករណីផ្សេងទៀត អ្នកប្រព្រឹត្តត្រូវបានឃាត់ខ្លួន ឬ បង់សំណងជម្ងឺចិត្តដល់គ្រួសារជនរងគ្រោះ។ មានករណីការសំលាប់ចំនួន ៩ករណីដោយយោធា និង ៤ករណីដោយប៉ូលីស ហើយ ២ករណីទៀតដោយអង្គរក្សរបស់មន្ត្រីរដ្ឋាភិបាល ឬ អ្នកមានទ្រព្យសម្បត្តិ និង ២ករណីដោយឆ្មាំគុក ឬ អ្នកយាមល្បាតចំការ និង ១ករណីដោយអាជ្ញាធរព្រៃឈើ។ អង្គការមិនមែនរដ្ឋាភិបាលក៏បានរាយការណ៍បន្ថែមទៀតថា មានយ៉ាងហោចណាស់២ករណីទៀតដែលអ្នកប្រព្រឹត្តត្រូវបានទទួលការកាត់ទោស ហើយ ៥ករណីទៀតកំពុងតែជាប់ឃុំឃាំងរង់ចាំការកាត់ទោស និង ៥ករណីផ្សេងទៀត ត្រូវបានសងជម្ងឺចិត្តជាធនធានហិរញ្ញវត្ថុដល់គ្រួសារជនរងគ្រោះ ដើម្បីធ្វើការសំរបសំរួលគ្នា។ មិនមានព័ត៌មានណាផ្សេងទៀតដែលអាចបញ្ជាក់ពីករណីចំនួន ៣២ ទៀតនោះឡើយ។

នៅខែមីនា ថ្ងៃទី ២៩ មានជនជាប់សង្ស័យ ២ នាក់បានស្លាប់នៅក្នុងមន្ទីរឃុំខ្លួនរបស់ប៉ូលីសនៅក្នុងខេត្តកណ្តាល។ យោងទៅតាមគណៈកម្មការប្រព្រឹត្តកម្មសិទ្ធិមនុស្សកម្ពុជា (CHRAC) ថា លោក ប៉ាវ រំ និង លោក ខាត់ ធឿន បានស្លាប់នៅក្នុងស្រុកពីរផ្សេងគ្នាបន្ទាប់ពីប៉ូលីសឃុំខ្លួនពួកគេសំរាប់សួរចំលើយពីបទចោរកម្ម។ គណៈកម្មការនេះបានរាយការណ៍ថា ជនជាប់សង្ស័យទាំងពីរនាក់ទទួលរងរបួសខាងក្នុងយ៉ាងធ្ងន់ធ្ងរ ការរលាក និង ស្នាមជាំនៅលើជើង និង បានបាក់កមុនពេលពួកគេស្លាប់។ មន្ត្រីប៉ូលីស ៣ រូបដែលទទួលខុសត្រូវលើការឃុំខ្លួនរបស់លោក ប៉ាវ រំ នៅក្នុងស្រុកកណ្តាលស្ទឹង ត្រូវបានផ្អាកការងាររង់ចាំការស៊ើបអង្កេតលើករណីការស្លាប់របស់ប៉ាវ រំ។ នៅចុងឆ្នាំ ទាំងតុលាការ ទាំងក្រសួងមហាផ្ទៃមិនបានចាត់វិធានការណ៍ចំពោះមន្ត្រីប៉ូលីសទាំងនេះនោះទេ។ គណៈកម្មការនេះបានរាយការណ៍ផងដែរថា ប៉ូលីសស្រុកកោះធំបានធ្វើការបដិសេធមិនទទួលខុសត្រូវចំពោះការស្លាប់របស់លោក ខាត់ ធឿន ដោយចោទប្រកាន់ទាំងគ្មានភស្តុតាងថា គាត់ត្រូវបានទទួលការវាយដំពីសំណាក់កងរាជអាវុធហាត់មុនពេលដែលបញ្ជូនមកឱ្យពួកគេ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា មន្ត្រីកងរាជអាវុធហាត់ស្រុកត្រូវបានឃុំខ្លួន សួរចំលើយអស់រយៈពេល ៣ថ្ងៃ ហើយត្រូវបានដោះលែងវិញ។ មន្ត្រីប៉ូលីសដែលត្រួត

ពិនិត្យមន្ទីរឃុំឃាំងលោក ខាត់ ធឿន មិនត្រូវបានកាត់ទោសចំពោះករណីនោះឡើយ។ រហូតដល់ចុងឆ្នាំ ការស៊ើបអង្កេតចំពោះករណីលោក ខាត់ ធឿន ត្រូវបានបន្ត។

នៅថ្ងៃ ៧ មករា លោក នង សំ បានស្លាប់នៅក្នុងមន្ទីរពេទ្យខេត្តសៀមរាប ពីការរងរបួសក្បាលដែលកើតឡើងដោយសារការវាយដំពីប៉ូលីសខេត្តសៀមរាប។ យោងតាមការស៊ើបអង្កេតរបស់អង្គការមិនមែនរដ្ឋាភិបាល មន្ត្រីប៉ូលីសដែលទទួលខុសត្រូវ គឺ លោក ឈិត ប៊ុនឆាយ បានធ្វើការឃាត់ខ្លួន លោក នង សំ ចំពោះការវាយប្រពន្ធរបស់គាត់ ដែលត្រូវជាប្អូនស្រីរបស់ឈ្មោះ ឈិត ប៊ុនឆាយ នោះផងដែរ។ អាយ្យការតុលាការខេត្តបានធ្វើការស៊ើបអង្កេតពីរឿងហេតុ ប៉ុន្តែមិនមានធ្វើការចោទប្រកាន់ជាផ្លូវការណាមួយចំពោះ លោក ឈិត ប៊ុនឆាយ នោះទេ។

អ្នកយាមគុកនៅពន្ធនាគារចំនួន ២ នៅក្រុងកំពង់សោម និង បាត់ដំបង បានសំលាប់អ្នកទោសចំនួន ១០ នាក់ក្នុងពេលពួកគេហែកគុក។ នៅថ្ងៃទី៩ ខែមេសា អ្នកយាមគុកបានបាញ់សម្លាប់អ្នកទោស ១ រូបក្នុងចំណោមអ្នកទោស ៣ រូបដែលព្យាយាមរត់ចេញពីគុកនៅក្នុងខេត្តកំពង់ធំ។ អ្នកយាមគុកនោះបានរត់គេចខ្លួនបន្ទាប់ពីកើតហេតុ ហើយត្រូវបានចោទប្រកាន់ពីបទឃាតមនុស្សដោយចេតនា ប៉ុន្តែរហូតដល់ចុងឆ្នាំ អាជ្ញាធរនៅមិនទាន់រកគាត់ឃើញនៅឡើយ។

នៅថ្ងៃទី១៨ ខែមិថុនា នៅក្នុងពេលធ្វើការព្យាយាមរត់ចេញពីគុកដោយការហែកគុកនៅក្នុងខេត្តបាត់ដំបង អ្នកទោស ៩ នាក់ និង អ្នកយាម ១ រូប ត្រូវបានគេបាញ់សំលាប់នៅក្នុងគុក នៅពេលដែលអ្នកទោសបានចាប់ឆ្នាំគុកជាចំណាប់ខ្មាំង។ អាជ្ញាធរគុកមិនបានប្រគល់សាកសពឱ្យគ្រួសារជនរងគ្រោះតាមសំណើររបស់ពួកគេឡើយ ផ្ទុយទៅវិញបានកប់សាកសពទាំងនោះនៅក្នុងបរិវេណគុកនោះតែម្តង។ អាជ្ញាធរបានហាមឃាត់បុគ្គលិកអង្គការសិទ្ធិមនុស្សក្នុងស្រុកមិនឱ្យធ្វើការស៊ើបអង្កេតពីហេតុការណ៍នោះឡើយ។ អាជ្ញាធរគុកមិនផ្តល់សិទ្ធិសំរាប់អង្គការទាំងនោះធ្វើការស៊ើបអង្កេតឡើយ។

មិនមានរបាយការណ៍បញ្ជាក់អំពីការសំលាប់ជំរុញដោយនយោបាយនៅក្នុងឆ្នាំនេះនោះទេ។ នៅថ្ងៃទី២១ ខែមេសា លោក គឿត ឈួន ជំទប់ទី ២ របស់ក្រុមប្រឹក្សាឃុំសង្កាត់មកពីគណៈបក្សសមរង្ស៊ីនៅក្នុងស្រុកជំខ្សាន ខេត្តព្រះវិហារត្រូវបានគេសំលាប់។ យោងទៅតាមរបាយការណ៍ដំបូង មិនមានអង្គការសិទ្ធិមនុស្ស ឬ ប៉ូលីសបានជឿថា ការសំរាប់នេះត្រូវបានធ្វើឡើងដោយលក្ខណៈនយោបាយនោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើការស៊ើបអង្កេតនៅបន្តរហូតពេញមួយឆ្នាំ។ នៅថ្ងៃទី ១៦ ខែតុលា សកម្មជនរបស់គណៈបក្សសមរង្ស៊ី លោក ធឿង ធា ត្រូវបានគេបាញ់សំលាប់នៅក្នុងខេត្តកំពង់ចាម។ តុលាការខេត្តបានចេញដីការចាប់ខ្លួនលោក ឡុង សុភ័ក្រ្ត ដែលជាប្អូនប្រុសរបស់លោកអភិបាលរងស្រុក ដែលត្រូវបានគេឃើញកំពុងចាកចេញពីកន្លែងកើតហេតុ ប៉ុន្តែមិនទាន់បានចាប់ខ្លួននោះទេរហូតដល់ចុងឆ្នាំ។ នៅថ្ងៃទី១៨ ខែវិច្ឆិកា លោក ម៉ាន់ ម៉េត ត្រូវបានគេបាញ់សំលាប់នៅក្នុងខេត្តព្រៃវែង។ នៅថ្ងៃទី២១ ខែធ្នូ ប៉ូលីសបានឃាត់ខ្លួនមនុស្ស ៣ នាក់ចំពោះការបាញ់សំលាប់នោះ។ អង្គការមិនមែនរដ្ឋាភិបាលមិនអាចបញ្ជាក់ថា ការសំលាប់ចំពោះករណីទាំងពីរ គឺ លោក ធឿង ធា និង លោក ម៉ាន់ ម៉េត ជាការសំលាប់ធ្វើឡើងជាលក្ខណៈនយោបាយនោះឡើយ។

មិនមានការរីកចំរើនចំពោះការសំលាប់មនុស្សនៅក្នុងឆ្នាំ ២០០៥ ចំពោះសកម្មជនគណៈបក្សសមរង្ស៊ីចំនួន ៥នាក់នោះទេ ឬ ក្នុងករណីខែមីនា ឆ្នាំ២០០៥ នៃការប៉ុនប៉ងរត់គេចខ្លួនរបស់អ្នកទោសនៅក្នុងគុកត្រពាំងផ្លុង ដែលក្នុងនោះមានអ្នកទោសចំនួន ១៩នាក់ និង អ្នកគ្រប់គ្រងគុក ១រូបត្រូវបានសំលាប់។ រហូតមកដល់ចុងឆ្នាំ តុលាការឧទ្ធរណ៍ក្រុងភ្នំពេញមិនបានចាត់វិធានការណ៍ចំពោះករណីការសំលាប់ខែមីនា ឆ្នាំ២០០៥ ចំពោះអ្នកតវ៉ាចំនួន ៥រូប ដែលធ្វើឡើងដោយកងកំលាំងសន្តិសុខរបស់រដ្ឋាភិបាលនៅក្នុងភូមិក្បាលស្ពាននោះឡើយ។

នៅថ្ងៃទី៩ ខែសីហា សម្តេចនរោត្តមសីហនុ ដែលបានចូលនិវត្តន៍ បានធ្វើសេចក្តីថ្លែងការណ៍ចំពោះគ្រួសាររបស់ជន ២ រូប ដែលត្រូវគេកាត់ទោសនៅឆ្នាំ ២០០៥ ចំពោះករណីសំលាប់សកម្មជនសហជីព គឺ លោក ជា វិជ្ជា ដែលព្រះមហាក្សត្របានជឿជាក់ថា ពួកគេមិនមែនជាឃាតករនោះឡើយ និង បានសុំឱ្យរដ្ឋាភិបាលធ្វើការគិតឡើងវិញចំពោះករណីរបស់ពួកគេទាំងពីរនាក់។ គ្រួសារលោក ជា វិជ្ជា និង សង្គមស៊ីវិល បានទាមទារឱ្យរដ្ឋាភិបាលដោះលែងពួកគេ ហើយសាក្សីដែលឃើញហេតុការណ៍ក៏បានរៀបរាប់បញ្ជាក់ដល់អាជ្ញាធរក្នុងពេលថ្មីៗនេះថា ពួកគេមិនមែនជាឃាតករពិតប្រាកដនោះទេ ហើយមិនមានជនណាម្នាក់នៅក្នុងចំណោមពួកគេត្រូវទទួលខុសត្រូវចំពោះការសំលាប់នោះឡើយ។ នៅថ្ងៃទី៦ ខែតុលា តុលាការឧទ្ធរណ៍បានធ្វើកាលកំណត់បើកសវនាការ ប៉ុន្តែត្រូវបានផ្អាកដោយសារចៅក្រម ១ រូបក្នុងចំណោម ៣ រូបមានជម្ងឺ។ រហូតដល់ចុងឆ្នាំ មិនមានកាលបរិច្ឆេទណាមួយត្រូវបានគេកំណត់សំរាប់សវនាការថ្មីនោះឡើយ ហើយជនដែលគេបានកាត់ទោសនោះនៅជាប់ពន្ធនាគារដដែល។

មិនមានវិធានការច្បាប់ណាមួយត្រូវបានចាត់ចំពោះមន្ត្រីប៉ូលីសដែលបានសំលាប់អ្នកទោសនៅឆ្នាំ ២០០៤ នៅពេលរង់ចាំការកាត់ទោសនៅក្នុងខេត្តតាកែវនោះទេ។

មិនមានការរីកចំរើនឡើយចំពោះករណីប្រធានភូមិពីគណៈបក្សហ៊្វុនស៊ិនប៉ិច ឬ សកម្មជនគណៈបក្សសមរង្ស៊ី ដែលត្រូវគេសំលាប់នៅក្នុងហេតុការណ៍ផ្សេងៗគ្នានៅឆ្នាំ ២០០៤ ក្នុងខេត្តកំពត។

នៅថ្ងៃទី២ ខែសីហា តុលាការក្រុងភ្នំពេញបានចេញដីការឃាត់ខ្លួនលោក ហេង ពៅ ដែលជាអតីតអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដែលត្រូវចោទប្រកាន់ពីករណីជាច្រើនចំពោះការសំលាប់ដោយមានការគ្រោងទុក និង ការពាក់ព័ន្ធនឹងការឃាត់ខ្លួន និង ការដាក់ឃុំឃាំងដោយខុសច្បាប់។ គាត់ត្រូវបានគេចោទប្រកាន់ដោយគ្មានភស្តុតាងថា មានការពាក់ព័ន្ធទៅនឹងការសំលាប់លោកចៅក្រម សុខ សេដ្ឋាមុន្នី ក្នុងឆ្នាំ ២០០៣។ លោក ហេង ពៅ បានបដិសេធនឹការចោទប្រកាន់ ហើយបានស្វែងរកសិទ្ធិជ្រកកោនផ្នែកនយោបាយនៅប្រទេសក្រៅ។ នៅថ្ងៃទី១៨ ខែកញ្ញា តុលាការក្រុងភ្នំពេញបានកាត់ទោសលោក ហេង ពៅ ដោយកំបាំងមុខពីបទឧក្រិដ្ឋកម្ម ដោយគិតរួមទាំងការធ្វើឃាតលោកចៅក្រម សុខ សេដ្ឋាមុន្នី និង បានកាត់ទោសគាត់ និង មន្ត្រីប៉ូលីស ៥ រូបទៀតឱ្យជាប់ទោសចំនួន ១៨ឆ្នាំនៅក្នុងពន្ធនាគារ។ នៅថ្ងៃទី២១ ខែធ្នូ អាជ្ញាធរម៉ាឡេស៊ីបាននិរទ្ទេស លោក ហេង ពៅ មកកាន់ប្រទេសកម្ពុជា ហើយគាត់ត្រូវបានគេបញ្ជូនទៅដាក់គុកព្រៃស។ អាជ្ញាធរអនុញ្ញាតឱ្យ លោក ហេង ពៅ ជួបជាមួយក្រុមប្រឹក្សាច្បាប់របស់គាត់ ប៉ុន្តែសមាជិកគ្រួសារ និង អង្គការមិនមែនរដ្ឋាភិបាលមិនអនុញ្ញាតឱ្យជួបគាត់ឡើយ។

ការរងរបួសដោយសារគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅមានកំរិតខ្ពស់ ប៉ុន្តែមានការថយចុះយ៉ាងឆាប់រហ័សបើធៀបទៅនឹងឆ្នាំ ២០០៥។ យោងទៅតាមប្រព័ន្ធផ្តល់ព័ត៌មានពីជនរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ការរងរបួសដោយគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ សរុបមានចំនួន ៤៤០ ករណីនៅក្នុងឆ្នាំនេះ ដែលជាចំនួនមានការថយចុះពី ៨៧៥ ករណីក្នុងឆ្នាំ ២០០៥។ ការរងគ្រោះថ្នាក់រួមមាន ស្លាប់ ៥៨ ករណីថយចុះពី ១៦៨ ករណីក្នុងឆ្នាំ ២០០៥ ការពិការដៃជើង ៩១ ករណី ថយចុះពី ១៧៣ ករណី និង ការរងរបួស ៥៨ ករណី ថយចុះពី ៥៣៤ ករណីក្នុង ឆ្នាំ ២០០៥។

អំពើអយុត្តិធម៌ ក៏ដូចជាការសំលាប់ធ្វើឡើងដោយក្រុមមនុស្សនៅបន្តកើតមាន។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា យ៉ាងហោចណាស់មានមនុស្ស ៦ នាក់ត្រូវបានសំលាប់ដោយក្រុមមនុស្សនៅក្នុងឆ្នាំនេះ។ មានអ្នកប្រព្រឹត្តមួយចំនួនតូចត្រូវបានចាប់ខ្លួន។ ជាឧទាហរណ៍ អាជ្ញាធរមិនអាចការពារជនសង្ស័យពីក្រុមមនុស្សដែលមានការខឹងសម្បា។ អង្គការទាំងនោះបានកត់សំគាល់ឃើញថា ភាគច្រើននៃការសំលាប់ដោយក្រុមមនុស្សគឺពាក់ព័ន្ធទៅនឹងការលួច ការប្លន់ ឬ សង្ស័យថា អំពើអាបធ្មប់។ នៅថ្ងៃទី៥ ខែកុម្ភៈ បុរសម្នាក់ត្រូវបានវាយ និងសំលាប់បន្ទាប់ពីចោទប្រកាន់ថា គាត់ចេះអំពើធ្មប់។ មិនមានអ្នកណាម្នាក់ត្រូវបានចាប់ខ្លួនពាក់ព័ន្ធទៅនឹងការសំលាប់នោះឡើយ។ នៅថ្ងៃទី៥ ខែសីហា លោក សំ រឿន ជាជនជាប់សង្ស័យថាបានលួចទូកមួយ ត្រូវបានចាប់ខ្លួននៅក្នុងស្រុកព្រៃប្រសព្វក្នុងខេត្តក្រចេះ ហើយត្រូវបានគេច្រកបាវចងជុំថ្ម ហើយបោះចូលទៅក្នុងទឹកទន្លេ។ ប៉ូលីសបញ្ជាក់ថា ប្រជាពលរដ្ឋសំលាប់លោក សំ រឿន ព្រោះពួកគេមិនមានទំនុកចិត្តលើប្រព័ន្ធតុលាការ។ អង្គការសិទ្ធិមនុស្សដែលមានមូលដ្ឋាននៅក្នុងខេត្តក្រចេះបានរាយការណ៍ថា មានអ្នកភូមិចំនួន ៦ នាក់ត្រូវបានឃាត់ខ្លួនពីករណីសំលាប់លោក សំ រឿន និង ត្រូវបានឃុំខ្លួនរង់ចាំការកាត់ទោស។

**ខ- ការបាត់ខ្លួន**

មិនមានរបាយការណ៍ណាឱ្យដឹងពីការបាត់ខ្លួនជាប់ពាក់ព័ន្ធទៅនឹងនយោបាយនោះទេ។

**គ- ការធ្វើទារុណកម្ម និង ការប្រព្រឹត្តិ ឬ ដាក់ទោសដ៏ព្រៃផ្សៃ អមនុស្សធម៌ ឬ គ្មានការគោរពសិទ្ធិ**

រដ្ឋធម្មនុញ្ញបានហាមឃាត់រាល់ទង្វើប្រភេទនេះ។ តែទោះជាយ៉ាងណា ការវាយដំ និង ការធ្វើទុក្ខទោសផ្នែករាង្គកាយក្នុងរូបភាពផ្សេងៗចំពោះអ្នកទោសនៅតែជាបញ្ហាធ្ងន់ធ្ងរដដែល។

មានព័ត៌មានគួរឱ្យទុកចិត្តមួយរាយការណ៍ថា យោធា និង បុគ្គលិកប៉ូលីសស៊ីវិលប្រើប្រាស់ការធ្វើទារុណកម្មរាង្គកាយ និង ផ្លូវចិត្ត និង វាយដំជនជាប់ឃុំឃាំងយ៉ាងខ្លាំង ជាពិសេសក្នុងពេលសួរចំលើយ។ អង្គការសិទ្ធិមនុស្សឈ្មោះលីកាដូបានរាយការណ៍ថា នៅក្នុងដំណាក់កាល ៦ ខែដំបូងនៅឆ្នាំនេះ អាជ្ញាធរបានធ្វើទារុណកម្មអ្នកជាប់ឃុំចំនួន ៩៦ នាក់ ដែលក្នុងនោះមាន ៧៨ នាក់ត្រូវបានធ្វើទារុណកម្មនៅក្នុងមន្ទីរឃុំខ្លួនរបស់ប៉ូលីស និង ១៨ នាក់ទៀតនៅក្នុងពន្ធនាគារ។ យោងតាមការសម្ភាសន៍ជាមួយអ្នកជាប់ឃុំរាប់ពាន់នាក់ពីគុកចំនួន ១៨ នៃគុកទាំង ២៤នៅក្នុងប្រទេស អង្គការនេះបានឱ្យដឹងទៀតថា មានការទាត់ធាក់ ការវាយដោយកណ្តាប់ដៃ និង វាយដោយស្នាយកាំភ្លើង ដែលទាំងនេះជាមធ្យោបាយដ៏សាមញ្ញបំផុតចំពោះការធ្វើទារុណកម្មរាង្គកាយ ប៉ុន្តែមានវិធីផ្សេង

ទៀតត្រូវបានគេប្រើផងដែរ ដូចជា ការឆក់ដោយខ្សែភ្លើង ការច្របាច់ក ការវាយនឹងដំបង និង វាយដោយប្រើខ្សែភ្លើងអគ្គីសនី។ អង្គការអាដហុក ដែលជាអង្គការសិទ្ធិមនុស្សមួយផ្សេងទៀតដែលកំពុងធ្វើការត្រួតពិនិត្យបញ្ហាសិទ្ធិមនុស្សទូទាំងប្រទេស បានកត់ត្រាទុកប្រហែលជា ១៥០ ករណី ពីបទធ្វើទុក្ខទោសផ្នែករាង្គកាយ និង ការធ្វើទារុណកម្មដែលធ្វើឡើងដោយប៉ូលីស និង ភ្នាក់ងារយោធា។ រដ្ឋធម្មនុញ្ញ ការពារជនជាប់សង្ស័យពីការធ្វើទារុណកម្ម តែទោះជាយ៉ាងណាក៏ដោយ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា វាមានភាពខុសពីធម្មតាដែលថា ប៉ូលីសធ្វើទារុណកម្មដល់ជនជាប់សង្ស័យរហូតដល់ពួកគេសារភាពថា បានប្រព្រឹត្តបទល្មើស។ យោងតាមរបាយការណ៍របស់អង្គការលីកាដូសំរាប់ឆ្នាំនេះ មានជនជាប់សង្ស័យចំនួន ១៩១ នាក់ ដែលក្នុងនោះមាន ១៤ នាក់ ជាស្ត្រីត្រូវបានគេធ្វើទារុណកម្មនៅក្នុងមន្ទីរឃុំឃាំងរបស់ប៉ូលីស និង ២២ករណីផ្សេងទៀត ត្រូវបានគេធ្វើទារុណកម្មនៅក្នុងពន្ធនាគារ។ យោងតាមការសម្ភាសន៍ជាមួយអ្នកទោសចំនួន ៣០០ នាក់នៅក្នុងពន្ធនាគារចំនួន ២៤ ក្នុងប្រទេសមានអ្នកទោស ៥៥ នាក់បាននិយាយថា ពួកគេត្រូវបានគេធ្វើទារុណកម្មបន្ទាប់ពីត្រូវបានឃាត់ខ្លួន និង មុនពេលដាក់ឃុំឃាំងក្នុងពន្ធនាគារ។ បទសម្ភាសន៍របស់អង្គការអាដហុកបានបង្ហាញថា ហេតុការណ៍ធ្វើទារុណកម្មចំនួនពាក់កណ្តាលកើតមាននៅក្នុងមន្ទីរឃុំឃាំងរបស់ប៉ូលីស ចំណែកពាក់កណ្តាលទៀតកើតឡើងនៅឯមន្ទីរឃុំឃាំងរបស់កងរាជអាវុធហត្ថ ឬ ក្នុងការិយាល័យរបស់អាជ្ញាធរតំបន់។ យោងតាមចំលើយរបស់មន្ត្រីតុលាការ តុលាការប្រើប្រាស់ចំលើយដែលត្រូវបានគេបង្ខំឱ្យសារភាព ជាភស្តុតាងផ្លូវច្បាប់នៅពេលធ្វើការកាត់សេចក្តី។ លើសពីនេះទៀត មន្ត្រីរដ្ឋាភិបាល និង អ្នកដែលបំរើការងារទាំងអស់ បានប្រើប្រាស់អំពើហិង្សាដើម្បីគៀបសង្កត់អ្នកទន់ខ្សោយ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា នៅក្នុងឆ្នាំនេះ មានករណីធ្វើទារុណកម្មរាង្គកាយចំនួន ១៦៧ ករណីដែលធ្វើឡើងដោយអាជ្ញាធរ ភ្នាក់ងាររដ្ឋាភិបាល ឬ ដោយអង្គរក្សរបស់អ្នកមានអំណាច និង អ្នកមានទ្រព្យសម្បត្តិ បើធៀបទៅនឹងឆ្នាំ ២០០៥ ដែលមាន ១៥៤ ករណី និង ១៤៥ ករណី ក្នុងឆ្នាំ ២០០៤។ អង្គការមិនមែនរដ្ឋាភិបាលបានឱ្យដឹងថា រដ្ឋាភិបាលតែងតែមិនអើពើរលើការទាមទាររបស់សង្គមស៊ីវិលចំពោះការនាំជនល្មើសមកកាត់ទោស។ របាយការណ៍ដូចគ្នានេះក៏បានឱ្យដឹងដែរថា អាជ្ញាធរធ្វើតាមច្បាប់តែចំនួន ១៥%នៃករណីទាំងអស់តែប៉ុណ្ណោះ។

នៅថ្ងៃទី ២៨ ខែមករា មន្ត្រីប៉ូលីសចំនួន ៦រូប ដែលរួមមានប្រធានអង្គភាពប៉ូលីសព្រហ្មទណ្ឌកិរិតស្រាលក្រុងភ្នំពេញផងដែរ ត្រូវបានឃាត់ខ្លួនចំពោះការធ្វើទារុណកម្មស្ត្រីមួយរូបរហូតដល់ស្លាប់ និង ការសំលាប់ផ្សេងៗទៀត។ នៅថ្ងៃទី ២១ ខែកក្កដា តុលាការក្រុងភ្នំពេញបានកាត់ទោសមន្ត្រីទាំងនោះឱ្យជាប់ពន្ធនាគាររយៈពេល ១២ ឆ្នាំ ក្នុង១នាក់។

នៅថ្ងៃទី ១៤ ខែកុម្ភៈ ប៉ូលីស២រូបមកពីអង្គភាពការពារព្រំដែនលេខ ៧០១ បានចងព្យួរក្មេងប្រុសអាយុ ១៣ឆ្នាំដោយទំលាក់ក្បាលចុះក្រោម ហើយវាយដំក្មេងប្រុសនោះ។ ប៉ូលីសចោទប្រកាន់ក្មេងនោះថា បានធ្វើការវាយប្រហារដល់ប៉ូលីស។ បន្ទាប់ពីអង្គការមិនមែនរដ្ឋាភិបាលធ្វើអន្តរាគមន៍ មន្ត្រីប៉ូលីសបានសងជម្ងឺចិត្តជាទឹកប្រាក់ចំនួន ៥០០ ដុល្លារ (២,១លានរៀល) ដល់ក្មេងប្រុសនោះ។ មិនមានវិធានការណ៍ផ្លូវច្បាប់ណាមួយត្រូវបានចាត់ចំពោះមន្ត្រីប៉ូលីសនោះឡើយ។

នៅថ្ងៃទី ២៩ ខែមីនា ជនជាប់សង្ស័យ ២ នាក់បានស្លាប់នៅក្នុងហេតុការណ៍ដាច់ដោយឡែកពីគ្នា ដោយសារអំពើរឃោរឃៅរបស់ប៉ូលីសនៅក្នុងស្រុកពីរនៅក្នុងខេត្តកណ្តាល។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជារកឃើញថាពួកគេទាំងពីរនាក់ស្លាប់ដោយសារការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ (សូមមើលផ្នែក ១-ក.)។

នៅថ្ងៃទី ១៨ ខែមេសា បន្ទាប់ពីមានជំលោះរវាង គង់ សាឡាត់ និង ប្រជាពលរដ្ឋផ្សេងៗទៀតក្នុងភូមិ លោកអធិការប៉ូលីស ធៀម សង្គ្រាម នៅស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ និង ភ្នាក់ងារប៉ូលីស ៣ រូបទៀតបានធ្វើការឃុំខ្លួនលោក គង់ សាឡាត់ ដោយមិនមានដីការរបស់តុលាការ និង បានវាយដំរូបគាត់នៅពេលដាក់ខ្នោះដៃជើង។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា លោកអធិការបានឃុំខ្លួនលោក សាឡាត់ ខុសច្បាប់អស់រយៈពេល១យប់ មុនពេលអនុញ្ញាតឱ្យឪពុករបស់លោក សាឡាត់ យកគាត់ទៅធ្វើការព្យាបាល។ នៅក្នុងខែមិថុនា លោកអិធការត្រូវបានគេដកចេញទៅកាន់ខេត្តមួយផ្សេងទៀត។ រហូតមកដល់ចុងឆ្នាំ តាមសេចក្តីរាយការណ៍ តុលាការខេត្តបានកំពុងរងចាំលទ្ធផលការស៊ើបអង្កេតរបស់ប៉ូលីស មុនពេលធ្វើការសំរេចថាតើត្រូវចាត់វិធានការច្បាប់ចំពោះលោកអធិការ ឬ មិនត្រូវចាត់នោះ។

នៅថ្ងៃទី ២៤ ខែមេសា កងរាជអាវុធហត្ថខេត្តបាត់ដំបងបានចាប់ខ្លួនអ្នកបើកបរម៉ូតូដោយមិនមានដីការពីតុលាការ ហើយបានចោទប្រកាន់រូបគាត់ពីបទចោរកម្ម។ កងរាជអាវុធហត្ថរូបនោះបានវាយដំរូបគាត់យ៉ាងខ្លាំងនៅកន្លែងឃាត់ខ្លួន ហើយបានវាយបន្ថែម និង យកថង់ផ្លាស្ទិកមកច្រកក្បាលរបស់គាត់ទៀត។ ទោះជាមានការប្តឹងតវ៉ាពីអង្គការសិទ្ធិមនុស្សក្នុងស្រុកទៅតុលាការ និង មេបញ្ជាការកងរាជអាវុធហត្ថក៏ដោយ រហូតមកដល់ចុងឆ្នាំមិនមានការដាក់ពិន័យ ឬ វិធានការច្បាប់ណាមួយត្រូវបានចាត់ចំពោះមន្រ្តីរូបនោះឡើយ។

នៅថ្ងៃទី ៧ ខែមិថុនា លោក នង សំ ស្លាប់នៅក្នុងមន្ទីរពេទ្យខេត្តសៀមរាបពីការរងរបួសក្បាល ដែលបង្កឡើងដោយក្រុមមន្រ្តីប៉ូលីសខេត្តសៀមរាប (សូមមើលផ្នែក ១-ក.)។

នៅថ្ងៃទី ២៩-៣០ ខែធ្នូ តួស ស្តើង បានស្លាប់ដោយសារការរងរបួសពីការឃុំខ្លួន។ លោកស្នងការនគបាលខេត្តកំពង់ធំ គឺ លោក ម៉ៅ ពៅ បានបញ្ជាក់ថា បុរសនោះត្រូវបានធ្វើទារុណកម្មដោយមន្រ្តីកងរាជអាវុធហត្ថ ២ រូប។ នៅថ្ងៃទី ២៩ ខែធ្នូ លោក ស្តើង ត្រូវបានចាប់ខ្លួនបន្ទាប់ពីគាត់បានដុតផ្ទះរបស់គាត់ និង វាយប្រពន្ធក្នុងពេលស្រវឹងស្រា។ សាកសពដែលគេវាយយ៉ាងព្រៃផ្សៃត្រូវបានគេប្រគល់ឱ្យគ្រួសាររបស់គាត់នៅថ្ងៃបន្ទាប់។ គ្រួសាររបស់លោក ស្តើង បានយល់ព្រមមិនធ្វើការប្តឹងផ្តល់អ្វីឡើយនៅពេលនោះ ប្រសិនបើមានការសងជម្ងឺចិត្តជាទឹកប្រាក់ចំនួន ១ ២៥០ ដុល្លារសហរដ្ឋ (ប្រហែល ៥,២៥ លានរៀល) ប៉ុន្តែក្រោយមកក្រុមគ្រួសារបានសុំជំនួយផ្នែកហិរញ្ញវត្ថុបន្ថែមទៀត ហើយបានដាក់ពាក្យបណ្តឹងទារយកការសងជម្ងឺចិត្តជាទឹកប្រាក់ ១ ២៥០ ដុល្លារសហរដ្ឋផ្សេងទៀត (ប្រហែល ៥,២៥ លានរៀល)។ ករណីនេះត្រូវបានទទួលដោយតុលាការខេត្ត ប៉ុន្តែរហូតដល់ចុងឆ្នាំ មិនមានវិធានការណាមួយត្រូវបានចាត់ចំពោះមន្រ្តីទាំងពីររូបនោះឡើយ។

នៅចុងឆ្នាំនេះ មិនមានវិធានការច្បាប់ណាមួយត្រូវបានគេចាត់ចំពោះពាក្យបណ្តឹងឆ្នាំ ២០០៥ ចំពោះឆ្មាំគុកដែលបានវាយធ្វើបាបអ្នកទោសជាស្ត្រីដែលបដិសេធមិនធ្វើការរួមភេទ ទោះជាតាមរបាយការណ៍របស់អង្គការថា ឆ្មាំគុកនោះត្រូវបានគេបញ្ជូនទៅកាន់ខេត្តផ្សេងទៀតនៅក្នុងខែមិថុនាក៏ដោយ ។

**ស្ថានភាពពន្ធនាគារ និង មជ្ឈមណ្ឌលឃុំឃាំង**

ស្ថានភាពពន្ធនាគារ គឺមិនបានបំពេញទៅតាមស្តង់ដាអន្តរជាតិនោះឡើយ និង មានការគំរាមកំហែងដល់អាយុជីវិតថែមទៀតផង។ ស្ថានភាពគុកមានសភាពក្តៅខ្លាំង ហើយការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកែលំអត្រូវបានរារាំងដោយសារការខ្វះខាតមូលនិធិ និង ការអនុវត្តន៏ការងារទន់ខ្សោយ។ អង្គការសិទ្ធិមនុស្សបានដកស្រង់បញ្ហាធ្ងន់ធ្ងរជាច្រើនដូចជា មានអ្នកទោសច្រើនហួសកំរិត បញ្ហាការព្យាបាល និង អនាម័យ ការខ្វះខាតអាហារ និងទឹក ការខ្វះអាហារបំប៉ន និង ស្ថានភាពសន្តិសុខអន់ថយ។ យោងតាមស្ថិតិរបស់អាជ្ញាធរពន្ធនាគារមានអ្នកទោសចំនួន ១០ ២៥០ នាក់នៅក្នុងពន្ធនាគារ បើគិតត្រឹមខែតុលា ធៀបទៅនឹងអ្នកទោសចំនួន ៨ ៩៣៤ នាក់ ក្នុងឆ្នាំ ២០០៥។ ទោះបីជាមានការដោះដូរទីកន្លែងពន្ធនាគារចំនួន ៣ កន្លែងទៅកាន់កន្លែងធំជាងក៏ដោយ - នៅខេត្តបាត់ដំបង កណ្តាល និង កំពង់ធំ និង ការកែលំអដល់ពន្ធនាគារផ្សេងៗទៀតនៅក្នុងឆ្នាំនោះ ស្ថានភាពពន្ធនាគារជាច្រើនមានភាពកកកុញខ្លាំង។ យោងតាមរបាយការរបស់អង្គការលីកាដូ ដែលបានត្រួតពិនិត្យពន្ធនាគារចំនួន ១៨ ក្នុងចំណោមពន្ធនាគារ ២៤ បានឱ្យដឹងថា ពន្ធនាគារទាំង ១៨ នោះអាចផ្ទុកអ្នកទោសបានចំនួន ៦ ៤១០ នាក់ ប៉ុន្តែបានដាក់អ្នកទោសរហូតដល់ ៨ ៨៣៥ នាក់។ ស្ថិតិរបស់អាជ្ញាធរពន្ធនាគារដែលបានកត់ត្រាពីខែមករា ដល់ខែវិច្ឆិកា បានបញ្ជាក់ថា អ្នកទោស ៩០ នាក់បានស្លាប់ ភាគច្រើនដោយសារមេរោគអេដស៍ និង របេង។ អង្គការមិនមែនរដ្ឋាភិបាលបានកត់ត្រាថា មានករណីរត់ចេញពីគុកចំនួន ១២ ករណីនៅក្នុងឆ្នាំនេះ ដែលធ្វើឱ្យមានអ្នកទោសចំនួន ១២ នាក់ត្រូវបានគេបាញ់សម្លាប់ ២៤ នាក់ចាប់ខ្លួនបានវិញ និង ១៧ នាក់នៅមិនទាន់ចាប់ខ្លួនបានវិញឡើយ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៏ថា អ្នកទោស ២ នាក់នៅក្នុងខេត្តកោះកុង បានស្លាប់ក្នុងខែសីហារយៈពេលពីរបីថ្ងៃបន្ទាប់ពីមានការវាយតប់គ្នាយ៉ាងខ្លាំងក្លានៅក្នុងបន្ទប់ ទោះជាយ៉ាងណា អាជ្ញាធរគុកបានអះអាងថាពួកគេទាំងពីរនាក់ស្លាប់ដោយសារតែជម្ងឺ។

ក្នុងឆ្នាំ ២០០៥ អង្គការមិនមែនរដ្ឋាភិបាលបានកត់សំគាល់ឃើញថា ចំនួនអ្នកទោសមធ្យមដែលគេដាក់ក្នុងបន្ទប់មានទំហំ ២៣ គុណនឹង ២៦ ហ៊ីត បានកើនឡើងព ៤៥ នាក់ ទៅ ៥០ នាក់ និង ៦០ នាក់។ នៅក្នុងពន្ធនាគារមួយចំនួន បន្ទាប់ពីមានការព្យាយាមចង់រត់ចេញពីគុក អាជ្ញាធរបានប្រើខ្នោះជើង និង ដាក់អ្នកទោសនៅក្នុងបន្ទប់ងងឹតខ្លាំង។

ភាគរយប្រាក់ឧបត្ថមធនរបស់រដ្ឋាភិបាលសំរាប់ការទិញអាហារប្រចាំថ្ងៃ មិនត្រូវបានចាត់ចែងត្រឹមត្រូវ និង មានចំនួនមិនគ្រប់គ្រាន់ ដែលជាកត្តាជំរុញឱ្យមានរោគខ្វះចំណីអាហារ និង ជម្ងឺផ្សេងៗ។ ទោះជានៅក្នុងឆ្នាំនេះរដ្ឋាភិបាលបានបង្កើនរបបប្រាក់ឧបត្ថមធនពី ០,២៣ ដុល្លារ(១០០រៀល) ទៅ ០,៣៦ ដុល្លារ (១៥០០រៀល) សំរាប់អាហារអ្នកទោស១នាក់ក៏ដោយ អង្គការមិនមែនរដ្ឋាភិបាលបានកត់សំគាល់ឃើញថា របបអាហារសំរាប់អ្នកទោសនៅតែមិនគ្រប់គ្រាន់។ យោងតាមអង្គការសិទ្ធិមនុស្ស វិប្បធម៌អំពើពុករលួយកើតមាននៅគ្រប់ទីកន្លែងដែលគ្រួសារអ្នកទោសបានធ្វើការសូកប៉ាន់ដល់អាជ្ញាធរ ដើម្បីឱ្យពួកគេសំរួលការបន្ធូរបន្ថយចំពោះអ្នកទោស។ បទបញ្ជាបានអនុញ្ញាតឱ្យគ្រួសារផ្តល់អាហារ និង វត្ថុចាំបាច់មួយចំនួនដល់អ្នកទោស ហើយអ្នកទោសមានការពឹងពាក់ក្នុង

ចំណែកយ៉ាងធំពីជំនួយពីខាងក្រៅបែបនេះ។ ទោះជាយ៉ាងណា គ្រួសារទាំងនោះតែងតែត្រូវបានគេជំរុញឱ្យធ្វើការផ្តល់សំណូកដល់មន្ត្រីពន្ធនាគារ ដើម្បីឱ្យពួកគេអាចយកអាហារ និង សម្ភារៈផ្សេងៗអោយដល់អ្នកទោសបាន ឬ ដើម្បីចូលសួរសុខទុក្ខអ្នកទោស។ នៅក្នុងឆ្នាំ ២០០៥ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា អ្នកទោស ៨៩ នាក់បានស្លាប់ ដោយសារខ្វះអាហារ ឬ ថ្នាំពេទ្យ ឬ ដោយសារជម្ងឺឆ្លង ឬ ដោយសារភាពកាន់តែដុនដាបរបស់ជម្ងឺ។

នៅថ្ងៃទី ៩ ខែកញ្ញា ឆ្មាំគុកបានបាញ់សំលាប់អ្នកទោស ១ រូបក្នុងចំណោម ៣ រូបដែលបានរត់ចេញពីគុក នៅក្នុងខេត្តកំពង់ធំ (មើលផ្នែក១-ក.)។

នៅថ្ងៃទី ១១ ខែមិថុនា អ្នកជាប់ឃុំមុនពេលកាត់ទោសចំនួន ១២ នាក់ដែលត្រូវចោទប្រកាន់ពីបទមនុស្សឃាត បានរត់គេចខ្លួនពីគុកព្រៃស។ ឆ្មាំគុកម្នាក់ដែលត្រូវបានគេសង្ស័យថាបានជួយអ្នកទោស ត្រូវបានចាប់ខ្លួន។ អង្គការមិនមែនរដ្ឋាភិបាលបានស្តីបន្ទោសការរត់គេចខ្លួននោះទៅលើអាជ្ញាធរគុកថា មិនចាប់អារម្មណ៍ និង មានអំពើពុករលួយ។

នៅថ្ងៃទី ១៨ ខែមិថុនា អ្នកទោស ៩ នាក់ និង ឆ្មាំគុក ១ នាក់នៅខេត្តបាត់ដំបងត្រូវបានគេសំលាប់នៅក្នុងគុកនៅពេលអ្នកទោសបានចាប់ឆ្មាំគុកជាចំណាប់ខ្មាំង ហើយព្យាយាមធ្វើការរត់ចេញពីគុក (មើលផ្នែក ១-ក.)។

មានរបាយការណ៍ថា អាជ្ញាធរបានទាមទារសំណូកមុនពេលដោះលែងអ្នកទោសដែលបានផុតកំណត់កាលជាប់ទោសហើយនោះ។

នៅក្នុងពន្ធនាគារភាគច្រើន មិនមានការដាក់ឱ្យដាច់ដោយឡែកពីគ្នារវាងមនុស្សពេញវ័យ និង កុមារ រវាងបុរស និង នារី ឬ អ្នកជាប់ទោសធ្ងន់ និង អ្នកជាប់ទោសស្រាលនោះឡើយ។

ជាទូទៅរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រុមសិទ្ធិមនុស្សក្នុងស្រុក និង អន្តរជាតិចូលពិនិត្យពន្ធនាគារ និង ផ្តល់ការបណ្តុះបណ្តាលពីសិទ្ធិមនុស្សដល់ឆ្មាំគុក។ ទោះជាយ៉ាងណាក៏ដោយ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា ជួនកាលការសហការរបស់អាជ្ញាធរនៅមានក៏រិត។ អង្គការដែលធ្វើការត្រួតពិនិត្យពន្ធនាគារបានលើកឡើងថា នៅដើមខែមីនា រដ្ឋាភិបាលបានក៏រិតសិទ្ធិរបស់ពួកគេក្នុងការត្រួតពិនិត្យស្ថានភាពគុកទាំង ២៤ នៅក្នុងប្រទេស។ មន្ត្រីពន្ធនាគារខេត្តបាត់ដំបង មិនអនុញ្ញាតឱ្យអង្គការសិទ្ធិមនុស្សធ្វើការស៊ើបអង្កេតពីករណីការស្លាប់របស់អ្នកទោសទាំង ៩ នាក់ដែលត្រូវបានគេបាញ់ស្លាប់នៅពេលព្យាយាមធ្វើការរត់គេចចេញពីគុកនៅថ្ងៃទី ១៨ ខែមិថុនា នោះឡើយ។ ក្រសួងមហាផ្ទៃបន្តតំរូវឱ្យមេធាវី អ្នកត្រួតពិនិត្យតាមដានសិទ្ធិមនុស្ស និង អ្នកសួរសុខទុក្ខត្រូវទទួលការអនុញ្ញាតសិនមុនពេលជួបជាមួយអ្នកទោស។ ក្រសួងមហាផ្ទៃធ្វើបដិសេធមិនផ្តល់ការអនុញ្ញាតបែបនេះទេ នៅក្នុងករណីបញ្ហានយោបាយធ្ងន់ធ្ងរ។ អង្គការមិនមែនរដ្ឋាភិបាលមិនអនុញ្ញាតឱ្យធ្វើការសម្ភាសន៍អ្នកទោសក្នុងលក្ខណៈឯកជនឡើយ។

**ឃ- ការឃាត់ខ្លួន ឬ ដាក់ឃុំឃាំងតាមតែទំនើងចិត្ត**

ច្បាប់របស់ប្រទេសបានហាមឃាត់មិនឱ្យមានការឃាត់ខ្លួន ឬ ការឃុំខ្លួនតាមតែទំនើងចិត្តនោះឡើយ។ តែទោះជាយ៉ាងណា រដ្ឋាភិបាលមិនបានគោរពទៅតាមការហាមឃាត់នេះនោះទេ។ អង្គការអាដហុកបានផ្តល់សេចក្តី

របាយការណ៍ថា មានមនុស្សចំនួន ៩០ នាក់ត្រូវបានឃាត់ខ្លួន និង ឃុំខ្លួនខុសនីតិវិធីច្បាប់នៅក្នុងឆ្នាំនេះ។ អង្គការនេះបានជឿថា ចំនួនការឃាត់ខ្លួន និងការដាក់ឃុំឃាំងតាមតែទំនើងចិត្តជាក់ស្តែងមានកំរិតខ្ពស់ ព្រោះជនរងគ្រោះមួយចំនួននៅទីជនបទដាច់ស្រយាលមិនបានដាក់ពាក្យបណ្តឹងនោះទេ ដោយសារមានការលំបាកនៅក្នុងការធ្វើដំណើរមកកាន់ការិយាល័យអង្គការ ឬ ដោយសារការភ័យខ្លាចចំពោះបញ្ហាសន្តិសុខក្រុមគ្រួសាររបស់ពួកគេ។ យោងតាមអង្គការអាដហុក ប៉ូលីសមានកំហុសនៅក្នុងករណីជាងពាក់កណ្តាលនៃករណីទាំងអស់ ហើយសមាជិកក្រុមប្រដាប់អាវុធ និង កងរាជអាវុធហត្ថ ត្រូវទទួលខុសត្រូវចំពោះករណីចំនួន ១០%។ ករណីផ្សេងៗទៀត គឺត្រូវបានធ្វើឡើងដោយមន្ត្រីស៊ីវិល មន្ត្រីរដ្ឋាភិបាលមូលដ្ឋាន ឬ មន្ត្រីតុលាការ។ របាយការណ៍អង្គការអាដហុកក៏បានឱ្យដឹងថា ជនជាប់ឃុំដែលធ្វើឡើងដោយខុសច្បាប់ភាគច្រើន ត្រូវបានដោះលែងបន្ទាប់ពីមានការដាក់ពាក្យបណ្តឹងពីជននោះ បទអន្តរាគមន៍ពីអង្គការសិទ្ធិមនុស្ស ឬ ដោយការបង់សំណូក។ អង្គការសិទ្ធិមនុស្សបានកត់សំគាល់ឃើញថា មានករណីចំនួនពាក់កណ្តាលត្រូវបានដោះស្រាយដោយការដោះលែង ឬ ការបង់សំណងជម្ងឺចិត្តដល់ជនរងគ្រោះ។ ករណីផ្សេងទៀត ត្រូវបានបញ្ជូនទៅតុលាការ ហើយជនរងគ្រោះត្រូវបានគេឃុំខ្លួនរហូតដល់ពេលតុលាការបើកសវនាការ។ របាយការណ៍នោះបានធ្វើក្តីសន្និដ្ឋានថា មិនមានការដាក់ពិន័យ ឬ វិធានការណ៍ច្បាប់ណាមួយត្រូវបានគេចាត់ចំពោះបុគ្គលដែលធ្វើសកម្មភាពខុសច្បាប់នោះឡើយ។

**តួនាទីរបស់ប៉ូលីស និង កងរក្សាសន្តិសុខ**

អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ ធ្វើការចាត់ចែងគ្រប់កងអង្គភាពប៉ូលីសស៊ីវិលទាំងអស់។ កងកំលាំងប៉ូលីសត្រូវបានគេបែងចែកជាក្រុមដែលមានអាជ្ញាក្នុងការចាប់ខ្លួន អ្នកមិនមានអាជ្ញាដូចនេះ និង ប៉ូលីសយុត្តិធម៌។ កងរាជអាវុធហត្ថ គឺអនុញ្ញាតឱ្យធ្វើការឃាត់ខ្លួនតែចំពោះជនស៊ីវិលប៉ុណ្ណោះ នៅពេលចេញបញ្ជាដោយរដ្ឋាភិបាលមូលដ្ឋាន។

មន្ត្រីប៉ូលីសបានប្រព្រឹត្តបទល្មើសដោយមិនមានការដាក់ទោសឡើយ ហើយនៅក្នុងករណីភាគច្រើនរដ្ឋាភិបាលបានចាត់វិធានការតិចតួច ឬ មិនមានចាត់វិធានការច្បាប់ចំពោះមន្ត្រីទាំងនេះឡើយ។ មានរបាយការណ៍ថា ប៉ូលីស អាយ្យការតុលាការ និង ចៅក្រមស៊ើបអង្កេត និង ចៅក្រមជំនុំជំរះ បានទទួលសំណូកពីម្ចាស់អាជីវកម្មខុសច្បាប់។

ប៉ូលីស អាយ្យការតុលាការ និង ចៅក្រម ត្រូវបានតំរូវដោយច្បាប់ឱ្យធ្វើការស៊ើបអង្កេតរាល់ពាក្យបណ្តឹងទាំងអស់ ដោយគិតរួមទាំងបណ្តឹងពីបទល្មើសដោយប៉ូលីសផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តន៍ជាក់ស្តែង ចៅក្រម និង អាយ្យការតុលាការ កំរធ្វើការស៊ើបអង្កេតមុនពេលធ្វើការកាត់សេចក្តីជាសាធារណៈណាស់។ ចៅក្រមជុំនុំជំរះធ្វើការសំរេចសាលក្រមដោយផ្អែកលើរបាយការណ៍ជាលាយលក្ខណ៍អក្សរដោយប៉ូលីស និង ភស្តុតាងពីសាក្សី។ ជាទូទៅ ប៉ូលីសទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈតិចតួចប៉ុណ្ណោះ។ ប៉ូលីសដែលខកខានមិនបានការពារ ឬ ឆ្លើយតបទៅអំពើហិង្សាសង្គម កំរទទួលការពិន័យដាក់ទណ្ឌកម្មណាស់។

**ការឃាត់ខ្លួន និង ការឃុំខ្លួន**

ច្បាប់តំរូវឱ្យប៉ូលីសទទួលយកដីការនាំខ្លួនពីអាយ្យការតុលាការមុនពេលធ្វើការឃាត់ខ្លួន ប៉ុន្តែប៉ូលីសអាចធ្វើការឃាត់ខ្លួនដោយមិនមានដីការចំពោះជនណាដែលប្រព្រឹត្តបទឧក្រិដ្ឋ។ ច្បាប់អនុញ្ញាតឱ្យប៉ូលីសនាំខ្លួនជននោះទៅកាន់មន្ទីរឃុំឃាំង និង ធ្វើការសួរដេញដោលរយៈពេល ៤៨ ម៉ោង ដោយមិនគិតបញ្ចូលពេលវេលាចុងសប្តាហ៍ និង ថ្ងៃឈប់សំរាករបស់រដ្ឋាភិបាលនោះទេ មុនពេលធ្វើការចោទប្រកាន់។ ទោះជាយ៉ាងណា អាជ្ញាធរជាទម្លាប់បានធ្វើការឃុំខ្លួនជនល្មើសលើសពីរយៈពេលកំណត់មុនពេលធ្វើការចោទប្រកាន់។ អ្នកទោសជាច្រើន ជាពិសេសអ្នកដែលមិនមានតំណាងស្របច្បាប់ មិនមានឱកាសសុំការដោះលែងដោយបង់ប្រាក់ធានានោះឡើយ។ ជនជាប់ចោទតាមច្បាប់ ត្រូវមានសិទ្ធិរកមេធាវីការពារក្តី ប៉ុន្តែជាទូទៅអ្នកទោសត្រូវបានគេឃុំខ្លួនរយៈពេលជាច្រើនថ្ងៃមុនពេលទទួលបានមេធាវី ឬ ជួបជាមួយសមាជិកគ្រួសារ។ យោងទៅតាមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិសំរាប់សិទ្ធិមនុស្ស ការពន្យាពេលយូរបែបនេះ គឺដោយសារសមត្ថភាពរបស់ប្រព័ន្ធតុលាការមានកំរិត។

ដោយសារមានការលំបាកនៅក្នុងការធ្វើសម្ភាសន៍ដល់អ្នកទោសនៅក្នុងឆ្នាំទាំងមូល អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការត្រួតពិនិត្យពន្ធនាគារ មិនអាចផ្តល់ភាពពិតប្រាកដថាតើមានអ្នកទោសចំនួនប៉ុន្មាននាក់ត្រូវបានគេឃុំខ្លួនរយៈពេលលើសពីរយៈពេលកំណត់ដោយច្បាប់ចំនួន ៦ ខែមុនពេលទទួលការកាត់ទោស។ អង្គការលីកាដូបានរាយការណ៍ថា យ៉ាងហោចណាស់មានអ្នកទោសចំនួន ២៨៦ នាក់ ត្រូវបានឃុំខ្លួនលើសពីរយៈពេល ៦ ខែ។ លើសពីនេះទៀត អង្គការអាដហុកបានផ្តល់របាយការណ៍ថា យ៉ាងហោចណាស់មានទណ្ឌិតចំនួន ៤០ នាក់មិនបានដឹងពីរយៈពេលដែលពួកគេត្រូវបំរើនៅក្នុងពន្ធនាគារនោះឡើយ។ អាជ្ញាធរពន្ធនាគារអះអាងថា តុលាការមិនបានប្រាប់ពួកគេពីសាលក្រមនោះទេ។

នៅថ្ងៃទី ២៩ ខែតុលា មនុស្សចំនួន ៦ នាក់មកពីខេត្តស្វាយរៀង សៀមរាប និង ខេត្តកណ្តាល ត្រូវបានឃាត់ខ្លួន និង ចោទប្រកាន់ដោយតុលាការក្រុងភ្នំពេញថា បានរួមគំនិតប្រព្រឹត្តអំពើភារវកម្ម។ ប៉ូលីសធ្វើការចោទប្រកាន់ដោយគ្មានភស្តុតាងថា ជនជាប់សង្ស័យបានរៀបចំដាក់គ្រាប់បែកនៅក្នុងពិធីបុណ្យអំទូកសំពះព្រះខែប្រចាំឆ្នាំនៅក្នុងទីក្រុងភ្នំពេញ ដែលពិធីនេះបានទាក់ទាញមនុស្សប្រហែលជា ១ លាននាក់មកកាន់ទីក្រុងភ្នំពេញ។ ទោះជាយ៉ាងណា មេធាវីរបស់ជនជាប់ចោទបាននិយាយថា មិនមានដីការណាមួយត្រូវបានគេបង្ហាញជូនដល់កូនក្តីរបស់គាត់នៅពេលដែលពួកគេត្រូវបានឃាត់ខ្លួននោះឡើយ ឬ ត្រូវបានគេផ្តល់ព័ត៌មានពីការចោទប្រកាន់នោះដែរ។ មេធាវីរូបនោះបានបន្ថែមទៀតថា ភស្តុតាងដែលអាចនាំឱ្យមានការចាប់ខ្លួនមិនត្រូវបានគេបង្ហាញជូនឡើយ។ មន្ត្រីតុលាការបានឆ្លើយតបថា ការស៊ើបអង្កេតកំពុងត្រូវបានគេធ្វើឡើង ហើយភស្តុតាងនឹងត្រូវបានបង្ហាញជូននៅពេលការស៊ើបអង្កេតត្រូវបានបញ្ចប់។

មជ្ឈមណ្ឌលសិទ្ធិមនុស្សបានរាយការណ៍ថា នៅក្នុងទីក្រុងភ្នំពេញថ្ងៃទី ១ ខែមីនា លោក ភោគ សម្បត្តិ ជាកងទ័ពជើងអាកាសពិសេសកងពលតូចលេខ ៩១១ ត្រូវបានឃុំខ្លួនតាមបញ្ជារបស់ឧត្តមសេនីយ៍ ចាប ភក្តី ជាមេបញ្ជាការកងពលតូចពីបញ្ហាជំលោះទ្រព្យសម្បត្តិ។ នៅថ្ងៃទី ៨ ខែមីនា គ្រួសារលោក សម្បត្តិ បានដាក់ពាក្យបណ្តឹងទៅអង្គការសិទ្ធិមនុស្ស។ លោកមេបញ្ជាការកងពលតូចរូបនោះបានអះអាងថា លោក សម្បត្តិ ត្រូវបានឃាត់

ខ្លួនដោយសារមិនបានផ្តល់របាយការណ៍ពីភារកិច្ច។ បន្ទាប់ពីបានដោះលែងនៅថ្ងៃទី ១៣ ខែមេសា លោក សម្បត្តិ បានប្រាប់អ្នកស៊ើបអង្កេតរបស់អង្គការសិទ្ធិមនុស្សថា គាត់បានលាឈប់ពីយោធាអស់រយៈពេលជិត ១ ឆ្នាំមកហើយ ប៉ុន្តែមិនបានចុះហត្ថលេខាលើក្រដាសស្នាមអ្វីឡើយ។ គាត់បានបន្ថែមទៀតថា គាត់មិនបានទទួលប្រាក់បៀវត្សនោះទេក្នុងពេលនោះ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សបានធ្វើការសន្និដ្ឋានថា ទំនាស់ទ្រព្យសម្បត្តិបានធ្វើឱ្យមានការឃាត់ខ្លួនរូបគាត់ ហើយហៅការឃាត់ខ្លួននោះថា ខុសច្បាប់ និង បានលើកឡើងថា មន្ត្រីយោធាមិនមានសិទ្ធិអំណាចទៅធ្វើការកាត់សេចក្តីករណីរដ្ឋប្បវេណីនោះឡើយ។ នៅចុងឆ្នាំដដែល ទំនាស់ទ្រព្យសម្បត្តិបានមកដល់តុលាការរដ្ឋប្បវេណីក្រុងភ្នំពេញដោយរង់ចាំការសំរេចចិត្ត។

នៅក្នុងខែមិថុនា លោក ធៀម សង្គ្រាម ស្នងការប៉ូលីសខេត្តព្រះវិហារ និង សហការីជាប៉ូលីស ៣ រូបបានធ្វើការឃុំខ្លួនលោក គង់ សាឡាត់ ដោយគ្មានដីកាតុលាការ និង ធ្វើទារុណកម្មរូបគាត់យ៉ាងធ្ងន់ធ្ងរមុនពេលដោះលែងរយៈពេល ១ ថ្ងៃក្រោយមក។ លោកស្នងការប៉ូលីស នៅពេលក្រោយមក ត្រូវបានគេផ្លាស់ចេញពីមុខដំណែងរបស់គាត់ដោយសារពាក្យបណ្តឹងបទឧក្រិដ្ឋដែលអង្គការមិនមែនរដ្ឋាភិបាលបានប្តឹងនៅតុលាការខេត្ត។ នៅចុងឆ្នាំការស៊ើបអង្កេតបានកំពុងតែបន្ត ហើយមិនមានវិធានការណ៍ផ្លូវច្បាប់ណាមួយត្រូវបានគេចាត់ចំពោះលោកស្នងការរូបនោះឡើយ (មើលផ្នែក ១-គ.)។

នៅថ្ងៃទី ៤ ខែមករា លោក ប៉ា ងួនទៀង ដែលធ្វើការជាមួយសកម្មជនសិទ្ធិមនុស្សលោក កឹម សុខា ត្រូវបានឃាត់ខ្លួនពីបទបរិហាកេរ្តិ៍។ រដ្ឋាភិបាលបានដោះលែងរូបគាត់ ២ សប្តាហ៍បន្ទាប់មក។

នៅថ្ងៃទី ១១ ខែមករា អ្នកគាំទ្រសិទ្ធិមនុស្សលោក យ៉េង វីរៈ ដែលត្រូវឃាត់ខ្លួននៅក្នុងខែធ្នូ ឆ្នាំ ២០០៥ ត្រូវបានដោះលែងដោយការបង់ប្រាក់ធានា។ នៅថ្ងៃទី ១៧ ខែមករា លោក ប៉ា ងួនទៀង និង អ្នកទោស ៣ រូបទៀតត្រូវបានឃុំខ្លួននៅក្នុងឆ្នាំ ២០០៥ -- ម្ចាស់ស្ថានីយ៍វិទ្យុសម្បុកឃ្មុំលោក ម៉ម សូណង់ដូ ត្រូវបានឃុំខ្លួននៅក្នុងខែតុលា ឆ្នាំ ២០០៥ , សកម្មជនផ្នែកការងារ គឺ លោក រ៉ុង ឈុន ក៏ត្រូវបានឃុំខ្លួននៅក្នុងខែតុលា ឆ្នាំ ២០០៥ ផងដែរ និង លោក កឹម សុខា ត្រូវបានឃុំខ្លួននៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៥ -- ត្រូវបានដោះលែង ហើយករណីទាំងនេះត្រូវបានព្យួរទុកសិន។ ពួកគេទាំងអស់ត្រូវបានឃុំខ្លួនពីបទបរិហាកេរ្តិ៍។

**ការលើកលែងទោស**

នៅថ្ងៃទី ៥ ខែកុម្ភៈ ព្រះមហាក្សត្រនរោត្តម សីហមុនី បានធ្វើការលើកលែងទោសចំពោះសមាជិកសភាគណបក្សប្រឆាំងលោក សម រង្ស៊ី លោក ជាម ចន្នី និង លោក ជា ប៉ូច (សូមមើលផ្នែក ១-ង និង ៣)។

**ង- ការបដិសេធចំពោះការកាត់សេចក្តីជាសាធារណៈដោយយុត្តិធម៌**

រដ្ឋធម្មនុញ្ញបានផ្តល់ឱ្យមានប្រព័ន្ធតុលាការឯករាជ្យ ប៉ុន្តែរដ្ឋាភិបាលមិនបានគោរពភាពឯករាជ្យរបស់តុលាការនោះទេ។ តុលាការងាយទទួលរងឥទ្ធិពល និង ការជ្រៀតជ្រែកពីសាខានីតិប្រតិបត្តិ ហើយមានអំពើពុករលួយនៅគ្រប់ទិសទីក្នុងចំណោមចៅក្រម អាយ្យការ និង មន្ត្រីតុលាការ។

ប្រព័ន្ធតុលាការមានតុលាការជាន់ទាប តុលាការឧទ្ធរណ៍ និង តុលាការកំពូល។ រដ្ឋធម្មនុញ្ញ ក៏បានផ្ដល់អណត្តិជា**ក្រុមប្រឹក្សាធម្មនុញ្ញ** ដែលត្រូវបានគេប្រគល់អំណាចឱ្យធ្វើការសើរើឡើងវិញនូវច្បាប់រដ្ឋធម្មនុញ្ញ និង **ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** ដែលធ្វើការតែងតាំង ត្រួតពិនិត្យ និង ដាក់ទោសពិន័យដល់ចៅក្រម។ សមាសភាគនៃក្រុមប្រឹក្សាទាំងពីរនេះ មានការគាំទ្រដល់គណបក្សប្រជាជនកម្ពុជាយ៉ាងខ្លាំង។

មានតុលាការយោធាដាច់ដោយឡែកមួយ ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងប្រព័ន្ធតុលាការស៊ីវិលដែរ។ ភាពខុសគ្នារវាងតុលាការយោធា និង តុលាការស៊ីវិល ជួនកាលត្រូវបានគេមិនចាប់អារម្មណ៍សំរាប់ការអនុវត្តន៍ជាក់ស្ដែង ហើយជនស៊ីវិលត្រូវបានកោះហៅមកធ្វើការសាកសួរដោយតុលាការយោធា ដោយមិនមានយុត្តាធិការច្បាស់លាស់ចំពោះករណីរបស់ពួកគេឡើយ។

នៅថ្ងៃទី ៣ ខែកក្កដា ចៅក្រមក្នុងស្រុកចំនួន ៧ នាក់ និង ចៅក្រមអន្តរជាតិចំនួន ១០ នាក់ រួមទាំងសហការីអាយ្យការមួយចំនួនចំពោះសាលាក្ដីវិសាមញ្ញសំរាប់កាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងប្រទេសកម្ពុជា (ECCC) ត្រូវបានធ្វើការសច្ចារប្រណិធាន។ នៅថ្ងៃទី ២១ ខែកក្កដា លោក អ៊ុង ជឿន ដែលមានឈ្មោះមួយទៀតហៅថា តាម៉ុក ដែលគេគិតថាជាចុងចោទដ៏មានសក្ដានុពលចំពោះតុលាការនេះ បានស្លាប់បាត់បង់ជីវិតនៅឯមន្ទីរពេទ្យយោធាក្រុងភ្នំពេញ។ ការស្លាប់របស់គាត់ គឺត្រូវបានគេរាយការណ៍ថា ដោយសារវ័យចំណាស់ ជម្ងឺរបេង និង ភាពដុនដាបនៃសុខភាពរបស់គាត់ជាយូរមកហើយ។ តា ម៉ុក ដែលស្ថិតក្រោមការឃុំខ្លួនផ្នែកយោធាតាំងពីឆ្នាំ ១៩៩៧ គឺជាលេខាធិការប្រចាំតំបន់ សមាជិកគណៈកម្មការមជ្ឈិម និង គណៈកម្មការអចិន្ត្រៃ និង ជាមេបញ្ជាការយោធាភូមិភាគអាគ្នេយ៍របស់ខ្មែរក្រហម។

មកដល់ចុងឆ្នាំ សាលាក្ដីវិសាមញ្ញសំរាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា មិនអាចដំណើរការក្ដីនេះបាន ដោយសារមានការបរាជ័យនៅក្នុងការបញ្ចប់បទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។ ការពន្យាពេលនេះបានធ្វើឱ្យមានការបារម្ភណ៍ពីសាធារណៈជនកាន់តែខ្លាំងឡើង ដែលថា មេដឹកនាំកំពូល១របស់របបខ្មែក្រហមនឹងត្រូវស្លាប់អស់ មុនពេលសាលាក្ដីចាប់ផ្ដើមដំណើរការនៅក្នុងអាណត្តិរបស់ខ្លួន។

**នីតិវិធីជុំនំជំរះ**

ការជំនំជំរះ គឺធ្វើឡើងដោយបើកចំហជាសាធារណៈ។ ក្រុមអង្គចៅក្រមមិនត្រូវបានគេប្រើឡើយ។ ចៅក្រមជុំនំជំរះ ត្រូវបានគេប្រគល់អំណាចក្នុងការសំរេចសាលក្រម។ ចុងចោទអាចមានសិទ្ធិធ្វើការពិគ្រោះយោបល់ជាមួយមេធាវីការពារក្ដី ប្រឈមមុខ និង សួរសំនួរដល់សាក្សីខាងដើមចោទ និង ធ្វើការបង្ហាញសាក្សី និង ភស្តុតាងដោយខ្លួនឯងបាន។ ប្រសិនបើចុងចោទមិនអាចមានលទ្ធភាពរកមេធាវីបាន តុលាការត្រូវផ្ដល់សិទ្ធិឱ្យចុងចោទរកអ្នកតំណាងស្របច្បាប់តាមការជ្រើសរើសរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ អង្គចៅក្រមមានការខ្វះខាតធនធានចំពោះការផ្ដល់ការប្រឹក្សាផ្លូវច្បាប់ ហើយចុងចោទភាគច្រើនព្យាយាមរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ឬធ្វើឡើងដោយមិនមានអ្នកតំណាងស្របច្បាប់។ ការកាត់ទោសជាទូទៅ ត្រូវបានគេធ្វើឡើងដោយគ្រាន់តែបង្គ្រប់កិច្ចតែប៉ុណ្ណោះ ហើយជាធម្មតា ការធ្វើកោសល្យពិច្ច័យល្អិតល្អន់មិនត្រូវបានធ្វើឡើងនោះឡើយ។ ចុងចោទ និង

មេធាវីការពារក្ដី មានសិទ្ធិធ្វើការត្រួតពិនិត្យលើភស្ដុតាងពាក់ព័ន្ធទៅនឹងរឿងក្ដីរបស់ពួកគេ ដែលធ្វើដោយរដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ ពេលខ្លះវាមានការលំបាកសំរាប់ពួកគេក្នុងការចូលទៅពិនិត្យមើល ជាពិសេសនៅពេលដែលរឿងក្ដីមានការពាក់ព័ន្ធទៅនឹងនយោបាយ ឬមន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់ ឬក្រុមអ្នកមានទ្រព្យសម្បត្តិ។

តាមច្បាប់ ចុងចោទមានសិទ្ធិធ្វើការសន្និដ្ឋានពីភាពគ្មានទោសរបស់ខ្លួន និង ធ្វើការប្ដឹងឧទ្ធរណ៍ ប៉ុន្ដែដោយសារអំពើពុករលួយដែលមានវិសាលភាពធំធេង ចុងចោទតែងតែសង្ឃឹមលើការបង់សំណូកដល់ចៅក្រម ដើម្បីធានាថា សាលក្រមត្រូវបានឈ្នះ។ ជួនកាលសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍របស់ប្រជាពលរដ្ឋមានកំរិត ដោយសារមានការលំបាកក្នុងការបញ្ជូនអ្នកទោសពីពន្ធនាគារខេត្ត ទៅកាន់តុលាការឧទ្ធរណ៍ក្នុងក្រុងភ្នំពេញ។ ដូចនេះហើយ ការជំនុំជំរះឧទ្ធរណ៍ជាច្រើន ធ្វើឡើងដោយមិនមានចុងចោទ។

ការខ្វះខាតធនធាន ប្រាក់បៀវត្សទាប និង ការបណ្ដុះបណ្ដាលទាប បានធ្វើឱ្យមានអំពើពុករលួយកំរិតខ្ពស់ និង អប្រសិទ្ធិភាពការងារនៅក្នុងផ្នែកផ្សេងៗរបស់តុលាការ ហើយរដ្ឋាភិបាលមិនបានធ្វើការធានាឱ្យមានដំណើរការប្រសើរឡើយ។ របាយការណ៍មួយចេញផ្សាយនៅក្នុងខែមីនាដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ដែលបានធ្វើការតាមដានរឿងក្ដីនៅតុលាការចំនួនប្រហែល ១000 ករណីនៅក្នុង ១ ឆ្នាំ បានបង្ហាញថា មានតែចំនួន ១៥% ប៉ុណ្ណោះដែលធ្វើឡើងដោយមានសាក្សី និង ៧១% មានរយៈពេលតិចជាង ៣0 នាទី។ របាយការណ៍របស់មជ្ឈមណ្ឌលនេះបានរកឃើញថា ការរកមេធាវីការពារក្ដីបានកើនឡើងចំពោះករណីបទអាជ្ញា ដែលកើនពី ៨៥% ក្នុងឆ្នាំ ២00៤ ទៅ ៩៧% ក្នុងឆ្នាំ ២00៥។ នៅចុងឆ្នាំ ២00៥ លោកប្រធានតុលាការក្រុងភ្នំពេញបានហាមអ្នកសារព័ត៌មានទាំងអស់មិនឱ្យនៅក្នុងបរិវេណតុលាការនៅបន្ទាប់ពីការកាត់ទោស។ ទោះជាយ៉ាងណា ការហាមប្រាមបែបនេះមិនមាននៅក្នុងប្រព័ន្ធច្បាប់ឡើយ (សូមមើលផ្នែក ២-ក.)។

ប៊ិន សំណាង និង សុខ សំអឿន ស្ថិតនៅក្នុងពន្ធនាគារនៅឡើយពីបទធ្វើឃាតលោក ជា វិជ្ជា ដែលបន្ទាប់ពីការកាត់ទោស បានបង្ហាញឱ្យឃើញពីភាពមិនប្រក្រតីជាច្រើន និង ការថ្កោលទោសពីអ្នកសង្កេតការណ៍អន្តរជាតិផងដែរ។ នៅថ្ងៃទី ៦ ខែតុលា តុលាការឧទ្ធរណ៍បានព្យួរការបើកសវនាការចំពោះបុរសទាំងពីររូបនេះ។ រហូតមកដល់ចុងឆ្នាំ មិនទាន់មានកាលបរិច្ឆេទណាមួយត្រូវបានគេកំណត់សំរាប់ការធ្វើសវនាការនៅឡើយនោះទេ។

ចៅក្រម និង អាយ្យការ ជាញឹកញយតែងតែទទួលបានការបណ្ដុះបណ្ដាលតិចតួចប៉ុណ្ណោះ។ នៅដើមឆ្នាំ សាលាភូមិន្ទចៅក្រម និង អាយ្យការ បានចាប់ផ្ដើមរៀបចំបណ្ដុះបណ្ដាលក្រុមវគ្គទី២ ដែលមានសិក្ខាកាមចំនួន ៥៥ នាក់ ដើម្បីឱ្យក្លាយជាចៅក្រម និង អាយ្យការតុលាការ។

នៅមានការកង្វះខាតយ៉ាងខ្លាំងចំពោះមេធាវីការពារក្ដីដែលទទួលបានការបណ្ដុះបណ្ដាលត្រឹមត្រូវនៅឡើយ ជាពិសេសតំបន់នៅក្រៅពីទីក្រុងភ្នំពេញ។ បុគ្គលដែលមិនមានមធ្យោបាយក្នុងការទទួលការពិគ្រោះយោបល់ ជាញឹកញាប់ត្រូវបានគេបដិសេធមិនផ្ដល់សិទ្ធិក្នុងការទទួលបានការកាត់ទោសដោយភាពយុត្តិធម៌នោះឡើយ។ យោងទៅតាមគណៈមេធាវីការពារក្ដី មានមេធាវីប្រហែលជា ៣0% នៃចំនួនមេធាវី ៣00 នាក់ បានធ្វើការផ្ដល់ការប្រឹក្សាយោបល់ដល់អ្នកក្រីក្រ ទោះបីនេះជាចំនួនមួយមិនគ្រប់គ្រាន់ចំពោះការបំរើតាមសេចក្ដីត្រូវការផ្នែកច្បាប់

របស់អ្នកក្រីក្រនៅក្នុងប្រទេសក៏ដោយ។ នៅថ្ងៃទី ១៨ ខែសីហា សមាគមមេធាវីគ្មានព្រំដែន (Association of Lawyers Without Border) បានចុះហត្ថលេខាជាមួយគណៈមេធាវីការពារក្តី ដើម្បីផ្តល់មូលនិធិសំរាប់មេធាវីស្ម័គ្រចិត្តចំនួន ២៤ រូប ដើម្បីផ្តល់សេវាកម្មច្បាប់ដល់អ្នកក្រីក្រនៅក្នុងខេត្តទាំង ២១។

របាយការណ៍បញ្ជាក់ជាលាយលក្ខណ៍អក្សរពីសាក្សី និង ជនជាប់ចោទ ជាធម្មតាត្រូវបានគេប្រើប្រាស់ជាភស្តុតាងតែមួយគត់នៅពេលធ្វើការកាត់ទោស។ សេចក្តីបញ្ជាក់របស់ជនជាប់ចោទជួនកាលត្រូវបានគេគំរាមកំហែងតាមរយៈការវាយធ្វើទារុណកម្ម ឬ ការគំរាមកំហែងផ្សេងៗ ហើយចុងចោទជាអនក្ខរជនភាគច្រើនមិនត្រូវបានគេប្រកាសប្រាប់ឱ្យដឹងពីខ្លឹមសារនៃការសារភាពរបស់ខ្លួនដែលខ្លួនត្រូវបានគេបង្ខំឱ្យចុះហត្ថលេខានោះឡើយ។ នៅក្នុងករណីមានការពាក់ព័ន្ធទៅនឹងបុគ្គលិកយោធា មន្ត្រីយោធាតែងតែប្រើសម្ពាធលើចៅក្រមរបស់តុលាការស៊ីវិលឱ្យធ្វើការដោះលែងជនល្មើសដោយមិនមានការកាត់ទោសឡើយ។

តុលាការតែងតែធ្វើការពន្យាពេល ឬ ប្រព្រឹត្តអំពើពុករលួយ ដែលអាចធ្វើឱ្យជនជាប់ចោទគេចផុតពីការកាត់ទោស។ មន្ត្រីរដ្ឋាភិបាល ឬ សមាជិកក្រុមគ្រួសាររបស់ពួកគេដែលប្រព្រឹត្តបទល្មើសតែងតែទទួលបាននូវនិទណ្ឌភាព។ នៅចុងឆ្នាំ អាជ្ញាធរមិនបានចាត់វិធានការណ៍ច្បាប់ចំពោះករណីការសំលាប់បុរសម្នាក់នៅខែមិថុនា ឆ្នាំ២០០៥ នៅក្នុងផ្ទះរបស់គ្រួសារលោកអធិការប៉ូលីសខេត្តនោះឡើយ។

ទោះជា តុលាការបានកាត់ទោសសមាជិកមួយចំនួនរបស់កងកំលាំងសន្តិសុខចំពោះការរំលោភសិទ្ធិមនុស្សក៏ដោយ និទណ្ឌភាពចំពោះជនទាំងដែលរំលោភសិទ្ធិមនុស្សនៅតែជាបញ្ហា។ ចំពោះករណីបទឧក្រិដ្ឋជាច្រើន អ្នកមានទ្រព្យសម្បត្តិ ឬ អ្នកមានអំណាច បានបង់ប្រាក់ទៅឱ្យជនរងគ្រោះ និង អាជ្ញាធរ ដើម្បីឱ្យដកពាក្យបណ្តឹងបទឧក្រិដ្ឋ។ គេបានដឹងថា អាជ្ញាធរតែងតែជំរុញឱ្យជនរងគ្រោះទទួលសំណងជម្ងឺចិត្តជាទឹកប្រាក់ ជាការដោះដូរក្នុងការដកពាក្យបណ្តឹងបទឧក្រិដ្ឋ (សូមមើលផ្នែក ១-ក.)។

នៅថ្ងៃទី ១៣ ខែមេសា មន្ត្រីប៉ូលីសមកពីផ្នែកប្រឆាំងគ្រឿងញៀន និង កងរាជអាវុធហត្ថ១រូប បានបាញ់ធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរចំពោះនាង សុវណ្ណ សុជាតា ដែលជាអ្នកចំរៀងនៅក្នុងហាងខារ៉ាអូខេក្នុងក្រុងភ្នំពេញដោយចៃដន្យ។ មន្ត្រីប៉ូលីសបានសងជាទឹកប្រាក់ប្រហែល ៣ ០០០ ដុល្លារ (១២.៣ លានរៀល) ដល់ស្ត្រីរងរបួសដើម្បីធ្វើការសំរបសំរួលរឿងក្តីបទឧក្រិដ្ឋ។ នៅចុងឆ្នាំ ទាំងតុលាការក្នុងតំបន់ ទាំងអាជ្ញាធរប៉ូលីសតំបន់មិនបានចាត់វិធានការណ៍ច្បាប់ចំពោះមន្ត្រីទាំងពីររូបនោះឡើយ។

នៅថ្ងៃទី ២៦ ខែមេសា លោកវរសេនីយ៍ត្រី ផាត សុផល និង អនុសេនីយឯក ស៊ីម រី ដែលអ្នកទាំងពីរនៅក្នុងកងពលតូចលេខ ៧០ អង្គភាពយោធាដែលត្រូវបានចោទប្រកាន់ពីបទល្មើសបង្កអសន្តិសុខនៅក្នុងក្រុងភ្នំពេញត្រូវបានឃាត់ខ្លួនដោយកងរាជអាវុធហត្ថនៅក្នុងខណ្ឌទួលគោក ក្រុងភ្នំពេញភ្លាមៗ បន្ទាប់ពីពួកគេបាញ់ឱ្យរបួសនារីម្នាក់។ មន្ត្រីទាំងពីររូបនេះត្រូវបានដោះលែងក្នុងរយៈពេលប៉ុន្មានម៉ោងក្រោយមកនៅពេលដែលលោកមេបញ្ជាការឧត្តមសេនីយ ម៉ៅ សុភាន់ បានមកធ្វើអន្តរាគមន៍។ បន្ទាប់មក លោកឧត្តមសេនីយ៍បាននិយាយថា គាត់នឹងដាក់

ទណ្ឌកម្មមន្ត្រីទាំងពីររូបនេះដោយចាប់កោរក្បាលរបស់ពួកគេ។ នៅចុងឆ្នាំ មិនមានវិធានការណ៍ច្បាប់ណាមួយត្រូវបានគេចាត់ចំពោះមន្ត្រីទាំងពីររូបនេះឡើយ។

នៅថ្ងៃទី ១ ខែកក្កដា នាង លឹម ស្រី ដែលជាកម្មការនីនៅក្នុងរោងចក្រកាត់ដេរ ត្រូវបានលោក គុច បញ្ញា ដែលជាមន្ត្រីយោធាបាញ់ឱ្យរបួសយ៉ាងធ្ងន់ធ្ងរក្នុងពេលដែលគាត់បាញ់រះដាក់ជនដែលគប់ដុំថ្មដាក់ផ្ទះគាត់។ អាជ្ញាធរក្នុងតំបន់បានឃាត់ខ្លួនលោក គុច បញ្ញា ប៉ុន្តែក្រោយមកត្រូវបានដោះលែងនៅបន្ទាប់ពីបានសងជាទឹកប្រាក់ដល់ជនរងគ្រោះ។

ថ្ងៃទី ១១ ខែវិច្ឆិកា ដល់ ថ្ងៃទី ១៣ ខែវិច្ឆិកា មន្ត្រីប៉ូលីស ៣ រូបនៅក្នុងខេត្តសៀមរាបត្រូវបានចោទប្រកាន់ដោយគ្មានភស្តុតាងថា បានរំលោភសេពសន្ថវៈដល់កុមារីម្នាក់អាយុ ១២ ឆ្នាំនៅស្នាក់ការប៉ូលីស។ អង្គការមិនមែនរដ្ឋាភិបាលបានជួយកុមារីរងគ្រោះដែលជាអ្នកមានជម្ងឺផ្លូវចិត្តផងនោះ ដោយបានដាក់ពាក្យបណ្តឹងទៅកាន់តុលាការខេត្ត។ លោកអភិបាលរងស្រុក ដែលកូនប្រុសរបស់គាត់ជាមនុស្សម្នាក់នៅក្នុងចំណោមជនដែលត្រូវបានចោទប្រកាន់បានទទួលកំហុស ហើយផ្តល់ជូនជាទឹកប្រាក់ចំនួន ៥០០ ដុល្លារ (ប្រហែលជា ២,១ លានរៀល) ទៅឱ្យគ្រួសារជនរងគ្រោះ។ ប៉ូលីសខេត្តសៀមរាបបានដាក់ពាក្យសុំដីកាចាប់ខ្លួនចំពោះជនជាប់ចោទទាំងបីរូប ប៉ុន្តែរហូតមកដល់ចុងឆ្នាំ តុលាការមិនបានធ្វើការតាមសំណើរនោះឡើយ។

នៅថ្ងៃទី ២១ ខែមេសា នៅក្នុងការបើកការកាត់ទោសឡើងវិញចំពោះចៅក្រម ៣ រូប អាយ្យការរង ២ រូប និង ក្រឡាបញ្ជី ២ រូបដែលត្រូវបានកាត់ទោសនៅក្នុងខែធ្នូ ឆ្នាំ២០០៥ ចំពោះការប្រព្រឹត្តអំពើពុករលួយ និងការសំគំនិតប្រព្រឹត្តអំពើពុករលួយ តុលាការខេត្តបាត់ដំបងបានកាត់សេចក្តីឱ្យរួចពីការចោទប្រកាន់ដល់មន្ត្រីទាំង ៧ រូប។ លោកអាយ្យការបានជំទាស់ចំពោះសាលក្រមថ្មី និង បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ រហូតមកដល់ចុងឆ្នាំ តុលាការឧទ្ធរណ៍បានព្យួរទុកបណ្តឹងនេះសិន។ នៅថ្ងៃទី ៤ ខែមិថុនា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានតែងតាំងមន្ត្រីចំនួន ៥ រូបក្នុងចំណោម អ្នកទាំង ៧ រូបឱ្យឡើងកាន់តំណែងរបស់ខ្លួនឡើងវិញ និង បានបណ្តេញចេញនូវចៅក្រម ១ រូប និង អាយ្យការ ១ រូប។

នៅចុងឆ្នាំ តុលាការកំពូលមិនបានចាត់វិធានការណ៍ចំពោះករណីជំលោះដីធ្លីក្នុងខែមីនា ឆ្នាំ២០០៥ ដែលមានភ្នាក់ងារកងសន្តិសុខរដ្ឋាភិបាលចំនួន ១០០ នាក់បានសំលាប់មនុស្ស ៥នាក់ និង ធ្វើឱ្យរបួសមនុស្ស ៨នាក់ផ្សេងទៀតនៅក្នុងភូមិក្បាលស្ពាន។ យោងទៅតាមអង្គការមិនមែនរដ្ឋាភិបាល គ្រួសារជនរងគ្រោះបានយល់ព្រមទទួលយកការផ្តល់ឱ្យដីមួយចំនួនទៅពួកគេដោយមានការចេញប្លង់កាន់កាប់ដីធ្លី។

ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធតុលាការ (Judicial Reform Council) មិនបានធ្វើឱ្យមានការរីកចំរើនណាមួយនៅក្នុងការបំពេញអាណត្តិរបស់ខ្លួនដើម្បីរៀបចំ និង អនុវត្តវិធានការណ៍កំណែទម្រង់នោះឡើយ។ ក្នុងឆ្នាំ ២០០៥ រដ្ឋាភិបាលរួមជាមួយអ្នកជំនាញការច្បាប់មកពីប្រទេសម្ចាស់ជំនួយ បានបញ្ចប់ពង្រាងច្បាប់ឧក្រិដ្ឋកម្ម និងរដ្ឋប្បវេណី និង បានចាប់ផ្តើមធ្វើការពិនិត្យឡើងវិញលើច្បាប់នេះ។ នៅក្នុងអំឡុងពេលឆ្នាំនោះ មានការចាត់វិធានការបន្ថែមទៀតដោយរដ្ឋាភិបាល ដើម្បីបង្កឱ្យមានភាពរលូនដល់ពង្រាងច្បាប់ទាំងអស់នោះ។

ក្រុមអង្គការសិទ្ធិមនុស្សបន្តរាយការណ៍ថា រដ្ឋាភិបាលបានបង្ហាញឱ្យឃើញពីការគ្រប់គ្រងលើតុលាការតាមរយៈការបញ្ជាឱ្យធ្វើការឃាត់ខ្លួនឡើងវិញចំពោះជនជាប់សង្ស័យដែលត្រូវបានដោះលែងដោយតុលាការ ឬ តាមរយៈនីតិវិធីក្រៅផ្លូវច្បាប់។ ចៅក្រមបានដកស្រង់ឧទាហរណ៍នៃការជ្រៀតជ្រែករបស់មន្ត្រីមានអំណាច ដោយបានដាក់កំរិតឱ្យពួកគេធ្វើការជំនុំជំរះឱ្យស្របតាមអាទិភាពផ្នែកនយោបាយ។

មេធាវីក៏បានធ្វើការកត់សំគាល់ចំពោះមន្ត្រីប៉ូលីស និង មន្ត្រីពន្ធនាគារមួយចំនួន ដែលរំលោភច្បាប់ និងមានការគាំទ្រច្បាស់លាស់ពីមន្ត្រីរដ្ឋាភិបាល បដិសេធមិនឱ្យពួកគេចូលជួបអ្នកទោសជាសំងាត់ ឬ ផ្តល់ពេលវេលាមិនបានគ្រប់គ្រាន់។

**អ្នកទោស និង អ្នកជាប់ឃុំឃាំងផ្នែកនយោបាយ**

មិនមានរបាយការណ៍ចំពោះអ្នកទោស និង អ្នកជាប់ឃុំឃាំងផ្នែកនយោបាយនោះឡើយ។ នៅថ្ងៃទី ៥ ខែកុម្ភៈ សមាជិកសភាគណបក្សប្រឆាំង លោក ជាម ចន្នី ដែលត្រូវបានកាត់ទោសនៅក្នុងខែសីហា ឆ្នាំ២០០៥ ចំពោះការរៀបចំកងទ័ពស្រមោល និង ការក្លែងបន្លំ ត្រូវបានដោះលែងឱ្យរួចទោសបន្ទាប់ពីមានការលើកលែងទោសពីព្រះមហាក្សត្រតាមសំណើររបស់នាយករដ្ឋមន្ត្រី។ រដ្ឋសភាជាតិក៏បានផ្តល់អភ័យឯកសិទ្ធិរបស់គាត់ឡើងវិញផងដែរ។

**នីតិវិធីច្បាប់រដ្ឋប្បវេណី និង សំណងការខូចខាត**

ប្រទេសកម្ពុជាមានតុលាការផ្នែករដ្ឋប្បវេណី ហើយប្រជាពលរដ្ឋមានសិទ្ធិធ្វើការប្តឹងដើម្បីទាមទារសំណងការខូចខាតចំពោះការរំលោភសិទ្ធិមនុស្ស។ ជាទូទៅ មានសំណងទាំងផ្នែករដ្ឋបាល និង ផ្នែកច្បាប់។ ទោះជាយ៉ាងណាក៏ដោយ តុលាការនេះត្រូវបានគេមើលឃើញថា មានអំពើពុករលួយ មានការលំអៀងផ្នែកនយោបាយ និង មានភាពទន់ខ្សោយ ហើយប្រជាពលរដ្ឋកំរដាក់ពាក្យបណ្តឹងណាស់ ព្រោះពួកគេមិនជឿជាក់លើប្រព័ន្ធតុលាការ។ សាធារណៈជនតែងតែមិនមានការទុកចិត្តចំពោះតុលាការដែលថា តុលាការអាចធ្វើសកម្មភាពក្នុងលក្ខណៈតម្លាភាព នៅពេលជំលោះនោះមានការពាក់ព័ន្ធទៅនឹងរដ្ឋាភិបាល។ ការប្រកាសបញ្ជារបស់តុលាការក្នុងតំបន់តែងតែមានបញ្ហាជានិច្ច។ ប្រជាពលរដ្ឋក្នុងពេលខ្លះបានប្រែក្លាយរឿងទាំងនេះទៅជាអំពើហិង្សា ដោយសារពួកគេបាត់បង់ទំនុកចិត្តលើតុលាការ។

**ច- ការជ្រៀតជ្រែកខុសច្បាប់លើភាពសំងាត់ផ្ទាល់ខ្លួន គ្រួសារ ផ្ទះសំបែង ឬ ការឆ្លើយឆ្លងគ្នា**

ច្បាប់បានផ្តល់ឱ្យមានភាពសំងាត់ផ្ទាល់ខ្លួនចំពោះការរស់នៅ និង ការឆ្លើយឆ្លងគ្នា និង បានហាមឃាត់ចំពោះការស្រាវជ្រាវដែលខុសច្បាប់។ ទោះជាយ៉ាងណា ប៉ូលីសតែងតែធ្វើការតាមដាន និង ធ្វើការរឹបអូសយកសម្ភារៈដោយមិនមានដីការតុលាការឡើយ។

យោងតាមការបង្ខំមនុស្សឱ្យធ្វើការជាសហករួមនៅក្នុងរបបប៉ុលពត និង ការវិលត្រឡប់របស់ជនភៀសខ្លួន សិទ្ធិក្នុងការកាន់កាប់ដីធ្លីតែងតែមិនមានភាពច្បាស់លាស់ ហើយអ្នកកាន់កាប់ដីធ្លីភាគច្រើនមានការខ្វះខាតឯកសារកាន់កាប់ដីធ្លីស្របច្បាប់។ នៅបន្ទាប់ពីការបញ្ចប់របបបះបោររបស់ពួកឧទ្ទាមខ្មែរក្រហម មានការប្រញាប់ប្រញាល់ក្នុងការចាប់យកដីមានតំលៃនៅជិតផ្លូវច្រកទ្វារព្រំដែន ដែលធ្វើឱ្យមានបញ្ហាការកាន់កាប់ដីធ្លីកាន់តែខ្លាំង

ជាងមុន។ នៅពេលតម្លៃដីដែលកាន់តែឡើងខ្ពស់នៅក្នុងទូទាំងប្រទេស បានធ្វើឱ្យមានជំលោះកាន់តែច្រើន និង ធ្វើឱ្យមានភាពតានតឹងកាន់តែខ្លាំងរវាងសហគមន៍ជនក្រីក្រនៅតាមទីជនបទ និង អ្នកមានទ្រព្យសម្បត្តិជាឈ្មួញដីធ្លី។ គណៈកម្មការសូរិយោដី ដែលត្រូវបង្កើតឡើងនៅក្នុងឆ្នាំ ២០០៥ ដើម្បីដោះស្រាយវិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជីកាន់កាប់ ឬ នៅកន្លែងដែលមិនទាន់បានផ្តល់លិខិតកាន់កាប់ដីធ្លីដល់ម្ចាស់ដី បានបន្តអនុវត្តការងារយ៉ាងយឺតបំផុត។ តុលាការដែលនៅក្រោមក្រសួងយុត្តិធម៌ មិនមានការទទួលខុសត្រូវចំពោះការដោះស្រាយវិវាទនៅក្នុងករណីដែលដីត្រូវបានចុះបញ្ជីហើយ ឬ ជនបង្កវិវាទត្រូវបានគេប្រគល់ប្លង់ដី។ នៅថ្ងៃទី ១៥ ខែមីនា អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លីត្រូវបានគេបង្កើតឡើងដើម្បីដោះស្រាយវិវាទដីធ្លី ប៉ុន្តែវាបានបង្ហាញឱ្យឃើញថា ការងារទាំងនេះមិនមានប្រសិទ្ធិភាពនោះឡើយ។

បញ្ហាដែលថា ប្រជាពលរដ្ឋកំពុងតែត្រូវបានគេបង្ខំឱ្យរុះរើលំនៅដ្ឋាន នៅបន្តកើតមាននៅពេលមន្ត្រីមានអំណាច ឬ អ្នកជំនួញនានា បានរួមផ្សំគំនិតគ្នាជាមួយអាជ្ញាធរមូលដ្ឋាន។ មនុស្សមួយចំនួនបានប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីធ្វើការបំភិតបំភ័យប្រជាជនក្រីក្រ និង ជនដែលងាយរងគ្រោះឱ្យពួកគេធ្វើការដោះដូរដីរបស់ពួកគេជាមួយនឹងសំណងតិចតួច។ អង្គការមិនមែនរដ្ឋាភិបាលមួយបានរាយការណ៍ថា បានទទួលពាក្យបណ្តឹងពាក់ព័ន្ធទៅនឹងដីធ្លីចំនួន ១២៤ ករណីនៅក្នុងទីក្រុងភ្នំពេញ និង ខេត្តផ្សេងទៀតចំនួន ១២ ខេត្ត ដែលផ្តល់ផលប៉ះពាល់ដល់ប្រជាពលរដ្ឋសរុបចំនួន ១៥ ២៧៤ នាក់នៅក្នុងឆ្នាំនេះ។ មានអង្គការមួយទៀតបានរាយការណ៍ថា មានករណីវិវាទដីធ្លីចំនួន ៤៦០ ករណីនៅក្នុងរយៈពេលដូចគ្នាដែលកើតឡើងដោយសារបុគ្គលនានាជាមួយអាជ្ញាធរ និង អ្នកជំនួញឯកជន។ ជនក្រីក្រមិនដែលមានឯកសារផ្លូវច្បាប់ដើម្បីធ្វើការបញ្ជាក់ពីរឿងក្តីរបស់ខ្លួនឡើយ ហើយពួកគេមានការបាត់បង់ជំនឿទុកចិត្តលើប្រព័ន្ធតុលាការ ពីព្រោះតែមានអំពើពុករលួយនៅក្នុងប្រព័ន្ធនេះ។ មានប្រជាពលរដ្ឋមួយចំនួនបានចាត់វិធានការណ៍តាមផ្លូវច្បាប់នៅក្នុងតុលាការ ប៉ុន្តែលទ្ធផលដែលពួកគេទទួលបានភាគច្រើនគឺការចាញ់ក្តី។

នៅថ្ងៃទី ៥ ខែមករា តុលាការខេត្តបានចេញបញ្ជាធ្វើការចាប់ខ្លួន និង ឃុំខ្លួនមនុស្ស ២ នាក់ដែលជាអ្នកតំណាងឱ្យប្រជាពលរដ្ឋនៅក្នុងឃុំឯករាជ្យនៅក្នុងខេត្តរតនគិរីនៅក្នុងករណីពាក់ព័ន្ធទៅនឹងគ្រួសារចំនួន ១០៨ គ្រួសារ និង បានកាន់កាប់ដីធ្លីទំហំលើសពី ៤៩៤ អែកក្រែស (acres) (ស្មើនឹង ២០០ ហិចតា)។ លោក ខេត្ត សុខខៃ ដែលអះអាងថាជាម្ចាស់ដីទំហំ ២០០ ហិចតា បានទទួលដី ១៤៨ អែកក្រែស (acres)(ស្មើនឹង ៥៩.៨៩ហិចតា)មកពីប្រជាពលរដ្ឋក្នុងឆ្នាំ ១៩៩៦ ប៉ុន្តែមិនទាន់បានអភិវឌ្ឍន៍ដីធ្លីនេះអស់រយៈពេលជាច្រើនឆ្នាំ។ នៅក្នុងឆ្នាំ ២០០៤ លោក សុខខៃ បានចាប់ផ្តើមគាស់រានដីនៅជុំវិញនោះដែលជាកន្លែងប្រជាពលរដ្ឋរស់នៅ និង កំពុងដាំដុះដំណាំ។ ប្រជាពលរដ្ឋបានធ្វើការតវ៉ា និង ដាក់ពាក្យបណ្តឹងដល់គណៈកម្មការសុរិយោដីដែលមិនបានចាត់វិធានការណ៍ណាមួយឡើយ។ នៅចុងឆ្នាំ ២០០៥ លោក សុខខៃ បានដាក់ពាក្យបណ្តឹងនៅតុលាការខេត្តរតនគិរី ដោយចោទប្រកាន់ប្រជាពលរដ្ឋ ២ រូបដែលធ្វើការរារាំងដល់ការឈូសឆាយដីរបស់គាត់។ បុរសទាំងពីររូបនេះត្រូវបានឃាត់ខ្លួន ប៉ុន្តែក្រោយមកត្រូវបានដោះលែងវិញ។ នៅដើមខែមករា តុលាការខេត្តរតនគិរីបានចាប់ប្រជាពលរដ្ឋ ២ រូបផ្សេងទៀត

ដាក់គុក ប៉ុន្តែក្រោយមកបានដោះលែងវិញដែរ។ ប្រពលរដ្ឋរស់នៅក្នុងភូមិបានឡើងទៅក្រុងភ្នំពេញ ដើម្បីសុំបទអន្តរាគមន៍ពីរដ្ឋសភា និង ការិយាល័យនាយករដ្ឋមន្ត្រី។ រដ្ឋសភាបានបញ្ជាឱ្យអាជ្ញាធរតំបន់ចាត់វិធានការណ៍ ដើម្បីដោះស្រាយបញ្ហាដោយធ្វើការគាំទ្រប្រជាពលរដ្ឋក្នុងភូមិ។ តាមសេចក្តីរាយការណ៍ អាជ្ញាធរតំបន់មិនអនុវត្តតាមបញ្ជានោះឡើយ ហើយការប៉ុនប៉ងកាន់កាប់ដីធ្លីពីអ្នកមានអំណាចនោះនៅបន្តកើតមានដដែល។ អង្គការមួយទៀតបានរាយការណ៍ថា ដីនោះក្រោយមកទៀតត្រូវបានគេផ្ទេរពីលោក សុខខៃ ទៅឱ្យឈ្មោះ ពិសិទ្ធ។ ប្រជាពលរដ្ឋចុះចាញ់ទៅនឹងការគំរាម និង ការបំភិតបំភ័យ ហើយបានយល់ព្រមទទួលទឹកប្រាក់ ៣០០០ ដុល្លារ (ស្មើនឹង ១២.៦ លានរៀល) ជាសំណង។ នៅថ្ងៃទី ៩ ខែកក្កដា តុលាការខេត្តបានចេញសាលក្រមថា ដីនេះត្រូវប្រគល់ទៅឱ្យម្ចាស់ថ្មីដែលប្រជាពលរដ្ឋបានយល់ព្រមទទួល។

នៅថ្ងៃទី ១១ ខែកុម្ភៈ មានប្រជាពលរដ្ឋប្រហែលជា ២០០ នាក់មកពីខេត្តរតនគីរី ឃុំប៉ាតែក បានមកប្រមូលផ្តុំនៅមុខសាលាឃុំដើម្បីធ្វើកាតតវ៉ាទៅនឹងការរឹបអូសយកដីធ្លីរបស់ពួកគេដែលធ្វើឡើងដោយក្រុមហ៊ុនឯកជនមួយដែលជាកម្មសិទ្ធិរបស់ប្អូនស្រីរបស់លោករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ តាមរបាយការណ៍របស់អង្គការ ប្អូនស្រីនោះបានចុះទៅកន្លែងដីនោះនៅក្នុងឆ្នាំ ២០០៤ ដើម្បីព្យាយាមទិញដីពីប្រជាពលរដ្ឋ។ ដំបូងគាត់បានប្រើការបញ្ចុះបញ្ចូល ប៉ុន្តែក្រោយមកបានប្រើការគំរាមកំហែង និង ការបំភិតបំភ័យដោយមានការជួយជ្រោមជ្រែងពីអាជ្ញាធរក្នុងតំបន់ផងដែរ។ ដោយជួបការប្រឈមមុខនឹងការបាត់បង់ដីធ្លីដោយមិនទទួលបានសំណង ឬ ទទួលបានទឹកប្រាក់តិចតួចនោះ ប្រជាពលរដ្ឋបានយល់ព្រមលក់ដីទំហំ ៥០ ហិចតា។ បន្ទាប់ពីការប្រារព្ធពិធីជប់លៀងស៊ីផឹករួចមក ប្រជាពលរដ្ឋក៏បានផ្តិតមេដៃលក់ដីនោះដែលជាដីរបស់ឃុំ។ មិនមានប្រជាពលរដ្ឋណាមួយបានអានលិខិតកិច្ចសន្យានោះឡើយ ដែលជាការពិតបានកំណត់ថា បានលក់ដីទំហំ ៥០០ ហិចតា ដែលលើសពីទំហំដី ៥០ ហិចតាដែលបានព្រមព្រៀងលក់។ ប្រជាពលរដ្ឋបានដាក់ពាក្យបណ្តឹងដើម្បីសុំជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែតុលាការខេត្តរតនគីរីមិនបានចាត់វិធានការណ៍ណាមួយឡើយ។

នៅថ្ងៃទី ៣០ ខែមីនា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើការសន្យាចែកដីចំនួន ២០០០ ហិចតាដល់កសិករគ្មានដីធ្លីចំនួន ៥០ ០០០ នាក់នៅក្នុងក្រុងព្រះសីហនុ។ លោកមានមានប្រសាសន៍ថា លោករៀបចំគំរោងដើម្បីយកដីពីអ្នកមាន និង មន្ត្រីដែលមានអំណាចដើម្បីផ្តល់ឱ្យប្រជាពលរដ្ឋក្រីក្រ និង កសិករគ្មានដីធ្លីដើម្បីធ្វើជាសម្បទានដីសង្គមកិច្ច។ ទោះជាយ៉ាងណា រហូតដល់ចុងឆ្នាំ មិនមានដីណាមួយត្រូវបានគេចែកឱ្យប្រជាពលរដ្ឋឡើយ។

នៅចុងឆ្នាំនេះ តុលាការឧទ្ធរណ៍មិនបានចាត់វិធានការណ៍ចំពោះវិវាទដីធ្លីដែលធ្វើឱ្យមានការជន្លៀសប្រជាពលរដ្ឋយ៉ាងច្រើននៅភូមកក្បាលស្ពានក្នុងខែមីនា ឆ្នាំ២០០៥ ដែលបានធ្វើឱ្យយ៉ាងហោចណាស់មនុស្ស ៥នាក់បាត់បង់ជីវិត និង រងរបួសជាច្រើននាក់ទៀត (មើលផ្នែក ១-ង.)។

រហូតដល់ចុងឆ្នាំ ក្រសួងមហាផ្ទៃនៅមិនទាន់បានចាត់វិធានការណ៍ចំពោះវិវាទដីធ្លីក្នុងឆ្នាំ ២០០៥ រវាងក្រុមជនជាតិភាគតិចព្នងក្នុងខេត្តរតនគីរី និង ក្រុមហ៊ុនចិននៅឡើយ។ នៅក្នុងខែសីហា អ្នកតំណាងជនជាតិភាគតិចបានសុំឱ្យក្រសួងមហាផ្ទៃឱ្យដាក់ខ័ណ្ឌសីម៉ាព្រំដែន និង កាត់ដីនេះឱ្យទៅសហគមន៏ជនជាតិភាគតិច។

មិនមានការអភិវឌ្ឍន៏ណាមួយចំពោះវិវាទដីធ្លីឆ្នាំ២០០៤ ដែលពាក់ព័ន្ធរវាងប្រជាពលរដ្ឋក្នុងខេត្តពោធិសាត់ និងកំពង់ឆ្នាំង ជាមួយនឹងក្រុមហ៊ុនភាពភីម៉ិច។ ទំនាស់ដីធ្លីកើតមានស្ទើរគ្រប់ទីកន្លែង ដែលភាគច្រើនប៉ះពាល់ទៅលើតែអ្នកក្រីក្រ និង ក្រុមជនជាតិភាគតិច។ លោក សុន ឆៃ ជាអ្នកតំណាងរាស្ត្រដែលនិយាយឥតសំចៃរបស់គណៈបក្សប្រឆាំង ត្រូវបានជាប់ពាក់ព័ន្ធទៅក្នុងជំលោះដីធ្លីរវាងអាជ្ញាធរអប្សរា ដែលជាភ្នាក់ងាររបស់រដ្ឋាភិបាលលើផ្ទៃដីទំហំប្រហែល ៣ ហិចតាដែលគាត់បានទិញនៅក្នុងឆ្នាំ ១៩៩០ នៅក្នុងខេត្តសៀមរាប។ ដោយការរក្សាទុកដីនេះសំរាប់រៀបចំទីក្រុងវប្បធមិ និង ទេសចរណ៏ អាជ្ញាធរអប្បរាបានដាក់ពាក្យបណ្តឹងទៅតុលាការខេត្តសៀមរាបដោយទាមទារឱ្យអ្នកតំណាងរាស្ត្ររូបនេះគោរពតាមបញ្ញាច្បាប់ឱ្យលក់ដីរបស់គាត់ក្នុងតំលៃប្រហែលជា ២០ ០០០ ដុល្លារ (ប្រហែល ៨៤ លានរៀល)។ លោកតំណាងរាស្ត្របានទាមទារតាមតំលៃទីផ្សារដីដែលមានតំលៃខ្ពស់ជាង និង បានស្នើសុំឱ្យអាជ្ញាធរអប្សរាបង្ហាញថា ដីនេះនឹងត្រូវប្រើប្រាស់សំរាប់ប្រយោជន៏សាធារណៈ។ នៅថ្ងៃទី ១៨ ខែធ្នូ តុលាការខេត្តសៀមរាបបានបើកសវនាការគាំទ្រចំពោះអាជ្ញាធរអប្សរា ហើយបានចេញបញ្ជាឱ្យ លោក សុនឆៃ លក់ដីនោះតាមតំលៃកំណត់ដោយបទបញ្ជាច្បាប់។ នៅចុងឆ្នាំ លោកតំណាងរាស្ត្របានធ្វើគំរោងប្តឹងឧទ្ធរណ៏បន្តទៀត។

ការបង្ខំឱ្យប្រជាពលរដ្ឋឱ្យរុះរើលំនៅដ្ឋាន បានកើតមានឡើងជាញឹកញាប់នៅក្នុងក្រុងភ្នំពេញ ហើយវិវាទដីធ្លី និង ការរុះរើលំនៅដ្ឋាននេះ បានក្លាយទៅជាអំពើហិង្សា។ នៅក្នុងឆ្នាំនេះ អង្គការក្នុងស្រុកបានរាយការណ៏ថាមានការចាប់ខ្លួន ឬ ការចោទប្រកាន់មនុស្សចំនួន ១២៦ នាក់ ពាក់ព័ន្ធទៅនឹងការរឹបអូសយកដីធ្លី ឬ ការបញ្ជាឱ្យរុះរើលំនៅដ្ឋាន។ នៅក្នុងករណីទាំងនេះ ប្រជាពលរដ្ឋចំនួន ១១៧ នាក់ត្រូវបានដោះលែង និង ៩ នាក់ត្រូវបានដាក់ឃុំឃាំង។

នៅក្នុងការបង្ខំប្រជាពលរដ្ឋឱ្យរុះរើលំនៅដ្ឋាននៅសហគមន៏សំបុកចាបសង្កាត់ទន្លេបាសាក់ក្នុងខែមិថុនាមានប្រជាពលរដ្ឋចំនួន ១ ២០០ គ្រួសារត្រូវបានគេផ្លាស់ទីទៅទីតាំងថ្មីចំងាយប្រហែលជា ២០ គីឡូម៉ែត្រពីទីក្រុងភ្នំពេញ។ មានមនុស្ស ៣ នាក់ ក្នុងនោះមានអ្នកសារព័ត៌មាន១រូបដែរដែលចូលរួមនៅក្នុងការតវ៉ា ត្រូវបានឃាត់ខ្លួន និង ចោទប្រកាន់ពីបទញុសញង់ និង ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ។ ក្រុម ១ ទៀតដែលមានចំនួនប្រហែល ២០០ គ្រួសារនៅក្នុងតំបន់នោះ ក៏ត្រូវបានគេចាត់ជាគោលដៅធ្វើការរុះរើលំនៅដ្ឋានផងដែរ។

នៅក្នុងការរុះរើលំនៅដ្ឋានរបស់ប្រជាពលរដ្ឋនៅភូមិសំបុកចាប អាជ្ញាធរមូលដ្ឋានបានធ្វើឱ្យរបួសកុមារីអាយុ១១ឆ្នាំម្នាក់ និង ស្ត្រីមានផ្ទៃពោះម្នាក់ ក្នុងពេលធ្វើការបំផ្លាញតង់ជំរករបស់ពួកគេ។ អ្នកភូមិដែលមានកំហឹងបានធ្វើកុប្បកម្មតបត ហើយបានបំផ្លាញចោលការិយាល័យរបស់មេភូមិ និង ព្យាយាមប៉ុនប៉ងសំលាប់មន្ត្រីសន្តិសុខដែលបង្កឱ្យមានរបួសស្នាមដល់ប្រជាពលរដ្ឋ។ មានបុគ្គលចំនួន ៤ រូប ដែលក្នុងនោះមានអ្នកសារព័ត៌មាន ១រូបត្រូវ

បានឃាត់ខ្លួន និង ចោទប្រកាន់ពីបទធ្វើការញុះញង់ និង បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ។ នៅថ្ងៃទី ៣០ ខែវិច្ឆិកា តុលាការក្រុងភ្នំពេញបានកាត់ទោសអ្នកសារព័ត៌មាន និង បុរស ២ រូបទៀតឱ្យជាប់ពន្ធនាគាររយៈពេល ២ ឆ្នាំពីបទបំផ្លាញទ្រព្យសម្បត្តិសាធារណៈ។ មេធាវីការពារក្តីបានហៅការចេញសាលក្រមនោះថា អយុត្តិធម៌ និង និយាយថា គាត់នឹងដាក់ពាក្យបណ្តឹងឧទ្ធរណ៍។

នៅដើមខែមិថុនា អ្នករស់នៅក្នុងតំបន់អនាធិបតេយ្យចំនួនប្រហែល ២០០០ នាក់ បានធ្វើការប្រឈមមុខជាមួយប៉ូលីសដែលបានព្យាយាមបង្ខំឱ្យពួកគេឱ្យចាកចេញពីដីរបស់រដ្ឋាភិបាលនៅក្នុងខេត្តកំពត។ ការប្រឈមមុខបានធ្វើឱ្យមានការបំផ្លិចបំផ្លាញស្ពានឈើមួយ ដែលភ្ជាប់ដែនដីមានវិវាទទៅនឹងផ្លូវតែមួយគត់ទៅកាន់ទីរួមខេត្ត។ អ្នករស់នៅក្នុងតំបន់អនាធិបតេយ្យដែលជាប្រជាពលរដ្ឋមកពីខេត្តផ្សេងៗ បានប្រមូលផ្តុំគ្នាស្នាក់ផ្លូវស្រុកឈ្លូកដើម្បីធ្វើការតវ៉ា ដោយសង្ឃឹមថា នឹងអាចលក់ដីនេះនៅពេលក្រោយដើម្បីបានប្រាក់កំរៃ។ មានមនុស្សចំនួន ៦ នាក់ត្រូវបានឃាត់ខ្លួនចំពោះការញុះញង់ប្រជាពលរដ្ឋឱ្យចាប់យកដីនៅក្នុងតំបន់នោះ។ មនុស្សម្នាក់ទៀតត្រូវបានឃាត់ខ្លួននៅថ្ងៃក្រោយមកទៀត ចំពោះការពាក់ព័ន្ធទៅនឹងរឿងក្តីនេះ ហើយតុលាការបានព្យាយាមធ្វើការឃាត់ខ្លួនមនុស្ស ៥នាក់ទៀត។ នៅថ្ងៃទី២៨ ខែវិច្ឆិកា តុលាការខេត្តកំពតបានកាត់ទោសមនុស្សចំនួន ១២នាក់ ក្នុងនោះមាន ៥នាក់ត្រូវបានកាត់ទោសដោយកំបាំងមុខ ហើយបានកាត់ទោសមនុស្ស ៣នាក់ក្នុងចំណោមពួកគេឱ្យជាប់ទោសរយៈពេល៨ឆ្នាំ និង អ្នកផ្សេងៗទៀតឱ្យជាប់ទោសរយៈពេល ៦ ឆ្នាំ ពីបទល្មើសកាប់បំផ្លាញព្រៃឈើ និង កាន់កាប់ដីធ្លីរបស់រដ្ឋ។ អង្គការដែលឈរជាតំណាងដល់ប្រជាពលរដ្ឋបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍បន្ត។

នៅថ្ងៃទី ៥ ខែកក្កដា ក្រសួងមហាផ្ទៃបានបង្ខំឱ្យប្រជាពលរដ្ឋចំនួនច្រើនជាង ១៦៨ គ្រួសារដែលរស់នៅក្នុងតំបន់មន្ទីរពេទ្យព្រះមុនីវង្សក្នុងក្រុងភ្នំពេញឱ្យធ្វើការរើលំនៅដ្ឋាន។ មានស្ត្រីម្នាក់បានរងរបួសនៅពេលមានការប៉ះទង្គិចគ្នាជាមួយប៉ូលីស។ ប្រជាពលរដ្ឋភាគច្រើនដែលមានមួយចំនួនជាមន្ត្រីរបស់រដ្ឋាភិបាល បានរស់នៅក្នុងតំបន់នោះចាប់តាំងពីឆ្នាំ ១៩៨៨ មកម្លេះ។ គ្រួសាររបស់ប៉ូលីសបានទទួលទឹកប្រាក់ ១៣០០ ដុល្លារ (ស្មើនឹង ៥.៤៦លានរៀល) ចំពោះការដោះដូរទីតាំង ចំណែកអ្នកផ្សេងទៀតទទួលបានត្រឹមតែ៥០០ ដុល្លារ (២.១លានរៀល) ប៉ុណ្ណោះ។ លើសពីការសងជម្ងឺចិត្តជាទឹកប្រាក់ គ្រួសារដែលផ្លាស់ទីជំរកនីមួយៗទទួលបានដី ១ ប្លង់តូចដែលមានចំងាយប្រហែល ២២ ម៉ាយពីក្រុងភ្នំពេញ។ មានការខ្វះខាតលើផ្នែកហេដ្ឋារចនាសម្ព័ន្ធដូចជា ទឹក ភ្លើងអគ្គិសនី សាលារៀន មន្ទីរពេទ្យ និង ផ្សារនៅកន្លែងសំណង់ថ្មីនោះ។

នៅដើមឆ្នាំ គ្រួសារចំនួន ៣ ដែលនៅបន្តរស់នៅលើភូមិកោះពេជ្រ ដែលជាកោះតូចមួយនៅក្នុងទន្លេបាសាក់ បានយល់ព្រមធ្វើការផ្លាស់ទីជំរកដោយទទួលយកការសងជាទឹកប្រាក់ចំនួន ១២ ដុល្លារ/ម² (ស្មើនឹង ៥០ ៤០០ រៀល)។ គ្រួសារចំនួន ២ ចុងក្រោយបានទាមទាយកតម្លៃតាមទីផ្សារ ២៥ ដុល្លារ/ម² (ស្មើនឹង ១០៥ ០០០ រៀល)។ នៅក្នុងខែសីហា តុលាការក្រុងភ្នំពេញបានចេញបញ្ជាឱ្យគ្រួសារទាំងនេះទទួលយកតម្លៃតាមការផ្តល់ឱ្យរបស់មន្ត្រីសាលាក្រុង។ គ្រួសារទាំងនោះបានបដិសេធ និង ព្យាយាមដាក់ពាក្យបណ្តឹងបន្តទៅតុលាការឧទ្ធរណ៍។ រហូតមកដល់ចុងឆ្នាំ តុលាការឧទ្ធរណ៍មិនបានចាត់វិធានការណ៍ចំពោះករណីនោះនៅឡើយទេ។

នៅថ្ងៃទី ៧ ខែសីហា មានប្រជាពលរដ្ឋច្រើនជាង ២០០នាក់មកពីស្រុកអង្គស្នួលខេត្តកណ្ដាល បានប៉ះទង្គិចគ្នាជាមួយប៉ូលីសដែលព្យាយាមធ្វើការរារាំងពួកគេមិនឱ្យចូលមកទីក្រុង ដើម្បីធ្វើការតវ៉ាលើជំលោះដីធ្លីសហគមន៍របស់ពួកគេ។ មានមនុស្សប្រហែល ៣០ នាក់ត្រូវបានរងរបួស ដែលក្នុងនោះមានមនុស្សមួយចំនួនត្រូវការការព្យាបាលផ្នែកវេជ្ជសាស្ត្រចំពោះការរងរបួសរបស់ពួកគេ។ តាមសេចក្តីរាយការណ៍ ប៉ូលីសបានប្រើប្រាស់ផ្សែងបង្ហូរទឹកភ្នែក និង ដំបងឆក់ និង បាញ់រះឡើងលើដើម្បីបញ្ឈប់ក្រុមប្រជាពលរដ្ឋ។

ជំលោះដីធ្លីចំនួន ២ កន្លែងនៅស្រុកពាមជរ ខេត្តព្រៃវែង បានធ្វើឱ្យមនុស្សម្នាក់ស្លាប់បាត់បង់ជីវិត និង រងរបួសមនុស្សចំនួន ៤ នាក់ផ្សេងទៀត។ ជំលោះទីមួយគឺពាក់ព័ន្ធទៅនឹងដីទំហំប្រហែល ៤៨ ហិចតាដែលមានការប៉ះពាល់ដល់គ្រួសារចំនួន ៥៣គ្រួសារ។ នៅថ្ងៃទី ១៤ ខែធ្នូ នៅក្នុងពេលធ្វើការតវ៉ារបស់អ្នកភូមិប្រឆាំងទៅនឹងការរឹបអូសយកដីធ្លីរបស់ពួកគេ មន្ត្រីក្នុងមូលដ្ឋានបានបាញ់គ្រាប់កាំភ្លើង និង ធ្វើឱ្យស្លាប់ក្មេងប្រុសអាយុ ១៧ ឆ្នាំម្នាក់។ ប៉ូលីសមិនបានឃាត់ខ្លួនអ្នកដែលទទួលខុសត្រូវចំពោះការបាញ់សំលាប់នោះទេ ផ្ទុយទៅវិញតុលាការខេត្តបានចោទប្រកាន់ប្រជាពលរដ្ឋចំនួន ៨ នាក់ដែលជាប់ពាក់ព័ន្ធទៅនឹងជំលោះ ពីបទប្លន់ទ្រព្យសម្បត្តិទៅវិញ។ នៅថ្ងៃទី ៥ ខែធ្នូ អាជ្ញាធរក្នុងស្រុកបានធ្វើឱ្យរងរបួសអ្នកភូមិ ២ នាក់នៅលើជំលោះដដែលនោះ។ នៅថ្ងៃទី ២៦ ខែធ្នូ នៅក្នុងជំលោះមួយដាច់ដោយឡែក មន្ត្រីប៉ូលីសបានបាញ់អ្នកភូមិ ២នាក់។ តាមសេចក្តីរាយការណ៍ ជនល្មើសបានរត់គេចខ្លួនបាត់។

វិវាទដីធ្លីដែលធ្វើឱ្យមានការចាប់អារម្មណ៍ខ្លាំងមួយទៀត បានកើតមាននៅក្នុងខេត្តកោះកុង ដែលបង្កឱ្យមានការស្លាប់មនុស្សម្នាក់ដោយមិនដឹងមូលហេតុច្បាស់លាស់ និង របួសស្ត្រីម្នាក់។ នៅក្នុងខែសីហា មានគ្រួសារចំនួន ៤០០ គ្រួសារ នៅស្រុកស្រែអំបិល ខេត្តកោះកុង បានធ្វើការតវ៉ាជាមួយការផ្ដល់ដីសម្បទាន២កន្លែងនៅជាប់គ្នារបស់ក្រសួងកសិកម្មដែលមានទំហំ ១០ ០០០ ហិចតា ទៅឱ្យក្រុមហ៊ុនដែលជាកម្មសិទ្ធិរបស់អ្នកជំនួញ និង ជាសមាជិកព្រឹទ្ធសភាគណបក្សប្រជាជនកម្ពុជា លោក លី យ៉ុងផាត។ យោងទៅតាមច្បាប់ ការសម្បទានដីអតិបរិមាមិនអាចលើសពី ១០ ០០០ ហិចតាឡើយ។ នៅពេលក្រុមហ៊ុនបានចាប់ផ្តើមឈូសឆាយដីសំរាប់ដាំដើមអំពៅ វាបានធ្វើឱ្យមានការប៉ះពាល់ដល់ដំណាំ និង ដីចំការរបស់អ្នកភូមិ ហើយអ្នកភូមិទាំងនោះបានធ្វើការតវ៉ាដោយធ្វើការទាមទារឱ្យក្រុមហ៊ុនផ្អាកការឈូសឆាយ និង ធ្វើការចចារពីការផ្តល់សំណងឱ្យបានសមស្រប។ ក្រុមហ៊ុនបានយល់ព្រមធ្វើការផ្តល់សំណងតែចំពោះអ្នកភូមិដែលមានលិខិតកាន់កាប់ដីធ្លីស្របច្បាប់ និង បានបង្ខំប្រជាពលរដ្ឋមួយចំនួនឱ្យទទួលយកសំណងតិចតួចដែលមានតំលៃពី ៣៥ ដុល្លា ទៅ ៧១ ដុល្លារ (ពី ១៥០ ០០០រៀលទៅ ៣០០ ០០០ រៀល)។ អង្គការក្រៅរដ្ឋាភិបាលមួយបានបញ្ជាក់ថា ទោះបីជាអ្នកភូមិជាច្រើនមិនមានលិខិតកាន់កាប់ដីស្របច្បាប់ក៏ដោយ ពួកគេបានរស់នៅទីនោះតាំងពីការដួលរលំរបបខ្មែរក្រហមមកម្លេះ ដែលតាមច្បាប់ អាចឱ្យពួកគេមានសិទ្ធិកាន់កាប់ដីធ្លីនោះបាន។ នៅថ្ងៃទី ១៥ ខែធ្នូ អ្នកភូមិម្នាក់ដែលមានភាពសកម្មនៅក្នុងការតវ៉ា ត្រូវបានគេប្រទះឃើញដេកស្លាប់ដោយមានស្នាមកាប់នឹងពូថៅ។ ប៉ូលីសនិយាយថា ការស្លាប់នេះមិនមានជាប់ពាក់ព័ន្ធទៅនឹងជំលោះដីធ្លីនោះឡើយ។ នៅក្នុងខែកញ្ញា សន្តិសុខយាមដី និង ប៉ូលីសបានបាញ់ស្ត្រីម្នាក់ត្រូវរបួសជើងនៅក្នុងពេលពួកគេធ្វើការតវ៉ាជាមួយអ្នកភូមិផ្សេងទៀត។

## ផ្នែកទី ២ : ការគោរពសិទ្ធិសេរីភាពជនស៊ីវិល ដែលរួចមាន :

### ក- សេរីភាពក្នុងការបញ្ចេញមតិ និង សារព័ត៌មាន

រដ្ឋធម្មនុញ្ញបានផ្តល់ឱ្យមានសេរីភាពក្នុងការបញ្ចេញមតិ និង សារព័ត៌មាន។ តែទោះជាយ៉ាងណាក៏ដោយ សិទ្ធិទាំងនេះ ជានិច្ចកាលមិនត្រូវបានគេគោរពឡើយ។ រដ្ឋាភិបាលប្រើប្រាស់ប្រព័ន្ធតុលាការដែលមានភាពទន់ខ្សោយ និង មានលក្ខណៈលំអៀងផ្នែកនយោបាយ ដើម្បីធ្វើការប្តឹងពីបទបរិហារកេរ្តិ៍ និង ការផ្តល់ព័ត៌មានមិនពិត ដើម្បីធ្វើការបំភិតបំភ័យ និង បំបិតសំលេងអ្នករិះគន់រដ្ឋាភិបាល និង អ្នកដឹកនាំសង្គមស៊ីវិលដែលនិយាយឥតមានការលាក់លៀមនោះ។ អ្នកសារព័ត៌មាន និង ចាងហ្វាងការផ្សាយភាគច្រើនបានសារភាពជាសំងាត់ថា មានការកំរិតការផ្សាយដោយមានការភ័យខ្លាចការវាយបករបស់រដ្ឋាភិបាល។ រដ្ឋធម្មនុញ្ញបានដាក់កំរិតសេរីភាពក្នុងការបញ្ចេញមតិដោយកំរិតតំរូវការថា ការផ្សព្វផ្សាយមិនឱ្យមានការប៉ះពាល់សន្តិសុខសាធារណៈខ្លាំងនោះឡើយ។ រដ្ឋធម្មនុញ្ញក៏បានប្រកាសថា ព្រះមហាក្សត្រ គឺជាអង្គ "ដែលមិនអាចប៉ះពាល់បានឡើយ"។

នៅថ្ងៃទី ១៧ ខែមករា រដ្ឋាភិបាលបានដោះលែងជាបណ្តោះអាសន្នចំពោះជនជាប់ឃុំ ៤ នាក់ដែលត្រូវបានឃាត់ខ្លួនពីបទបរិហារកេរ្តិ៍ : អ្នកសារព័ត៌មាន និង ជាស្ថាបនិកវិទ្យុអេហ្វអឹម ១០៥ លោកម៉ម សូណង់ដូ អ្នកដឹកនាំសមាគមគ្រូបង្រៀនឯករាជ្យ លោក រ៉ុង ឈុន ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក កឹម សុខា និង មន្ត្រីមជ្ឈមណ្ឌលសិទ្ធិមនុស្សលោក ប៉ា ងួនទៀង (មើលផ្នែក១-ឃ.)។ នៅពេលដែលការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ចំពោះជនទាំងនេះនៅមិនទាន់ត្រូវបានដកជាផ្លូវការ ឬ ចំពោះជនផ្សេងទៀតដែលបានរត់គេចចេញពីប្រទេសដើម្បីគេចពីការចាប់ខ្លួនពីបទបរិហាកេរ្តិ៍-- ដែលក្នុងនោះមានអ្នកនយោបាយរាជានិយម ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធមិកោ និង សមាជិកក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា លោក ម៉ែន ណាត លោកអៀ ចាន់ណា និង លោក ជា មន្នី-- រដ្ឋាភិបាលមិនបានបន្តការកាត់ទោសនោះឡើយ។

នៅក្នុងខែសីហា អាជ្ញាធររបស់រដ្ឋាភិបាលនៅក្នុងខេត្តបាត់ដំបងបានរឹបអូសយកកាសែតវីដេអូឌីឃីថលដែលមានរូបភាពពីការរៀបចំការក្លែងបន្លំរបស់មន្ត្រីប៉ូលីសថា អ្នកទោសទាំង ៩ នាក់បានធ្វើអត្តឃាតខ្លួនឯង និង ចំណាប់ខ្មាំងដោយមានគ្រាប់បែកដៃនៅក្នុងការប្រទូសសារាយគ្នាដែលមិនអាចចចារបានក្នុងខែមិថុនា ប៉ុន្តែ ឌីវីឌីនោះនៅតែអាចរកបាននៅក្នុងទីក្រុងភ្នំពេញ និងក្នុងកន្លែងផ្សេងៗទៀតនៅក្នុងប្រទេស (សូមមើលផ្នែក ១-ក.)។ អ្នកនាំពាក្យរបស់ក្រសួងមហាផ្ទៃបានបញ្ជាក់ថា ក្រសួងសង្ឃឹមថា នឹងធ្វើការចាប់ខ្លួនអ្នកផលិតខ្សែភាពយន្តនោះ និង កាត់ទោសជននោះចំពោះការបង្កបញ្ហាដល់សន្តិសុខជាតិ ប៉ុន្តែរហូតមកដល់ចុងឆ្នាំ មិនមានការចាប់ខ្លួនជនណាមួយត្រូវបានធ្វើឡើងនោះឡើយ។

នៅចុងខែសីហា រដ្ឋសភាជាតិបានអនុម័តច្បាប់មួយដែលមានមនុស្សជាច្រើនបានបកស្រាយថា ជាការកំរិតសិទ្ធិរបស់សមាជិសភាក្នុងការបញ្ចេញមតិដោយសេរី។ ច្បាប់ថ្មីនេះចែងថា សមាជិកសភាមិនអាចប្រើអភ័យឯកសិទ្ធិរបស់ខ្លួនដើម្បីបង្កអសន្តិសុខជាតិ រំលោភលើច្បាប់ទម្លាប់សង្គម ឬ កិត្តិយសរបស់បុគ្គលឡើយ។ លើសពីនេះ

ច្បាប់អនុញ្ញាតឱ្យមានការចាប់ខ្លួន ការចោទប្រកាន់ និង ការឃុំខ្លួនសមាជិកសភាមុនពេលដកអភ័យឯកសិទ្ធិផងដែរ។ រហូតមកដល់ចុងឆ្នាំ មិនមានសមាជិកសភាណាមួយត្រូវបានគេចោទប្រកាន់ក្រោមច្បាប់ថ្មីនេះឡើយ។

នៅឆ្នាំ ១៩៩៥ ច្បាប់សារព័ត៌មានផ្តល់សិទ្ធិឱ្យអ្នកសារព័ត៌មាននូវសិទ្ធិជាច្រើន ដោយគិតរួមទាំងសេរីភាពចំពោះការបោះពុម្ពផ្សាយ និង ការការពារមិនឱ្យមានការដាក់ទោសចំពោះការបញ្ចេញមតិយោបល់របស់ខ្លួន។ ទោះជាយ៉ាងណា រដ្ឋាភិបាលបន្តប្រើប្រាស់ច្បាប់អន្តរកាលរបស់អ៊ុនតាក់ ដើម្បីធ្វើការដាក់ទោសចំពោះអ្នកសារព័ត៌មាន និងជនផ្សេងៗលើការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ជាបទឧក្រិដ្ឋ ច្រើនជាងការប្រើប្រាស់ច្បាប់សារព័ត៌មានឆ្នាំ១៩៩៥ ដែលចាត់ទុកថា ការបរិហារកេរ្តិ៍ជាបទល្មើសរដ្ឋប្បវេណី។ នៅក្នុងខែមីនា រដ្ឋសភាបានធ្វើវិសោធនកម្មច្បាប់អន្តរកាលរបស់អ៊ុនតាក់ ដោយបានដកចេញនូវការដាក់ទោសឱ្យជាប់ពន្ធនាគារជាការពិន័យចំពោះបទបរិហារកេរ្តិ៍ ប៉ុន្តែចៅក្រមនៅតែអាចបញ្ជាឱ្យមានការបង់ប្រាក់ពិន័យយ៉ាងច្រើន ដែលប្រជាពលរដ្ឋជាច្រើនមិនអាចរកមកបង់បាន។ លើសពីនេះទៀត មាត្រាទី ៦២ នៃច្បាប់អ៊ុនតាក់ ដែលចាត់ទុកថា ជាបទឧក្រិដ្ឋលើការផ្តល់ព័ត៌មានមិនពិត នៅបន្តដាក់ជាទោសជាប់ពន្ធនាគារដែលមានរយៈពេលរហូតដល់ ៣ ឆ្នាំ។

រដ្ឋាភិបាល និង បុគ្គលមានអំណាច ប្រើប្រាស់បណ្តឹងបទបរិហារកេរ្តិ៍ជាបទរដ្ឋប្បវេណី និង ឧក្រិដ្ឋ ក៏ដូចជាការចោទប្រកាន់ពីការផ្តល់ព័ត៌មានមិនពិតក្នុងគោលបំណងដើម្បីបំបាត់សំលេងអ្នករិះគន់។ នៅក្នុងខែមិថុនា ក្មួយប្រុសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺលោក ហ៊ុន តូ បានដាក់ពាក្យបណ្តឹងពីបទបរិហារកេរ្តិ៍ចំពោះ លោក យូ សារ៉ាវុធ ដែលជាសហចាងហ្វាងការផ្សាយរបស់ការសែតប្រឆាំងឈ្មោះ ស្រទ្បាញ់ខ្មែរ ចំពោះការចោទប្រកាន់ថា លោក ហ៊ុន តូ មានការជាប់ពាក់ព័ន្ធទៅនឹងការរឹបអូសយកដីធ្លីខុសច្បាប់។ នៅក្នុងខែកក្កដា មន្ត្រីជាន់ខ្ពស់របស់គណបក្សហ្វ៊ុនស៊ិនប៉ិចព្រះអង្គម្ចាស់ចក្រពង្ស បានដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីបទបរិហារកេរ្តិ៍ចំពោះសារព័ត៌មានដដែលនេះចំពោះការសរសេររបាយការណ៍ពីសកម្មភាពរបស់ព្រះអង្គនៅក្នុងដើមទសវត្សឆ្នាំ ១៩៩០។ នៅក្នុងខែកញ្ញា ចាង ហ្វាងការផ្សាយរបស់សារព័ត៌មានប្រឆាំង មនះសិការខ្មែរ ត្រូវបានកាត់ទោសកំបាំងមុខចំពោះការផ្តល់ព័ត៌មានមិនពិត ដែលការសែតនេះបានចោទប្រកាន់លោកឧបនាយករដ្ឋមន្ត្រី សុខ អាន ថា បានប្រព្រឹត្តអំពើពុករលួយ និង ត្រូវបានតុលាការចេញបញ្ជាឱ្យសងជម្ងឺចិត្តដល់លោកឧបនាយករដ្ឋមន្ត្រី សុខ អាន ចំនួន ២ ៥០០ ដុល្លារ (ស្មើនឹង ១០,៥ លានរៀល) និង ការផាកពិន័យជាទឹកប្រាក់ចំនួន ២ ០០០ ដុល្លារ (ស្មើនឹង ៨,៤ លានរៀល)។ នៅក្នុងខែកញ្ញានេះដែរ លោក Julio Jeldres ជាអ្នកសរសេរជីវប្រវត្តិរបស់សម្តេចនរោត្តមសីហនុដែលបានចូលនិវត្តន៍ ត្រូវបានកាត់ទោសកំបាំងមុខចំពោះការបរិហារកេរ្តិ៍លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងសារអេឡិចត្រូនិចឯកជនមួយ ដែលត្រូវបានយកមកផ្សព្វផ្សាយជាសាធារណៈដោយសារព័ត៌មានក្នុងស្រុក។ លោក Jeldres ត្រូវបានបញ្ជាឱ្យបង់ប្រាក់ប្រហែល ២ ០០០ ដុល្លារ (ស្មើនឹង ៨,៤ លានរៀល) ជាការផាកពិន័យ និង ២ ៥០០ ដុល្លារ (ស្មើនឹង ១០,៥ លានរៀល) ជាទឹកប្រាក់សងជម្ងឺចិត្តចំពោះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។

អ្នកសារព័ត៌មានងាយរងការយាយី និង ការបំភិតបំភ័យក្នុងទំរង់មួយបែបទៀត ដែលក្នុងនោះមានការគំរាមកំហែងដល់អាយុជីវិតផងដែរ។ នៅក្នុងករណីបទបរិហារកេរ្តិ៍ពាក់ព័ន្ធជាមួយលោក ហ៊ុន តូ និង យូ សារាវុធ

លោកយូ បានដាក់ពាក្យបណ្ដឹងតបវិញចំពោះលោក ហ៊ុន តូ ចំពោះការគំរាមកំហែងអាយុជីវិតរបស់គាត់ និង បន្ទាប់មកបានភៀសខ្លួនចេញទៅប្រទេសទី ៣ តាមការផ្ដល់សិទ្ធិជ្រកកោនពីឧត្តមស្នងការជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ។ នៅក្នុងខែកញ្ញា អ្នកសារព័ត៌មានប្រចាំទូរទស្សន៍ លោក សយ សុភាព ទទួលបានការគំរាមកំហែងអាយុជីវិតអាណាមិកភាព បន្ទាប់ពីលោកនាយករដ្ឋមន្ត្រីរិះគន់កម្មវិធីទូរទស្សន៍ដ៏មានប្រជាប្រិយភាពរបស់លោក គឺ "កម្មវិធីអានលិខិតសារព័ត៌មាន" ហើយអ្នកគ្រប់គ្រងស្ថានីយ៍បានដកកម្មវិធីចេញពីការផ្សាយ។ នៅក្នុងខែមិថុនា អ្នកសារព័ត៌មានសំរែកយុត្តិធម៌ ត្រូវបានឃុំខ្លួន និង ចោទប្រកាន់ពីការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន និង ទ្រព្យសម្បត្តិសាធារណៈ។ តាមសំបុត្រថ្ងៃទី១៤ ខែសីហា ជូនសម្ដេចនរោត្តមសីហមុនី លោកនាយករដ្ឋមន្ត្រីបានបដិសេធមិនព្រមដោះលែងអ្នកសារព័ត៌មាននោះឡើយ ដោយអះអាងថា អ្នកសារព័ត៌មានរូបនោះបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ដោយបានធ្វើឱ្យមានរបួសស្នាមដល់ប៉ូលីស និង ញុះញង់ឱ្យមានការដុតបំផ្លាញការិយាល័យភូមិក្នុងអំឡុងពេលធ្វើការបង្ខំឱ្យប្រជាពលរដ្ឋរុះរើលំនៅដ្ឋានពីតំបន់ទន្លេបាសាក់(មើលផ្នែក១-ច.)។ នៅមានឧទាហរណ៍ជាច្រើនទៀតដែលមន្ត្រីរដ្ឋាភិបាលបានរឹបអូសយកហ្វីល និង ម៉ាស៊ីនថតពីអ្នកសារព័ត៌មាន ឬ លុបចោលរូបភាពឌីជីថលដែលជាញឹកញាប់មានការពាក់ព័ន្ធទៅនឹងការដឹកឈើខុសច្បាប់ ឬ ការបង្ខំឱ្យប្រជាពលរដ្ឋរុះរើលំនៅដ្ឋាន។

គណបក្សនយោបាយធំៗទាំងអស់ អាចមានសិទ្ធិប្រើប្រាស់សារព័ត៌មានបោះពុម្ពផ្សាយជាអត្ថបទ។ ទោះបីជាច្បាប់សារព័ត៌មានមិនបានចែងច្បាស់លាស់ ដែលអនុញ្ញាតឱ្យសារព័ត៌មានទទួលជំនួយការគាំទ្រផ្នែកហិរញ្ញវត្ថុពីគណបក្សនយោបាយក៏ដោយ ជាទូទៅសារព័ត៌មានតែងតែមានការពាក់ព័ន្ធទៅនឹងផ្នែកនយោបាយ។ សារព័ត៌មានធំៗដែលបោះពុម្ពផ្សាយជាភាសាខ្មែរ ទទួលបានការគាំទ្រពីគណបក្សនយោបាយផ្សេងៗ។ មានការប៉ាន់ស្មានថាមានសារព័ត៌មានបោះពុម្ពផ្សាយជាភាសាខ្មែរប្រមាណ ២០ សារព័ត៌មាន បានចេញផ្សាយជាប្រចាំ។ មានចំនួនច្រើនជាងពាក់កណ្ដាលមានការគាំទ្រចំពោះគណបក្សប្រជាជនកម្ពុជា និង យ៉ាងហោចណាស់មានសារព័ត៌មានចំនួន ២ ដែលគេគិតថា មានការគាំទ្រចំពោះគណបក្សនយោបាយធំៗផ្សេងទៀត -- គណបក្សហ៊្វុនស៊ិប៉ិច គណបក្សសមរង្ស៊ី និង គណៈបក្សនរោត្តមនរណឫទ្ធិ។ ទោះជាសារព័ត៌មានធំៗជាងគេចំនួន ៣ ធ្វើចរាចរគាំទ្រគណ បក្សប្រជាជនកម្ពុជាក៏ដោយ មានសារព័ត៌មានជាច្រើនធ្វើការរិះគន់រដ្ឋាភិបាលជាញឹកញាប់ ជាពិសេសពាក់ព័ន្ធទៅនឹងអំពើពុករលួយ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និង អតីតប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ព្រះអង្គម្ចាស់ នរោត្តមនរណឫទ្ធិ តែងតែទទួលការវាយប្រហារជាញឹកញាប់ពីសារព័ត៌មានប្រឆាំង។

រដ្ឋាភិបាល កងកំលាំងយោធា និង គណបក្សកាន់អំណាចនៅបន្តធ្វើការគ្រប់គ្រងលើប្រព័ន្ធផ្សព្វផ្សាយ និង ប្រើឥទ្ធិពលលើខ្លឹមសារការផ្សាយនានា។ មានស្ថានីយ៍ទូរទស្សន៍ចំនួន ៧ ស្ថានីយ៍ ដែលស្ថានីយ៍ទាំងអស់គ្រប់គ្រង ឬ ទទួលឥទ្ធិពលខ្លាំងពីគណបក្សប្រជាជនកម្ពុជា។ យោងតាមរបាយការណ៍ឆ្នាំ ២០០១ របស់ឧត្តមស្នងការសិទ្ធិមនុស្ស (UNHCHR) នីតិវិធីសំរាប់ផ្ដល់អាជ្ញាប័ណ្ណ និង ការបែងចែកចេញប្រេកង់វិទ្យុ និង ទូរទស្សន៍ គឺមានភាពលំអៀង។ ចាប់តាំងពីឆ្នាំ ២០០៣ មក ក្រសួងព័ត៌មានបានបដិសេធមិនផ្ដល់ឱ្យអាជ្ញាប័ណ្ណសំរាប់ការផ្សព្វផ្សាយថ្មីណាមួយនៅក្នុងទីក្រុងភ្នំពេញឡើយ ដោយអះអាងថា ទីផ្សារប្រព័ន្ធផ្សព្វផ្សាយពេញអស់ទៅហើយ។ គោលការណ៍នេះបានធ្វើ

ឱ្យមានការប៉ះពាល់ដល់គណបក្សសមរង្ស៊ី និង ក្រុមធ្វើការតស៊ូមតិឯករាជ្យដើម្បីទាមទារសិទ្ធិមនុស្សដែលមាននិន្នាការស្របជាមួយគណបក្សប្រឆាំង ក្នុងការដាក់ពាក្យសុំបើក ស្ថានីយ៍វិទ្យុ និង ទូរទស្សន៍ថ្មី។ ទោះជាយ៉ាងណានៅក្នុងខែកញ្ញា ក្រសួងព័ត៌មាន និង អង្គការវប្បធម៌ វិទ្យាសាស្ត្រ និង ការអប់រំរបស់អង្គការសហប្រជាជាតិ ដែលហៅកាត់ថា យូនីស្កូ បានយល់ព្រមព្រៀងគ្នាបង្កើតស្ថានីយ៍វិទ្យុភាសាក្រឹងមួយនៅក្នុងខេត្តរតនគិរី ដែលផ្សាយលើតំបន់ក្រុមជនជាតិភាគតិច។

ទោះបីជាមិនអាចទទួលបានអាជ្ញាប័ណ្ណសំរាប់ការផ្សព្វផ្សាយក៏ដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សបានបង្កើតកម្មវិធីសំលេងប្រជាធិបតេយ្យ ដែលបានដាក់បញ្ចូលទស្សនៈឯករាជ្យ និង ទស្សនៈប្រឆាំងនឹងរដ្ឋាភិបាល ដែលកាន់តែមានប្រជាប្រិយភាពយ៉ាងខ្លាំង និងបន្តផ្សព្វផ្សាយកម្មវិធីនៅលើវិទ្យុដែលមាននិន្នាការស្របនឹងគណបក្សសមរង្ស៊ីអែហ្វអឹម ៩៣.៥ មេកាហឺត។ សំលេងសហរដ្ឋអាមេរិក (វីអូអេ) និង វិទ្យុអាស៊ីសេរីជាខេមរភាសា ក៏ត្រូវបានផ្សាយជាប្រចាំតាមវិទ្យុសម្បុកឃ្មុំអែហ្វអឹម ១០៥ មេកាហឺត និង មជ្ឈមណ្ឌលសំលេងស្ត្រីកម្ពុជា បានចុះហត្ថលេខានៅក្នុងខែកញ្ញា ដើម្បីធ្វើការផ្សាយកម្មវិធីវិទ្យុអាស៊ីសេរី និង វីអូអេតាមស្ថានីយ៍វិទ្យុអែហ្វអឹម ១០២ មេកាហឺតរបស់ខ្លួនផងដែរ។

ស្ថានីយវិទ្យុ និង ទូរទស្សន៍ជាតិដែលគ្រប់គ្រងដោយរដ្ឋាភិបាល បានថតសំលេងការប្រជុំរដ្ឋសភាពជាតិដើម្បីធ្វើការផ្សព្វផ្សាយ។ តែទោះជាយ៉ាងណា នៅក្នុងករណីជាច្រើន ការផ្សព្វផ្សាយទាំងនេះត្រូវបានដាក់ការត្រួតពិនិត្យដកចេញខ្លឹមសារ (ដាក់សែនស័រ)។ ស្ថានីយ៍វិទ្យុ និង ទូរទស្សន៍ជាតិ មានការផ្សព្វផ្សាយជាប្រចាំស្តីពីសិទ្ធិមនុស្ស សកម្មភាពសង្គម សុខភាពសារធារណៈ ការអប់រំ និង កម្មវិធីរបស់អង្គការសង្គមស៊ីវិលដែលផលិតដោយអង្គការក្នុងស្រុក។

រដ្ឋាភិបាលបន្តដាក់កំរិតសិទ្ធិក្នុងការចូលទៅក្នុងអគាររបស់រដ្ឋាភិបាល។ ទោះជារដ្ឋធម្មនុញ្ញបានផ្តល់សិទ្ធិដល់សារព័ត៌មានចូលរួមនៅក្នុងប្រជុំពេញអង្គរបស់រដ្ឋសភាជាតិក៏ដោយ រដ្ឋសភានៅបន្តហាមប្រាមដល់អ្នកសារព័ត៌មានមិនឱ្យចូលទៅបរិវេណរដ្ឋសភាដោយមិនមានការអនុញ្ញាតពីអគ្គលេខាធិការរបស់រដ្ឋសភា ដោយសារមិនមានកន្លែងគ្រប់គ្រាន់នៅក្នុងបន្ទប់ប្រជុំ។ អ្នកយកព័ត៌មានមិនត្រូវបានគេផ្តល់សិទ្ធិដោយសេរីក្នុងការចូលទៅក្នុងតុលាការចាប់តាំងពីខែតុលា ឆ្នាំ២០០៥ ដែលតុលាការក្រុងភ្នំពេញចេញបញ្ជាតំរូវឱ្យអ្នកសារព័ត៌មានទទួលការអនុញ្ញាតដើម្បីធ្វើការសម្ភាសន៍បុគ្គលិករបស់តុលាការ និង ការអនុញ្ញាតជាលាយលក្ខណ៍អក្សរសំរាប់អ្នកសារព័ត៌មាន ដើម្បីយកឧបករណ៍ថតខ្សែអាត់ចូលក្នុងបន្ទប់ជំនុំជំរះ។ នៅថ្ងៃទី ៧ ខែកក្កដា ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញបញ្ជាហាមឃាត់មន្ត្រីរបស់រដ្ឋាភិបាល និង បុគ្គលិកទាំងអស់មិនឱ្យនិយាយជាមួយអ្នកសារព័ត៌មាន ឬ សាធារណៈជន អំពីអំពើពុករលួយរបស់រដ្ឋាភិបាលឡើយ។

**សេរីភាពក្នុងការប្រើប្រាស់អ៊ីនធឺណែត**

មិនមានការហាមឃាត់ពីសំណាក់រដ្ឋាភិបាលចំពោះការប្រើប្រាស់អ៊ីនធឺណែត ឬ មានរបាយការណ៍ថា រដ្ឋាភិបាលធ្វើការត្រួតពិនិត្យអ៊ីនធឺណែត ឬ បន្ទប់ធ្វើការពិភាក្សាតាមអ៊ីនធឺណែតនោះទេ។ បុគ្គលនានា ឬ ក្រុមនានា

អាចធ្វើការទំនាក់ទំនងគ្នាតាមអ៊ីនធឺណែតបានយ៉ាងងាយស្រួល ដោយគិតទាំងការទំនាក់ទំនងតាមសារអក្សរអេឡិចត្រូនិចផងដែរ។ អ៊ីនធឺណែតអាចរកបាននៅគ្រប់ហាងបំរើសេវាកម្មអ៊ីនធឺណែត និង តាមការទិញសេវាកម្មតាមផ្ទះចំពោះអ្នករស់នៅតំបន់ទីក្រុង។

**សេរីភាពក្នុងការសិក្សា និង ព្រឹត្តិការវប្បធមិ**

ជាទូទៅមិនមានការហាមឃាត់ផ្លូវច្បាប់ចំពោះសេរីភាពក្នុងការសិក្សាឡើយ។ ទោះជាយ៉ាងណាក៏ដោយគ្រូបង្រៀនតែងតែមានការប្រុងប្រយ័ត្ន នៅពេលបង្រៀនពីប្រធានបទដែលមានការពាក់ព័ន្ធទៅនឹងបញ្ហានយោបាយដោយមានការភ័យខ្លាចថា មានការប៉ះពាល់ដល់អ្នកនយោបាយនានា។ នៅក្នុងខែកញ្ញា លេខាធិការដ្ឋានក្រសួងធម្មការ និង កិច្ចការសាសនា បានចេញបញ្ជាដកលោក ទ្បេង ណារិទ្ធិ ដែលជាសាស្ត្រាចារ្យនៅសកលវិទ្យាល័យពុទ្ធសាសនបណ្ឌិតព្រះសីហនុរាជ្យ។ រដ្ឋាភិបាលអះអាងថា លោក ទ្បេង ណារិទ្ធិ ដោយមិនបានទទួលការអនុញ្ញាតពីអ្នកគ្រប់គ្រងសាលា បានរៀបចំអត្ថបទសិក្សាមួយដែលមានភាពមិនត្រឹមត្រូវចំពោះប្រវត្តិសាស្ត្ររបស់ប្រទេស និងបានចោទប្រកាន់មន្ត្រីរដ្ឋាភិបាលដោយមិនសមស្របថា បានប្រព្រឹត្តបទឧក្រិដ្ឋដូចជា អំពើពុករលួយ និង ការធ្វើឃាតផ្នែកនយោបាយ។ បន្ទាប់មក តុលាការក្រុងភ្នំពេញបានចោទប្រកាន់លោកសាស្ត្រាចារ្យពីបទផ្តល់ព័ត៌មានមិនពិត និង បានឃុំខ្លួនគាត់។ គ្រួសាររបស់គាត់បានអះអាងថា គាត់មានបញ្ហាផ្នែកខួរក្បាល។ ទោះជាយ៉ាងណា លទ្ធផលការពិនិត្យផ្នែកចិត្តសាស្ត្រដែលចេញបញ្ជាដោយតុលាការ មិនត្រូវបានតុលាការ ឬ សាធារណៈជនបានដឹងឡើយ។ រហូតមកដល់ចុងឆ្នាំ លោក ទ្បេង ណារិទ្ធិ នៅជាប់ឃុំនៅឡើយដើម្បីរង់ចាំការកាត់ទោស។

មិនមានការហាមឃាត់ពីសំណាក់រដ្ឋាភិបាលលើព្រឹត្តិការណ៍ផ្នែកវប្បធមិនោះទេ។

**ខ- សេរីភាពខាងការប្រជុំដោយសន្តិភាព និង សមាគម**

**សេរីភាពខាងការប្រជុំ**

រដ្ឋធម្មនុញ្ញផ្តល់ឱ្យមានសិទ្ធិសេរីភាពខាងការជួបជុំគ្នាដោយសន្តិភាព ជាការអនុវត្តន៍ជាក់ស្តែង ប៉ុន្តែរដ្ឋាភិបាលមិនបានគោរពសិទ្ធិទាំងនេះឡើយ។ រដ្ឋាភិបាលបានទាមទារឱ្យមានការអនុញ្ញាតជាមុនចំពោះការដើរហែក្បួន ឬ ការធ្វើបាតុកម្មនានា។ ជាធម្មតារដ្ឋាភិបាលមិនចេញលិខិតអនុញ្ញាតដល់ក្រុមធ្វើការរិះគន់ដល់គណបក្សកាន់អំណាចឡើយ។ រដ្ឋាភិបាលបានដកស្រង់យកកុប្បកម្មប្រឆាំងជនជាតិថៃនៅឆ្នាំ ២០០៣ ដោយលើកយកហេតុផលសំរាប់រក្សាស្ថេរភាពសង្គម និង សន្តិសុខសាធារណៈ ជាហេតុផលចំពោះការមិនបានផ្តល់ការអនុញ្ញាត។ ក្រុមប៉ូលីសតែងតែធ្វើការបង្ក្រាបបាតុករដោយកំរោលចំពោះការជួបជុំគ្នាទាំងឡាយណាដែលមិនមានការអនុញ្ញាត ដែលជាញឹកញាប់តែងតែបង្កឱ្យមានការរងរបួសដល់បាតុករ។

អង្គការអាដហុកបានរាយការណ៍ថា នៅក្នុងឆ្នាំនេះ ប៉ូលីស និងកងរាជអាវុធហត្ថបានធ្វើការបំបែកការតវ៉ាចំនួន ៤៦ ដែលក្នុងនោះមានការតវ៉ាចំនួន ១១ ជាការតវ៉ារបស់កម្មកររោងចក្រ និង ៣៥ ជាការតវ៉ាដោយអ្នកដែលត្រូវគេរំលោភយកដីធ្លី។ មានអ្នកតវ៉ាលើការរំលោភយកដីធ្លីចំនួន ២១ នាក់ត្រូវបានតុលាការកាត់ទោស និងកម្មករ ២៧ នាក់ត្រូវបានទទួលរងការធ្វើការស៊ើបអង្កេត។ អង្គការអាដហុកបានបន្ថែមទៀតថា មានកម្មករចំនួន

១២ នាក់ បានលាឈប់ពីការងាររោងចក្ររបស់ខ្លួនដោយសារមានការព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ។ របាយការណ៍នោះបានកត់សំគាល់ទៀតថា អាជ្ញាធរតែងតែប្រើការចោទប្រកាន់បទឧក្រិដ្ឋជាឧបករណ៍ដើម្បីឃាត់ខ្លួនបាតុករ។

ក្រុមសង្គមស៊ីវិលបានធ្វើការកត់សំគាល់ថា អាជ្ញាធរប្រើអំពើហិង្សា និង ប្រើកំលាំងបាយហួសហេតុ ដើម្បីធ្វើការបំបែកក្រុមបាតុករ។ នៅថ្ងៃទី ៧ ខែកក្កដា នៅក្នុងតំបន់ជាយក្រុងភ្នំពេញ ប៉ូលីសប្រឆាំងបាតុករបានប្រើផ្សែងបាញ់បង្ហូរទឹកភ្នែក និង ដំបងឆក់ រួមជាមួយនឹងការបាញ់រះទៅលើដើម្បីបំបែកបាតុករតវ៉ាបញ្ហាដីធ្លីចំនួន ២០០នាក់មកពីខេត្តកណ្តាល ដែលព្យាយាមធ្វើការដើរហែរក្បួនទៅកាន់រដ្ឋសភាជាតិដើម្បីសុំឱ្យមានការដោះលែងដល់អ្នកតំណាងរបស់ពួកគេ ដែលត្រូវបានឃាត់ខ្លួនលើបញ្ហាជំលោះដីធ្លី។

សាលាក្រុងភ្នំពេញបានបដិសេធមិនផ្តល់លិខិតអនុញ្ញាតដល់សហគមន៍កម្ពុជាក្រោម ដើម្បីធ្វើបាតុកម្មប្រឆាំងនឹងការធ្វើទស្សនកិច្ចថ្ងៃទី៦ ខែមីនា របស់លោកនាយករដ្ឋមន្រ្តីវៀតណាម គឺ លោក ខាន់ វ៉ាន់ខាយ។ អាជ្ញាធរក្រុងភ្នំពេញបានបញ្ជាក់ថា ពួកគេមានការព្រួយបារម្ភដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និង សេចក្តីថ្លៃថ្នូររបស់ជាតិ។ សហគមន៍នេះបានធ្វើគំរោងទាមទារឱ្យរដ្ឋាភិបាលប្រទេសវៀតណាមគោរពសិទ្ធិមនុស្ស និង សេរីភាពរបស់ខ្មែរក្រោមនៅវៀតណាមខាងត្បូង។

អាជ្ញាធរក្រុងភ្នំពេញបានបដិសេធមិនផ្តល់ការអនុញ្ញាតដល់សហជីពកម្មករ ចំពោះការសុំធ្វើការជួបជុំគ្នានៅថ្ងៃទី១ ខែឧសភា នៅក្នុងទីសាធារណៈ ដើម្បីប្រារព្ធកម្មវិធីទិវាពលកម្មអន្តរជាតិ។ សហជីពបានបន្តធ្វើការហែរក្បួនដោយគ្មានការអនុញ្ញាត (មើលផ្នែក ៦-ខ.)។ នៅថ្ងៃទី១ ខែសីហា កងប្រដាប់អាវុធប៉ូលីសបានធ្វើការបំបែកក្រុមបាតុករចំនួន ៥០ នាក់ដែលធ្វើការជួបជុំគ្នាដើម្បីទាមទារឱ្យមានការដោះលែងបុរស ២ រូបដែលត្រូវបានគេកាត់ទោសពីបទធ្វើឃាតប្រធានសហជីពកម្មករ លោក ជា វិជ្ជា នៅក្នុងឆ្នាំ ២០០៤ (សូមមើលផ្នែក ១-ក.)។

នៅថ្ងៃទី ១៨ ខែសីហា នៅក្នុងការចេញបទបញ្ជាចំពោះព្រះសង្ឃព្រះពុទ្ធសាសនា សម្តេចព្រះសង្ឃរាជបានហាមឃាត់ចំពោះព្រះសង្ឃគ្រប់ព្រះអង្គមិនឱ្យចូលរួមនៅក្នុងការធ្វើកូដកម្ម ការតវ៉ា ឬ ការបះបោរផ្សេងៗ ដោយមិនមានការអនុញ្ញាតពីសម្តេចព្រះសង្ឃរាជនោះឡើយ។

**សេរីភាពខាងសមាគម**

រដ្ឋធម្មនុញ្ញបានផ្តល់សិទ្ធិក្នុងការធ្វើសកម្មភាពសមាគម ហើយតាមការអនុវត្តន៍ជាក់ស្តែង រដ្ឋាភិបាលក៏បានគោរពសិទ្ធិនេះដែរ។ ទោះជាយ៉ាងណា រដ្ឋាភិបាលមិនបានអនុវត្តបទបញ្ញត្តិនៃច្បាប់ការងារឱ្យមានប្រសិទ្ធិភាពឡើយ (មើលផ្នែក ៦-ក.)។

រដ្ឋាភិបាលមិនបានបង្ខិតបង្ខំ ឬ ហាមឃាត់ការចូលជាសមាជិកភាពអង្គការនយោបាយណាមួយឡើយ។ ជាធម្មតា គណបក្សនយោបាយអាចរៀបចំសកម្មភាពរបស់ខ្លួនបានដោយសេរី និង មិនមានការជ្រៀតជ្រែកពីរដ្ឋាភិបាលឡើយ។ នៅថ្ងៃទី៦ ខែកុម្ភៈ សមាជិករដ្ឋសភាគណបក្សប្រឆាំងលោក សម រង្ស៊ី លោក ជាម ចន្នី និង លោក ជា ប៉ូច ត្រូវបានទទួលការលើកលែងទោស និង ទទួលបាននូវអភ័យឯកសិទ្ធិសភាបស់ខ្លួនឡើងវិញ។

អង្គការសិទ្ធិមនុស្សបានរាយការណ៍ថា អាជ្ញាធរមូលដ្ឋានមួយចំនួនបានធ្វើការព្រមានដល់សមាជិកគណបក្សនយោបាយមួយចំនួនថា ប្រសិនបើពួកគេបន្តធ្វើការគាំទ្រដល់គណបក្សនយោបាយទាំងនោះទៀត ពួកគេនឹងមានការបាត់បង់សិទ្ធិកាន់កាប់លំនៅដ្ឋាន មានការរឹបអូសយកទ្រព្យសម្បត្តិ និង ការហាមឃាត់ចំពោះការប្រើប្រាស់ប្រព័ន្ធហេត្ថារចនាសម្ព័ន្ធក្នុងតំបន់នោះឡើយ។ ទោះជាយ៉ាងណា នៅក្នុងឆ្នាំនេះមិនមានរបាយការណ៍ណាមួយកើតមានទៀតឡើយ។

សមាជិកភាពរបស់ខ្មែរក្រហម ដែលដឹកនាំប្រទេសពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ និង បន្ទាប់ពីការដួលរលំរបបនេះ គេបានបង្កជាកងកំលាំងបះបោរប្រឆាំងនឹងរដ្ឋាភិបាល គឺត្រូវបានគេចាត់ទុកថា ខុសច្បាប់ ព្រោះជាសមាជិកភាពរបស់ក្រុមកងកំលាំងប្រដាប់អាវុធ។

**គ- សេរីភាពខាងសាសនា**

រដ្ឋធម្មនុញ្ញផ្តល់ឱ្យមានសេរីភាពខាងសកម្មភាពសាសនា និង ជាធម្មតា ចំពោះការអនុវត្តន៍ជាក់ស្តែង រដ្ឋាភិបាលតែងគោរពសិទ្ធិទាំងនេះ។ រដ្ឋធម្មនុញ្ញក៏បានហាមឃាត់មិនឱ្យមានការរើសអើងផ្នែកសាសនា ហើយសាសនាក្រុមជនជាតិភាគតិចទទួលការរើសអើងតិចតួច ឬ មិនមានការរើសអើងអ្វីឡើយ។ សាសនាព្រះពុទ្ធ គឺជាសាសនារបស់រដ្ឋ ហើយមានប្រជាពលរដ្ឋច្រើនជាង ៩៣% ជាពុទ្ធសាសនិក។ សាសនាជនជាតិភាគតិចចាម ត្រូវបានគោរពដោយប្រជាពលរដ្ឋភាគច្រើនដែលនៅសេះសល់ពីសាសនាព្រះពុទ្ធ។

ច្បាប់តំរូវឱ្យក្រុមសាសនាទាំងអស់ ដោយគិតរួមទាំងសាសនាព្រះពុទ្ធផងដែរ ឱ្យដាក់ពាក្យសុំការអនុញ្ញាតទៅក្រសួងធម្មការ និង សាសនា ដើម្បីធ្វើការសាងសង់ទីសក្ការៈបូជា និង ប្រារព្ធសកម្មភាពសាសនានានា។ ទោះជាយ៉ាងណា មិនមានការដាក់ទោសពិន័យចំពោះការខកខានមិនបានចុះឈ្មោះសាសនានោះទេ។ ក្នុងឆ្នាំ ២០០៣ ក្រសួងធម្មការ និង សាសនា បានចេញបញ្ជាហាមឃាត់ដល់ការញុំាងឱ្យមានការផ្លាស់ប្តូរសាសនាជាសាធារណៈ ប៉ុន្តែបញ្ជានោះត្រូវបានអនុវត្តតែនៅក្នុងរយៈពេលឆាន់ត្រង់ ២ ម៉ោងប៉ុណ្ណោះ។

**ការរំលោភផ្នែកសង្គម និង ការរើសអើង**

សាសនារបស់ជនជាតិភាគតិចទទួលការរើសអើងតិចតួចបំផុត ឬ មិនមានទទួលការរើសអើងពីសង្គមអ្វីឡើយ។ មិនមានអ្នកណាដឹងថា មានសហគមន៍ជនជាតិជ្វានៅក្នុងប្រទេសនេះនោះទេ និង មិនមានរបាយការណ៍ណាចំពោះសកម្មភាពការប្រឆាំងសាសនាចាមនោះដែរ។

ចំពោះការពិភាក្សាលំអិត សូមមើលរបាយការណ៍សេរីភាពសាសនាអន្តរជាតិឆ្នាំ ២០០៦។

**ឃ- សេរីភាពក្នុងការដើរហើរក្នុងប្រទេស ការធ្វើដំណើរក្រៅប្រទេស ការធ្វើចំណាកស្រុក និង ការធ្វើមាតុភូមិនិវត្ត**

ច្បាប់ផ្តល់ឱ្យមានសិទ្ធិទាំងអស់នេះ ហើយជាធម្មតា រដ្ឋាភិបាលក៏គោរពសិទ្ធិទាំងអស់នេះផងដែរ។ រដ្ឋាភិបាលមិនមានដាក់កំរិតចំពោះការធ្វើដំណើរក្រៅប្រទេសឡើយ។ រដ្ឋាភិបាលក៏មិនដាក់កំរិតចំពោះការធ្វើចំណាកស្រុក ឬ ការវិលត្រឡប់របស់ប្រជាពលរដ្ឋដែលបានចាកចេញពីប្រទេសនោះដែរ។

រដ្ឋធម្មនុញ្ញបានហាមឃាត់មិនឱ្យមានការបង្ខំឱ្យធ្វើការនិរទេស ហើយរដ្ឋាភិបាលមិនបានទទួលយកវិធីបែប នោះដែរ។

**ការការពារជនភៀសខ្លួន**

ច្បាប់ផ្តល់ឱ្យមានការផ្តល់សិទ្ធិជ្រកកោន ឬ សិទ្ធិស្នាក់នៅរបស់ជនភៀសខ្លួន ហើយប្រទេសនេះបានចូលជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិឆ្នាំ ១៩៥១ ពាក់ព័ន្ធទៅនឹងសិទ្ធិជ្រកកោនរបស់ជនភៀសខ្លួន និង ពិធីការឆ្នាំ ១៩៦៧។ ទោះជាយ៉ាងណា ជាការអនុវត្តន៍ជាក់ស្តែង រដ្ឋាភិបាលមិនបានគោរពច្បាប់នេះឱ្យបានខ្ជាប់ខ្ជួន និង មិនបានអនុវត្តច្បាប់ពាក់ព័ន្ធទៅនឹងសន្ធិសញ្ញាឆ្នាំ ១៩៥១ របស់អង្គការសហប្រជាជាតិនោះឡើយ។

អង្គការសិទ្ធិមនុស្សដែលមានមូលដ្ឋាននៅក្នុងខេត្តរតនគិរីបានរាយការណ៍ថា នៅក្នុងខែសីហា មានជនជាតិម៉ុងតាញ៉ាចំនួន ៦ នាក់ដែលព្យាយាមស្វែងរកសិទ្ធិជ្រកកោននៅក្នុងខេត្តនេះត្រូវបានចាប់ខ្លួន និង បញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ ដោយមិនមានការពិនិត្យមើលពីឧត្តមស្នងការជនភៀសខ្លួនក្នុងប្រទេសកម្ពុជានោះឡើយ។

នៅថ្ងៃទី ២៧ ខែមីនា អាជ្ញាធរខេត្តរតនគិរីបានប្រទះឃើញសាកសពកុមារីជនជាតិម៉ុងតាញ៉ាម្នាក់អាយុ ៨ ឆ្នាំនៅក្នុងទន្លេស៊ីសាន និង បានប្រគល់ឱ្យទៅអាជ្ញាធរវៀតណាមវិញ។ អង្គការមួយបានរាយការណ៍ថា សាកសពនោះ គឺជាសាកសពម្នាក់ក្នុងចំណោមជនម៉ុងតាញ៉ា ៥ នាក់ដែលបានបាត់ខ្លួនចាប់តាំងពីថ្ងៃទី ២៥ ខែមិថុនា នៅពេលដែលអាជ្ញាធរព្រំដែនវៀតណាមធ្វើការដេញតាមពួកគេ និង បានបាញ់រះមកលើពួកគេនៅពេលពួកគេបានឆ្លងស្ទឹងដើម្បីសុំសិទ្ធិជ្រកកោន។ ទោះជាយ៉ាងណា ឧត្តមស្នងការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនក្នុងប្រទេសកម្ពុជាដែលបានធ្វើការស៊ើបអង្កេតបង្ហាញថា ជនភៀសខ្លួនទាំងនោះធ្វើការភៀសខ្លួននៅក្នុងទូកមួយដែលមានមនុស្សជិះច្រើនដែលបានក្រឡាប់ ហើយកុមារីនោះមិនចេះហែលទឹក។

នៅថ្ងៃទី ២៥ ខែសីហា ប៉ូលីសនៅក្នុងខេត្តមណ្ឌលគិរីបានឃាត់ខ្លួនយុវជនវ័យជំទង់ជាជនជាតិព្នង ២នាក់។ ប៉ូលីសដែលកំពុងធ្វើការស្រាវជ្រាវរកក្រុមម៉ុងតាញ៉ាត្រូវបានគេរាយការណ៍ថា បានលាក់ខ្លួននៅក្នុងព្រៃ ហើយធ្វើការចោទប្រកាន់យុវជនទាំងពីររូបថា បានផ្តល់ម្ហូបអាហារដល់ក្រុមម៉ុងតាញ៉ា។ ប៉ូលីសបានដោះលែងពួកគេក្នុងរយៈពេល ១ ថ្ងៃក្រោយមក។

នៅថ្ងៃទី ៤ ខែធ្នូ តុលាការក្រុងភ្នំពេញបានកាត់ទោសជនជាតិខ្មែរក្រោមសញ្ជាតិវៀតណាមឈ្មោះ ឡាំ ហ៊ួយ៉េន ឱ្យជាប់ទោសរយៈពេល ៣ខែ។ គាត់ត្រូវបានគេឃាត់ខ្លួននៅថ្ងៃទី៦ ខែកញ្ញា ចំពោះការនាំផ្លូវក្រុមជនជាតិម៉ុងតាញ៉ាឱ្យចូលមកសុំសិទ្ធិជ្រកកោនក្នុងប្រទេសកម្ពុជា។ ការអន្តរាគមន៍របស់ឧត្តមស្នងការទទួលបន្ទុកជនភៀសខ្លួន និង ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានជួយរារាំងមិនឱ្យមានការបញ្ជូនជននោះទៅកាន់ប្រទេសវៀតណាមវិញ។

អង្គការសិទ្ធិមនុស្សបានអះអាងថា អាជ្ញាធរតំបន់នៅតាមព្រំដែនវៀតណាម បានបង្កើនការតាមដានរកជនជាតិម៉ុងតាញ៉ា នៅពេលដែលអាជ្ញាធរវៀតណាមបានផ្តល់ព័ត៌មានមកដល់ពួកគេពីការមកដល់របស់ក្រុមម៉ុងតាញ៉ា។

មានព័ត៌មានដែលមិនបានបញ្ជាក់ច្បាស់លាស់ថា អាជ្ញាធរប្រទេសវៀតណាមបានផ្តល់គ្រឿងលើកទឹកចិត្តដល់ប៉ូលីសព្រំដែនកម្ពុជាដែលបានបញ្ជូនជនភៀសខ្លួនទៅកាន់ប្រទេសវៀតណាមវិញ និង មានប៉ូលីសសំងាត់របស់វៀតណាមកំពុងតែធ្វើសកម្មភាពនៅក្នុងព្រំដែនប្រទេសកម្ពុជាផងដែរ។

អនុស្សារណៈនៃការយោគយល់គ្នាមួយដែលប្រទេសនេះបានចុះហត្ថលេខានៅក្នុងខែមករា ឆ្នាំ២០០៥ ជាមួយ UNHCR និង រដ្ឋាភិបាលប្រទេសវៀតណាមដើម្បីដោះស្រាយស្ថានភាពក្រុមម៉ុងតាញ៉ាក្រោមការការពាររបស់ UNHCR ក្រុងភ្នំពេញ នៅតែជាក្របខណ្ឌការងារមួយសំរាប់ UNHCR នៅក្នុងប្រទេស។ ទោះជាយ៉ាងណា អង្គការសិទ្ធិមនុស្សដែលមានមូលដ្ឋាននៅក្នុងខេត្តរតនគីរីបានរាយការណ៍ថា នៅក្នុងខែសីហា មានជនជាតិម៉ុងតាញ៉ាចំនួន ៦ នាក់ដែលព្យាយាមស្វែងរកសិទ្ធិជ្រកកោនត្រូវបានឃាត់ខ្លួន និង បញ្ជូនត្រឡប់ទៅកាន់ប្រទេសវៀតណាមវិញដោយមិនមានការត្រួតពិនិត្យពី UNHCR ឡើយ។

អ្នកសុំសិទ្ធិជ្រកកោនដែលបានមកដល់ការិយាល័យ UNHCR ក្រុងភ្នំពេញ ត្រូវបានអមដំណើរដោយកិច្ចសហប្រតិបត្តិការរបស់រដ្ឋាភិបាល។ នៅក្នុងអំឡុងឆ្នាំនេះ មានជនម៉ុងតាញ៉ាមកដល់ថ្មីចំនួន ២៧៧ នាក់ ដែលព្យាយាមស្វែងរកសិទ្ធិជ្រកកោនពី UNHCR។ ក្នុងចំនួនទាំងអស់នេះ មាន ៣០ នាក់ត្រូវបានគេរកឃើញថា ជាជនជាតិកម្ពុជា។ យោងតាម UNHCR អាជ្ញាធរបានបញ្ជូនជនជាតិម៉ុងតាញ៉ាចំនួន ២៨ នាក់ដែលត្រូវបានគេបដិសេធមិនផ្តល់សិទ្ធិជ្រកកោនទៅកាន់ប្រទេសវៀតណាមវិញ។ នៅថ្ងៃទី ៦ ខែធ្នូ មានជនជាតិភៀសខ្លួនម៉ុងតាញ៉ាចំនួន ៤៣នាក់ត្រូវបានគេបញ្ជូនទៅកាន់ប្រទេសទី ៣។ រហូតមកដល់ចុងឆ្នាំ មានជនជាតិម៉ុងតាញ៉ានៅក្នុងកន្លែងជនភៀសខ្លួនក្នុងក្រុងភ្នំពេញចំនួន ២៣៥ នាក់ ដោយគិតរួមទាំងជនជាតិម៉ុងតាញ៉ាភៀសខ្លួនដែលបានមកដល់កាលពីឆ្នាំមុនផងដែរ។

## ផ្នែកទី ៣ ការគោរពសិទ្ធិធ្វើនយោបាយ : សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការផ្លាស់ប្តូររដ្ឋាភិបាលរបស់ខ្លួន

រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការធ្វើការផ្លាស់ប្តូររដ្ឋាភិបាលដោយសន្តិភាព និង ជាទូទៅ ប្រជាពលរដ្ឋបានអនុវត្តសិទ្ធិរបស់ពួកគេតាមរយៈការបោះឆ្នោតតាមគោលការណ៍ជាសកល។ ការបោះឆ្នោតនេះ គឺធ្វើឡើងដោយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋដែលមានអាយុលើសពី ១៨ ឆ្នាំ។

នៅក្នុងអំឡុងឆ្នាំនេះ រដ្ឋសភាជាតិបានអនុម័តលើការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលនៅពេលក្រោយមកត្រូវបានអនុម័តដោយព្រឹទ្ធសភា និង ព្រះមហាក្សត្រ ដែលធ្វើការកែប្រែសំលេងភាគច្រើននៃការបោះឆ្នោតដើម្បីបង្កើតរដ្ឋាភិបាលពីមតិ ២ ភាគ ៣ នៃអាសនរដ្ឋសភាជាតិ ទៅជាទំរង់ភាគច្រើនដ៏សមញ្ញ ៥០ បូក ១ ដែលផ្តល់អំណាចកាន់តែខ្លាំងចំពោះគណបក្សប្រជាជនកម្ពុជាចំពោះនីតិវិធីច្បាប់។

### ការបោះឆ្នោត និង ការចូលរួមសកម្មភាពនយោបាយ

នៅថ្ងៃទី ២២ ខែមករា ការបោះឆ្នោតលើកទី ១ សំរាប់ជ្រើសរើសព្រឹទ្ធសភាត្រូវបានធ្វើឡើងដើម្បីជ្រើសរើសសមាជិកព្រឹទ្ធិសភាចំនួន ៥៧ រូប ក្នុងចំណោមចំនួនព្រឹទ្ធសាភារសរុប ៦១ រូប។ គណបក្សនយោបាយ និង

បុគ្គលនានាមានសិទ្ធសេរីភាពនៅក្នុងការឈរឈ្មោះជាបេក្ខជនដោយមិនមានការដាក់កំរិតអ្វីឡើយ។ តាមប្រព័ន្ធអសកលដោយប្រយោល ដែលប្រព័ន្ធនេះឱ្យសមាជិករដ្ឋសភា និង ក្រុមប្រឹក្សាឃុំសង្កាត់ ជាអ្នកមានសិទ្ធិធ្វើការបោះឆ្នោត គណបក្សប្រជាជនកម្ពុជាបានឈ្នះអាសនចំនួន ៤៥ គណបក្សហ៊្វុនស៊ិនប៉ិចបាន ១០ អាសន និង គណបក្សសមរង្ស៊ីបាន ២ អាសន។ លើសពីនេះទៀត សមាជិកព្រឹទ្ធសភា ២រូបត្រូវបានតែងតាំងដោយព្រះមហាក្សត្រ និង ២រូបទៀតត្រូវបានតែងតាំងដោយរដ្ឋសភាជាតិ។ ការបោះឆ្នោតនោះត្រូវបានធ្វើឡើងដោយសន្តិភាព ប៉ុន្តែមានការរិះគន់ពីសង្គមស៊ីវិលចំពោះនីតិវិធីបោះឆ្នោតដោយប្រយោលនេះ។ កាលពីពេលមុន គណបក្សនយោបាយនៅក្នុងរដ្ឋសភាជាតិ និង ព្រះមហាក្សត្រ ធ្វើការតែងតាំងសមាជិកទាំងអស់នៅក្នុងព្រឹទ្ធសភា។

គណៈកម្មការជាតិរៀបចំការបោះឆ្នោត(គជប) បានធ្វើផែនការកាលវិភាគដើម្បីធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់នៅថ្ងៃទី១ ខែមេសា ឆ្នាំ ២០០៧។ នៅក្នុងពេលធ្វើការចុះឈ្មោះអ្នកដែលមានសិទ្ធិបោះឆ្នោត និង បេក្ខជនមុនចុងឆ្នាំ អង្គការឃ្លាំមើលដំណើរការបោះឆ្នោតមានការព្រួយបារម្ភណ៍ពីការកើនឡើងនៃអំពើហិង្សា និង ការគំរាមកំហែងដែលធ្វើឡើងចំពោះសកម្មជនគណបក្សនយោបាយ និង ប្រជាពលរដ្ឋ។ អង្គការនេះបានធ្វើការកត់សំគាល់ឃើញថា មានមនុស្សជាច្រើននៅក្នុងខេត្តតាកែវត្រូវបានគេបង្ខំឱ្យធ្វើការស្បថស្បែរដើម្បីធ្វើជាសមាជិកគណបក្សប្រជាជនកម្ពុជា។ នៅចុងឆ្នាំ អង្គការបានធ្វើការកត់ត្រាទុកយ៉ាងហោចណាស់ចំពោះករណីចំនួន ១២ ករណី ចំពោះការរារាំងដល់ការធ្វើសកម្មភាពរបស់គណបក្សសមរង្ស៊ី និង សកម្មភាពធ្វើការអប់រំរបស់អង្គការ។ អង្គការ និង គណបក្សសមរង្ស៊ី បានរកឃើញភាពមិនប្រក្រតីជាច្រើននៅក្នុងដំណើរការចែកចាយប័ណ្ណព័តិមានស្តីពីការបោះឆ្នោត និង ការចុះឈ្មោះបេក្ខជនសំរាប់ការបោះឆ្នោតឃុំ/សង្កាត់។ ពាក្យបណ្តឹងភាគច្រើនផ្តោតលើប្រតិភូរបស់ គ.ជ.ប ដែលចុះទៅជួបមេភូមិដែលមានភាពជិតស្និទនឹងគណបក្សប្រជាជនកម្ពុជា ដើម្បីធ្វើការផ្តល់សន្លឹកប័ណ្ណដែលមានព័តិមានកែលំអស្តីពីការចុះឈ្មោះបោះឆ្នោតដល់អ្នកមានសិទ្ធិបោះឆ្នោត។ អ្នកបោះឆ្នោតមានពេលវេលាខ្លីណាស់សំរាប់ធ្វើការកែលំអព័តិមានដែលមានការខុសឆ្គង ឬ អាចមានការប្រឈមមុខទៅនឹងការបដិសេធមិនអនុញ្ញាតឱ្យបោះឆ្នោតនៅថ្ងៃបោះឆ្នោត។ តាមសេចក្តីរាយការណ៍ មានមេភូមិមួយចំនួនមិនបានផ្តល់ប័ណ្ណព័តិមានទៅកាន់អ្នកបោះឆ្នោតដែលមិនគាំទ្រគណបក្សប្រជាជនកម្ពុជានោះឡើយ។

ពីខែមិថុនា ដល់ខែកក្កដា ក្រុមប្រឹក្សាឃុំ/សង្កាត់ដែលមានសមាជិកភាគច្រើនពីគណបក្សប្រជាជនកម្ពុជាបានធ្វើការជ្រើសរើសមេភូមិ តាមរយៈនីតិវិធីធ្វើការជ្រើសដោយប្រយោល ដែលទទួលបានការរិះគន់យ៉ាងខ្លាំងពីសង្គមស៊ីវិលថា មិនមែនជាអ្នកតំណាង និង រៀបចំឡើងដើម្បីឱ្យគណបក្សប្រជាជនកម្ពុជាកាន់តែមានការគ្រប់គ្រងអំណាចដល់ប្រជាពលរដ្ឋតាមមូលដ្ឋានកាន់តែខ្លាំង។ រដ្ឋាភិបាលបានលើកឡើងថា ការបោះឆ្នោតដោយផ្ទាល់នឹងត្រូវចំណាយប្រាក់ច្រើន ហើយមេភូមិមិនមានតួនាទីផ្នែកនយោបាយនោះឡើយ - តួនាទីរបស់ពួកគេ គឺត្រឹមតែដើរតួនាទីតាមធម្មតាជាអ្នកសំរបសំរួលទំនាស់ និង ជាអ្នកចេញលិខិតសំបុត្រកំណើត និង ឯកសារសាធារណៈដែលចេញដោយក្រុមប្រឹក្សាឃុំ/សង្កាត់។ ទោះបីជាមានការគាំទ្រថា តួនាទីរបស់ពួកគេមិនជាប់ពាក់ព័ន្ធនឹងនយោបាយ

ក៏ដោយ  គណៈកម្មការជាតិរៀបចំការបោះឆ្នោតបានប្រកាសថា  មេភូមិត្រូវចាប់ផ្តើមធ្វើការទទួលខុសត្រូវចំពោះការចែកចាយសន្លឹកប័ណ្ណផ្តល់ព័ត៌មានពីការបោះឆ្នោតប្រហែលជាង  ៦  លានសន្លឹក  ក៏ដូចជាការជួយផ្តល់ព័ត៌មានដល់អ្នកដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតពីនីតិវិធីធ្វើការចុះឈ្មោះផងដែរ។ អង្គការមួយបានរកឃើញថា មានអ្នកមានសិទ្ធិបោះឆ្នោតចំនួន ១,៧ លាននាក់មិនបានទទួលព័ត៌មានពីការបោះឆ្នោតពីមេភូមិរបស់ខ្លួន។

នៅក្នុងការបោះឆ្នោតជ្រើសរើសសភាជាតិក្នុងពេលក្រោយគេបង្អស់  ដែលបានធ្វើឡើងក្នុងឆ្នាំ  ២០០៣ គណបក្សប្រជាជនកម្ពុជាទទួលបាន ៧៣ អាសន គណបក្សហ៊្វុនស៊ិនប៉ិច ២៦ អាសន និង គណបក្សសមរង្ស៊ីបាន ២៤ អាសន។ ក្នុងឆ្នាំ ២០០៤ គណបក្សប្រជាជនកម្ពុជា និង គណបក្សហ៊្វុនស៊ិនប៉ិចបានបង្កើតរដ្ឋាភិបាលចំរុះ ប៉ុន្តែគណបក្សប្រជាជនកម្ពុជាបានក្តោបក្តាប់លើរដ្ឋាភិបាល។ ក្រុមអ្នកសង្កេតការណ៍លើកិច្ចការបោះឆ្នោតទាំងអស់បានធ្វើការកត់សំគាល់ថា មានភាពរីកចំរើនគួរសមនៅក្នុងការបោះឆ្នោត ប៉ុន្តែបានធ្វើ សេចក្តីសន្និដ្ឋានថា វាមិនទាន់ពេញលេញទៅតាមស្តង់ដាអន្តរជាតិនៅឡើយទេ។    នៅមានបញ្ហាអំពើហិង្សាដែលធ្វើឡើងដោយការជំរុញខាងនយោបាយ ប៉ុន្តែមានចំនួនតិចជាងការបោះឆ្នោតកាលពីពេលមុនៗមក។ រដ្ឋាភិបាលបានចាត់វិធានការណ៍តែចំពោះអ្នកប្រព្រឹត្តមួយចំនួនតូចប៉ុណ្ណោះ និង បានដោះស្រាយរាល់ការរំលោភផ្សេងៗទៀតម្តងម្កាល។ នៅមានបញ្ហាបច្ចេកទេសនៅក្នុងដំណើរការចុះឈ្មោះបោះឆ្នោត និង ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត ឱ្យមានប្រសិទ្ធិភាព ដែលបង្កឱ្យមានការរារាំងដល់ប្រជាពលរដ្ឋជាច្រើននៅក្នុងការបោះឆ្នោត។  ក៏នៅមានបញ្ហាគំរាមកំហែងដល់អ្នកបោះឆ្នោតដោយមន្ត្រីនៅតាមតំបន់ផងដែរ។   គណៈកម្មការជាតិរៀបចំការបោះឆ្នោតមិនបានបង្កើតនីតិវិធីដែលអាចទុកចិត្តបានដើម្បីដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធទៅនឹងការបោះឆ្នោតឡើយ។  ការតែងតាំងសមាជិកគណៈកម្មការជាតិរៀបចំការបោះឆ្នោតដោយក្រសួងមហាផ្ទៃ  គឺមិនមានតម្លាភាព  និង  ធ្វើឱ្យគណៈកម្មការនេះមានភាពចំហចំពោះការទទួលរងឥទ្ធិពលនយោបាយពីគណបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជា។

ក្នុងអំឡុងការបោះឆ្នោតឆ្នាំ  ២០០៣  មានភាពរីកចំរើនផ្នែកប្រព័ន្ធផ្សព្វផ្សាយសំរាប់គណបក្សនយោបាយទាំងឡាយណាដែលបានចុះបញ្ជីត្រឹមត្រូវ  និង  មានការពិភាក្សាបញ្ហានយោបាយដោយបើកចំហរ  និង  ការពិភាក្សាជាពហុភាគីត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ទូទាំងប្រទេសជាលើកដំបូង។  ទោះជាយ៉ាងណា  ប្រព័ន្ធផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិចភាគច្រើនមានការគាំទ្រចំពោះគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច។

មានអង្គការមិនមែនរដ្ឋាភិបាល  និង  គណបក្សនយោបាយមួយចំនួនបានចោទប្រកាន់ថា  មានសមាជិកគណបក្សប្រជាជនកម្ពុជាដែលមានអំណាចខ្លាំងជាងគេ  ត្រូវបានគេផ្តល់ផលប្រយោជន៍ផ្សេងៗដូចជា  អំណោយ  ឬអាទិភាពចំពោះការទទួលជំនួយសង្គ្រោះបន្ទាន់របស់រដ្ឋាភិបាល។

នៅក្នុងឆ្នាំ ២០០២ រដ្ឋាភិបាលបានរៀបចំឱ្យមានការបោះឆ្នោតឃុំ/សង្កាត់ទី១ទូទាំងប្រទេស ជាការបោះឆ្នោតថ្នាក់មូលដ្ឋាន។ នៅក្នុងចន្លោះពេលធ្វើការឃោសនាបោះឆ្នោត  អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថាមានសកម្មជន និង បេក្ខជនគណបក្សហ៊្វុនស៊ិនប៉ិច និង គណបក្សសមរង្ស៊ីចំនួន២៥នាក់ត្រូវបានគេសម្លាប់ដោយមិនដឹងមូលហេតុច្បាស់លាស់ ដោយគិតរួមទាំងមនុស្ស ៧នាក់ដែលអង្គការតាមដានបញ្ហាសិទ្ធិមនុស្សយល់ស្របថា ការ

សម្លាប់នោះ គឺធ្វើឡើងដោយលក្ខណៈនយោបាយ។ លទ្ធផលការបោះឆ្នោតបានកាត់បន្ថយការគ្រប់គ្រងរបស់គណបក្សប្រជាជនកម្ពុជាចំពោះការដឹកនាំថ្នាក់មូលដ្ឋានជាយូរយាមកហើយនោះ។ មេឃុំ/ចៅសង្កាត់ពីគណបក្សប្រជាជនកម្ពុជានៅមានចំនួន ៩៩% នៃចំនួនឃុំទាំង ១ ៦២១។ ទោះជាយ៉ាងណា ដោយសារលទ្ធផលនៃការបោះឆ្នោត អំណាចត្រូវបានចែករំលែកទៅឱ្យគណបក្សនយោបាយផ្សេងៗទៀតនៅក្នុងគ្រប់ឃុំទាំងអស់ លើកលែងតែឃុំចំនួន ១៤៨ ឃុំប៉ុណ្ណោះ។ រហូតមកដល់ចុងឆ្នាំ ក្រសួងមហាផ្ទៃ នៅមិនទាន់បានចេញការណែនាំសំរាប់ក្រុមប្រឹក្សាឃុំ/សង្កាត់នៅក្នុងការអនុវត្តន៍ច្បាប់រដ្ឋបាលឃុំសង្កាត់ ដែលបញ្ជាក់ពីអំណាច ភារកិច្ច និង មុខងារក្រុមប្រឹក្សាឃុំនៅឡើយ។

បន្ទាប់ពីបានធ្វើការបង្រួបបង្រួមរវាងគណបក្សកាន់អំណាច និង គណបក្សសមរង្ស៊ីកាលពីខែកុម្ភៈ សម្តេចនរោត្តម សីហមុនី បានផ្តល់ការលើកលែងទោសដល់លោក សម រង្ស៊ី និង លោកជាម ចន្នី ហើយលោក ជា ប៉ូច ក៏ត្រូវបានគេដកពាក្យបណ្តឹងវិញដែរ។ បន្ទាប់មករដ្ឋសភាជាតិបានធ្វើការបោះឆ្នោតផ្តល់អភ័យឯកសិទ្ធិ និង ឋានៈសមាជិកសភាឡើងវិញ។ លោក សម រង្ស៊ី បានវិលត្រឡប់ពីក្រៅប្រទេសនៅថ្ងៃទី ១០ ខែកុម្ភៈ។

នៅខែសីហា ថ្ងៃទី១៨ សម្តេចព្រះសង្ឃរាជនៃពុទ្ធសាសនាបានលុបបំបាត់ចោលនូវបំរាមកាលពីឆ្នាំ ២០០២ ដែលហាមមិនអោយព្រះសង្ឃចូលរួមក្នុងការបោះឆ្នោត។ តែទោះជាយ៉ាងណាក៏ដោយ នៅខែវិច្ឆិការ លោកបានហាមព្រះសង្ឃមិនអោយចូលរួមក្នុងចលនានយោបាយរិះគន់ណាមួយដល់រដ្ឋាភិបាលឡើយ។

វប្បធម៌ដើមបានកំរិតតួនាទីរបស់នារីក្នុងរដ្ឋាភិបាល តែទោះជាយ៉ាងណាក៏ដោយ នារីជាផ្នែកមួយយ៉ាងសកម្មនៅក្នុងការបោះឆ្នោតឆ្នាំ ២០០៣។ ចំនួននារីនៅក្នុងសភា ព្រឹទ្ធសភាជាតិ និង តួនាទីក្នុងជួររដ្ឋាភិបាលជាន់ខ្ពស់បានកើនឡើង។ មាននារី ២២ នាក់នៅក្នុងចំណោមកៅអីទាំង ១២៣ របស់សភាជាតិ នារី ៩ នាក់នៅក្នុងកៅអីទាំង ៦១ នៅព្រឹទ្ធសភា ហើយនារី ២៤ រូបធ្វើជារដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងសមាជិកស្របច្បាប់របស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត។ នារីបំរើការងារជាទីប្រឹក្សា ហើយមានចៅក្រម ១៤ នាក់ជានារីនៅក្នុងតុលាការទូទាំងខេត្ត ក្រុង និងសាលាឧទ្ធរណ៍។ បន្ទាប់ពីការបោះឆ្នោតថ្នាក់ជាតិនាឆ្នាំ ២០០២ នារីកាន់កាប់ ៩៣៣ សំលេង ដែលស្មើរនឹង ៨.៣ ភាគរយនៃ ១១,២៦១ សំលេងនៃកៅអីសរុបរបស់ក្រុមព្រឹក្សាឃុំ-សង្កាត់។

ក្រុមជនជាតិភាគតិចក៏មានតួនាទីនៅក្នុងរដ្ឋាភិបាលដែរ។ មានសមាជិកសភាជាតិ ៤ នាក់ជាជនជាតិភាគតិចដែល ២ នាក់ជាជនជាតិចាម និង ២ នាក់ទៀតជាកុលសម្ព័ន្ធដើម។ នៅក្នុងព្រឹទ្ធសភាក៏មានជនជាតិភាគតិច ៦ នាក់ជាសមាជិកផងដែរ ដែលរួមមាន ២ នាក់ជាជនជាតិចាម ២នាក់ជាកុលសម្ព័ន្ធដើម និង ២ នាក់ជាជនជាតិថៃ។ យ៉ាងហោចណាស់ មានមនុស្ស ៨ នាក់មកពីក្រុមជនជាតិភាគតិចកាន់តួនាទីជាមន្ត្រីថ្នាក់ខ្ពស់ស្របច្បាប់នៅក្នុងជួររដ្ឋាភិបាល។

**អំពើពុករលួយរបស់រដ្ឋាភិបាល និងតម្លាភាព**

អំពើរពុករលួយត្រូវបានចាត់ទុកជាជំងឺរ៉ាំរ៉ៃ និង បន្តរអូសបន្លាយយ៉ាងយូរនៅគ្រប់ចំណែកនៃសង្គម រួមទាំងអង្គនីតិបញ្ញត្តិ នីតិប្រតិបត្តិ និង តុលាការរបស់រដ្ឋាភិបាល។ ទស្សនាទានសាធារណៈនៃអំពើរពុករលួយបានរីក

សាយភាយយ៉ាងខ្លាំង។ ប្រាក់បៀវត្សន៏តិចតួច ជាមូលហេតុដើមមួយនៃ "ការរស់រានរបស់អំពើរពុករលួយ " នៅក្នុងជួរអ្នកបំរើការងារសាធារណៈថ្នាក់ទាប រីឯវប្បធម៌និទណ្ឌភាពកំពុងនាំអោយអំពើពុករលួយកាន់តែរីកលូតលាស់បានយ៉ាងល្អនៅក្នុងជួរមន្ត្រីជាន់ខ្ពស់។ នៅខែមករា ឆ្នាំ២០០៥ សម្តេចនាយករដ្ឋមន្ត្រីបានណែនាំអោយក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច អោយរៀបចំសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ។ នៅចុងឆ្នាំច្បាប់នេះបានជាប់គាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី។ សម្តេចនាយករដ្ឋមន្ត្រីមានប្រសាសន៏ថា ពង្រាងច្បាប់នេះត្រូវដើរស្របគ្នាទៅនឹងក្រិតក្រមនីតិវិធីព្រហ្មទណ្ឌ។

នៅខែមិថុនា ធនាគារពិភពលោកបានប្រកាសថា ការធ្វើសវនកម្មបានរកឃើញអំពើរពុករលួយលើគំរោងដែលឧបត្ថម្ភមូលនិធិដោយធនាគារពិភពលោកសរុបជាទឹកប្រាក់ចំនួន ៦៨.៤លានដុល្លារសហរដ្ឋអាមេរិក។ ធនាគារបានធ្វើការបញ្ឈប់គំរោងទាំងនោះ ហើយទាមទារអោយមានការសងវិញនូវទឹកប្រាក់ចំនួន ៧.៦ លានដុល្លារសហរដ្ឋអាមេរិកសំរាប់ការប្រើខុសគោលដៅ។ ក្រសួងទំនាក់ទំនងសភា-ព្រឹទ្ធសភា និងអធិការរកិច្ច ដែលជាស្ថាបន័មួយប្រឆាំងនឹងអំពើពុករលួយបានធ្វើការស៊ើបអង្កេតមួយ ដែលនាំទៅដល់ការឃាត់ខ្លួនអ្នកចាត់ការទូទៅរបស់ក្រសួងអភិវឌ្ឍន៏ជនបទមួយរូប។ នៅថ្ងៃទី១ ខែកញ្ញា តុលាការក្រុងភ្នំពេញបានដោះលែងមន្ត្រីជាប់ឃុំនោះអោយនៅក្រៅឃុំដោយសារកង្វះខាតឯកសារ។

នៅខែសីហា ឆ្នាំ២០០៥ ច្បាប់បណ្ណសារជាតិ អនុញ្ញាតអោយមានការរុករកព័តិមានដោយសេរីលើឯកសារនៅក្នុងបណ្ណសារសាធារណៈ។ តែទោះជាយ៉ាងណាក៏ដោយ ច្បាប់បានផ្តល់លទ្ធភាពដល់ការរុករកឯកសាររដ្ឋាភិបាលមិនជាក់លាក់នានាដែលកន្លងផុតទៅ ២០ ឆ្នាំរួចហើយប៉ុណ្ណោះ ហើយឯកសារដែលពាក់ពន្ធ័នឹងសន្តិសុខជាតិ និង ការអភិរក្សដល់ជីវិតឯកជន នឹងត្រូវផ្សព្វផ្សាយនៅបន្ទាប់ពី ៤០ ទៅ ១២០ ឆ្នាំ។ ជាការអនុវត្តន៏ជាក់ស្តែងរដ្ឋាភិបាលតែងតែបដិសេធការរុករកព័ត៌មាន ដោយលើកហេតុផលថា ជាការសំងាត់ ឬជាសន្តិសុខជាតិ។

## ផ្នែកទី ៤ អាកប្បកិរិយារបស់រដ្ឋាភិបាលចំពោះការស៊ើបអង្កេតរបស់ស្ថាប័នមិនមែនរដ្ឋាភិបាល និង ស្ថាប័នអន្តរជាតិលើការរំលោភសិទ្ធិមនុស្ស

ក្រុមសិទ្ធិមនុស្សជាតិ និងអន្តរជាតិជាច្រើនតែងតែធ្វើប្រតិបត្តិការធ្វើការស៊ើបអង្កេត និង ការបោះពុម្ពផ្សាយលទ្ធផលស្តីពីករណីសិទ្ធិមនុស្សដែលពួកគេរកឃើញ ដោយមិនមានការដាក់កំរិតណាមួយពីរដ្ឋាភិបាលឡើយ។ រដ្ឋាភិបាល ជាទូទៅ ធ្វើកិច្ចសហការជាមួយបុគ្គលិកសិទ្ធិមនុស្សនៅក្នុងការដំណើរការការស៊ើបអង្កេតរបស់ពួកគេ តែទោះជាយ៉ាងណា ក៏មានរបាយការណ៏ជាច្រើនស្តីពីកង្វះខាតកិច្ចសហការ ឬ មានការបំភ័យពីអាជ្ញាធរមូលដ្ឋាននៅពាសពេញផ្ទៃប្រទេសផងដែរ។

មានអង្គការក្រៅរដ្ឋាភិបាលប្រមាណជា ៤០ ធ្វើសកម្មភាពពាក់ពន្ធ័ទៅនឹងសិទ្ធិមនុស្ស ប៉ុន្តែមានតែមួយចំនួនតូចប៉ុណ្ណោះដែលចូលរួមយ៉ាងសកម្មក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល ឬ ធ្វើការស៊ើបអង្កេតលើអំពើហិង្សា។

នៅខែមីនា តាមការស្នើសុំពីអង្គការនានា រដ្ឋាភិបាលបានចេញបញ្ជាឱ្យដោះលែងមនុស្សចំនួន ១៨ នាក់ ដែលត្រូវបានឃាត់ខ្លួន និង ដាក់ឃុំចំពោះបញ្ហាជំលោះដីធ្លីនៅចុងឆ្នាំ២០០៥។

ទោះបីជារដ្ឋាភិបាលថ្នាក់កណ្តាលធ្លាប់មានកិច្ចសហការ អង្គការសិទ្ធិមនុស្សបានប្រឈមមុខនឹងការគំរាមកំហែង និង ការយាយីរំខានជាច្រើនពីមន្ត្រីថ្នាក់មូលដ្ឋាន។ នេះបានធ្វើឱ្យមានការដាក់កំរិតលើការប្រមូលទិន្នន័យរបស់អង្គការក្រៅរដ្ឋាភិបាល តាមរយៈការសំលុតបំភ័យដោយពាក្យសំដី ការគំរាមគំហែងដោយសកម្មភាពស្របច្បាប់ ឧបសគ្គការិយាលយ័និយម និង សកម្មភាពរំខានផ្សេងៗទៀត។ ក្នុងកំឡុងពេលនៃឆ្នាំនេះ អង្គការអាដហុកបានរាយការណ៍ពីបណ្តឹងចំនួន ៧ ដែលក្នុងនោះសកម្មជន និង អ្នកស៊ើបអង្កេតរបស់ពួកគេ ត្រូវបានហាមឃាត់ និង រារាំង ឬ បំភ័យដោយអាជ្ញាធរមូលដ្ឋាននានា។ លើសពីនេះទៀត រដ្ឋាភិបាលមិនបានផ្តល់កិច្ចសហការពេញលេញជាមួយការស៊ើបអង្កេតរបស់អង្គការក្រៅរដ្ឋាភិបាលលើការសំលាប់ក្រុមជនជាប់ទោសនៅខេត្តបាត់ដំបង នាខែមីនានោះឡើយ។

នៅថ្ងៃទី ២២ ខែឧសភា ក្រុមល្បាតព្រៃឈើពីអង្គការសត្វព្រៃ និង ក្រសួងបរិស្ថាននៅស្រុកមណ្ឌលសីម៉ា នាខេត្តកោះកុង បានឃាត់ខ្លួនសកម្មជនរបស់អង្គការអាដហុក និង បំផ្លាញចោលហ្វីលក្នុងម៉ាស៊ីនថតរូបរបស់គាត់ ក្រោយពេលគាត់ព្យាយាមថតយករូបភាពជម្លោះរវាងប្រជាជន និង ក្រុមល្បាត។ គាត់បានដាក់ពាក្យបណ្តឹងទៅតុលាការខេត្ត ក្នុងពេលប៉ុន្មានថ្ងៃក្រោយឧប្បត្តិហេតុ។ លោកក្រឡាបញ្ជីបានបើកការស៊ើបអង្កេតមួយក្នុងករណីនេះ ប៉ុន្តែរហូតដល់ចុងឆ្នាំហើយ នៅមិនទាន់ធ្វើការសំរេចចិត្តនៅឡើយ។ នៅខែឧសភា អ្នកឃ្លាំមើលមកពីអង្គការអាដហុក លីកាដូ និង មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានឃុំខ្លួន និង គំរាមគំហែងដោយការភ្ជង់កាំភ្លើងពីសំណាក់មន្ត្រីប៉ូលីសខេត្តកំពត នៅខណៈពេលដែលចុះធ្វើការស៊ើបអង្កេតជម្លោះដីធ្លីមួយកន្លែង។ នៅក្នុងករណីផ្សេងទៀត អង្គការលីកាដូបានធ្វើសេចក្តីរាយការណ៍ថា មានកងកំលាំងប្រដាប់អាវុធដែលគេមិនស្គាល់អត្តសញ្ញាណបានធ្វើការគំរាមកំហែងដល់អ្នកត្រួតពិនិត្យសិទ្ធិមនុស្សមកពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ២ ដោយមានភ្ជង់កាំភ្លើង និង ធ្វើការវាយតប់លើក្បាលពោះ នៅខណៈពេលដែលពួកគេធ្វើការឃ្លាំមើលជម្លោះដីធ្លីមួយកន្លែង នៅខេត្តមណ្ឌលគីរី។

ខុសពីឆ្នាំ ២០០៥ ឆ្នាំនេះមិនមានការគំរាមគំហែងគួរអោយកត់សំគាល់ណាមួយប្រឆាំងចំពោះបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលផ្តល់ជំរកដល់ជនរងគ្រោះពីការជួញដូរ និង ធ្វើការតស៊ូមតិប្រឆាំងការជួញដូរ និង ការស៊ើបអង្កេតនានានោះឡើយ។

ក្នុងកំឡុងពេលមួយឆ្នាំៗ អង្គការ UNHCHR ធ្វើសកម្មភាពទាក់ទងនឹងសិទ្ធិមនុស្ស និង យុត្តិធមិ ព្រមទាំងបានដាក់ការិយាល័យកណ្តាលរបស់ខ្លួននៅទីក្រុងភ្នំពេញ និង ការិយាលយ័តំបន់ នៅខេត្តបាត់ដំបង។ តំណាងពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានបំពេញនូវបេសកកម្មទី ២ របស់ខ្លួននៅខែមីនា ក្រោយការតែងតាំងនា ខែវិច្ឆិការ ឆ្នាំ២០០៥។ នៅលើវេទិការសាធារណៈថ្ងៃទី ២៨ ខែមិនា គាត់បានធ្វើការសង្កត់ធ្ងន់លើតំរូវការឯករាជ្យភាព និង ប្រពន្ធ័តុលាការរឹងមាំ ដើម្បីដកចេញនូវបញ្ហានៃនិទណ្ឌភាពដែលជាហេតុ

បង្កឱ្យមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរជាច្រើននៅក្នុងប្រទេស។ គាត់ក៏បានធ្វើការកត់ត្រាពីភាពមិនសប្បាយចិត្ត ដែលថា រដ្ឋាភិបាលមិនបានបើកកកាយព័ត៌មានសម្បទានធនធានធម្មជាតិ និង សំគាល់ឃើញថា ព័ត៌មានអំពីដីសម្បទាន មានការធ្លាក់ចុះក្រោមការរំពឹងទុក។

គណៈកម្មាធិការសិទ្ធិមនុស្សរបស់កម្ពុជា ដែលបង្កើតឡើងដោយរដ្ឋាភិបាលកម្ពុជានាឆ្នាំ ១៩៩៨ នៅតែមិនមានសកម្មភាពដដែលនៅក្នុងសង្គម។ គណៈកម្មាធិការមិនមានការប្រជុំជាប្រចាំ ឬដំណើរការប្រតិបត្តិការដែលមានតម្លាភាពណាមួយឡើយ។

## ផ្នែកទី៥ ការរើសអើង អំពើហិង្សាក្នុងសង្គម និង ការជួញដូរមនុស្ស

រដ្ឋធម្មនុញ្ញកម្ពុជា ធ្វើការហាមឃាត់មិនអោយមានការរើសអើងលើជាតិសាសន៍ ភេទ ពណ៌សម្បុរ ឬភាសាឡើយ តែទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនបានធ្វើការការពារលើសិទ្ធិទាំងនោះឡើយ។

### ស្ត្រី

ច្បាប់បានហាមប្រាមមិនអោយមានការរំលោភ និងការធ្វើបាបនារីភេទឡើយ តែទោះជាយ៉ាងណានៅមានរបាយការណ៍ពីអង្គការជាតិ និង អន្តរជាតិស្តីពីអំពើហិង្សាប្រឆាំងនារីភេទ រួមមាន ការប្រើអំពើហិង្សាក្នុងគ្រួសារ និង ការចាប់រំលោភ នៅជាបញ្ហាដដែល។ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ដែលត្រូវបានឆ្លងនាឆ្នាំ ២០០៥ ធ្វើការដាក់ទោសលើអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែមិនទាន់បានដាក់ចេញនូវក៏រិតទោសនៅឡើយនោះទេ។ តែទោះជាយ៉ាងណាក៏ដោយ មាត្រាទី៤១ នៃច្បាប់របស់អ៊ុនតាក់ ស្តីពីការរំលោភ និង ការបង្ករបួសស្នាម អាចត្រូវបានប្រើដើម្បីដាក់ទណ្ឌកម្មដល់ជនល្មើសដែលប្រើអំពើហិង្សាក្នុងគ្រួសារ ជាមួយនឹងទណ្ឌកម្មនានាទៀតដែលមានការដាក់ទោសជាប់ពន្ធនាគារចាប់ពី ២ ខែ ទៅ ៥ ឆ្នាំ។ ការរំលោភ គឺជាបទល្មើសព្រហ្មទណ្ឌ និង អាចទទួលទំងន់ទោសដោយការកាត់អោយជាប់ពន្ធនាគារពី ៥ ទៅ ១០ ឆ្នាំ យោងតាមមាត្រាទី ៣៣នៃច្បាប់របស់អ៊ុនតាក់។ ការរំលោភប្រពន្ធ និង ការប្រើអំពើហិង្សាក្នុងគ្រួសារ មិនត្រូវបានរាប់ថាជាទោសតែមួយនោះទេ។ ករណីរំលោភប្រពន្ធ អាចត្រូវបានកាត់ទោសថាជាអំពើរំលោភ បង្ករបួសស្នាម ឬ ការរំលោភបំពានឃោឃៅ ប៉ុន្តែទោសទាំងនេះកំរមានណាស់។ យោងតាមអង្គការក្រៅរដ្ឋាភិបាលមួយដែលធ្វើការនៅក្នុងខេត្ត ៣ បានអោយដឹងថា មាន ៨២៧ ករណីនៃអំពើហិង្សាក្នុងគ្រួសារ ក្នុងនោះមាន ៦ ករណីដែលបណ្តាលអោយមានមនុស្សស្លាប់។ ក្នុងមួយឆ្នាំនេះ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សរបស់ក្រសួងមហាផ្ទៃ បានធ្វើការស៊ើបអង្កេតលើ ៦១៤ ករណីនៃអំពើហិង្សាប្រឆាំងស្ត្រី និងកុមារ ឈានទៅដល់ការចាប់ខ្លួនឧក្រិដ្ឋជនចំនួន ៦៧០ នាក់ និង សង្គ្រោះបានជនរងគ្រោះចំនួន ៧៨៤ នាក់។ ក្នុងចំនោមជនល្មើស ៦៧០ នាក់ដែលត្រូវបានចាប់ខ្លួន មាន ៤៧៧នាក់ជាប់ចោទពីបទប៉ុនប៉ងរំលោភ និង រំលោភសេពសន្ធវៈ។ មានករណីរំលោភសេពសន្ធវៈចំនួន ១៤ ករណីដែលបណ្តាលអោយជនរងគ្រោះបាត់បង់ជីវិត។ នៅក្នុងកំឡុងពេលនៃឆ្នាំ ជំនួយផ្លូវច្បាប់ពីអង្គការក្រៅរដ្ឋាភិបាលមួយបានរាយការណ៍ពី ៤១៧ ករណីនៃអំពើរហិង្សា

ប្រឆាំងស្ត្រី និងកុមារ រួមទាំងការជួញដូរ អំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ។ ក្នុងចំណោមទាំង ៤១៧ ករណី មាន ១៦៦ ករណីត្រូវបានជំនុំជំរះ ដែលក្នុងនោះមាន ១១៤ ករណីត្រូវបានកាត់ទោស។ ជនជាប់ចោទក្នុងករណីផ្សេងទៀត ត្រូវបានដោះលែងអោយមានសេរីភាព ដោយសារតែខ្វះភស្តុតាងបញ្ជាក់ ឬដោយសារតែជនរងគ្រោះបានដកពាក្យបណ្តឹងរបស់ខ្លួនចេញ។ ចំនួនករណីហាក់នៅមិនសូវបានធ្វើការរាយការណ៍ពីវិសាលភាពនៃបញ្ហា ដោយសារអសមត្ថភាពនៃការអនុវត្តន៏ច្បាប់ និង ដោយសារស្ត្រីមានការភ័យខ្លាចមិនហ៊ានធ្វើការប្តឹងប្រឆាំងជនល្មើស។ តែទោះជាមានការអនុមត័ច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារនាឆ្នាំ ២០០៥ ក៏ដោយ ក៏របាយការណ៏របស់អង្គការក្រៅរដ្ឋាភិបាលថា អាជ្ញាធរនៅតែបន្តមិនលូកដៃចូលក្នុងបញ្ហាអំពើហិង្សាក្នុងគ្រួសារឡើយ ហើយជនរងគ្រោះតែងតែមានការស្ទាក់ស្ទើរក្នុងការធ្វើពាក្យបណ្តឹងស្របច្បាប់។

ពេស្យាចារត្រូវបានហាមឃាត់ដោយច្បាប់រដ្ឋធម្មនុញ្ញ តែទោះជាយ៉ាងណាក៏មិនមានស្ថាបន័ច្បាប់ជាក់លាក់ណាមួយប្រឆាំងការបំរើការងារជាពេស្យាចារឡើយ។ ការជួញដូរស្ត្រីដើម្បីធ្វើជាពេស្យាចារ គឺជាបញ្ហាធ្ងន់ធ្ងរមួយ បើទោះបីជាមានច្បាប់ប្រឆាំងការបង្ខាំង និងចាប់ជំរិតមនុស្សដើម្បីកេងប្រវ័ញ្ចលើផ្លូវភេទក៏ដោយ (មើលផ្នែកទី ៥ ស្តីពីការជួញដូរមនុស្ស)។ មានរបាយការណ៏ដែលថា មន្រ្តីប៉ូលីសកេ្បៀសង្កត់លើពេស្យាចារ។ ថ្វីបើមានការចាត់វិធានការណ៏ម្តងម្កាលចំពោះប្រតិបត្តិការពេស្យាចារនានានៅក្រុងភ្នំពេញក៏ដោយ ក៏ពេស្យាចារ និង ការជួញដូរមនុស្សប្រភេទនេះនៅតែកើតមាន។ ចំនួនប៉ាន់ស្មាននៃពេស្យាចារដែលធ្វើការមានពី ១៤,៧២៥ នាក់ ទៅ ១៨,២៥០ នាក់។ ទេសចរណ៏ផ្លូវភេទ ជាបញ្ហាមួយបណ្តាលមកពីភាពក្រីក្រ និង ទស្សនៈមិនមានការដាក់ទោស។

ច្បាប់ការងារមានខចែងនានាប្រឆាំងនឹងការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ ហើយអង្គការអន្តរជាតិមួយបានធ្វើរបាយការណ៏ដែលថា ការបៀតបៀនផ្លូវភេទបែបនេះនៅផ្នែកឧស្សាហ៏កម្ម គឺកំរមានណាស់។

តែទោះជាយ៉ាងណាក៏ដោយ ការសិក្សាមួយរបស់អង្គការក្រៅរដ្ឋាភិបាលនាឆ្នាំ ២០០៥ ដែលធ្វើឡើងចំពោះស្ត្រីបំរើការងារជានារីផ្សព្វផ្សាយស្រាបៀរ បានធ្វើរបាយការណ៏ថា មានការបៀតបៀនផ្លូវភេទជីរកសុះសាយ។

មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួនធំបានផ្តល់វគ្គបណ្តុះបណ្តាលដល់ស្ត្រីក្រីក្រ និងងាយរងគ្រោះ ដែលមានបញ្ហាសង្គមដូចជា ទទួលការរំលោភបំពានពីប្តី ពេស្យាចារ និងការជួញដូរជាដើម។ មជ្ឈមណ្ឌលព័ត៌មានក្នុងស្រុកមួយបានផលិត និងផ្សព្វផ្សាយកម្មវិធីស្តីពីបញ្ហានានារបស់ស្ត្រី។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនផ្តល់ជំរកសំរាប់ស្ត្រីមានវិបត្តិនានា។

រដ្ឋធម្មនុញ្ញមានភាសាជាក់លាក់ ដែលផ្តល់សិទ្ធិស្មើគ្នាដល់ស្ត្រី ផ្តល់ប្រាក់កំរៃស្មើគ្នាចំពោះកិច្ចការដូចគ្នា និងថានៈដូចគ្នានៅក្នុងអាពាហ៏ពិពាហ៏។ ជាការអនុវត្តន៏ ស្ត្រីមានសិទ្ធិស្មើគ្នា មានថានៈស្របច្បាប់ស្មើគ្នាក្នុងដំណើរការលែងលះ និងមានសិទ្ធិទទួលការសិក្សា និងការងារស្មើគ្នា។ តែទោះជាយ៉ាងណាក៏ដោយ ក៏ទំនៀមទំលាប់ប្រពៃណីបន្តដាក់កំរិតលើសមត្ថភាពរបស់ស្ត្រីក្នុងការទទួលតួនាទីខ្ពស់ នៅក្នុងអាជីវកម្ម និងផ្នែកផ្សេងៗទៀត។ ស្ត្រីតែងតែត្រូវបានជំរុញអោយធ្វើការដែលមានកំរៃទាប និងត្រូវដកចេញពីតួនាទីដឹកនាំនានា។ បុរសមានចំនួនដ៏ច្រើននៅក្នុងជួរកងទ័ព នគរបាល និង សេវាកម្មស៊ីវិល។

ក្រសួងកិច្ចការនារីមានតួនាទីការពារ និងលើកស្ទួយសមភាពយែនឌ័រនៅក្នុងសង្គម ដោយបានបន្តដំណើរការកម្មវិធីនារីរតនៈរបស់ខ្លួន (ស្ត្រីជាត្បូងដ៏មានតំលៃ)។ កម្មវិធីមានគោលដៅដើម្បីជំរុញរូបភាពស្ត្រីតាមរយៈការបញ្ជ្រាបយែនឌ័រ ជំរុញអោយស្ត្រីចូលរួមក្នុងជីវភាពសេដ្ឋកិច្ច និងនយោបាយ និងការការពារសិទ្ធិស្ត្រី។ ទំនោរប្រជាពលរដ្ឋ និងប្រវត្តិសាស្ត្រនៃជម្លោះ បាននាំអោយមានកំណើនការចូលរួមរបស់ស្ត្រីនៅក្នុងកំលាំងការងារ។ នៅឆ្នាំ ២០០៤ ស្ត្រីមាន ៥៤ ភាគរយជាកម្មករនៅក្នុងវិស័យកសិកម្ម ៥១ ភាគរយនៅក្នុងវិស័យឧស្សាហ៍កម្ម និង ៤៦ ភាគរយនៅក្នុងវិស័យសេវាកម្ម។

**កុមារ**

រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិដល់កុមារ ហើយរដ្ឋាភិបាលបានកំនត់សុខមាលភាពកុមារឱ្យមានគោលដៅជាក់លាក់។ រដ្ឋាភិបាលពឹងផ្អែកទៅលើជំនួយអន្តរជាតិដើម្បីឧបត្ថម្ភដល់កម្មវិធីសុខមាលភាពសង្គមរបស់កុមារជាច្រើន ដែលនាំអោយមានតែមូលនិធិតិចតួចប៉ុណ្ណោះសំរាប់ដោះស្រាយបញ្ហាដែលមានផលប៉ះពាល់ដល់កុមារ។

កុមារត្រូវទទួលផលប៉ះពាល់ពីកង្វះខាតប្រព័ន្ធអប់រំ។ ការសិក្សាគឺមិនមានគិតថ្លៃឡើយរហូតដល់ថ្នាក់ទី ៩ តែមិនមានការដាក់កំរិតឡើយ។ មានកុមារជាច្រើនបានបោះបង់ចោលការសិក្សារបស់ពួកគេ ដើម្បីជួយគ្រួសារនៅក្នុងការធ្វើកសិកម្ម ខ្លះចូលរៀនយឺត ឬ មិនចូលសាលាតែម្តង។ របាយការណ៍មួយរបស់ក្រសួងអប់រំនាឆ្នាំ ២០០៥ បានបង្ហាញថា មាន ៩១ ភាគរយនៃកុមារគ្រប់អាយុ ត្រូវបានចុះឈ្មោះអោយចូលរៀននៅបឋមសិក្សា តែមានតែ ២៦ភាគរយប៉ុណ្ណោះដែលបន្តចូលរៀនទៅថ្នាក់មធ្យមសិក្សា ហើយ ៩ ភាគរយទៀតរៀនថ្នាក់វិទ្យាល័យ។ បើទោះជាមានកម្មវិធីសាងសង់សាលាបន្ថែមក៏ដោយ សាលារៀនមានចំនួនសិស្សច្រើនហួស និងមានកង្វះខាតឧបករណ៍។ នៅជនបទ សាលារៀនផ្តល់ការអប់រំបានតែ ២-៣ ឆ្នាំប៉ុណ្ណោះ។ យោងតាមទិន្នន័យរបស់ក្រសួង ៤៦ ភាគរយនៃសាលារៀនខ្វះទឹកស្អាតសំរាប់ប្រើប្រាស់ ហើយ ៣៧ ភាគរយមិនមានបន្ទប់ទឹក។ ប្រាក់បៀវត្សន៍របស់គ្រូបើកមិនបានទៀងទាត់ និង មិនគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ជីវភាព ដែលតំរូវឱ្យគ្រូទារប្រាក់បន្ថែមពីសិស្ស ដែលប្រការនេះធ្វើឱ្យគ្រួសារជនក្រីក្រមិនអាចមានលទ្ធភាព។ រដ្ឋាភិបាលមិនបានបដិសេធសិទ្ធិរបស់កុមារីក្នុងការទទួលយកការអប់រំនោះឡើយ តែគ្រួសារដែលមានធនធានមានកំរិត ផ្តល់អាទិភាពដល់កុមារាក្នុងការទទួលយកការសិក្សា។ នៅតំបន់ជាច្រើន សាលារៀនស្ថិតនៅដាច់ស្រយ៉ាល ហើយការធ្វើដំណើរគឺជាបញ្ហាដ៏ចំបងមួយ។ បញ្ហានេះមានផលប៉ះពាល់ដល់កុមារីជាពិសេសដោយសារការព្រួយបារម្ភពីសុវត្ថិភាពក្នុងការធ្វើដំណើរ រវាងផ្ទះពួកគេ និងសាលារៀន។

កុមារតែងទទួលរងគ្រោះដោយកង្វះអាហាររូបត្ថម្ភ ហើយប្រព័ន្ធថែទាំសុខភាពក៏មានកង្វះខាតផងដែរ។ យោងតាមរបាយការណ៍ស្តីពីការសិក្សាលើចំនួនប្រជាជន និងសុខភាពឆ្នាំ ២០០៥ អត្រាមរណៈរបស់ទារកត្រូវបានប៉ាន់ស្មានពី ៦៥ ក្នុងចំណោម ១ ០០០ នាក់។ ក៏មានការប៉ាន់ស្មានផងដែរពីអត្រាមរណៈរបស់កុមារដែលមាន ១៩ នាក់ ក្នុងចំណោម ១ ០០០ នាក់។

អំពើហិង្សាលើកុមារត្រូវបានគេជឿថា មានចំនួនច្រើន បើទោះបីជាមិនមានស្ថិតិណាមួយមកបញ្ជាក់ក៏ដោយ។ អង្គការក្នុងស្រុកមួយបានធ្វើការប៉ាន់ស្មានថា មានកុមារតាមចិញ្ចើមថ្នល់ចំនួន ១ ២០០ នាក់នៅភ្នំពេញដែលមិនមានទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់ពួកគេឡើយ ហើយមានកុមារជាង ១០ ០០០ នាក់ទៀតធ្វើការនៅតាមចិញ្ចើមថ្នល់រួចត្រឡប់ចូលផ្ទះវិញនៅពេលល្ងាច។ មានកុមារប្រមាណ ៥០០ - ១ ៥០០ នាក់រស់នៅតាមចិញ្ចើមថ្នល់នៃទីប្រជុំជនខេត្តជាមួយគ្រួសាររបស់ពួកគេ។ អង្គការក្រៅរដ្ឋាភិបាលមួយបានធ្វើរបាយការណ៍ថា មានកុមារតាមចិញ្ចើមថ្នល់ប្រមាណ ៦០ នាក់នៅរៀងរាល់ខែ ចូលក្នុងកន្លែងស្នាក់នៅរបស់ខ្លួនដើម្បីទទួលយកការអប់រំវិជ្ជាជីវៈ និង អក្សរ។ អង្គការ ដដែលបានធ្វើសេចក្តីរាយការណ៍ថា គេសង្កេតឃើញកុមារពី ៨០ ទៅ ១០០នាក់ថ្មីទៀតនៅតាមចិញ្ចើមថ្នល់រៀងរាល់ខែ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងស្តារយុវនិតិសម្បទា ផ្តល់ស្ថិតិតិចជាងនេះ ដែលរាយការណ៍ថា មានកុមារតាមចិញ្ចើមថ្នល់តែ ៣ ០៨៤ នាក់ប៉ុណ្ណោះនៅទូទាំងប្រទេសនាឆ្នាំ ២០០៥។

បញ្ហានៃការរំលោភបំពានផ្លូវភេទលើកុមារនៅតែជាបញ្ហាធ្ងន់ធ្ងរដដែល ដោយមានអង្គការក្រៅរដ្ឋាភិបាលមួយធ្វើសេចក្តីរាយការណ៍ថា មាន ២០៦ ករណីនៃការរំលោភបំពានផ្លូវភេទលើកុមារដែលធ្វើឡើងចំពោះកុមារដែលមានអាយុក្រោម ១៨ ឆ្នាំ ដែល ៥ ករណីក្នុងនោះនាំអោយមានការស្លាប់។ នៅក្នុងឆ្នាំដដែលមាន ២១ ករណីនៃការរំលោភបំពានផ្លូវភេទដែលពាក់ពន្ធ័នឹងកុមារក្រោមអាយុ ៥ ឆ្នាំ ត្រូវបានធ្វើសេចក្តីរាយការណ៍ ដែលក្នុងនោះមាន ៥ នាក់ជាកុមារអាយុ ៣ ឆ្នាំ។

ការរួមភេទជាមួយមនុស្សមានអាយុតិចជាង ១៥ ឆ្នាំជាអំពើរល្មើសនឹងច្បាប់ តែទោះជាយ៉ាងណាក៏ដោយក៏ការធ្វើអនាចារលើកុមារ និងការជួញដូរកុមារនៅតែកើតមានឡើង (សូមមើលផ្នែកទី ៥ ការជួញដូរ)។ កម្មវិធីប្រឆាំងការកេងប្រវ័ញ្ចលើផ្លូវភេទកុមារ ៥ ឆ្នាំដំបូង ដែលត្រូវបានបញ្ចប់នាឆ្នាំ ២០០៥ សង្កត់ធ្ងន់លើការការពារតាមរយៈការផ្សព្វផ្សាយព័ត៌មាន និង ការការពារដោយការអនុវត្តន៍ច្បាប់ (សូមមើលផ្នែកទី ៥ ការជួញដូរ)។ របាយការណ៍របស់ក្រសួងមហាផ្ទៃបានរាយការណ៍ពីការចាប់ខ្លួនជនបរទេសចំនួន ១២ នាក់ដែលជាអ្នកប្រព្រឹត្តអំពើអនាចារនៅក្នុងឆ្នាំនោះ។

ការទិញដូរកុមារសំរាប់ធ្វើជាពេស្យាចារ គឺជាបញ្ហាមួយ។ នៅក្នុងឆ្នាំនោះ តាមរយៈការឆ្មក់ចូលក្នុងផ្ទះបន យើងសង្គ្រោះបានក្មេងស្រីមិនទាន់គ្រប់អាយុជាច្រើនដែលត្រូវបានគេជួញដូរអោយធ្វើជាស្រីពេស្យា(សូមមើលផ្នែកទី ៥ ការជួញដូរ)។

ពលកម្មកុមារ ក៏ជាបញ្ហាមួយនៅក្នុងផ្នែកមិនផ្លូវការនៃសេដ្ឋកិច្ចផងដែរ (សូមមើលផ្នែកទី ៦.ឃ.)។

**ការជួញដូរមនុស្ស**

ច្បាប់បានធ្វើការហាមប្រាមការជួញដូរមនុស្ស តែទោះជាយ៉ាងណាក៏ដោយ ប្រទេសនេះគឺជាប្រភព គោលដៅ និង ជាប្រទេសឆ្លងកាត់សំរាប់បុរស ស្ត្រី និង កុមារ ដែលត្រូវបានជួញដូរដើម្បីកេងប្រវ័ញ្ចលើផ្លូវភេទ និងពលកម្ម។ ការសិក្សានៅឆ្នាំ ២០០៣ ធ្វើការប៉ាន់ស្មានចំនួនជនរងគ្រោះដោយការជួញដូរក្នុងឧស្សាហ៍កម្មផ្លូវភេទ

បានបង្ហាញចំនួនដល់ទៅ ២ ០០០ នាក់ ដែលប្រហែលជា ៨០ ភាគរយនៃអ្នកទាំងនោះជាស្ត្រី និងក្មេងស្រីជនជាតិវៀតណាម។ ក្មេងស្រី និងស្ត្រីវៀតណាមខ្លះ ត្រូវបានជួញដូរតាមរយៈអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងប្រទេស និង នៅតាមបណ្តាប្រទេសអាស៊ានមួយចំនួនទៀត។

កុមាត្រូវបានបញ្ជូនទៅកាន់ប្រទេសវៀតណាម និង ថៃ ដើម្បីធ្វើការសុំទាន រៃប្រាក់ លក់អីវ៉ាន់តាមផ្លូវ និង លក់ផ្កា។ កុមារតែងត្រូវគេដាក់ជាកូនបំណុល ហើយអោយដើរសុំទាន ឬ លក់ដូរ ឬ ប្រមូលផ្តុំជាផ្នែកមួយនៃក្រុមស្នូម បើទោះបីជាមិនមានជាប់បំណុល ឬ មិនមានការលំបាកសេដ្ឋកិច្ចអ្វីក៏ដោយ។ ការសិក្សាមួយរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងស្តារយុវនិតិសម្បទា បានរកឃើញថា មាន ៧៦ ភាគរយនៃមនុស្សដែលត្រូវជួញដូរទៅប្រទេសថៃ បានចេញពីគ្រួសារដែលមានដីខ្លួនឯង, ៩៣ ភាគរយមានផ្ទះ និងមានជាប់បំណុលដី ឬផ្ទះ, ហើយ ៤៧ ភាគរយទៀតនិយាយថាម្តាយរបស់ពួកគេជាអ្នកសំរបសំរួល។ មានការកើនឡើងក្នុងការជួញដូរស្ត្រីទៅកាន់ប្រទេសម៉ាឡេស៊ី ដើម្បីបំរើការក្នុងឧស្សាហ៏កម្មផ្លូវភេទ។

ជនរងគ្រោះដោយការជួញដូរ ជាពិសេសអ្នកដែលរងគ្រោះដោយការជួញដូរផ្លូវភេទ ប្រឈមមុខនឹងការឆ្លងជំងឺផ្លូវភេទជាច្រើន ដូចជា ជំងឺអេដស៍ ជាដើម។ ក្នុងករណីខ្លះជនរងគ្រោះត្រូវបានឃុំឃាំង និង ប្រើហិង្សាលើរាង្គកាយ និងផ្លូវចិត្តដោយអ្នកជួញដូរ ម្ចាស់ផ្ទះបន និង ភ្ញៀវផងដែរ។

អ្នកជួញដូរក្នុងស្រុកគ្រប់គ្រងតំបន់តូចៗ និងដើរតួរជាឈ្មួញកណ្តាលសំរាប់ប្រព័ន្ធនៃការជួញដូរ។ ក្រុមជនឧក្រិដ្ឋមានការគ្រោងទុក ភ្នាក់ងាររកការងារធ្វើ ឈ្មួញកណ្តាលក្នុងចំណោមអាពាហ៏ពិពាហ៏ ត្រូវបានជឿថា មានការពាក់ព័ន្ធលើបញ្ហានេះ។ អ្នកជួញដូរបានប្រើប្រាស់វិធីសាស្ត្រជាច្រើនដើម្បីទទួលយកជនរងគ្រោះ។ នៅក្នុងករណីជាច្រើន ជនរងគ្រោះត្រូវបានបោកបញ្ឆោតដោយការសន្យាផ្តល់ការងារស្របច្បាប់អោយធ្វើ។ នៅក្នុងករណីផ្សេងទៀត សន្និដ្ឋិមិត្ត មិត្តភក្តិ និង សមាជិកគ្រួសារជាច្រើន បានលក់ជនរងគ្រោះ ឬ ទទួលប្រាក់សំរាប់ការបោកបញ្ឆោតពួកគេ។ កុមារក្មេងៗដែលភាគច្រើនជាកុមារី ត្រូវបានបញ្ជូនជាក្រុមសំរាប់ការផ្តល់កំចីដល់ឱពុកម្តាយដែលក្រីក្រ។ មានក្មេងខ្លះទៀតទទួលខុសត្រូវក្នុងការបង់ប្រាក់កំចី និងការប្រាក់ដែលចេះតែមានការកើនឡើង។

ច្បាប់បានចេញបញ្ញត្តិដាក់ទោសពី ១៥ ទៅ ២០ ឆ្នាំ ដល់ជនដែលបង្កបទល្មើសជួញដូរមនុស្សក្រោមអាយុ ១៥ឆ្នាំ។ ការដាក់ពិន័យពី ១០ ទៅ ១៥ ឆ្នាំ ដល់អ្នកជួញដូរមនុស្សមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ។ យោងតាមក្រសួងព័ត៌មានបានអោយដឹងថា ក្នុងមួយឆ្នាំៗនគរបាលបានធ្វើការស៊ើបអង្កេតករណីហិង្សាប្រឆាំងស្ត្រី និងកុមារចំនួន ៦១៤ ករណី រួមមាន ការកេងប្រវ័ញ្ចផ្លូវភេទកុមារ ការំលោភសេពសន្ថវៈ ការបង្ខំ និង ការជួញដូរមនុស្សដែលក្នុងនោះមាន ៦៥ ករណីដែលត្រូវបានចាប់ខ្លួនពីបទជួញដូរមនុស្សឆ្លងដែន និងក្នុងស្រុក។ អង្គការច្បាប់ក្រៅរដ្ឋាភិបាលមួយបាននាំបទល្មើស ២៤ ករណីទៅកាន់តុលាការ ដែលក្នុងនោះមាន ៩ ករណីត្រូវបានកាត់ទោស។ មានជនជាប់ចោទក្នុង ៦ ករណី ដែលត្រូវទទួលទោសជាប់ពន្ធនាគារពី ៣ ទៅ ២០ ឆ្នាំ និង ត្រូវពិន័យជាប្រាក់ពី ៧១៥ ទៅ ៩៥០ ដុល្លារ (ស្មើនឹង ៣ ទៅ ៤ លានរៀល) ជូនដល់ជនរងគ្រោះ។

នៅក្នុងករណីនេះរដ្ឋាភិបាលបង្កើនការឃាត់ខ្លួន និងការកាត់ទោសជនប្រកបរបរជួញដូរមនុស្ស និងបន្តការគាំទ្រដល់កម្មវិធីការពារ និងបង្ការ តាមរយៈកិច្ចសហការជាមួយអង្គការជាតិ និងអន្តរជាតិ។ កិច្ចខិតខំប្រឹងប្រែងក្នុងការប្រឆាំងការជួញដូរមនុស្សបានបន្តមានការរាំងស្ទះ ដោយសារអំពើពុករលួយ និង ប្រពន្ធ័តុលាការនៅទន់ខ្សោយ។ គេជឿជាក់ថា ស្ថាបន័អនុវត្តន៏ច្បាប់ និង មន្ត្រីរដ្ឋាភិបាលមួយចំនួន បានទទួលសំណូកដែលជាថ្នូរនឹងការសំរបសំរួលដល់កាជួញដូរ និង ធ្វើអាជីវកម្មផ្លូវភេទលើមនុស្ស។

នៅខែសីហា តុលាការក្រុងភ្នំពេញបានធ្វើការចោទប្រកាន់មន្ត្រីនគរបាលចំនួន ៣ នាក់ពីបទទួលសំណូកពាក់ពន្ធ័នឹងការជួញដូរមនុស្សនាឆ្នាំ ២០០៥ ដោយវិនិច្ឆយ័អោយជាប់ពន្ធនាគាររយៈពេលពី ៥ ទៅ ៧ ឆ្នាំ និង បញ្ជាអោយបង់ប្រាក់សំណងចំនួន ៩ ០០០ ដុល្លារ ស្មើរនឹង ៣៧,៨ លានរៀល ដែលបានគំរាមយកពីម្ចាស់ផ្ទះបននានានៅខេត្តកំពង់ស្ពឺ។ មន្ត្រីជាប់ចោទម្នាក់ក្នុងចំណោមនោះ បានបន្តទទួលរងការកាត់ទោស ហើយ ២ នាក់ផ្សេងទៀតបើតាមក្រសួងមហាផ្ទៃ គឺត្រូវបានបណ្តេញចេញពីការងារមុនពេលពួកគេត្រូវបានចាប់បញ្ជូនមកដាក់ពន្ធនាគារ។

នៅខែមករា លោក ម៉េង សាយ ប្រធានក្រុមប្រឆាំងបទល្មើសជួញដូរមនុស្សនៅភ្នំពេញ ត្រូវបានព្យួរការងារ ដោយសារការគំហែងយកប្រាក់ពីជនជាតិកូរ៉េខាងត្បូង។ នៅខែសីហា គាត់ត្រូវបានឃាត់ខ្លួនចំពោះការគំរាមទារប្រាក់ ហើយនៅចុងឆ្នាំដដែល បានត្រូវគេបញ្ជូនឡើងតុលាការ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងស្តារយុវនិតិសម្បទា បញ្ជូនជនរងគ្រោះដោយការជួញដូរទៅកាន់អង្គការក្រៅរដ្ឋាភិបាល ដែលផ្តល់ជំនួយជាច្រើនដល់ជនរងគ្រោះ។ រដ្ឋាភិបាលបានចូលរួមដូចជាសមាជិកមួយដែរនៅក្នុងកិច្ចខំប្រឹងប្រែងដ៏ច្រើននេះ តែទោះជាយ៉ាងណាការចូលរួមរបស់រដ្ឋាភិបាលមានការរាំងស្ទះយ៉ាងខ្លាំងដោយសារធនធានមានកំរិត។ ជនរងគ្រោះខ្លះ ត្រូវបានជំរុញដោយអង្គការក្រៅរដ្ឋាភិបាល និង ក្រសួងមហាផ្ទៃ ដើម្បីធ្វើការប្តឹងប្រឆាំងនឹងជនល្មើស ទោះជាយ៉ាងណា នៅក្នុងទិដ្ឋភាពទូទៅនៃនិទណ្ឌភាព ការការពារជនរងគ្រោះគឺជាបញ្ហាមួយ ហើយគេដឹងថា ជនរងគ្រោះនឹងត្រូវបានគំរាមអោយបោះបង់ចោលពាក្យបណ្តឹងរបស់ខ្លួន។ ក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងស្តារយុវនិតិសម្បទា និង អង្គការក្រៅរដ្ឋាភិបាល បានរាយការណ៏ថា នៅក្នុងមួយឆ្នាំៗ មានជនរងគ្រោះប្រមាណ ៣៦៦ នាក់ដោយការជួញដូរ អ្នកសុំទាន និង អ្នកលីសែងអីវ៉ាន់ ដែលភាគច្រើននៃពួកគេគឺជាកុមារ ដែលមានចំនួនដល់ទៅ ៧០ ភាគរយ ដែលត្រូវបានធ្វើសមារហណកម្មចូលសហគមន៏របស់ពួកគេវិញ។

មានក្រសួងរបស់រដ្ឋាភិបាលមួយចំនួនចូលរួមយ៉ាងសកម្មប្រឆាំងការជួញដូរមនុស្ស។ មាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការការពារអនីតិជនមួយ ព្រមទាំងអន្តរកាីដែលមានស្រាប់សំរាប់ការឃ្លាំមើល និងការធ្វើសេចក្តីរាយការណ៏លើការកេងប្រវញ្ច័ផ្លូវភេទកុមារ។ ក៏មានផ្នែកជំនាញប្រឆាំងការជួញដូរមនុស្សរបស់ក្រសួងមហាផ្ទៃរផងដែរ នៅតាមបណ្តារខេត្ត និង ក្រុងនានានោះ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងស្តារយុវនិតិសម្បទា បានធ្វើការជាមួយអង្គការអន្តោរប្រវេសន៏អន្តរជាតិ (IOM) ដើម្បីធ្វើមាតុភូមិនិវត្តន៏ជនរងគ្រោះដោយការជួញដូរមកពីប្រទេសថៃ និង វៀតណាមមកកាន់កម្ពុជា និង ពីកម្ពុជាទៅវៀតណាមវិញ។ តែទោះជាយ៉ាងណាក៏ដោយ ការធ្វើមាតុភូមិនិវត្តន៏ទៅកាន់វៀតណាមនៅបន្តជា

ដំណើរការយ៉ាងវែង និងលំបាក។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងស្តារយុវនីតិសម្បទា នេះក៏ធ្វើការជាមួយមូលនិធិសំរាប់កុមាររបស់អង្គការសហប្រជាជាតិ និង អង្គការក្នុងស្រុកផងដែរ ដើម្បីរៀបចំបណ្តាញសហគមន៍សំរាប់បង្ការការជួញដូរមនុស្ស។

នៅក្នុងពេលមួយឆ្នាំៗ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងស្តារយុវនីតិសម្បទា បានធ្វើមាតុភូមិនិវត្តន៍កុមារ ជនរងគ្រោះ និង ក្រុមមនុស្សងាយរងគ្រោះចំនួន ១ ២៧៣ នាក់ មកពីប្រទេសថៃ និង វៀតណាម អោយធ្វើសមាហរណកម្មទៅក្នុងគ្រួសាររបស់ពួកគេវិញ។ ដោយមានជំនួយឧបត្ថម្ភផ្នែកថវិការ និង បច្ចេកទេសពីអង្គការ IOM ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងស្តារយុវនីតិសម្បទា បានធ្វើមាតុភូមិនិវត្តន៍នារីជនជាតិវៀតណាមចំនួន ៤ នាក់ទៅកាន់ប្រទេសកំណើតរបស់ពួកគេវិញ។

នៅឆ្នាំ ២០០៥ អង្គការក្រៅរដ្ឋាភិបាលជាច្រើន បានធ្វើការជាមួយក្រសួងកិច្ចការនារី ដើម្បីធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយការជួញដូរពីប្រទេសម៉ាឡេស៊ីចំនួន ២៣ នាក់ ដែលនាំអោយតួលេខជនរងគ្រោះដោយការជួញដូរមកពីម៉ាឡេស៊ីកើនឡើងដល់ ៤០ នាក់ ចាប់តាំងពីឆ្នាំ ២០០៣ មក។ ក្រសួងមហាផ្ទៃ ដោយមានជំនួយពីក្រសួងកិច្ចការនារី ធ្វើការស៊ើបអង្កេតលើការជួញដូរស្ត្រី និងនារី ទៅកាន់ម៉ាឡេស៊ីធ្វើជាពេស្យាចារ។ បើទោះបីជាក្រសួងកិច្ចការនារីមិនមានតួលេខពាក់ពន្ធ័នឹងជនរងគ្រោះដោយការជួញដូរមនុស្សមកពីប្រទេសម៉ាឡេស៊ីក្នុងឆ្នាំនេះក៏ដោយ ក៏អង្គការក្រៅរដ្ឋាភិបាលមួយបានធ្វើសេចក្តីរាយការណ៍ថា មានជនរងគ្រោះដោយសារការជួញដូរចំនួន ៣៣ នាក់ មកពីម៉ាឡេស៊ី តែមិនដឹងថាជាជនរងគ្រោះដោយការជួញដូរផ្លូវភេទ ឬ ជាជនរងគ្រោះដោយការជួញដូរពលកម្មនោះទេ។

ច្បាប់ស្តីពីការជួញដូរមនុស្ស មិនមានខចែងណាមួយការពារជនរងគ្រោះបរទេសពីការចោទប្រកាន់ពីច្បាប់អន្តោរប្រវេសន៍របស់ប្រទេសឡើយ តែក្នុងឆ្នាំនីមួយៗ មិនមានរបាយកាណ៍ពីករណីនៃជនរងគ្រោះដោយការជួញដូរត្រូវបានចាត់ទុកជាជនអន្តោរប្រវេសន៍ខុសច្បាប់នៅឡើយទេ។

នៅក្នុងបណ្តារខេត្តក្រុងនានា មាននាយកដ្ឋានជំនាញប្រឆាំងការជួញដូរ និងការពារអនិតិជន ដែលបានធ្វើការឆ្មក់ចូលផ្ទះបននានា ហើយរំដោះបានជនរងគ្រោះជាច្រើន រួមទាំងកម្មករមិនទាន់គ្រប់អាយុផងដែរ។ រដ្ឋាភិបាលផ្តល់អោយជនរងគ្រោះភាគច្រើននូវការការពារ និង ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលដើម្បីបញ្ជូលពួកគេទៅក្នុងគ្រួសារគេវិញ ឬ ដាក់ពួកគេចូលក្នុងមណ្ឌល។ ជនរងគ្រោះដោយការជួញដូរ ជាពិសេសការជួញដូរផ្លូវភេទប្រឈមមុខនឹងការរើសអើងក្នុងសង្គម ជាពិសេសនៅក្នុងភូមិកំណើត និង ក្នុងក្រុមគ្រួសាររបស់ពួកគេ។

នៅក្នុងឆ្នាំនីមួយៗ ម្ចាស់ និងនាយកគ្រប់គ្រងសណ្ឋាគាភ្នំពេញ និង អ្នកសមគំនិតផ្សេងទៀត ត្រូវបានចាប់ខ្លួននាខែកញ្ញា ឆ្នាំ ២០០៥ ពីការបទជួញដូរមនុស្ស ត្រូវបានកាត់ទោសជាប់ពន្ធនាគារពី ៤ ទៅ ៥ ឆ្នាំ។

រដ្ឋាភិបាលប្រើប្រាស់ផ្ទាំងផ្សព្វផ្សាយ ទូរទស្សន៍ វិទ្យុ និង ល្ខោនជាតិ ដើម្បីលើកកំពស់ការយល់ដឹងសាធារណៈពីការជួញដូរមនុស្ស។ ក្រសួងកិច្ចការនារី ដោយមានកិច្ចសហការជាមួយអង្គការ IOM បន្តយុទ្ធនាការផ្តល់

ព័ត៌មានចំបងរបស់ខ្លួន ដើម្បីលើកកំពស់ការយល់ដឹងពីការជួញដូរមនុស្ស និង ការធ្វើអន្តោប្រវេសន៍ដោយសុវត្ថិភាពរហូតដល់ខែកញ្ញា នៅពេលគំរោងជាមួយអង្គការ IOM ត្រូវបានបញ្ចប់។

នៅថ្ងៃទី ០៦ ខែឧសភា រដ្ឋាភិបាល និងសមាជិករដ្ឋាភិបាល ៥ នាក់ផ្សេងទៀតនៃអន្តរក្រសួងប្រឆាំងការជួញដូរមនុស្សតាមដងទន្លេមេគង្គ បានធ្វើការជួបប្រជុំនៅទីក្រុងភ្នំពេញ និង អនុម័តយល់ព្រមផែនការសកម្មភាពដែលបង្កើតឡើងនៅខែមីនា ឆ្នាំ ២០០៥ នាទីក្រុងហាណូយ។

**ជនពិការ**

មិនមានច្បាប់ហាមឃាត់ជាក់ស្តែងលើការរើសអើងប្រឆាំងចំពោះជនពិការនោះទេ។ ជនពិការ មិនត្រូវបានតំរូវអោយមានលទ្ធភាពទទួលយកសេវារដ្ឋាភិបាល ឬចូលទៅកាន់អគាររដ្ឋាភិបាលឡើយ។ រដ្ឋាភិបាលធ្វើការហាមប្រាមមិនឱ្យជនពិការរ សូម្បីតែពិការតិចតួចក៏ដោយ មិនឱ្យធ្វើជាគ្រូបង្រៀននៅតាមសាលាសាធារណៈនោះឡើយ។

យោងតាមការសិក្សានាឆ្នាំ១៩៩៩ មានមនុស្សពិការចំនួន ១៧០ 000 នាក់ ក្នុងនោះមានមនុស្ស ២៤ 000 នាក់ដែលពិការដៃ/ជើងម្ខាង និង មនុស្ស ៦ ៧៤៤ នាក់ ដែលពិការអវយវៈលើសពីមួយ។ ពិការភាពដោយសារគ្រាប់មីនមានចំនួនដល់ទៅ ១១.៥ ភាគរយ នៃជនពិការ ចំណែកឯពិការភាពពីកំណើត និង ដោយសារជំងឺ មានចំនួន ៥៣ ភាគរយ។

កម្មវិធីដែលគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ បាននាំអោយមានការរីកចំរើនច្រើនគួរសមក្នុងការប្រព្រឹត្ត និង ស្តារលទ្ធភាពពលកម្មរបស់ជនដែលបាត់បង់អវយវៈ ប៉ុន្តែពួកគេបានប្រឈមមុខនឹងបញ្ហារើសអើងក្នុងសង្គមជាច្រើន ជាពិសេសក្នុងការទទួលការងារជាបុគ្គលិកជំនាញ។

មិនមានការកំរិតផ្លូវច្បាប់ណាមួយលើសិទ្ធិមនុស្សដែលមានពិការភាពដើម្បីបោះឆ្នោត ឬចូលរួមក្នុងកិច្ចការស៊ីវិលឡើយ ប៉ុន្តែរដ្ឋាភិបាលមិនបានធ្វើកិច្ចខំប្រឹងប្រែងរួមណាមួយ ដើម្បីជួយពួកគេក្នុងការចូលរួមអោយជិតស្និតនៅក្នុងសង្គមនោះឡើយ។ នាយកដ្ឋានស្តារលទ្ធភាពពលកម្មរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងស្តារយុវនិតិសម្បទា ទទួលខុសត្រូវលើការរៀបចំគោលនយោបាយដើម្បីការពារសិទ្ធិជនពិការ។

**ក្រុមជនជាតិភាគតិច/កុលសម្ព័ន្ធ**

សិទ្ធិរបស់ជនជាតិភាគតិចនៅក្រោមច្បាប់សញ្ជាតិឆ្នាំ ១៩៩៦ គឺមិនច្បាស់លាស់នោះទេ។ ការការពាររបស់រដ្ឋធម្មនុញ្ញ គឺសំដៅតែលើជនជាតិខ្មែរតែប៉ុណ្ណោះ។ ប្រជាជនជនជាតិចិន និង វៀតណាម មានចំនួនច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា។ ជនជាតិភាគតិចជាជនជាតិចិន ត្រូវបានទទួលស្គាល់នៅក្នុងសង្គម ប៉ុន្តែការរើសអើងនៅបន្តកើតមានចំពោះជនជាតិវៀតណាម ដែលយល់ឃើញថា ជាការគំរាមកំហែងមួយចំពោះវប្បធម៌ និង ជាតិសាសន៍។ ក្រុមខ្លះបានបន្តធ្វើសកម្មភាពយ៉ាងខ្លាំងក្លាប្រឆាំងនឹងជនជាតិវៀតណាម។ ពួកគេតវ៉ាអំពីការគ្រប់គ្រង

នយោបាយរបស់គណបក្សប្រជាជនដោយរដ្ឋាភិបាលវៀតណាម ពីការរំលោភបំពានលើព្រំដែន និងបញ្ហាផ្សេងទៀត ដែលគេគិតថា ជនជាតិភាគតិចវៀតណាម ទោះតិចក្តីច្រើនក្តី គឺត្រូវទទួលខុសត្រូវលើបញ្ហានេះ។

**ជនជាតិដើម**

រដ្ឋាភិបាលតែងតែព្រងើយកន្តើយនឹងកិច្ចខំប្រឹងប្រែងដោយសហគមន៍ជនជាតិដើមនានា ដើម្បីការពារទឹកដីដូនតា និង ធនធានធម្មជាតិរបស់ពួកគេ។ បើទោះបីជាមានច្បាប់ដីធ្លីពីឆ្នាំ ២០០១ ដែលអំពាវនាវអោយមានការចុះបញ្ជីរដីធ្លីនៅតាមសហគមន៍ជនជាតិភាគតិចក៏ដោយ ក៏ការចុះបញ្ជីរចេញប័ណ្ណកម្មសិទ្ធិនោះនៅមានតិចតួចនៅឡើយ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានអំពាវនាវអោយធ្វើការផ្អាកសិនទនូវសកម្មភាពលក់ដី និង ការធ្វើសម្បទានដី ដែលនាំអោយប៉ះពាល់ដល់អ្នកស្រុក។

អង្គការជាតិ និងអន្តរជាតិ មានភាពសកម្មនៅក្នុងការអប់រំដល់សហគមន៍ជនជាតិអំពីសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេ និង ការផ្តល់តំណាងតាមផ្លូវច្បាប់ដល់ពួកគេនៅពេលមានវិវាទដីធ្លីនានា។

**ការរើសអើង និងអំពើហិង្សានានាក្នុងសង្គម**

ការរើសអើងក្នុងសង្គមចំពោះអ្នកមានផ្ទុកមេរោគអេដស៍ នៅតែជាបញ្ហានៅទីជនបទ តែទោះជាយ៉ាងណាការរើសអើងត្រូវបានកាត់បន្ថយតាមរយៈកម្មវិធីយល់ដឹងពីជំងឺអេដស៍។ មិនមានការរើសអើងជាផ្លូវការចំពោះអ្នកផ្ទុកមេរោគអេដស៍នោះទេ។

## ផ្នែកទី ៦ សិទ្ធិកម្មករ

### ក. សិទ្ធិសកម្មភាពសមាគម

ច្បាប់ការងារ ផ្តល់អោយកម្មករនូវសិទ្ធិក្នុងការបង្កើតអង្គការវិជ្ជាជីវៈនានាតាមជំរើសរបស់ពួកគេដោយមិនចាំបាច់រង់ចាំទទួលការអនុញ្ញាតនោះឡើយ ហើយកម្មករឯកជននៅក្នុងសេដ្ឋកិច្ចស្របច្បាប់មានសេរីភាពក្នុងការចូលរួមសកម្មភាពសហជីពពាណិជ្ជកម្មតាមការជ្រើសរើសរបស់ពួកគេ។ តែទោះជាយ៉ាងណាការអនុវត្តន៍ច្បាប់របស់រដ្ឋាភិបាល គឺធ្វើឡើងតែចំពោះក្រុមមួយចំនួនប៉ុណ្ណោះ។ ការចូលជាសមាជិកភាពក្នុងសហជីពពាណិជ្ជកម្ម ឬ សមាគមកម្មករ មិនត្រូវបានចាត់តំរូវដោយច្បាប់នោះទេ ហើយកម្មករមានសេរីភាពក្នុងការដកខ្លួនចេញពីស្ថាប័នទាំងនោះ បើទោះបីជាមានសហជីពខ្លះព្យាយាមធ្វើការបំភ័យដល់កម្មករពេលមានបំណងចង់ចាកចេញក៏ដោយ។ សហជីពនឹងធ្វើទំនាក់ទំនងល្អជាមួយគ្នា ប៉ុន្តែច្បាប់មិនបានកំណត់សិទ្ធិក្នុងការធ្វើទំនាក់ទំនងនោះឡើយ។ ដោយសារច្បាប់ត្រូវអនុវត្តតែចំពោះជនបរទេស វាមិនត្រូវបានយកមកអនុវត្តជាមួយបុគ្គលិកសាធារណៈនោះទេ ដោយគិតរួមទាំងគ្រូបង្រៀន តុលាការ និង មន្ត្រីយោធា ឬក៏កម្មករនៅផ្នែកមិនស្របច្បាប់ផងដែរ។ បុគ្គលិកនៅក្នុងឧស្សាហ៍កម្មដឹកជញ្ជូនតាមផ្លូវទឹក និង ផ្លូវអាកាស មិនមានសិទ្ធិទទួលយកការការពារពេញលេញពីច្បាប់នោះទេ តែមានសេរីភាពក្នុងការបង្កើតជាសហជីព។

កម្មករជាច្រើនជាអ្នកធ្វើស្រែចំការ ហើយបើទោះបីជាមានការរីកចំរើនលើផ្នែកសេវាកម្ម ក៏កម្មករនៅទីក្រុងភាគច្រើនតែងមានជាប់ពាក់ព័ន្ធទៅនឹងជំនួញតូចតាច ជាកម្មករជំនាញធ្វើការអោយខ្លួនឯង ឬ ជាកម្មករមិនមានជំនាញលក់កំលាំងប្រចាំថ្ងៃ។ មានតែមួយចំណែកតូចប៉ុណ្ណោះ (តាមការប៉ាន់ស្មានមានតិចជាង ១ ភាគរយ) នៃកំលាំងពលកម្មមិនមានចូលជាសហជីព ហើយចលនាសហជីពដែលទើបចាប់កំណើតនៅមានភាពទន់ខ្សោយនៅឡើយ ប៉ុន្តែកំពុងរីកលូតលាស់រឹងមាំឡើង។ សហជីពទទួលរងនូវការខ្វះខាតធនធាន ការបណ្តុះបណ្តាល និង បទពិសោធន៍។ សហជីពផ្តោតជាសំខាន់ទៅលើឧស្សាហ៍កម្មស្បែកជើង និង វិស័យកាត់ដេរ ដែលមានប្រមាណពី ៤០ ទៅ ៥០ ភាគរយនៃកម្មករសរុប ៣៣៣ ១៤៤ នាក់ គឺជាសមាជិកសហជីព។ សហព័ន្ធកម្មករ សេវាកម្ម និង ទេសចរណ៍កម្ពុជា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៣ តំណាងអោយកម្មករជាង ៣ ៧៥៧ នាក់ នៅតាមសណ្ឋាគារ កាស៊ីណូ និង ព្រលានយន្តហោះ។

ដោយសារមានការហាមឃាត់មិនអោយមាននិយោជិកផ្នែករដ្ឋចូលរួមបង្កើតសហជីព សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជាមួយ ហៅកាត់ថា (ស៊ីតា) បានចុះបញ្ជីជា "សមាគម" ហើយតំណាងអោយសមាជិក ៨ ០០០ នាក់ នៅក្នុង ១៨ ខេត្ត/ក្រុង។ ស៊ីតាទទួលការរំខានពីសំណាក់អាជ្ញាធរខេត្តតិចជាងឆ្នាំមុនៗ តែនៅតែប្រឈមមុខនឹងការដាក់ករិតសំខាន់ៗនៅឡើយ។ ឧទាហរណ៍ ការធ្វើព្យុះហយាត្រា និង ការតវ៉ាផ្សេងៗ គឺត្រូវបានហាមឃាត់។ សមាគមផ្នែករដ្ឋមួយទៀតគឺ សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា ហៅកាត់ថា (ស៊ីកា) មានសមាជិក ២៥០ នាក់ មកពីក្រសួង មន្ទីរតាមខេត្ត និង ក្រុមប្រឹក្សាឃុំនៅទូទាំងប្រទេស។ មានមន្ត្រីរាជការជាច្រើនមានការភ័យខ្លាចថាខ្លួននឹងត្រូវបានគេធ្វើការយាយីរំខាន និង ទំលាក់ពីតំណែង ប្រសិនបើពួកគេចូលរួមជាមួយស៊ីកា ដែលប្រការនេះធ្វើឱ្យមានសមាគមនេះសមាជិកចំនួនតិច។

ច្បាប់តំរូវអោយសហជីព និងស្ថាប័ននិយោជកធ្វើការរៀបចំរចនាសម្ព័ន្ធ និង បញ្ជីមន្ត្រីមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(MOLVT)។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះបញ្ជីសហជីពរោងចក្រចំនួន ១ ០២៦ សហព័ន្ធកម្មករ ជាតិចំនួន ២៦ និង សហព័ន្ធសហជីពជាតិចំនួន ៤ (សម្ព័ន្ធភាពនៃសហព័ន្ធដែលមានគំនិតដូចគ្នាមួយចំនួន) ចាប់តាំង ពីពេលដែលច្បាប់បានចូលជាធរមានឆ្នាំ ១៩៩៧ មក ដោយរាប់ទាំងសហជីពចំនួន ១៩៣ និង សហព័ន្ធចំនួន ២ ក្នុង ឆ្នាំនេះ។ សហជីព និង សហព័ន្ធមួយចំនួនបានធ្វើការលើកឡើងពីការពន្យាពេលមិនចាំបាច់ និង ការចំណាយក្នុងដំណើរការចុះបញ្ជី។ នៅខែមិថុនា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បដិសេធក្នុងការចុះបញ្ជីសហព័ន្ធសហជីពការងារកម្ពុជា ដែលជាសហព័ន្ធសហជីពអន្តរផ្នែកទីមួយ ដោយហេតុថា សមាគមដែលបង្កើតចេញមក ជាតំណាងឱ្យមន្ត្រីរាជការ និង កម្មករក្នុងផ្នែកឯកជន មិនអាចចុះឈ្មោះក្រោមសហព័ន្ធសហជីពបានឡើយ។ បើទោះបីជាសហជីពទាំងអស់ធ្វើការប្រមូលពន្ធការពីសមាជិក មិនមានសហជីពណាមួយអាចដំណើរការទៅបានដោយមិនមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីខាងក្រៅនោះឡើយ។

ក្នុងចំណោមសហជីពកម្មករជាតិចំនួន ៣០ មាន ២៤ដែលមានសម្ព័ន្ធភាពជាមួយរដ្ឋាភិបាល ដែលក្នុងនោះមាន ១១ សហជីព ដែលជាផ្នែកមួយនៃរដ្ឋាភិបាលនិយមរបស់សហព័ន្ធសហជីពពាណិជ្ជកម្មកម្ពុជា (CCTU)។

សហព័ន្ធ ៥ ដែលនៅសល់ គឺមិនមានជាប់គំនាបពីរដ្ឋាភិបាលឡើយ ដែលមួយក្នុងចំណោមនោះមានការគាំទ្រ និង ឧបត្ថម្ភពីគណបក្សប្រឆាំង។ មានភស្តុតាងគួរអោយជឿពាក់ពន្ធ័នឹងការលូកដៃចូលក្នុងការងារសហជីពកម្មករពីសំណាក់អ្នកដឹកនាំ។ នៅរោងចក្រខ្លះ អ្នកគ្រប់គ្រងបានធ្វើការបង្កើតសហជីពដោយខ្លួនឯង ដែលធ្វើការគាំទ្រដល់អ្នកគ្រប់គ្រង ឬ ជាអ្នករួបរួមអ្នកដឹកនាំសហជីព។ អ្នកដឹកនាំសហជីពឯករាជ្យធ្វើការតវ៉ាថា CCTU តែងធ្វើអន្តរាគមន៍នៅក្នុងកិច្ចការរបស់សហជីពនានា គំរាមយកប្រាក់ពីអ្នកគ្រប់គ្រងជាការដោះដូរនឹងការបង្អាក់កម្មករពីការធ្វើកូដកម្ម និង បាតុកម្មស្របច្បាប់នានា និង គំរាមកំហែងដល់អ្នកដឹកនាំសហជីពប្រគួតប្រជែងផ្សេងទៀត។ ក៏មានពាក្យបណ្តឹងជាច្រើនដែលថា សហព័ន័យុវជនខ្មែរនៃសហជីពពាណិជ្ជកម្ម តែងតែគំរាមធ្វើបាតុកម្ម ដើម្បីទារប្រាក់ពីអ្នកគ្រប់គ្រង។

ការអនុវត្តន៍សិទ្ធិសកម្មភាពសមាគម និង សេរីភាពពីការប្រឆាំងចំពោះសហជីពនៅមានភាពទន់ខ្សោយនៅឡើយ។ កិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់របស់រដ្ឋាភិបាល ត្រូវបានបន្តរាំងដោយកង្វះខាតឆន្ទៈផ្នែកនយោបាយ និង ដោយទំនាក់ទំនងច្របូកច្របល់ផ្នែកហិរញ្ញវត្ថុ និង នយោបាយជាមួយនិយោជក និង អ្នកដឹកនាំសហជីព។ រដ្ឋាភិបាលក៏មានការលំបាកដោយសារកង្វះខាតធនធាន ដោយគិតរួមទាំងអ្នកអធិការកិច្ចជំនាញដែលមានបទពិសោធន៍ និងទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និង ដោយសារតែការមិនបានទូទាត់ប្រាក់កំរៃសមស្របដល់បុគ្គលិក។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តែងធ្វើការសំរេចចិត្តគាំទ្រដល់និយោជិក ប៉ុន្តែកំរប្រើអំណាចស្របច្បាប់របស់ខ្លួនក្នុងការដាក់ពិនយ័លើនិយោជកដែលបំពានលើបទបញ្ជារបស់ខ្លួនណាស់។

នៅក្នុងឆ្នាំនោះ មានរបាយការណ៏គួរឱ្យជឿជាក់ស្តីពីអំពើហិង្សាប្រឆាំងសហជីពដោយនិយោជក ដែលរួមមាន ការបណ្តេញចេញមេដឹកនាំរបស់សហជីពនៅក្នុងរោងចក្រកាត់ដេរ និង សហគ្រាសផ្សេងៗទៀត។ និយោជកពេលខ្លះពឹងផ្អែកលើតុលាការក្នុងការបណ្តេញ ឬ ដាក់ទោសអ្នកដឹកនាំសហជីព។ មាន ៣ ករណី ដែលប្រធានសហជីពត្រូវបានដាក់ទោសពីបទញុះញង់កម្មករអោយធ្វើបាតុកម្ម និង បំផ្លិចបំផ្លាញសម្បត្តិឯកជន។ នៅពេលខ្លះ មេដឹកនាំសហជីពដែលត្រូវបានបណ្តេញចេញ ទទួលយកប្រាក់ក្រោយពេលកោះហៅទៅបំភ្លឺដោយការអនុវត្តន៏ច្បាប់របស់រដ្ឋាភិបាល។ នៅពេលខ្លះទៀត រដ្ឋាភិបាលបានលើកកំពស់សិទ្ធិកម្មករ។ ឧទាហរណ៏ក្នុងឆ្នាំនោះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការព្រមានដល់ក្រុមហ៊ុនចំនួន ៩០២ ពីបទរំលោភច្បាប់ បានផាកពិន័យក្រុមហ៊ុនចំនួន ១៩ និង ប្តឹងក្រុមហ៊ុនចំនួន ១៧ ជូសមុខកម្មករ។ ក្នុងពេលតែមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនរឿងក្តី ៧៥ ករណី ពី ទំនាស់កម្មករដែលមិនអាចដោះស្រាយបាន ទៅក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីធ្វើការវិនិច្ឆ័យ។

### ខ. សិទ្ធិក្នុងការរៀបចំការប្រមូលផ្តុំ និង ការចចាររួម

ច្បាប់ផ្តល់សិទ្ធិក្នុងការរៀបចំការប្រមូលផ្តុំ និងការចចាររួម តែការអនុវត្តន៍ជាក់ស្តែង ច្បាប់របស់រដ្ឋនៅមិន ទាន់មានភាពចុះសំរុងគ្នានៅឡើយ។ ប្រាក់ឈ្នួលត្រូវបានកំណត់តាមតម្លៃកំលាំងពលកម្មទីផ្សារ លើកលែងតែចំពោះមន្ត្រីរាជការ ដែលប្រាក់ឈ្នួលត្រូវបានកំណត់ដោយរដ្ឋាភិបាលនោះ។

ក្រោយការចេញច្បាប់ការងារឆ្នាំ១៩៩៧ មានការយល់ច្រឡំពីការរំលោភលើតួនាទីនៃសហជីព និង អ្នកធ្វើការតាមហាងដែលត្រូវបានគេជ្រើសរើស។ នៅឆ្នាំ ២០០០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញបញ្ញត្តិដែលធ្វើអោយអ្នកដឹកនាំសហជីពពាណិជ្ជកម្មមានឋានៈស្មើរអ្នកតំណាងតាមហាងទាំងនោះ ហើយបានបន្ថែមការការពារពីការដកចេញនៃមន្ត្រីសហជីពជាច្រើននៅតាមសហគ្រាសនានា។ តែទោះជាយ៉ាងណាក៏ដោយ ក៏ការការពារទាំងនោះមិនត្រូវបានគោរពតាមទាំងស្រុងពីសំណាក់និយោជកឡើយ។

នៅក្នុងឆ្នាំនោះ មានកិច្ចសន្យាតវ៉ាចំនួន ១៣ ត្រូវបានផ្ញើរទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលភាគច្រើនជាកិច្ចសន្យាផ្សះផ្សាវិវាទដែលមិនស្របតាមបទដ្ឋាននៃកិច្ចចចាររួមអន្តរជាតិ។ មានតែ៥កិច្ចសន្យាប៉ុណ្ណោះដែលមាននៅក្នុងឧស្សាហ៏កម្មវាយនភ័ណ្ឌ កិច្ចសន្យានេះផ្តល់អោយនូវខចែងនានាស្តីពីសុខភាព និង សុខមាលភាព ដូចជា ច្បាប់ឈប់សំរាកពេលមានជំងឺ និង ច្បាប់លំហែមាតុភាព ការពិនិត្យសុខភាពនៅគ្លីនិករបស់រោងចក្រ និង មូលនិធិសុខមាលភាពគ្រប់គ្រងដោយសហជីព។

បញ្ញត្តិឆ្នាំ២០០១ បានបង្កើតឡើងនូវនីតិវិធីក្នុងការអនុញ្ញាតអោយសហជីពបង្ហាញថា ពួកគេជាអ្នកតំណាងឱ្យកម្មករក្នុងគោលបំណងនៃកិច្ចចចាររួម។ បញ្ញត្តិនេះ ក៏បង្កើតផងដែរនូវតំរូវការនានាសំរាប់និយោជក និង សហជីព ពាក់ព័ន្ធនឹងកិច្ចចចាររួម និង បានផ្តល់អោយប្រធានសហជីពនូវការការពារបន្ថែមពីការដកចេញពីមុខតំណែង។ ការិយាល័យទំនាក់ទំនងការងារ បានសំរបសំរួលដំណើរការចុះបញ្ជី និង ចេញវិញ្ញាបនប័ត្រដល់សហជីពដែលមានសិទ្ធិតំណាងអោយកម្មករមួយភាគធំនៅក្នុងសហគ្រាសមួយ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តល់តួនាទីជាតំណាងដល់សហជីពចំនួន ១១ ក្នុងឆ្នាំនោះ។ សហជីពដែលស្នើរសុំសិទ្ធិតែមិនបានទទួលបានធ្វើការរអ៊ូរទាំថា មានការពន្យាពេលផ្នែកប្រព័ន្ធរដ្ឋបាលដែលមិនមានភាពចាំបាច់។

ច្បាប់ផ្តល់សិទ្ធិក្នុងការធ្វើកូដកម្ម និងការការពារបាតុករពីការវាយបកវិញនានា។ ច្បាប់បានកំណត់ថា កូដកម្មអាចធ្វើឡើងចំពោះករណីតំរូវការចាំបាច់នានាត្រូវដោះស្រាយ ដោយគិតរួមទាំងការបរាជ័យនៃនីតិវិធីនានានៃការដោះស្រាយជម្លោះដូចជា ការចរចារ ការបញ្ចប់ជម្លោះ, និងការផ្សះផ្សារ) ការបោះឆ្នោតដោយសំងាត់សំរាប់ជ្រើសរើសសមាជិកសហជីព និង ការជូនដំណឹង ៧ ថ្ងៃមុនដល់និយោជក និង ក្រសួងការងារ។

មានការកើនឡើងពីការរំជើបរំជួលផ្នែកការងារគួរឱ្យចាប់អារម្មណ៏ចាប់ពីខែកុម្ភៈ ដល់មិថុនា ដែលនាំឱ្យមានការបាត់បង់ថ្ងៃធ្វើការដោយមានបាតុកម្មក្នុងរោងចក្រកាត់ដេរ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើរបាយការណ៏ថា មានកូដកម្មចំនួន ១០៣ ដែលកើតមានឡើងក្នុងឆ្នាំនេះ ដែលស្ទើរតែទាំងអស់មានការរំលោភបំពានលើតំរូវការនីតិវិធីធ្វើកូដកម្ម។ ប្រធានសហជីពខ្លះសារភាពថា ការធ្វើបាតុកម្មរបស់ខ្លួនមិនស្របតាមច្បាប់នោះឡើយ។ សហជីពខ្លះទៀតតវ៉ាថា មិនមានការចូលរួមពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលនាំ

អោយមានការកើនឡើងការធ្វើបាតុកម្មនៅក្នុងឧស្សាហ៍កម្មវាយនភ័ណ្ឌ ពីខែកុម្ភៈ ដល់ខែមិថុនា។ រដ្ឋបានអនុញ្ញាត អោយមានការធ្វើបាតុកម្មនៅក្នុងរោងចក្រ តែបដិសេធសំណើររបស់កម្មករក្នុងការធ្វើព្យុះហយាត្រាខាងក្រៅរោងចក្រ។ អន្តរាគមន៍របស់ប៉ូលិសនៅក្នុងបាតុកម្មនៅមានកំរិត បើទោះបីជាមានការបំផ្លាញដល់ទ្រព្យសម្បត្តិក៏ដោយ។ ប៉ូលិសមានវត្តមាននៅក្នុងព្យុះហយាត្រាមួយចំនួនដែលហាក់ដូចជាក្នុងចំនួនច្រើនជ្រុល ហើយមានទាំងប៉ូលីសអន្តរាគមន៍ពិសេសផងដែរ។

នៅថ្ងៃទី ២២ មករា សហជីពប្រមាណ ៣០០ និង បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលនានា បានបំពានដល់ការហាមឃាត់របស់រដ្ឋាភិបាល ហើយបានធ្វើក្បួនដង្ហែររំលឹកខួបមរណភាពប្រធានសហជីព លោក ជា វិជ្ជា។ ក្បួនដង្ហែរធ្វើឡើងដោយសន្តិភាព និង មិនមានការរំខានពីប៉ូលីសឡើយ។

នៅថ្ងៃទី ០១ ឧសភា ប៉ូលីសធ្វើការឃាត់ខ្លួនប្រធានសហជីពសេរីកម្មករ លោក ជា មុន្នី និង សហការី ២ នាក់ទៀត ដោយសារពួកគេព្យាយាមដឹកនាំកម្មករជាង ១ ០០០ នាក់ នៅថ្ងៃដង្ហែរក្បួន។ នៅពេលដែលមានការផ្សាយពីការដោះលែងរយៈពេល ២ ម៉ោងក្រោយមក លោក រ៉ុង ឈុន បានដឹកនាំកម្មករហែរក្បួនបន្តដោយសន្តិភាព។ ទោះជាយ៉ាងណាក៏ដោយ មានរបាយការណ៍ពីការរំខានពីប៉ូលីស និង អំពើហិង្សានៅផ្នែកផ្សេងទៀតនៃទីក្រុង។ ប៉ូលីសបានធ្វើការបិទផ្លូវសំខាន់ៗដែលចូលមកភ្នំពេញតាំងពីព្រឹកព្រលឹម ដើម្បីទបស្កាត់ការធ្វើបាតុកម្មរបស់កម្មករ។ លើសពីនេះទៅទៀត ក៏មានរបាយការណ៍ជាច្រើនទៀត ពីជម្លោះរវាងកម្មករ និង ប៉ូលីសនៅទីដាច់ស្រយ៉ាល រួមទាំងប្រតិកម្មដែលថា ប៉ូលីសប្រើដំបងឆក់ និង ទុយោទឹកបាញ់លើកម្មករផងដែរ។

នៅថ្ងៃទី ២០ មិថុនា មានប៉ូលីសប្រមាណ ២០០ នាក់ បានបំបែកហ្វូងបាតុករ ដែលមានកម្មករចូលរួម ១៥០០ នាក់ ធ្វើការតវ៉ាការផ្អាកដោយមិនស្របច្បាប់ចំពោះថ្នាក់ដឹកនាំសហជីព និង ការបង្ខំអោយរោងចក្រកាត់ដេរអនុវត្តស្របតាមការសំរេចរបស់ក្រុមប្រឹក្សាអជ្ញាកណ្តាល។ អ្នកប្រឆាំង ៤ នាក់ ត្រូវរងរបួសជាទំងន់ និង ១៥ នាក់ទៀត រងរបួសស្រាល។

នៅថ្ងៃទី ៧ សីហា ប្រធានសហជីពថ្នាក់រោងចក្រចំនួន ៣ នាក់មានទំនាក់ទំនងជាមួយនឹងសហជីពសេរីកម្មករ ត្រូវបានចោទប្រកាន់ពីបទឃុំឃាំងមនុស្សខុសច្បាប់ ដែលនេះជាលើកលើកទី១ហើយដែលប្រធានសហជីពកម្មករត្រូវបានដាក់ពន្ធនាគារ។ កម្មករដែលជាប់ពន្ធនាគារចាប់តាំងពីថ្ងៃទី០៣ កក្កដា កាត់ទោសអោយជាប់ពន្ធនាគារចំនួន១ខែ ៤ថ្ងៃ និង ការព្យួរទោសរយៈពេល ៣ ឆ្នាំ ជាមួយការការសាកល្បងរយៈពេល ៥ ឆ្នាំ។ ខណៈដែលបាតុកម្ម និង កម្មករដែលធ្វើការរាំងស្ទះបិទរោងចក្រ គឺជាការខុសច្បាប់ក៏ដោយ មិនមានភស្តុតាងបង្ហាញថា មានអ្នកគ្រប់គ្រងជាប់នៅខាងក្នុងរោងចក្រនោះឡើយ។

នៅចុងឆ្នាំ ករណីរបស់មេដឹកនាំសហព័ន្ធសហជីពទាំង ៣ ដែលត្រូវបានចាប់ខ្លួននៅខែឧសភា ឆ្នាំ ២០០៥ ពីបទទទួលលុយសំណូកពីរោងចក្រត្រូវបានព្យួរទុក។

នាថ្ងៃទី ១៦ ខែតុលា កម្មករនៅរោងចក្រកាត់ដេរប្រាយស្កាយ (Bright Sky) នៅភ្នំពេញចូលរួមក្នុងបាតុកម្មមិនស្របច្បាប់មួយ ដែលកើតចេញពីវិវាទលើកិច្ចសន្យាការងាររយៈពេលខ្លី។ នៅពេលបាតុកម្មឈានទៅរកភាព

ហិង្សា ប៉ូលីសប្រឆាំងបាតុកម្មបានចូលទៅបញ្ចប់ហេតុការណ៍។ មានកម្មការនីម្នាក់ពីរោងចក្រកាត់ដេរនៅជិតខាងត្រូវទទួលរងការបាញ់ចំពោះ ក្នុងពេលដើរចេញពីធ្វើការ និង កម្មកររោងចក្រ ប្រាយស្កាយ ជាច្រើនទៀត រាយការណ៍ថា ពួកគេត្រូវបានវាយដោយប៉ូលីស។ ប៉ូលីសបដិសេធលើការបាញ់ប្រហារ ឬវាយដំ ដែលគ្រាន់តែថា ពួកគេបាញ់កាំភ្លើងទៅលើ និង មិនសំដៅលើកម្មករណាមួយឡើយ។ កម្មករពីរនាក់ដែលត្រូវបានចាប់ខ្លួន តែត្រូវដោះលែងមកវិញក្រោយមក។ មួយសប្តាហ៍ក្រោយឧបត្តិហេតុ រោងចក្របានបិទផលិតកម្មវេនយប់ និង បញ្ឈប់កម្មករវេនយប់ទាំងអស់ ដោយសំអាងថា កម្មករវេនយប់នៅពីក្រោយខ្នងការរំខាននាថ្ងៃទី ១៦ តុលា និង ជាអ្នកបង្ករការប៉ះបោរ។

បើទោះបីជាមានការការពារតាមផ្លូវច្បាប់ដល់បាតុករពីការដាក់ពន្ធនាគារក៏ដោយ ក៏មានរបាយការណ៍ជាច្រើនបង្ហាញថា កម្មករត្រូវបានបណ្តេញចេញក្រោយការរៀបចំ ឬ ចូលរួមក្នុងបាតុកម្ម។ ក្នុងករណីខ្លះ បាតុករត្រូវទទួលសំពាធពីនិយោជកដើម្បីទទួលយកការទូទាត់ និង ចាកចេញពីការងារ។ មានសំណងសក្តានុពលនានាលើការបណ្តេញចេញពីការងារនេះ ប៉ុន្តែមិនមានប្រសិទ្ធិភាពលើករណីណាមួយឡើយ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចចេញបទបញ្ជាផ្សេងៗឱ្យកម្មករដែលគេបណ្តេញចេញទាំងនោះចូលធ្វើការវិញ តែប្រការទាំងនេះតែងជំរុញអោយអ្នកគ្រប់គ្រងព្យាយាមធ្វើការកៀបសង្កត់ដល់កម្មករឱ្យលាឈប់ជាការដោះដូរនឹងប្រាក់មួយចំនួន។ វិវាទជាក្រុមដូចជា នៅពេលកម្មករជាច្រើនត្រូវបានបណ្តេញចេញ អាចត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាអជ្ញាកណ្តាលដើម្បីដោះស្រាយ ដែលការសំរេចចិត្តមិនមានការចងជាកាតព្វកិច្ច។ ជម្លោះបុគ្គល អាចត្រូវបញ្ជូនទៅតុលាការ។

នៅខែកញ្ញា និងតុលា មានសហជីពរោងចក្រចំនួន ១៧ តំណាងឱ្យកម្មកររោងចក្រទូទាំងប្រទេសបានឈ្នះលើការប្រជែងជាយូរមកហើយ ដើម្បីធ្វើការចរចារជារួមជាមួយនឹងសមាគមកាត់ដេរកម្ពុជា។ ការចរចារដែលផ្តោតលើការតំឡើងនៃប្រាក់ឈ្នួលអប្បបរមា មានដំណើរការយ៉ាងយឺត ឬ មិនមានភាគីណាមួយចង់ធ្វើការសម្របសម្រួលនោះឡើយ។ នៅថ្ងៃទី ១៩ តុលា នៅថ្ងៃមុនការចរចារចុងក្រោយ រដ្ឋាភិបាលអំពាវនាវដល់ការប្រជុំ នៃគណៈកម្មាធិការប្រឹក្សាការងារ (LAC) ជាក្រុមត្រីភាគីដោយមានការទោរទន់ទៅរករដ្ឋាភិបាល និង អាជីវកម្ម។ គណៈកម្មាធិការប្រឹក្សាការងារ បានអនុម័តផែនការរដ្ឋដើម្បីបង្កើនប្រាក់ឈ្នួលអប្បបរមាចំនួន ៥ដុល្លារ (២១ 000 រៀល) ក្នុង ១ ខែ ដោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី០១ មករា ឆ្នាំ២00៧។ អ្នកសង្កេតការណ៍ការងារឯករាជ្យនានា មានការខកចិត្តជាខ្លាំងជាមួយទង្វើររបស់រដ្ឋាភិបាល ដោយសារពួកគេសង្ឃឹមថា ទទួលបានសំរបសំរួលដោយឯករាជ្យពីគណៈកម្មាធិការប្រឹក្សាការងារ។

### គ. ការហាមឃាត់ការបង្ខំ ឬ ការដាក់កំរិតការងារ

ច្បាប់ធ្វើការហាមឃាត់ការបង្ខំឱ្យធ្វើពលកម្ម រួមទាំងការបង្ខំពលកម្មដល់កុមារផងដែរ តែរដ្ឋាភិបាលមិនបានអនុវត្តខចែងរបស់ខ្លួនអោយបានពេញលេញនោះទេ។ ការធ្វើការលើសម៉ោង នៅតែជាបញ្ហាដែលកំពុងរាលដាល។ ក្រោមច្បាប់ ការធ្វើការលើសម៉ោងស្របច្បាប់ មិនអាចលើសពី ២ ម៉ោងនោះឡើយក្នុង ១ ថ្ងៃ ហើយត្រូវ

តែធ្វើតាមការស្ម័គ្រចិត្ត។ ទោះជាយ៉ាង នៅក្នុងការអនុវត្តន៍ការធ្វើការលើសម៉ោង តែងតែលើសពីការកំរិតកំណត់របស់ច្បាប់ ហើយនិយោជកធ្លាប់ប្រើកំលាំងដើម្បីបង្ខំនិយោជិកអោយធ្វើការផងដែរ។ កម្មករតែងតែប្រឈមមុខនឹងការដាក់ពិន័យ ការបណ្តេញចេញ ឬ ការកាត់ប្រាក់ខែ ប្រសិនបើពួកគេបដិសេធមិនធ្វើការលើសម៉ោង។ មានរបាយការណ៍ពីការបង្ខំមនុស្សឱ្យធ្វើពលកម្មនៅទីដាច់ដោយឡែកមួយ ចំពោះអ្នកបំរើការងារនៅតាមផ្ទះមួយចំនួនផងដែរ។

ការបង្ខំពលកម្មកុមារ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរនៅក្នុងឧស្សាហ៍កម្មផ្លូវភេទ (សូមមើលផ្នែកទី៥ និងទី៦ ឃ...)។

### ឃ. ការហាមឃាត់លើពលកម្មកុមារ និង អាយុអប្បបរមានៅពេលបំរើការងារ

រដ្ឋាភិបាលបាននាំយកច្បាប់ដើម្បីការពារកុមារពីការកេងប្រវ័ញ្ចកំលាំងពលកម្មនៅកន្លែងធ្វើការ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តន៍ច្បាប់នៅមានការទន់ខ្សោយនៅឡើយ។ ច្បាប់បានចែងថា ពលករត្រូវមានអាយុទាបបំផុត ១៥ ឆ្នាំ និង អាយុទាបបំផុត ១៨ ឆ្នាំសំរាប់ការងារដែលមានគ្រោះថ្នាក់។ ច្បាប់អនុញ្ញាតអោយកុមារអាយុរវាង ១២ ទៅ ១៥ ឆ្នាំ ចូលរួមក្នុងកិច្ចការស្រាលៗដែលមិនមានគ្រោះថ្នាក់ដល់សុខភាព និង ការរៀនសូត្ររបស់ពួកគេ។

មិនមានការហាមឃាត់ស្តីពីពលកម្មកុមារណាមួយឡើយ នៅផ្នែកឯកជន។ មិនមាននិយោជកណាមួយដែលត្រូវបានកាត់ទោសដោយសារការរំលោភច្បាប់ប្រឆាំងនឹងពលកម្មកុមារនោះដែរ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានការទទួលខុសត្រូវលើពលកម្មកុមារ ទាំងនៅក្នុងវិស័យផ្លូវការ និងក្រៅផ្លូវការនៃសេដ្ឋកិច្ច ប៉ុន្តែក្រុមអធិការកិច្ចការងាររបស់រដ្ឋមិនបានបំពេញតួនាទីរបស់ខ្លួនក្នុងវិស័យក្រៅផ្លូវការ ឬ ធ្វើការអនុវត្តច្បាប់នៅក្នុងវិស័យឧស្សាហកម្មក្រៅផ្លូវការនោះឡើយ។ នៅក្នុងវិស័យផ្លូវការ អធិការកិច្ចការងារធ្វើការត្រួតពិនិត្យជាប្រចាំលើឧស្សាហ៍កម្មមួយចំនួនដូចជា រោងចក្រកាត់ដេរ (ដែលឧបត្តិហេតុពលកម្មកុមារ កំរនឹងកើតមាននោះ) ប៉ុន្តែនៅក្នុងឧស្សាហ៍កម្មដែលមានការប្រឈមទៅនឹងគ្រោះថ្នាក់ពលកម្មកុមារខ្ពស់មួយចំនួនទៀត ការធ្វើអធិការកិច្ចការងារគឺធ្វើឡើងលុះត្រាតែមានបណ្តឹងប៉ុណ្ណោះ។

ក្នុងចំណោមកុមារអាយុចាប់ពី ៥ ទៅ ១៧ ឆ្នាំ មាន ៥៣ ភាគរយ ត្រូវបានគេជួលអោយធ្វើការ ហើយ ១ ភាគ ៣ នៃចំនួននេះ មានអាយុលើសពី ១៤ ឆ្នាំ។ ប្រហែល ៧១ ភាគរយនៃពួកគេ ធ្វើការនៅក្នុងវិស័យកសិកម្ម ដាំដុះ ឬ សកម្មភាពព្រៃឈើ។ ២១ ភាគរយនៅក្នុងសេវាកម្ម និងការលក់ដូរ និង ៧ ភាគរយទៀតនៅក្នុងផ្នែកផលិតកម្ម។

រដ្ឋធម្មនុញ្ញហាមឃាត់ពលកម្មដោយមានការបង្ខំ តែទោះជាយ៉ាងណា ការបង្ខំកំលាំងពលកម្មកុមារជាបញ្ហាដ៏ធ្ងន់ធ្ងរនៅក្នុងឧស្សាហ៍កម្មពាណិជ្ជកម្មផ្លូវភេទ (សូមមើលផ្នែកទី ៥)។ ភ្នាក់ងារអនុវត្តន៍ច្បាប់បរាជ័យក្នុងការប្រឆាំងទៅនឹងការធ្វើពេស្យាចារលើកុមារ ក្នុងលក្ខណៈសមស្រប និងមាននិរន្តរភាព។ ការរាលដាលនៃអំពើពុករលួយ កង្វះខាតតម្លាភាព ធនធានមិនគ្រប់គ្រាន់ និង កង្វះខាតបុគ្គលិក នៅតែជាឧបសគ្គដ៏ធ្ងន់ធ្ងរដដែល។

### ង. លក្ខខណ្ឌការងារដែលអាចទទួលយកបាន

ច្បាប់តំរូវឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើកំណត់ប្រាក់ឈ្នួលអប្បបរមា ដោយផ្អែកលើអនុសាសន៍ពីគណកម្មាធិការប្រឹក្សាការងារ។ ប្រាក់ឈ្នួលអប្បបរមា ត្រូវបានតំឡើងពី ៤៥ ទៅ ៥០ ដុល្លារ (ពី ១៨៩ ០០០ ទៅ ២១០ ០០០ រៀល) ក្នុងមួយខែ។ ចំនួននេះ ដែលអនុវត្តតែចំពោះរោងចក្រស្បែកជើង និងរោងចក្រកាត់ដេរ ត្រូវអនុវត្តនៅក្នុងឆ្នាំនោះ។ មិនមានប្រាក់ឈ្នួលអប្បបរមានៅក្នុងឧស្សាហ៍កម្មផ្សេងៗទៀតនោះទេ។

កម្មកររោងចក្ររកប្រាក់កំរៃបានពី ៧០ ទៅ ៨០ ដុល្លារ (ពី ២៩៤ ០០០ ទៅ ៣៣៦ ០០០រៀល) ក្នុងមួយខែ រួមទាំងការធ្វើការលើសម៉ោង និងប្រាក់ឧបត្ថម្ភ។ ប្រាក់ឈ្នួលនៅក្នុងផ្នែករោងចក្រកាត់ដេរ និងផ្នែកវិជ្ជាជីវៈជាច្រើនទៀតបច្ចុប្បន្ន មិនគ្រប់គ្រាន់ក្នុងការផ្តល់អោយកម្មករ និង គ្រួសារនូវកំរិតជីវភាពសមរម្យបានឡើយ។ ប្រាក់បៀវត្សន៍របស់មន្ត្រីរាជការ ក៏មិនសមស្របសំរាប់ការរស់នៅដែរ ដែលទាមទារអោយមន្ត្រីរដ្ឋាភិបាលធ្វើការស្វែងរកប្រភពចំណូលពីខាងក្រៅបន្ថែមទៀត ហើយក្នុងករណីជាច្រើន ដោយទទួលបានការងារទី ២ ឬ ទទួលសំណូក។

ច្បាប់កំនត់ម៉ោងធ្វើការក្នុងមួយសប្តាហ៍ ៤៨ ម៉ោង ដោយមិនអោយលើសពី ៨ ម៉ោងក្នុងមួយថ្ងៃ។ ច្បាប់កំណត់អត្រា ១,៥ ដង និង ២ ដងនៃប្រាក់ឈ្នួល ចំពោះការធ្វើការលើសម៉ោងនៅពេលយប់ នៅថ្ងៃអាទិត្យ ឬ នៅថ្ងៃឈប់សំរាក តែទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនបានអនុវត្តបទដ្ឋាននេះអោយមានប្រសិទ្ធិភាពទាំងស្រុងនោះទេ។ កម្មករនៅក្នុងរោងចក្របានធ្វើសេចក្តីរាយការណ៍មកថា ការធ្វើការលើសម៉ោងមានភាពលើសលប់ ឬដោយមិនមានការស្ម័គ្រចិត្ត ឬថា ពួកគេត្រូវតំរូវអោយធ្វើការ ៧ ថ្ងៃក្នុងមួយសប្តាហ៍។ ស្រដៀងគ្នានេះ នៅក្រៅឧស្សាហ៍កម្មកាត់ដេរ បញ្ញត្តិលើពេលម៉ោងធ្វើការ កំរនឹងទទួលបានការអនុវត្តន៍ណាស់។

ច្បាប់កំណត់ថា ទីកន្លែងការងារគួរមានបទដ្ឋានសុវត្ថិភាព និងសុខភាពគ្រប់គ្រាន់សំរាប់ធានាដល់សុខមាលភាពរបស់កម្មករ។ រដ្ឋាភិបាលធ្វើការអនុវត្តន៍បទដ្ឋានដែលមានស្រាប់ដោយអន្លើរៗ ដោយសារវាមានកង្វះខាតសំភារៈ និង បុគ្គលិក។ ការរងរបួសដែលពាក់ពន្ធ័នឹងការងារ និងបញ្ហាសុខភាព ជារឿងងាយនឹងកើតមាន។ រោងចក្រកាត់ដេរធំៗដែលផលិតផលិតផលដើម្បីទីផ្សារនៅក្នុងប្រទេសអភិវឌ្ឍន៍នានា អនុវត្តបទដ្ឋានសុខភាព និងសុវត្ថិភាពក្នុងលក្ខខណ្ឌនៃកិច្ចសន្យារបស់ពួកគេជាមួយអ្នកទិញ។ លក្ខខណ្ឌការងារនៅក្នុងរោងចក្រខ្នាតតូច និងឧស្សាហកម្មធនតូចមួយចំនួននៅមានកំរិតទាប និង មិនទាន់ស្របតាមស្តង់ដារអន្តរជាតិឡើយ។ ការដាក់ពិន័យត្រូវបានកំណត់នៅក្នុងច្បាប់ តែមិនមានខចែងជាក់លាក់ណាមួយ ដើម្បីការពារកម្មករដែលគេវ៉ាពីលក្ខខណ្ឌការងារដែលពុំមានសុវត្ថិភាពនោះឡើយ។ កម្មករដែលដកខ្លួនចេញពីលក្ខខណ្ឌការងារដែលមិនមានសុវត្ថិភាពប្រឈមមុខនឹងការ បាត់បង់ការងារ។